# សេចក្តីកំណត់ ចំពោះមាត្រានីមួយៗនៃ ក្រមរដ្ឋប្បវេណី

## ភាគ ៤ : គន្ថីទី៦

រៀបចំដោយ

គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី

និង

ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី

ក្រសួងយុត្តិធម៌

ភ្នំពេញ ២០១០

# សេចក្តីកំណត់
# ចំពោះមាត្រានីមួយៗនៃ
# ក្រមរដ្ឋប្បវេណី

## ភាគ ៤ ៖ គន្ថីទី ៦

រៀបចំដោយ

គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី

និង

ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី

ក្រសួងយុត្តិធម៌

ភ្នំពេញ ២០១០

# បុព្វកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយជាខ្លាំង ក្នុងការណែនាំជូននូវ **សៀវភៅស្តីពីសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា** ជាមួយនឹងសេចក្តីសង្ឃឹមដ៏មុតមាំថា សៀវភៅនេះនឹងក្លាយជាជំនួយដ៏សំខាន់មួយ ដើម្បីជួយសម្រួលដល់ការស្វែងយល់របស់បណ្តាអ្នកស្រាវជ្រាវនានា ជាពិសេសរបស់មន្ត្រី និងភ្នាក់ងារដែលត្រូវអនុវត្តក្រមរដ្ឋប្បវេណីនេះ ដោយផ្ទាល់តែម្តង ។

ដូចយើងទាំងអស់គ្នាបានដឹងហើយថា វិស័យគតិយុត្តកម្ពុជាត្រូវបានបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុង ដោយសារសង្គ្រាមស៊ីវិល ដែលក្នុងនោះ ច្បាប់និងលិខិតបទដ្ឋានក្រោមច្បាប់នានា សម្រាប់អនុវត្តទៅលើរឿងក្តីរដ្ឋប្បវេណី ក៏មានភាពខ្វះខាត និងទន់ខ្សោយដែរ។ ឧទាហរណ៍ ដូចជាចាប់តាំងពីក្រោយការដួលរលំនៃរបបខ្មែរក្រហមមកដល់មុនពេលអនុម័តក្រមរដ្ឋប្បវេណីថ្មី កម្ពុជាយើងមិនមានច្បាប់សារធាតុគ្រប់គ្រាន់ ដើម្បីយកមកដោះស្រាយរឿងក្តីរដ្ឋប្បវេណីទេ ។ អ្វីដែលជាការកត់សម្គាល់ គឺកម្ពុជាមានត្រឹមតែ ក្រឹត្យ-ច្បាប់លេខ ៣៨ ក្រ.ច ស្តីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យា ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៨៨ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ ច្បាប់ភូមិបាលដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ និងអមដោយអនុក្រឹត្យ ព្រមទាំងប្រកាស និងសារាចរណែនាំខ្លះៗ ផ្សេងទៀតរបស់ក្រសួងយុត្តិធម៌តែប៉ុណ្ណោះ ។

ដោយសារកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយការឧបត្ថម្ភគាំទ្រពីប្រទេសជប៉ុនជាមិត្តគំនិតផ្តួចផ្តើមក្នុងការបង្កើតឡើងវិញនូវក្រមរដ្ឋប្បវេណីកម្ពុជា ក៏បានលេចចេញជារូបរាងឡើង ។ ជាលទ្ធផល **ក្រមរដ្ឋប្បវេណី** ត្រូវបានរដ្ឋសភាអនុម័ត កាលពីថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៧ នាសម័យប្រជុំលើកទី ៧ នីតិកាលទី ៣ របស់ខ្លួន ហើយព្រឹទ្ធសភាក៏បានផ្តល់ការយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង កាលពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ។ ក្រមនេះត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ កន្លងទៅ ។ ការសម្រេចបាននូវ **ក្រមរដ្ឋប្បវេណី** នេះ គឺជាសមិទ្ធផលដ៏ថ្មីស្រឡាងនិងជាទីមោទនៈមួយទៀត នៅក្នុងប្រព័ន្ធគតិយុត្តកម្ពុជា ហើយនេះ ក៏ជាជំហានថ្មីមួយទៀត នៅក្នុងការចូលរួមអនុវត្តនូវគោលនយោបាយកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ របស់រាជរដ្ឋាភិបាលកម្ពុជា។

ទន្ទឹមគ្នានេះដែរ ដើម្បីជាការបន្ថែមលើវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សព្វផ្សាយស្តីពី **ក្រមរដ្ឋប្បវេណី** និងដើម្បីធ្វើឱ្យមានភាពជឿជាក់ថា ក្រមនេះ ត្រូវបានយល់ជ្រួតជ្រាបទៅក្នុងចំណោមមហាជន ក៏ដូចជា

ជួយសម្រួលដល់ការស្វែងយល់ ការបកស្រាយ និងការអនុវត្តដោយមន្ត្រី និងស្ថាប័នអនុវត្ត សៀវភៅស្តីពីសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានចងក្រង និងបោះពុម្ពឡើង។ ទាំងអស់នេះ គឺបានប្រសូតចេញពីកិច្ចខំប្រឹងប្រែង ជិតមួយទសវត្សរ៍របស់ក្រុមការងារនៃក្រសួងយុត្តិធមិកម្ពុជានិងក្រុមការងារជប៉ុន ក្នុងបុព្វហេតុក្រមរដ្ឋប្បវេណីកម្ពុជាមួយ ប្រកបដោយការផ្លាស់ប្តូរនិងប្រសិទ្ធភាពខ្ពស់សំដៅឆ្ពោះទៅរកការរួមចំណែកកសាងនីតិរដ្ឋ នៅកម្ពុជា ។

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ២០០៩

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

អង្គ វង្ស វឌ្ឍនា

សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

ត្រូវបានបោះពុម្ព នៅរាជធានីភ្នំពេញ
ដោយការិយាល័យកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌
នៅក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា
នៅឆ្នាំ ២០១០ ។

កម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌
គឺជាកម្មវិធីសហប្រតិបត្តិការបច្ចេកទេស
រវាងក្រសួងយុត្តិធម៌ និង ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

សិទ្ធិនិពន្ធ © ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី ឆ្នាំ២០១០
ISBN: 9789995083380

| | អ្នកនិពន្ធ |
|---|---|
| ជំពូកទី ១ទៅ ជំពូកទី ៧ | លោកសាស្ត្រាចារ្យ **Nomura Toyohiro** |
| ជំពូកទី ៨ ទៅ ជំពូកទី ៩ | លោកសាស្ត្រាចារ្យ **Niimi Ikufumi** |

កំណត់សម្គាល់

នៅក្នុងសេចក្តីកំណត់នៃមាត្រានីមួយៗ មានសេចក្តីកំណត់ខ្លះដែលមានការបង្ហាញអំពីការបកស្រាយរបស់អ្នកដែលបានរៀបចំសេចក្តីព្រាងដើមនៃមាត្រានោះ ។ សូមចាត់ទុកការបកស្រាយនោះជាទស្សនៈមួយក្នុងចំណោមការបកស្រាយជាច្រើនដែលអាចមាន ដើម្បីយកទៅចាត់ចែងកិច្ចការជាក់ស្តែងនៅប្រទេសកម្ពុជា ។

# មាតិកា


**គន្ថីទី ៦ ការធានាកាតព្វកិច្ច ..... ១**

**ជំពូកទី ១ បទប្បញ្ញត្តិទូទៅ ..... ១**

**ជំពូកទី ២ សិទ្ធិឃាត់ទុក ..... ៧**

**ជំពូកទី ៣ ឯកសិទ្ធិ ..... ១២**

ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ ..... ១២

ផ្នែកទី ២ ឯកសិទ្ធិទូទៅ ..... ១៤

ផ្នែកទី ៣ ឯកសិទ្ធិលើចលនវត្ថុ ..... ១៧

ផ្នែកទី ៤ ឯកសិទ្ធិលើអចលនវត្ថុ ..... ២៣

ផ្នែកទី ៥ លំដាប់នៃឯកសិទ្ធិ ..... ២៥

ផ្នែកទី ៦ អានុភាពនៃឯកសិទ្ធិ ..... ២៩

**ជំពូកទី ៤ សិទ្ធិលើការបញ្ចាំ ..... ៣៥**

ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ ..... ៣៥

ផ្នែកទី ២ ការបញ្ចាំចលនវត្ថុ ..... ៤៣

ផ្នែកទី ៣ ការបញ្ចាំអចលនវត្ថុ ..... ៤៧

ផ្នែកទី ៤ ការបញ្ចាំសិទ្ធិ ..... ៥៣

**ជំពូកទី ៥ ហ៊ីប៉ូតែក ..... ៥៦**

ផ្នែកទី ១ អត្ថន័យនៃហ៊ីប៉ូតែក ..... ៥៦

ផ្នែកទី ២ ការបង្កើតហ៊ីប៉ូតែក ..... ៥៧

ផ្នែកទី ៣ អានុភាពនៃហ៊ីប៉ូតែក ..... ៥៨

ផ្នែកទី ៤ ការអនុវត្តហ៊ីប៉ូតែក ..... ៦៣

ផ្នែកទី ៥ ការចាត់ចែងហ៊ីប៉ូតែក ..... ៦៨

ផ្នែកទី ៦ ការរលត់នៃហ៊ីប៉ូតែក ..... ៧៥

កថាភាគទី ១ ការរលត់ដោយការទាមទារ ..... ៧៥

កថាភាគទី ២ ការរលត់ដោយអាជ្ញាយុកាល ..... ៧៦

ផ្នែកទី ៧ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ៧៧

**ជំពូកទី ៦ ប្រាតិភោគដោយអនុប្បទាន ១០២**

ផ្នែកទី ១ និយមន័យនៃប្រាតិភោគដោយអនុប្បទាន ១០២

ផ្នែកទី ២ ការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ១០៣

ផ្នែកទី ៣ អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ១០៤

ផ្នែកទី ៤ ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន ១០៩

**ជំពូកទី ៧ ការធានា ១១១**

ផ្នែកទី ១ ការបង្កើតកិច្ចសន្យាធានា ១១១

ផ្នែកទី ២ អានុភាពនៃការធានា ១១៤

ផ្នែកទី ៣ សិទ្ធិទាមទារសំណង ១២១

ផ្នែកទី ៤ ឧបាទេសកម្ម ១២៧

**ជំពូកទី ៨ កាតព្វកិច្ចដោយសាមគ្គីភាព ១២៩**

ផ្នែកទី ១ ការបង្កើតកាតព្វកិច្ចដោយសាមគ្គីភាព ១២៩

ផ្នែកទី ២ អានុភាពនៃហេតុដែលកើតឡើងចំពោះកូនបំណុលដែលមានកាតព្វកិច្ច ដោយសាមគ្គីភាពណាម្នាក់ ១៣២

ផ្នែកទី ៣ ការទាមទារសំណង ១៣៦

ផ្នែកទី ៤ ឧបាទេសកម្មដោយការសង ១៤០

ផ្នែកទី ៥ បែបយ៉ាងផ្សេងទៀតនៃកាតព្វកិច្ចដែលមានកូនបំណុលច្រើននាក់ ១៤០

**សមាសភាពនៃគណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណីកម្ពុជា :**

| | |
|---|---|
| ឯកឧត្តម **អង្គ វង្ស វឌ្ឍនា** | រដ្ឋមន្ត្រី, ក្រសួងយុត្តិធម៌ ( ប្រធាន) |
| ឯកឧត្តម **ស៊ុយ នូ** | រដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ ( អាណត្តិទី ១) |
| ឯកឧត្តម **អ៊ី ជន** | រដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ ( អាណត្តិទី ២) |
| ឯកឧត្តម **ហ៊ី សោភា** | រដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ |
| លោកជំទាវ **ចាន់ សុទ្ធាវី** | រដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **យូ ប៊ុនឡេង** | ប្រធានសាលាឧទ្ធរណ៍ |
| ឯកឧត្តម **គង់ ស្រ៊ីម** | អនុប្រធានតុលាការកំពូល |
| ឯកឧត្តម **ប៊ុន ហ៊ុន** | អនុរដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **កើត រិទ្ធ** | អនុរដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **ជួន តេជ** | អគ្គាធិការរង, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **ម៉ែន ពេជ្រសាលី** | អគ្គនាយកអគ្គនាយកដ្ឋានបច្ចេកទេស, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **ឆូវ សំភី** | អគ្គនាយកអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌, ក្រសួងយុត្តិធម៌ |
| លោក **ម៉ុង មុន្នីចរិយា** | ប្រធានសាលាដំបូងខេត្តព្រះសីហនុ |
| លោក **យូរ ឧត្តរា** | ចៅក្រមតុលាការកំពូល |
| លោក **សីរិទ្ធ សុផល** | ចៅក្រមសាលាឧទ្ធរណ៍ |
| លោក **សាលី ធារ៉ា** | ចៅក្រមសាលាឧទ្ធរណ៍ |
| លោកស្រី **ខៀវ សុខា** | អគ្គនាយករងអគ្គនាយកដ្ឋានបច្ចេកទេស, ក្រសួងយុត្តិធម៌ |
| លោក **សឹង បញ្ញាវុឌ្ឍ** | ចៅក្រមតុលាការកំពូល |
| លោក **ហ៊ីង ធីឫទ្ធិ** | ចៅក្រមសាលាដំបូងខេត្តស្ទឹងត្រែង |
| លោក **ទូច ថារិទ្ធិ** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ |
| លោក **និត្យ ឫទ្ធី** | ចៅក្រមក្រសួងយុត្តិធម៌ |

**សមាសភាពនៃក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី :**

| | |
|---|---|
| លោក **Morishima Akio** | សាស្ត្រាចារ្យកិត្តិយស, សកលវិទ្យាល័យ Nagoya ( ប្រធាន) |
| លោក **Kamata Kaoru** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Waseda |
| លោក **Matsumoto Tsuneo** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Hitotsubashi |
| លោក **Minami Toshifumi** | ចៅក្រម, សាលាឧទ្ធរណ៍នៃតំបន់ Tokyo |

លោក **Motoyama Atsushi** សាស្ត្រាចារ្យ, សកលវិទ្យាល័យ Ritsumeikan

លោក **Niimi Ikufumi** សាស្ត្រាចារ្យ, សកលវិទ្យាល័យ Meiji

លោក **Nomi Yoshihisa** សាស្ត្រាចារ្យ, សកលវិទ្យាល័យ Tokyo

លោក **Nomura Toyohiro** ព្រឹទ្ធបុរស និង សាស្ត្រាចារ្យ, សកលវិទ្យាល័យ Gakushuin

លោក **Sato Keita** សាស្ត្រាចារ្យ, សកលវិទ្យាល័យ Chuo

លោក **Tanamura Masayuki** សាស្ត្រាចារ្យ, សកលវិទ្យាល័យ Waseda

លោក **Urakawa Michitaro** សាស្ត្រាចារ្យ, សកលវិទ្យាល័យ Waseda

លោក **Yamamoto Yutaka** សាស្ត្រាចារ្យ, សកលវិទ្យាល័យ Kyoto

លោក **Hatanaka Hisaya** សាស្ត្រាចារ្យ, សកលវិទ្យាល័យ Fukuoka

**ជំនាញការ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន** (JICA) **ប្រចាំក្រសួងយុត្តិធម៌ :**

លោក **Sakano Issei** ទីប្រឹក្សា នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

លោក **Yamada Yoichi** អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

លោក **Imaizumi Manabu** អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

លោកស្រី **Homma Yoshiko** អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

លោក **Kai Mineo** អតីតអ្នកសម្របសម្រួល នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

លោក **Kamiki Atsushi** អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

កញ្ញា **Manabe Kana** អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

កញ្ញា **Terauchi Kozue** អ្នកសម្របសម្រួល នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

លោក **Kiyohara Hiroshi** ទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

**អ្នកបកប្រែ :**

លោក **សរ សិនិរា** អតីតជំនួយការជាន់ខ្ពស់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

លោក **គង់ ផល្លះ** អ្នកបកប្រែជាប់កិច្ចសន្យា

លោក **កែវ វ៉ាន្នី** ជំនួយការ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

លោក **Sakano Issei** ទីប្រឹក្សា នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

# គន្ថីទី ៦ ការធានាកាតព្វកិច្ច

## ជំពូកទី ១ បទប្បញ្ញត្តិទូទៅ

(កំណត់)

ជំពូកនេះចែងអំពីបញ្ញត្តិមូលដ្ឋានស្ដីពីសិទ្ធិប្រាតិភោគប្រត្យក្ស ជាពិសេស បទប្បញ្ញត្តិរួមទូទៅសម្រាប់សិទ្ធិប្រាតិភោគប្រត្យក្ស ។ ដូច្នេះហើយ បញ្ញត្តិនៃជំពូកនេះគឺជាបញ្ញត្តិចែងអំពីគោលការណ៍ រីឯបញ្ញត្តិដែលខុសពីនេះ ចែងនៅក្នុងសិទ្ធិប្រាតិភោគប្រត្យក្សនីមួយៗ ។

លក្ខណៈចម្បងនៃសិទ្ធិប្រាតិភោគប្រត្យក្ស គឺជា (១) ជនដែលមានសិទ្ធិប្រាតិភោគប្រត្យក្សមានអាទិភាពក្នុងការទទួលការសង ជាងម្ចាស់បំណុលផ្សេងទៀត (អានុភាពនៃការទទួលការសងដោយមានអាទិភាព) និង (២) ម្ចាស់សិទ្ធិប្រាតិភោគប្រត្យក្សអាចឃាត់ទុកនូវវត្ថុដែលជាកម្មវត្ថុ រហូតដល់ពេលដែលទទួលការសងនៃកាតព្វកិច្ចនោះ (អានុភាពនៃការឃាត់ទុក) ។ ក៏ប៉ុន្តែ មានសិទ្ធិប្រាតិភោគប្រត្យក្សដែលពុំមានអានុភាពទាំងនេះដែរ ហេតុដូច្នេះ ក្នុងបទប្បញ្ញត្តិទូទៅនេះ មិនឱ្យនិយមន័យនៃសិទ្ធិប្រាតិភោគប្រត្យក្សទេ ។

**មាត្រា ៧៦៦.–** និយមន័យនៃអ្នកធានាដោយវត្ថុ និង តតិយជនដែលបានធ្វើលទ្ធកម្ម

១-បុគ្គលដែលបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើទ្រព្យសម្បត្តិរបស់ខ្លួន ដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃ ត្រូវហៅថា អ្នកធានាដោយវត្ថុ ។

២-បុគ្គលដែលបានធ្វើលទ្ធកម្មនូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្សដែលបង្កើតឡើងដោយកូនបំណុល ដើម្បីធានាកាតព្វកិច្ចរបស់ខ្លួន ត្រូវហៅថាតតិយជនដែលបានធ្វើលទ្ធកម្ម ។

(កំណត់)

មាត្រានេះកំណត់និយមន័យនៃអ្នកធានាដោយវត្ថុ និង តតិយជនដែលបានធ្វើលទ្ធកម្ម ។ នៅក្នុងក្រមរដ្ឋប្បវេណី មានប្រើពាក្យទាំងនេះ (មាត្រា ៤៦០ មាត្រា ៨៥៥ និង មាត្រា ៨៥៦) ហេតុនេះហើយបានជាត្រូវមាននិយមន័យដំបូងនៅកន្លែងនេះ ។

អ្នកធានាដោយវត្ថុ គឺជាអ្នកដែលផ្ដល់នូវទ្រព្យសម្បត្តិរបស់ខ្លួន ដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃ ហើយក្នុងករណីខ្លះ ការចាត់ចែងចំពោះអ្នកនោះ ខុសពីករណីដែលកូនបំណុលខ្លួនឯងយកទ្រព្យសម្បត្តិរបស់ខ្លួនទៅធានាកាតព្វកិច្ចរបស់ខ្លួន ហេតុដូច្នេះ ចាំបាច់ត្រូវមានទស្សនៈស្ដីពីអ្នកធានាដោយវត្ថុនេះ ។ ម្យ៉ាងទៀត តតិយជនដែលបានធ្វើលទ្ធកម្មនូវទ្រព្យដែលត្រូវបានបង្កើតសិទ្ធិប្រាតិភោគ មានទំនាក់ទំនងជាមួយម្ចាស់បំណុល ដូចគ្នានឹងទំនាក់ទំនងរវាងម្ចាស់បំណុល និង អ្នកដែលបានយកទ្រព្យរបស់ខ្លួនទៅដាក់ជាប្រាតិភោគដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃ ។ ប៉ុន្តែ ទ្រព្យដែលអ្នកនោះ

បានធ្វើលទ្ធកម្ម គឺជាទ្រព្យដែលកូនបំណុលបានដាក់ជាប្រាតិភោគដើម្បីធានាកាតព្វកិច្ចរបស់ខ្លួន ហើយមានភាពចាំបាច់ចាត់ចែងដោយឡែកពីអ្នកធានាដោយវត្ថុ ហេតុដូច្នេះ មាត្រានេះបែងចែករវាងអ្នកធានាដោយវត្ថុ និង តតិយជនដែលបានធ្វើលទ្ធកម្ម មានភាពចាំបាច់ ។

**មាត្រា ៧៦៧.–** ប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្ស

១-ប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្សត្រូវកម្រិតតែប្រភេទដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ឬ ច្បាប់ពិសេសតែប៉ុណ្ណោះ ហើយក្រៅពីនេះមិនអាចបង្កើតបានឡើយ។

២-សិទ្ធិប្រាតិភោគប្រត្យក្សដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនេះ មាន ៥ (ប្រាំ) ប្រភេទ គឺ សិទ្ធិឃាត់ទុក ឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក និង សិទ្ធិប្រាតិភោគដោយអនុប្បទាន ។

(កំណត់)

មាត្រានេះចែងថា មានតែសិទ្ធិប្រាតិភោគប្រត្យក្ស ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ឬ ក្នុងច្បាប់ពិសេសទេ ដែលអាចត្រូវបានបង្កើតឡើង ហើយភាគីពុំមានសិទ្ធិសេរីភាពក្នុងការបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សប្រភេទផ្សេងតាមការព្រមព្រៀងឡើយ ។

មាត្រានេះចែងបញ្ជាក់ថា សិទ្ធិប្រាតិភោគប្រត្យក្សដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនេះ មាន ៥ ប្រភេទ រីឯនៅក្នុងក្រមរដ្ឋប្បវេណីជប៉ុនវិញ មានបញ្ញត្តិតែ ៤ ប្រភេទទេ គឺ សិទ្ធិឃាត់ទុក ឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ និង ហ៊ីប៉ូតែក ។ ក្រមរដ្ឋប្បវេណីកម្ពុជានេះ ក្រៅពី ៤ ប្រភេទនេះ មានបញ្ញត្តិស្ដីពីប្រាតិភោគដោយអនុប្បទាន ដែលជាប្រភេទមួយផ្សេងទៀត (នៅជប៉ុន គេទទួលស្គាល់នូវប្រាតិភោគដោយអនុប្បទាន ដោយយុត្តិសាស្ត្រ និង ដោយទ្រឹស្ដីនីតិសាស្ត្រ) ។ ម្យ៉ាងទៀត ចំពោះហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតវិញ ក្នុងនេះបញ្ញត្តថា នេះគឺជាហ៊ីប៉ូតែកមួយប្រភេទ គឺដូចដែលបានចែងនៅក្នុងក្រមរដ្ឋប្បវេណីជប៉ុនដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៧៥ នៃក្រមរដ្ឋប្បវេណីជប៉ុន (សិទ្ធិប្រត្យក្សទូទៅ)

**មាត្រា ៧៦៨.–** វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្ស

សិទ្ធិប្រាតិភោគប្រត្យក្សមិនអាចយកវត្ថុ ឬ សិទ្ធិណាដែលមិនអាចធ្វើអនុប្បទានបាន មកធ្វើជាកម្មវត្ថុបានទេ ។ ប៉ុន្តែ បញ្ញត្តិនេះមិនរារាំងការបង្កើតសិទ្ធិឃាត់ទុកលើវត្ថុដែលមិនអាចធ្វើអនុប្បទានបានឡើយ ។

(កំណត់)

មាត្រានេះចែងថា វត្ថុ ឬ សិទ្ធិ ដែលមិនអាចធ្វើអនុប្បទានបាន មិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្ស បានឡើយ ។ អត្ថន័យនៃសិទ្ធិប្រាតិភោគមានត្រង់ចំណុចថា ក្នុងករណីដែលកាតព្វកិច្ចមិនត្រូវបានសងទេ វត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគនោះ ត្រូវបានចាត់ចែងប្តូរជាប្រាក់ ហើយម្ចាស់សិទ្ធិប្រាតិភោគនឹងទទួលការសងពីប្រាក់នោះដោយមានអាទិភាព ហេតុដូច្នេះ វត្ថុដែលមិនអាចត្រូវបានប្តូរជាប្រាក់ដោយសារមិនអាចធ្វើអនុប្បទានបានទេ មិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគបានឡើយ ។ ក៏ប៉ុន្តែ ចំពោះសិទ្ធិឃាត់ទុកវិញ ពុំមានសិទ្ធិទទួលការសងដោយមានអាទិភាពទេ ហើយសិទ្ធិឃាត់ទុកគឺជាសិទ្ធិដើម្បីតឿនឱ្យកូនបំណុលសងកាតព្វកិច្ចដោយអានុភាពនៃការឃាត់ទុកនេះ ហេតុនេះហើយបានជាអាចទទួលស្គាល់នូវការយកវត្ថុដែលពុំអាចធ្វើអនុប្បទានបាន មកធ្វើជាកម្មវត្ថុនៃសិទ្ធិឃាត់ទុក ។ ហេតុដូច្នេះ វាក្យខណ្ឌទី ២ បានចែងថា ចំពោះសិទ្ធិឃាត់ទុកវិញ អាចយកវត្ថុដែលពុំអាចធ្វើអនុប្បទានបាន មកបង្កើតសិទ្ធិនេះបាន ។ ក៏ប៉ុន្តែ ក្នុងករណីនេះ គ្មានសិទ្ធិលក់ដោយបង្ខំទេ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៣៤៣ នៃក្រមរដ្ឋប្បវេណីជប៉ុន ( ស្តីពីសិទ្ធិលើការបញ្ចាំ)

**មាត្រា ៧៦៩.–** ភាពបន្ទាប់បន្សំនៃសិទ្ធិប្រាតិភោគប្រត្យក្ស

១-សិទ្ធិប្រាតិភោគប្រត្យក្ស ត្រូវបានបង្កើតឡើង ដើម្បីធានាកាតព្វកិច្ចដែលមានអត្ថិភាពហើយ ។ ប៉ុន្តែ ទោះបីជាកាតព្វកិច្ចដែលនឹងកើតឡើងនាពេលអនាគតក៏ដោយ ក្នុងករណីដែលអាចកំណត់កាតព្វកិច្ចបាន ក៏សិទ្ធិប្រាតិភោគប្រត្យក្សអាចបង្កើតបានដែរ ដោយយកកាតព្វកិច្ចនោះមកធ្វើជាកាតព្វកិច្ចដែលត្រូវបានធានា ។

២-ក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានាមិនត្រូវបានបង្កើតឡើង ដោយសារខ្វះល័ក្ខខ័ណ្ឌ សិទ្ធិប្រាតិភោគប្រត្យក្សក៏មិនត្រូវបានបង្កើតឡើងដែរ ។

៣-ក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានាត្រូវបានចាត់ទុកជាមោឃៈ ដោយសារមានវិការៈក្នុងការបង្ហាញឆន្ទៈ ឬ ដោយសារហេតុផ្សេងទៀត ឬ ក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានាត្រូវបានលុបចោល សិទ្ធិប្រាតិភោគប្រត្យក្សក៏មិនត្រូវមានអានុភាពឡើយ ។

៤-ក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានាបានរលត់ ដោយសារការសង ឬ អាជ្ញាយុកាលនៃការរលត់សិទ្ធិ ឬ ហេតុផ្សេងទៀត សិទ្ធិប្រាតិភោគប្រត្យក្សក៏ត្រូវរលត់ដែរ ។

៥-បញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ ទី ៣ និង កថាខណ្ឌទី ៤ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលត្រូវបានបង្កើតឡើងដើម្បីធានាសិទ្ធិលើបំណុលច្រើនដែលកើតឡើងដោយកិច្ចសន្យាបន្តបន្ទាប់ ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះចែងថា សិទ្ធិប្រាតិភោគអាចបង្កើតឡើង មិនមែនតែដើម្បីធានាកាតព្វកិច្ចដែលមានអត្ថិភាពហើយប៉ុណ្ណោះទេ ព្រមទាំងដើម្បីធានាកាតព្វកិច្ចដែលនឹងកើតមានឡើងនាពេលអនាគតបានដែរ ប្រសិនបើអាចកំណត់កាតព្វកិច្ចនោះបាន ។ ចំពោះបញ្ហាថា តើត្រូវកំណត់កាតព្វកិច្ចនោះនៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដូចម្តេចដើម្បីអាចសន្និដ្ឋានថា កំណត់កាតព្វកិច្ចដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគ បញ្ហានេះទុកសម្រាប់ការបកស្រាយ ។

ម្យ៉ាងទៀត បញ្ញត្តិចាប់ពីកថាខណ្ឌទី ១ ដល់កថាខណ្ឌទី ៤ ចែងអំពីភាពបន្ទាប់បន្សំនៃសិទ្ធិប្រាតិភោគប្រត្យក្ស ។ មានន័យថា ប្រសិនបើមិនអាចបង្កើតសិទ្ធិលើបំណុលបានទេ សិទ្ធិប្រាតិភោគប្រត្យក្សក៏មិនអាចបង្កើតឡើងបានដែរ ហើយប្រសិនបើសិទ្ធិលើបំណុលបានរលត់ សិទ្ធិប្រាតិភោគប្រត្យក្សក៏ត្រូវរលត់ដែរ ។ ឧទាហរណ៍ A បានឱ្យ B ខ្ចីលុយ រីឯ B បានបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុរបស់ខ្លួន ដើម្បីធានាកាតព្វកិច្ចរបស់ខ្លួន ។ ក្នុងករណីនេះ ពេលដែលបំណុលនោះត្រូវបានសងរួចហើយ កាតព្វកិច្ចត្រូវរលត់ ហើយហ៊ីប៉ូតែកក៏ត្រូវរលត់ដែរ ។

ក៏ប៉ុន្តែ មានបញ្ញត្តិដើម្បីបន្ធូរភាពបន្ទាប់បន្សំនេះដែរ ។ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ចំពោះសិទ្ធិលើបំណុលច្រើនដែលនឹងកើតឡើងនាពេលអនាគត តាមកិច្ចសន្យាជាបន្តបន្ទាប់ ទោះបីជាសិទ្ធិលើបំណុលនីមួយៗនោះមិនទាន់បានកើតឡើងជាក់ស្តែងក៏ដោយ ក៏អាចបង្កើតសិទ្ធិប្រាតិភោគជាមុន ដើម្បីធានានូវសិទ្ធិលើបំណុលដែលនឹងកើតឡើងនាពេលអនាគតដែរ (គេហៅថា ប្រាតិភោគដើម្បីធានាបំណុលអណ្តែត) ។ ឧទាហរណ៍ ក្នុងកិច្ចសន្យាផ្គត់ផ្គង់ទំនិញជាបន្តបន្ទាប់ រវាងអ្នកផលិតទំនិញ (ឬ អ្នកលក់ដុំ) និង អ្នកលក់រាយ ភាគីអាចបង្កើតហ៊ីប៉ូតែកដើម្បីធានាសិទ្ធិលើបំណុលចំពោះថ្លៃលក់ជឿដែលនឹងកើតឡើងនាពេលអនាគត តាមកិច្ចការជំនួញនេះបាន ។ ចំពោះករណីនេះ ការមិនបង្កើតមោឃភាព ការលុបចោល ឬ ការរលត់នៃហ៊ីប៉ូតែក មិនអាចកើតឡើងដោយសារការមិនបង្កើត មោឃភាព ការលុបចោល ឬ ការរលត់នៃកាតព្វកិច្ចនីមួយៗនោះទេ ហេតុដូច្នេះ កថាខណ្ឌទី ៥ បានចែងថា ក្នុងករណីនេះ មិនត្រូវអនុវត្តតាមបញ្ញត្តិចាប់ពី កថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ ទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៣៨៨ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា (ការបញ្ចាំចលនវត្ថុ)

**មាត្រា ៧៧០.–** ភាពទៅជាមួយគ្នានៃសិទ្ធិប្រាតិភោគប្រត្យក្ស

១-ក្នុងករណីដែលសិទ្ធិលើបំណុលដែលសិទ្ធិប្រាតិភោគប្រត្យក្សត្រូវបានបង្កើតត្រូវបានផ្ទេរ បើគ្មានការបង្ហាញឆន្ទៈផ្សេងទេ សិទ្ធិប្រាតិភោគប្រត្យក្សនោះក៏ត្រូវបានផ្ទេរ

ទៅឱ្យអ្នកដែលទទួលសិទ្ធិលើបំណុលនេះដែរ ។ ប៉ុន្តែ ក្នុងករណីដែលចាំបាច់តម្រូវឱ្យម្ចាស់សិទ្ធិលើប្រាតិភោគ កាន់កាប់វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគនោះ អ្នកទទួលការផ្ទេរសិទ្ធិលើបំណុលក៏ចាំបាច់ត្រូវទទួលនូវការកាន់កាប់វត្ថុដែលជាកម្មវត្ថុនោះដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានា ដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។[1]

(កំណត់)

វាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រានេះចែងថា ក្នុងករណីដែលមានការអនុប្បទានសិទ្ធិលើបំណុលដែលត្រូវបានធានា ប្រសិនបើមិនបានបង្ហាញឆន្ទៈច្បាស់លាស់ថា មិនធ្វើអនុប្បទានសិទ្ធិប្រាតិភោគប្រត្យក្សដូច្នេះទេ សិទ្ធិប្រាតិភោគប្រត្យក្សក៏ត្រូវផ្ទេរដែរ ។ ហើយវាក្យខណ្ឌទី ២ នៃកថាខណ្ឌនេះ បានចែងថា ចំពោះសិទ្ធិឃាត់ទុក និង សិទ្ធិលើការបញ្ចាំ ចាំបាច់ត្រូវផ្ទេរនូវការកាន់កាប់វត្ថុដែលជាកម្មវត្ថុនោះ (នេះជាការធម្មតាទេ) ។ ឧទាហរណ៍ ក្នុងករណីដែល A បានឱ្យ B ខ្ចីលុយ ហើយដើម្បីធានាសិទ្ធិលើបំណុលនេះ B បានបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុរបស់ខ្លួន ប្រសិនបើ A បានធ្វើអនុប្បទានសិទ្ធិលើបំណុលនេះទៅឱ្យ C ហ៊ីប៉ូតែកនោះក៏ត្រូវផ្ទេរទៅឱ្យ C ដែរ លើកលែងតែមានការព្រមព្រៀងក្នុងកិច្ចសន្យាអនុប្បទាននេះថា មិនផ្ទេរហ៊ីប៉ូតែកទេ (មានន័យថា ការព្រមព្រៀងទាំងដោយការបង្ហាញឆន្ទៈជាក់ស្តែង ទាំងដោយតុណ្ហីភាព) ។ ហេតុនេះហើយ ប្រសិនបើ B មិនសងកាតព្វកិច្ចទេ C អាចអនុវត្តហ៊ីប៉ូតែកនោះបាន ដើម្បីយកមកបំពេញការសងនៃកាតព្វកិច្ចនោះបាន ។

កថាខណ្ឌទី ២ បញ្ញត្តថា ពេលដែលសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតត្រូវបានធ្វើអនុប្បទាន ហ៊ីប៉ូតែកដើម្បីធានាលើបំណុលអណ្តែតនោះ មិនត្រូវបានផ្ទេរឡើយ ។

**មាត្រា ៧៧១.–** អវិភាគភាពនៃសិទ្ធិប្រាតិភោគប្រត្យក្ស

អានុភាពនៃសិទ្ធិប្រាតិភោគប្រត្យក្សត្រូវមានលើវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្សទាំងអស់ រហូតដល់ពេលដែលម្ចាស់សិទ្ធិប្រាតិភោគបានទទួលសំណងនៃសិទ្ធិលើបំណុលទាំងអស់ ។

(កំណត់)

មាត្រានេះចែងថា ទោះជាបានសងសិទ្ធិលើបំណុលមួយភាគក៏ដោយ ក៏សិទ្ធិប្រាតិភោគប្រត្យក្សមិនត្រូវបានបង្រួញដែរ ។ ឧទាហរណ៍ ចំពោះករណីដែល A បានឱ្យ B ខ្ចីប្រាក់ ហើយ B បានបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុរបស់ខ្លួន

---

[1] មាត្រា ៧៧០ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

ដើម្បីធានាសិទ្ធិលើបំណុលនោះ ទោះបីជា B បានសងកាតព្វកិច្ចនោះមួយភាគហើយក៏ដោយ ក៏ហ៊ីប៉ូតែកនោះមិនរលត់ដែរ ប្រសិនបើកាតព្វកិច្ចនៅសល់ ហើយ A អាចអនុវត្តហ៊ីប៉ូតែកចំពោះអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកនោះទាំងស្រុងបាន ។

ម្យ៉ាងទៀត ចំពោះសិទ្ធិប្រាតិភោគប្រត្យក្សដែលត្រូវបានបង្កើតឡើងដោយកិច្ចសន្យា ភាគីអាចរំលត់សិទ្ធិប្រាតិភោគប្រត្យក្សមួយភាគ ទៅតាមភាគនៃការសងនោះ តាមការព្រមព្រៀងបាន (ចំពោះសិទ្ធិប្រាតិភោគប្រត្យក្សដែលច្បាប់បានកំណត់ ក៏អាចគិតដូចគ្នាបានដែរ) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ២៩៦ នៃក្រមរដ្ឋប្បវេណីជប៉ុន (ស្តីពីសិទ្ធិឃាត់ទុក), មាត្រា ១៣៣៧ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា (ស្តីពីសិទ្ធិលើការបញ្ចាំចលនវត្ថុ ករណីយកិច្ចប្រគល់មកវិញនូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ពេលដែលសិទ្ធិនោះរលត់)

## មាត្រា ៧៧២.- អានុភាពតាមនៃសិទ្ធិប្រាតិភោគប្រត្យក្ស

ក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្សត្រូវបានធ្វើអនុប្បទានទៅតតិយជន ម្ចាស់សិទ្ធិប្រាតិភោគនោះ អាចយកអានុភាពនៃសិទ្ធិប្រាតិភោគប្រត្យក្សមកតតាំងចំពោះតតិយជននោះបាន លើកលែងតែករណីដែលបានកំណត់នៅក្នុងមាត្រា ៨០៧ (អានុភាពតាមចំពោះតតិយជនដែលបានធ្វើលទ្ធកម្ម) ស្តីពីឯកសិទ្ធិ និង មាត្រា ៨៩៤ (ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកបង្កើត) ស្តីពីប្រាតិភោគដោយអនុប្បទាន នៃក្រមនេះ ។ ប៉ុន្តែ តម្រូវឱ្យម្ចាស់សិទ្ធិប្រាតិភោគនោះមានគ្រប់គ្រាន់នូវល័ក្ខខ័ណ្ឌតតាំង ។

(កំណត់)

មាត្រានេះចែងថា ទោះបីជាវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្សត្រូវបានផ្ទេរក៏ដោយ ក៏អានុភាពនៃសិទ្ធិប្រាតិភោគប្រត្យក្សនោះនៅតែមានលើវត្ថុនោះដែរ ។ ឧទាហរណ៍ ក្នុងករណីដែល A មានសិទ្ធិលើបំណុលចំពោះប្រាក់កម្ចីចំពោះ B ហើយ B បានបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុរបស់ខ្លួន ដើម្បីធានាសិទ្ធិលើបំណុលនោះ ទោះជា B បានធ្វើអនុប្បទានអចលនវត្ថុនោះទៅឱ្យ C ក៏ដោយ ក៏ A អាចអនុវត្តហ៊ីប៉ូតែកចំពោះ C ដែលជាតតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកនោះបានដែរ ។ មានន័យថា ប្រសិនបើ B មិនសងកាតព្វកិច្ចទេ A អាចអនុវត្តហ៊ីប៉ូតែកបាន ហើយអាចទទួលនូវការសងដោយមានអាទិភាព ពីប្រាក់ដែលបានមកពីការលក់អចលនវត្ថុហ៊ីប៉ូតែកនោះបាន ។

ម្យ៉ាងទៀត មាត្រានេះក៏ចែងពិសេសដោយយោងតាមមាត្រាផ្សេងដែរថា ឯកសិទ្ធិនេះពុំមានអានុភាពតាមបែបនេះទេ (សូមមើលមាត្រា ៨០៧) ។

**មាត្រា ៧៧៣.–** ការអនុវត្តសិទ្ធិប្រាតិភោគប្រត្យក្ស

ប្រសិនបើម្ចាស់សិទ្ធិប្រាតិភោគមិនបានទទួលសំណងនៃសិទ្ធិលើបំណុលទេ អ្នកនោះអាចអនុវត្តសិទ្ធិប្រាតិភោគប្រត្យក្សនេះ តាមនីតិវិធីដែលច្បាប់បានកំណត់ បាន ។

(កំណត់)

មាត្រានេះចែងថា ក្នុងករណីដែលកូនបំណុលពុំសងកាតព្វកិច្ចទេ ម្ចាស់បំណុលអាចអនុវត្តសិទ្ធិប្រាតិភោគប្រត្យក្សបានដោយវិធីដូចជាការលក់ដោយបង្ខំនូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្សនោះ ។ ក្នុងករណីដែលទទួលស្គាល់ឱ្យម្ចាស់សិទ្ធិប្រាតិភោគប្រត្យក្សមានសេរីភាពក្នុងការប្តូរជាប្រាក់ ក្រៅពីការលក់ដោយបង្ខំនេះ ត្រូវបញ្ញត្តអំពីបញ្ហានេះនៅក្នុងភាគស្តីពីសិទ្ធិប្រាតិភោគនីមួយៗនោះ (ឧទាហរណ៍ ស្តីពីសិទ្ធិលើការបញ្ចាំចលនវត្ថុ មាននៅក្នុងមាត្រា ៨៣២ ជាអាទិ៍) ។ ម្យ៉ាងទៀត ចំពោះសិទ្ធិប្រាតិភោគដោយអនុប្បទានវិញ ក្រមនេះទទួលស្គាល់ឱ្យម្ចាស់សិទ្ធិប្រាតិភោគនោះអនុវត្តសិទ្ធិប្រាតិភោគ ដោយចាត់ចែងប្តូរជាប្រាក់ ឬ ដោយលទ្ធកម្មជាស្ថាពរ (មាត្រា ៨៩៨) មិនមែនដោយការលក់ដោយបង្ខំទេ ។

ម្យ៉ាងទៀត ចំពោះនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគ ដូចជាការលក់ដោយបង្ខំ ជាអាទិ៍ វិញ មានបញ្ញត្តិផ្សេងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៣៤០ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា (ស្តីពីការបញ្ចាំចលនវត្ថុ), មាត្រា ៧០ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច. (ស្តីពីការបញ្ចាំ)

## ជំពូកទី ២ សិទ្ធិឃាត់ទុក

(កំណត់)

នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន សិទ្ធិឃាត់ទុក គឺជាសិទ្ធិមួយប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្ស ក៏ប៉ុន្តែ នៅក្នុងក្រមរដ្ឋប្បវេណីបារាំងវិញ មិនគិតបែបនេះទេ (ជាសារធាតុ បញ្ញត្តិទាក់ទងនឹងសិទ្ធិឃាត់ទុក មិនដាក់នៅផ្តុំគ្នាទេ) ។ រីឯនៅក្នុងក្រមនេះវិញ ក៏ដូចក្រមរដ្ឋប្បវេណីជប៉ុនដែរ សិទ្ធិឃាត់ទុក គឺជាសិទ្ធិប្រាតិភោគប្រត្យក្សមួយប្រភេទ ។ ក៏ប៉ុន្តែ ម្ចាស់សិទ្ធិឃាត់ទុក ពុំមានសិទ្ធិទទួលការសងដោយមានអាទិភាពទេ ។

ឧទាហរណ៍ជាក់ស្តែងដែលសិទ្ធិឃាត់ទុកកើតឡើងមានដូចជា ករណីដែលអ្នកជួសជុលឡានបានអនុវត្តសិទ្ធិឃាត់ទុកលើឡានដែលបានជួសជុល ចំពោះសិទ្ធិលើបំណុលនៃថ្លៃឈ្នួលជួសជុលឡាន ឬ ករណីដែលភតិកៈជួលអាគារបានអនុវត្តសិទ្ធិឃាត់ទុកលើផ្ទះដែលបានជួលនោះក្រោយការបញ្ចប់នៃភតិសន្យា ចំពោះសិទ្ធិទាមទារនូវសំណងនៃថ្លៃជួសជុលអាគារ ជាដើម ។

**មាត្រា ៧៧៤.–** អត្ថន័យនៃសិទ្ធិឃាត់ទុក

១-ប្រសិនបើអ្នកកាន់កាប់វត្ថុរបស់អ្នកដទៃ មានសិទ្ធិលើបំណុលដែលបានកើតឡើង ដោយទាក់ទងនឹងវត្ថុនោះ អ្នកនោះអាចឃាត់ទុកនូវវត្ថុនោះបាន រហូតដល់ពេលដែលខ្លួនទទួលការសងចំពោះសិទ្ធិលើបំណុលនោះ ។ ប៉ុន្តែ សិទ្ធិឃាត់ទុកមិនត្រូវកើតមានឡើយ ប្រសិនបើសិទ្ធិលើបំណុលនោះមិនទាន់ដល់ពេលកំណត់ត្រូវសង ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការកាន់កាប់ត្រូវបានចាប់ផ្តើម ដោយអំពើអនីត្យានុកូល ។

(កំណត់)

មាត្រានេះកំណត់អំពីអត្ថន័យនៃសិទ្ធិឃាត់ទុក ។ ដើម្បីបង្កើតសិទ្ធិឃាត់ទុក ចាំបាច់ត្រូវមានទំនាក់ទំនងរវាងសិទ្ធិលើបំណុល និង វត្ថុនោះ (សិទ្ធិលើបំណុលបានកើតចំពោះវត្ថុនោះ) ។ ឧទាហរណ៍ ស្តីពីសិទ្ធិលើបំណុលនៃថ្លៃជួសជុលឡានរបស់អ្នកជួសជុលឡាន ក្នុងករណីដែល A បានពឹងឱ្យ B ជួសជុលឡាន ហើយ B បានអនុវត្តសិទ្ធិឃាត់ទុកលើឡានដែលខ្លួនបានជួសជុលនោះ ។ ក្នុងករណីនេះ B អាចឃាត់ទុកឡានដែលបានជួសជុលនោះបាន (អាចបដិសេធមិនប្រគល់ឡាននោះបាន) រហូតដល់ពេលបានទទួលនូវការបង់ថ្លៃជួសជុលឡាន ដោយអនុវត្តសិទ្ធិឃាត់ទុកចំពោះ A ។ ឧទាហរណ៍មួយទៀត ក្នុងករណីដែល C បានជួលផ្ទះឱ្យ D ហើយប្រសិនបើ D បានជួសជុលផ្ទះនោះដោយចេញសោហ៊ុយខ្លួនឯង D អាចអនុវត្តសិទ្ធិឃាត់ទុកលើផ្ទះដែលបានជួល ចំពោះសិទ្ធិទាមទារឱ្យសងថ្លៃជួសជុលផ្ទះនោះ ក្រោយពេលចប់ភតិសន្យាបាន ។ ក្នុងករណីនេះ ចំពោះថ្លៃជួសជុលដែល D បានចំណាយ D អាចឃាត់ទុកផ្ទះដែលបានជួលនោះទុកដោយមិនព្រមប្រគល់ទៅឱ្យ C វិញបាន រហូតដល់ពេលបានទទួលសំណងនៃថ្លៃជួសជុលនោះ ។

ម្យ៉ាងទៀត នៅប្រទេសជប៉ុន នៅក្នុងក្រមពាណិជ្ជកម្ម មានបញ្ញត្តិចែងថា សិទ្ធិឃាត់ទុកក្នុងកិច្ចការពាណិជ្ជកម្មមិនចាំបាច់មានទំនាក់ទំនងរវាងសិទ្ធិលើបំណុល និង វត្ថុទេ (មាត្រា ៥២១ នៃក្រមពាណិជ្ជកម្មជប៉ុន) ។

កូនបំណុលមិនចាំបាច់ជាកម្មសិទ្ធិករនៃវត្ថុដែលឃាត់ទុកនោះទេ ។ ទោះជាវត្ថុរបស់អ្នកផ្សេងក៏ដោយ ក៏សិទ្ធិឃាត់ទុកអាចកើតឡើងដែរ ។ ឧទាហរណ៍នៃករណីជួសជុលឡានដែលបានពិពណ៌នាខាងលើនេះ ប្រសិនបើ A បានឱ្យ B ជួសជុលឡានដែលខ្លួនបានជួលពី X ក៏ B អាចអនុវត្តសិទ្ធិឃាត់ទុក ចំពោះថ្លៃជួសជុលនោះបានដែរ ។ ហើយដោយសារសិទ្ធិឃាត់ទុកគឺជាសិទ្ធិប្រត្យក្ស សិទ្ធិឃាត់ទុកមានអានុភាពតតាំងចំពោះតតិយជន ហេតុនេះហើយ B អាចបដិសេធមិនប្រគល់ឡានដែលខ្លួនបានជួសជុលនោះមិនត្រឹមតែចំពោះ A ប៉ុណ្ណោះទេ គឺអាចធ្វើចំពោះ X បានផងដែរ ។

ម្ចាស់សិទ្ធិឃាត់ទុក ពុំមានសិទ្ធិទទួលការសងដោយមានអាទិភាពទេ ។ ក៏ប៉ុន្តែ ទោះបីជាមានតតិយជនបានទាមទារឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុនោះ (ឧទាហរណ៍ ម្ចាស់បំណុលផ្សេងទៀតដែលចង់លក់វត្ថុដែលជាកម្មវត្ថុនោះដោយបង្ខំ) ក៏ដោយ ក៏ម្ចាស់សិទ្ធិឃាត់ទុកអាចបដិសេធមិនប្រគល់វត្ថុដែលជាកម្មវត្ថុនោះបានដែរ រហូតដល់ពេលដែលខ្លួនបានទទួល

នូវការសងថ្លៃជួសជុលរួចហើយ ដូច្នេះ ទើបជាលទ្ធផលជាក់ស្តែង អ្នកនោះមានអាទិភាពក្នុងការទទួលសំណង ។

ក្នុងករណីដែលកូនបំណុលមិនបានសងកាតព្វកិច្ច អ្នកមានសិទ្ធិប្រាតិភោគអាចចាត់ចែងប្តូរវត្ថុឃាត់ទុកជាប្រាក់ ហើយទាមទារសំណងនៃកាតព្វកិច្ចពីប្រាក់មកពីការលក់នោះបាន ។ ចំពោះបញ្ហានេះ មានបញ្ញត្តិនៅក្នុងបទប្បញ្ញត្តិទូទៅ (មាត្រា ៧៧៣) ហេតុនេះហើយ មិនចាំបាច់បញ្ញត្តក្នុងនេះទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ២៩៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧៧៥.–** សិទ្ធិទទួលសំណងពីផលដោយមានអាទិភាព

១-ម្ចាស់សិទ្ធិឃាត់ទុក អាចទទួលផលពីវត្ថុដែលឃាត់ទុក និង អាចយកផលនោះមកកាត់សិទ្ធិលើបំណុល ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន ។

២-ផលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុនសិន ហើយប្រសិនបើមានសំណល់ ត្រូវយកមកកាត់ប្រាក់ដើម ។

(កំណត់)

មាត្រានេះចែងថា ម្ចាស់សិទ្ធិឃាត់ទុក មានសិទ្ធិអាស្រ័យផល ប៉ុន្តែ ចែងផងដែរថា ផលដែលបានមកពីវត្ថុឃាត់ទុក ត្រូវយកទៅកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុនសិន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ២៩៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧៧៦.–**ករណីយកិច្ចរបស់ម្ចាស់សិទ្ធិឃាត់ទុកក្នុងការរក្សាគ្រប់គ្រងវត្ថុដែលឃាត់ទុក

១-ម្ចាស់សិទ្ធិឃាត់ទុក ត្រូវកាន់កាប់វត្ថុដែលឃាត់ទុកនោះ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-ម្ចាស់សិទ្ធិឃាត់ទុក មិនអាចយកវត្ថុដែលឃាត់ទុកនោះ ទៅប្រើប្រាស់ ឬ ជួល ឬ ដាក់ជាប្រាតិភោគបានទេ បើគ្មានការយល់ព្រមពីសំណាក់កូនបំណុល ។ ប៉ុន្តែ ម្ចាស់សិទ្ធិឃាត់ទុកអាចប្រើប្រាស់វត្ថុដែលឃាត់ទុកបាន ត្រឹមកម្រិតដែលចាំបាច់ក្នុងការរក្សានូវវត្ថុឃាត់ទុកនោះ ។

៣-ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកបានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ កូនបំណុលអាចទាមទារឱ្យរំលត់នូវសិទ្ធិឃាត់ទុកនោះបាន ។

(កំណត់)

មាត្រានេះចែងថា ម្ចាស់សិទ្ធិឃាត់ទុកមានករណីយកិច្ចប្រុងប្រយ័ត្នបំផុត ក្នុងការកាន់កាប់វត្ថុឃាត់ទុកនោះ ក្នុងនាមជាអ្នករក្សាគ្រប់គ្រងវត្ថុអ្នកដទៃ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ២៩៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧៧៧.-** សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិឃាត់ទុក

១-ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ ចំពោះវត្ថុដែលឃាត់ទុក ម្ចាស់សិទ្ធិឃាត់ទុកនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងចំណាយវិញបាន ។

២-ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកបានចេញចំណាយបង្កើនតម្លៃ ចំពោះវត្ថុដែលឃាត់ទុក ម្ចាស់សិទ្ធិឃាត់ទុកនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងចំណាយទាំងអស់ដែលខ្លួនបានចេញ ឬ តម្លៃប្រាក់កំណើនដែលមានអត្ថិភាព តាមការជ្រើសរើសរបស់កម្មសិទ្ធិករបាន ក្នុងករណីដែលកំណើនតម្លៃនោះនៅតែមាន ។ ប៉ុន្តែ តុលាការអាចកំណត់ពេលសមរម្យដើម្បីសង តាមការទាមទាររបស់កម្មសិទ្ធិករបាន ។

(កំណត់)

មាត្រានេះចែងថា ម្ចាស់សិទ្ធិឃាត់ទុកអាចទាមទារនូវសំណងនៃសោហ៊ុយដែលខ្លួនបានចំណាយទៅលើវត្ថុឃាត់ទុកនោះបាន ។ មាត្រានេះបែងចែករវាងសោហ៊ុយចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ និង សោហ៊ុយបង្កើនតម្លៃ ។

កថាខណ្ឌទី ១ ចែងថា ចំពោះសោហ៊ុយចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ ម្ចាស់សិទ្ធិឃាត់ទុកដែលបានចេញចំណាយនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងចំណាយវិញភ្លាមបាន ។

កថាខណ្ឌទី ២ អនុញ្ញាតឱ្យម្ចាស់សិទ្ធិឃាត់ទុកទាមទារឱ្យកម្មសិទ្ធិករសងសោហ៊ុយបង្កើនតម្លៃវិញ ប៉ុន្តែ ករណីយកិច្ចត្រូវសងរបស់កម្មសិទ្ធិករ ត្រូវបានបន្ធូរ ។ ទី ១ ករណីដែលម្ចាស់សិទ្ធិឃាត់ទុកត្រូវបានអនុញ្ញាតឱ្យទាមទារសងសោហ៊ុយបង្កើនតម្លៃ ត្រូវបានកម្រិតតែករណីដែលកំណើនតម្លៃនោះនៅតែមាន ។ ទី ២ ចំពោះទំហំនៃការទាមទារសំណង កម្មសិទ្ធិករដែលមានករណីយកិច្ចសង អាចជ្រើសរើសចំណាយទាំងអស់ដែលខ្លួនបានចេញ ឬ តម្លៃប្រាក់កំណើនដែលមានអត្ថិភាពបាន (ក្នុងចំណោមនេះ កម្មសិទ្ធិករអាចជ្រើសរើសចំនួនទឹកប្រាក់តិចជាងបាន) ។ ទី ៣ តុលាការអាចកំណត់ពេល

សមរម្យដើម្បីសង តាមការទាមទាររបស់កម្មសិទ្ធិករបាន ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ២៩៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧៧៨.–** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ការអនុវត្តសិទ្ធិឃាត់ទុក មិនរារាំងដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ។

( កំណត់)

មាត្រានេះចែងថា ទោះជាបានអនុវត្តសិទ្ធិឃាត់ទុកក៏ដោយ ក៏ដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលត្រូវបានដាក់ធានាដោយសិទ្ធិឃាត់ទុកនោះ មិនត្រូវផ្អាកទេ ។ ដើម្បីឱ្យអាជ្ញាយុកាលនៃសិទ្ធិលើបំណុលផ្អាក ត្រូវធ្វើនីតិវិធីឱ្យផ្អាកអាជ្ញាយុកាល ដូចជាការទាមទារតាមផ្លូវតុលាការ ជាដើម ( គន្លឹស្ដីពីកាតព្វកិច្ច មាត្រា ៤៨៩ ទៅ) ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៣០០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧៧៩.–** ការរំលត់សិទ្ធិឃាត់ទុក ដោយការផ្ដល់នូវប្រាតិភោគ

កូនបំណុលអាចទាមទារឱ្យរំលត់នូវសិទ្ធិឃាត់ទុកបាន ដោយផ្ដល់នូវប្រាតិភោគដ៏សមរម្យ ។

( កំណត់)

មាត្រានេះចែងថា កូនបំណុលអាចរំលត់សិទ្ធិឃាត់ទុកបាន ដោយផ្ដល់នូវប្រាតិភោគដ៏សមស្របមួយ ។ ក្នុងករណីនេះមិនចាំបាច់មានការយល់ព្រមពីម្ចាស់សិទ្ធិឃាត់ទុក ( ដែលជាម្ចាស់បំណុល) ទេ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៣០១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧៨០.–** ការរំលត់សិទ្ធិឃាត់ទុក ដោយការបាត់បង់នូវការកាន់កាប់

១-សិទ្ធិឃាត់ទុកត្រូវរលត់ ពេលណាម្ចាស់សិទ្ធិឃាត់ទុកបានបាត់បង់នូវការកាន់កាប់វត្ថុឃាត់ទុកនោះ ។ ប៉ុន្តែ ក្នុងករណី ដែលម្ចាស់សិទ្ធិឃាត់ទុកបានយកវត្ថុនោះ ទៅជួល ឬដាក់បញ្ចាំ ដោយទទួលការយល់ព្រមពីកូនបំណុល តាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា

៧៧៦ (ករណីយកិច្ចរបស់ម្ចាស់សិទ្ធិឃាត់ទុកក្នុងការរក្សាគ្រប់គ្រងវត្ថុដែលឃាត់ទុក) នៃក្រមនេះ សិទ្ធិឃាត់ទុកនេះមិនត្រូវរលត់ឡើយ ។

២-ទោះបីជាម្ចាស់សិទ្ធិឃាត់ទុកបានបាត់បង់នូវការកាន់កាប់វត្ថុឃាត់ទុកក៏ដោយ ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកនោះ បានការកាន់កាប់នោះមកវិញ តាមបញ្ញត្តិនៃមាត្រា ២៣៧ (សិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ) នៃក្រមនេះ ការកាន់កាប់នោះ ត្រូវបានចាត់ទុកថា បានបន្តរហូតមក ។

(កំណត់)

មាត្រានេះចែងថា ដើម្បីឱ្យសិទ្ធិឃាត់ទុកបន្តមានអត្ថិភាព ម្ចាស់សិទ្ធិឃាត់ទុកចាំបាច់ត្រូវកាន់កាប់វត្ថុឃាត់ទុកនោះជានិរន្តរ៍ ។ ទោះបីជាម្ចាស់សិទ្ធិឃាត់ទុកបានបាត់បង់នូវការកាន់កាប់ក៏ដោយ ប្រសិនបើបានកាន់កាប់ឡើងវិញ ដោយសារបណ្តឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ សិទ្ធិឃាត់ទុកនឹងមិនរលត់ទេ (សូមមើលមាត្រា ២៣០ ស្តីពីអានុភាពនៃការអនុវត្តសិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ) ។

វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ គឺជាបញ្ញត្តិមួយដែលមិនចាំបាច់មាន ក៏អាចយល់ដឹងបានដែរ ក៏ប៉ុន្តែ បញ្ញត្តិនេះត្រូវបានដាក់បញ្ចូលដើម្បីឱ្យបានច្បាស់លាស់ថែមទៀត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣០២ នៃក្រមរដ្ឋប្បវេណីជប៉ុន

# ជំពូកទី ៣ ឯកសិទ្ធិ

## ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ

**មាត្រា ៧៨១.-** អត្ថន័យនៃឯកសិទ្ធិ

១-ម្ចាស់បំណុលដែលមានឯកសិទ្ធិ អាចទទួលការសងពីទ្រព្យដែលជាកម្មវត្ថុនៃឯកសិទ្ធិ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន ។

២-ឯកសិទ្ធិដែលម្ចាស់បំណុលមានលើទ្រព្យទាំងអស់របស់កូនបំណុល ត្រូវហៅថាជាឯកសិទ្ធិទូទៅ ។

៣-ឯកសិទ្ធិដែលម្ចាស់បំណុលមានលើទ្រព្យរបស់កូនបំណុលដែលកំណត់ជាក់លាក់ ត្រូវហៅថាជាឯកសិទ្ធិពិសេស ។ ក្នុងករណីនេះ ឯកសិទ្ធិដែលម្ចាស់បំណុលមានលើចលនវត្ថុ

ដែលកំណត់ជាក់លាក់ ត្រូវហៅថាជាឯកសិទ្ធិលើចលនវត្ថុ រីឯ ឯកសិទ្ធិដែលម្ចាស់បំណុលមានលើអចលនវត្ថុដែលកំណត់ជាក់លាក់ ត្រូវហៅថាជាឯកសិទ្ធិលើអចលនវត្ថុ ។

(កំណត់)

មាត្រានេះចែងអំពីអត្ថន័យ និង និយមន័យនៃឯកសិទ្ធិ ។

កថាខណ្ឌទី ១ បញ្ជាក់អំពីអត្ថន័យនៃឯកសិទ្ធិ ដោយចែងថា ម្ចាស់ឯកសិទ្ធិអាចទទួលការសងពីទ្រព្យដែលជាកម្មវត្ថុនៃឯកសិទ្ធិ ដោយមានអាទិភាពបាន ។

កថាខណ្ឌទី ២ កំណត់និយមន័យនៃឯកសិទ្ធិទូទៅ ដោយចែងថា ឯកសិទ្ធិដែលយកទ្រព្យទូទៅមកធ្វើជាកម្មវត្ថុត្រូវហៅថាជាឯកសិទ្ធិទូទៅ ។

កថាខណ្ឌទី ៣ កំណត់និយមន័យនៃឯកសិទ្ធិពិសេស ដោយចែងថា ឯកសិទ្ធិដែលយកទ្រព្យជាក់លាក់មកធ្វើជាកម្មវត្ថុត្រូវហៅថាជាឯកសិទ្ធិពិសេស ហើយក្នុងចំណោមឯកសិទ្ធិពិសេសនោះ ឯកសិទ្ធិដែលយកចលនវត្ថុមកធ្វើជាកម្មវត្ថុ ត្រូវហៅថាជាឯកសិទ្ធិលើចលនវត្ថុ រីឯឯកសិទ្ធិដែលយកអចលនវត្ថុមកធ្វើជាកម្មវត្ថុ ត្រូវហៅថាជាឯកសិទ្ធិលើអចលនវត្ថុ ។ បញ្ញត្តិនៃកថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ អាចមិនចំបាច់បញ្ចូលបានដែរ ប៉ុន្តែ ដោយសារពាក្យទាំងនោះ ត្រូវបានប្រើប្រាស់នៅក្នុងមាត្រាបន្តបន្ទាប់ (ដូចជាមាត្រា ៨០៣) មាត្រានេះកំណត់និយមន័យ នៃពាក្យទាំងនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣០៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៧៨២.- ឧបាទេសកម្មលើវត្ថុ

១-ឯកសិទ្ធិអាចអនុវត្តបានចំពោះប្រាក់ ឬ វត្ថុផ្សេងទៀតដែលកូនបំណុលត្រូវទទួល ដោយការលក់ ការជួល ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុ ។ ប៉ុន្តែ អ្នកមានឯកសិទ្ធិពុំអាចអនុវត្តឯកសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងត្រូវបានប្រគល់ ទៅឱ្យកូនបំណុល ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះតម្លៃថ្នូរនឹងសិទ្ធិប្រត្យក្សដែលបង្កើតឡើង ដោយកូនបំណុល លើវត្ថុដែលជាកម្មវត្ថុនៃឯក-សិទ្ធិ ។

(កំណត់)

វត្ថុដែលជាកម្មវត្ថុនៃឧបាទេសកម្មលើវត្ថុ អាចខុសគ្នាបន្តិចបន្តួចទៅតាមប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្ស ហេតុនេះហើយបានជាក្នុងនេះត្រូវបញ្ញត្តផ្សេងៗគ្នាទៅតាមប្រភេទនីមួយៗនោះ ។

កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃមាត្រានេះ ចែងថា អានុភាពនៃឯកសិទ្ធិ មានចំពោះតម្លៃ និង វត្ថុដែលជំនួសជាសារធាតុជាមួយនឹងវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិ ។ ក៏ប៉ុន្តែ ចំពោះឯកសិទ្ធិទូទៅវិញ វត្ថុ ឬ តម្លៃដែលជំនួសវត្ថុដែលជាកម្មវត្ថុ ក៏ស្ថិតនៅក្នុងទ្រព្យសម្បត្តិទូទៅរបស់កូនបំណុលដែរ ហេតុដូច្នេះ មិនចាំបាច់គិតអំពីឧបាទេសកម្មលើវត្ថុទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣០៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ២ ឯកសិទ្ធិទូទៅ

**មាត្រា ៧៨៣.–** អត្ថន័យនៃឯកសិទ្ធិទូទៅ

បុគ្គលដែលមានសិទ្ធិលើបំណុលដែលកើតឡើងដោយសារមូលហេតុណាមួយដូចខាងក្រោមនេះ មានឯកសិទ្ធិលើទ្រព្យទាំងអស់របស់កូនបំណុល :

ក-សោហ៊ុយចំណាយសម្រាប់ប្រយោជន៍រួម ។

ខ-សិទ្ធិលើបំណុលរបស់កម្មករនិយោជិត ។

គ-សោហ៊ុយសម្រាប់បុណ្យសព ។

ឃ-ការផ្គត់ផ្គង់នូវវត្ថុសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ។

(កំណត់)

មាត្រានេះបានរៀបរាប់នូវសិទ្ធិលើបំណុលដែលអាចត្រូវបានធានាដោយឯកសិទ្ធិទូទៅបាន ។ មានសិទ្ធិលើបំណុល ៤ ប្រភេទ គឺសោហ៊ុយចំណាយសម្រាប់ផលប្រយោជន៍រួម ប្រាក់បៀវត្សរបស់កម្មករនិយោជិត សោហ៊ុយសម្រាប់បុណ្យសព និង ការផ្គត់ផ្គង់នូវវត្ថុប្រើប្រាស់ប្រចាំថ្ងៃ ។ មូលហេតុដែលទទួលស្គាល់សិទ្ធិលើបំណុលជាឯកសិទ្ធិ គឺមានផ្សេងៗគ្នា ។ ចំពោះសោហ៊ុយចំណាយសម្រាប់ផលប្រយោជន៍រួម ឯកសិទ្ធិត្រូវបានទទួលស្គាល់ ដោយសារតែសោហ៊ុយនោះត្រូវបានចំណាយសម្រាប់ផលប្រយោជន៍របស់ម្ចាស់បំណុលទាំងអស់ ។ ចំពោះប្រាក់បៀវត្សរបស់កម្មករនិយោជិតវិញ មានគោលបំណងការពារសិទ្ធិលើបំណុលរបស់កម្មករដែលជាអ្នកទន់ខ្សោយក្នុងសង្គម ។ ចំពោះសោហ៊ុយចំណាយសម្រាប់បុណ្យសព ព្រមទាំងការផ្គត់ផ្គង់នូវវត្ថុប្រើប្រាស់ប្រចាំថ្ងៃវិញ មានគោលបំណងធានានូវជីវភាពរស់នៅរបស់កូនបំណុល តាមរយៈការផ្តល់ឯកសិទ្ធិដល់ម្ចាស់បំណុល ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣០៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧៨៤.–** ឯកសិទ្ធិចំពោះសោហ៊ុយចំណាយសម្រាប់ប្រយោជន៍រួម

១-ឯកសិទ្ធិចំពោះសោហ៊ុយចំណាយសម្រាប់ប្រយោជន៍រួម មានអត្ថិភាពចំពោះសោហ៊ុយចំណាយដើម្បីថែរក្សាទ្រព្យ ឬ ជម្រះបញ្ជី ឬ ចែកចំណែកទ្រព្យ ដែលបានចេញសម្រាប់ប្រយោជន៍រួមរបស់ម្ចាស់បំណុលនីមួយៗ ។

២-ក្នុងចំណោមសោហ៊ុយចំណាយដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះសោហ៊ុយចំណាយដែលមានប្រយោជន៍ដល់ម្ចាស់បំណុលតែមួយចំនួន ឯកសិទ្ធិចំពោះសោហ៊ុយចំណាយនោះ មានអត្ថិភាពចំពោះតែម្ចាស់បំណុលដែលបានទទួលប្រយោជន៍ពីសោហ៊ុយចំណាយនោះតែប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះចែងអំពីវិសាលភាពនៃសិទ្ធិអាទិភាពនៃឯកសិទ្ធិចំពោះសោហ៊ុយចំណាយសម្រាប់ផលប្រយោជន៍រួម ។ ចំពោះសោហ៊ុយចំណាយសម្រាប់ផលប្រយោជន៍រួម មានឧទាហរណ៍ដូចតទៅ : ឧទាហរណ៍ នៅពេលដែលអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិដោយ X ជិតបានសម្រេច ចំពោះដីធ្លីរបស់កូនបំណុល A ប្រសិនបើម្ចាស់សិទ្ធិលើបំណុល B បានធ្វើនីតិវិធីឱ្យផ្អាកអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិនោះជំនួស A នោះ B អាចទាមទារឱ្យ A សងនូវសោហ៊ុយដែលខ្លួនបានចំណាយសម្រាប់សកម្មភាពនេះបាន ។ ក៏ប៉ុន្តែ សកម្មភាពរបស់ B មានប្រយោជន៍ចំពោះម្ចាស់បំណុលផ្សេងដែរនោះ ហេតុដូច្នេះសោហ៊ុយនេះអាចចាត់ទុកថាជាសោហ៊ុយចំណាយសម្រាប់ផលប្រយោជន៍រួមបាន ។ ក្នុងករណីនេះ ចំពោះសិទ្ធលើបំណុលនៃសោហ៊ុយនេះ B មានឯកសិទ្ធិ ហើយអាចទទួលនូវសំណងដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣០៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧៨៥.–** ឯកសិទ្ធិចំពោះសិទ្ធិលើបំណុលរបស់កម្មករនិយោជិត

ឯកសិទ្ធិចំពោះសិទ្ធិលើបំណុលរបស់កម្មករនិយោជិត មានអត្ថិភាពចំពោះសិទ្ធិលើបំណុលទាំងអស់ ដែលកម្មករនិយោជិតត្រូវទទួលពីនិយោជក ដោយផ្អែកលើកិច្ចសន្យាការងារ ។

(កំណត់)

មាត្រានេះចែងអំពីវិសាលភាពនៃសិទ្ធិអាទិភាពនៃឯកសិទ្ធិចពោះសិទ្ធិលើបំណុលរបស់កម្មករនិយោជិត ។ មានន័យថា បញ្ញត្តិនេះទទួលស្គាល់នូវឯកសិទ្ធិទូទៅ ចំពោះសិទ្ធិលើបំណុលទាំងអស់ដែលកម្មករនិយោជិតដែលជាម្ចាស់បំណុល ត្រូវទទួលពីនិយោជកដែលជាកូនបំណុល ដោយផ្អែកទៅលើកិច្ចសន្យាការងារ ។ ម្យ៉ាងទៀត ចំពោះឯកសិទ្ធិនេះ ពុំមានការកម្រិតនូវអំឡុងពេល ដូចក្នុងករណីនៃឯកសិទ្ធិចំពោះការផ្គត់ផ្គង់នូវវត្ថុប្រើប្រាស់ប្រចាំថ្ងៃទេ (មាត្រា ៧៨៧) ។

ឧទាហរណ៍ ក្នុងករណីដែលនិយោជកមិនបង់ប្រាក់បៀវត្សឱ្យកម្មករនិយោជិតទេ កម្មករនិយោជិតនោះមានឯកសិទ្ធិទទួលនូវសំណងដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតរបស់និយោជកនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣០៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧៨៦.–** ឯកសិទ្ធិចំពោះសោហ៊ុយសម្រាប់បុណ្យសព

១-ឯកសិទ្ធិចំពោះសោហ៊ុយសម្រាប់បុណ្យសព មានអត្ថិភាពចំពោះសោហ៊ុយសម្រាប់បុណ្យសពដែលបានធ្វើឡើង ទៅតាមឋានៈរបស់កូនបំណុលដែលបានទទួលមរណភាព ។

២-ក្នុងករណីដែលញាតិរបស់កូនបំណុលដែលមានអាហារកិច្ចបានទទួលមរណភាព ឯកសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក៏មានអត្ថិភាពចំពោះសោហ៊ុយសម្រាប់បុណ្យសពដែលកូនបំណុលបានធ្វើឡើង ទៅតាមឋានៈរបស់ញាតិនោះដែរ ។

(កំណត់)

មាត្រានេះបង្ហាញអំពីវិសាលភាពនៃសិទ្ធិលើបំណុល ដែលត្រូវបានទទួលស្គាល់នូវឯកសិទ្ធិចំពោះសោហ៊ុយបុណ្យសព ។ ក្រៅពីសោហ៊ុយសម្រាប់បុណ្យសព ដោយមរណភាពរបស់សាមីខ្លួនកូនបំណុល (កថាខណ្ឌទី ១) សោហ៊ុយសម្រាប់បុណ្យសព ដោយមរណភាពរបស់ញាតិដែលកូនបំណុលនោះបានផ្តល់អាហារកិច្ច (ឧទាហរណ៍ ឪពុកម្តាយ សហព័ទ្ធ កូនជាអាទិ៍) ក៏ជាកម្មវត្ថុនៃឯកសិទ្ធិនេះដែរ (កថាខណ្ឌទី ២) ។

ឯកសិទ្ធិចំពោះសោហ៊ុយសម្រាប់បុណ្យសព មានន័យថា អ្នកដែលបានក្លាយទៅជាម្ចាស់បំណុលដោយបុណ្យសព មានឯកសិទ្ធិ ។

កថាខណ្ឌទី ១ បញ្ញត្តអំពីករណីដែលសាមីខ្លួនជាមតកជនបានទទួលមរណភាព ហើយជាអ្នកទទួលបន្ទុកនូវសោហ៊ុយសម្រាប់បុណ្យសព ។ ឧទាហរណ៍ ក្នុងករណីដែល A បានទទួលមរណភាព ហើយ B ដែលជាញាតិរបស់មរណជននោះបានធ្វើបុណ្យសព ហើយបានចេញសោហ៊ុយធ្វើបុណ្យនោះ ប្រសិនបើ A ត្រូវទទួលបន្ទុកសោហ៊ុយនោះ B អាចទាមទារឱ្យ A សងនូវសោហ៊ុយនោះមកវិញបាន ហើយដោយសារសិទ្ធិលើបំណុលនេះមានឯកសិទ្ធិ B មានអាទិភាពក្នុងការទទួលសំណងពី A ជាងម្ចាស់បំណុលផ្សេងទៀតរបស់ A ។ តាមភាពជាក់ស្តែង សោហ៊ុយនោះត្រូវបង់ដោយប្រើមតិក ដូច្នេះនេះជាបញ្ហាទូទៅនៃសន្តតិកម្មនៃកាតព្វកិច្ចរបស់មតកជន ហេតុដូច្នេះ ត្រូវចាត់ចែងតាមបញ្ញត្តិស្តីពីសន្តតិកម្ម ។

កថាខណ្ឌទី ២ ជាបញ្ញត្តិស្តីពីករណីដែលញាតិរបស់មរណជនជាអ្នកធ្វើបុណ្យសព ហើយទទួលបន្ទុកនូវសោហ៊ុយនោះ ។ ឧទាហរណ៍ ក្នុងករណីដែល A បានទទួលមរណភាព ហើយ B ដែលជាញាតិរបស់មរណជនបានធ្វើបុណ្យសព ប្រសិនបើសោហ៊ុយសម្រាប់បុណ្យសពនោះ ជាបន្ទុករបស់ B ហើយ C (ឧទាហរណ៍ សហគ្រាសចាត់ចែងធ្វើបុណ្យសព) មាន

សិទ្ធិលើបំណុលដែលទាក់ទងនឹងបុណ្យសពនោះចំពោះ B នោះ C មានឯកសិទ្ធិចំពោះសិទ្ធិលើបំណុលនោះ ដូច្នេះ C មានអាទិភាពក្នុងការទទួលសំណងពី B ជាងម្ចាស់សិទ្ធិលើបំណុលផ្សេងទៀតរបស់ B ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣០៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧៨៧.-** ឯកសិទ្ធិចំពោះការផ្តល់នូវវត្ថុសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ

ឯកសិទ្ធិចំពោះការផ្តល់នូវវត្ថុប្រើប្រាស់ប្រចាំថ្ងៃ មានអត្ថិភាពចំពោះការផ្តល់ចំណីអាហារ និង វត្ថុប្រើប្រាស់ផ្សេងៗរៀងរាល់ថ្ងៃ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែចុងក្រោយ ដែលចាំបាច់សម្រាប់ជីវភាពរបស់កូនបំណុល ឬ ញាតិដែលរស់នៅជាមួយកូនបំណុល ហើយដែលកូនបំណុលនោះមានអាហារកិច្ច និង អ្នកបម្រើ ។

(កំណត់)

មាត្រានេះបង្ហាញអំពីវិសាលភាពនៃសិទ្ធិលើបំណុល ដែលត្រូវបានទទួលស្គាល់នូវឯកសិទ្ធិចំពោះការផ្តល់នូវវត្ថុប្រើប្រាស់ប្រចាំថ្ងៃ ។ មិនត្រឹមតែជីវភាពរបស់កូនបំណុលសាមីខ្លួនទេ គឺថែមទាំងជីវភាពរបស់ញាតិដែលរស់នៅជាមួយព្រមទាំងអ្នកបម្រើ ក៏ជាកម្មវត្ថុនៃឯកសិទ្ធិនេះដែរ ។ ឧទាហរណ៍ B ដែលបានទទួលលទ្ធកម្មនូវសិទ្ធិលើបំណុលចំពោះការផ្តល់ចំណីអាហារឱ្យទៅ A មានឯកសិទ្ធិចំពោះសិទ្ធិលើបំណុលដែលបានកើតឡើង ៦ ខែចុងក្រោយ ក្នុងចំណោមសិទ្ធិលើបំណុលទាំងអស់នោះ ហើយ B មានអាទិភាពក្នុងការទទួលសំណងពី A ជាងម្ចាស់បំណុលផ្សេងទៀតរបស់ A ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣១០ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៣ ឯកសិទ្ធិលើចលនវត្ថុ

**មាត្រា ៧៨៨.-** អត្ថន័យនៃឯកសិទ្ធិលើចលនវត្ថុ

បុគ្គលដែលមានសិទ្ធិលើបំណុលដែលកើតឡើងដោយមូលហេតុណាមួយដូចខាងក្រោមនេះ មានឯកសិទ្ធិលើចលនវត្ថុជាក់លាក់ដែលបានកំណត់ជាក់លាក់របស់កូនបំណុល :

ក-ការជួលអចលនវត្ថុ ។

ខ-ការដឹកជញ្ជូនអ្នកដំណើរ ឬ ទំនិញ ។

គ-ការរក្សាទុកចលនវត្ថុ ។

ឃ-ការលក់ចលនវត្ថុ ។

ង-ការផ្តល់គ្រាប់ពូជ កូនរុក្ខជាតិ ឬ ជី និង ពូជ កូនសត្វ ឬ ចំណីសត្វ ។

( កំណត់)

មាត្រានេះមានពិព័ណ៌នាអំពីសិទ្ធិលើបំណុលដែលត្រូវបានទទួលស្គាល់នូវឯកសិទ្ធិលើចលនវត្ថុ ។ បញ្ញត្តិស្តីពីភតិសន្យាក៏មានអានុភាពចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ដែរ ហេតុដូច្នេះ ការជួលអចលនវត្ថុដែលបានកំណត់នៅក្នុងចំណុច ក នៃមាត្រានេះ រាប់បញ្ចូលសិទ្ធិជួលអចិន្ត្រៃយ៍ដែរ ។

មាត្រានេះត្រូវបានបញ្ញត្តតាមមាត្រា ៣១១ នៃក្រមរដ្ឋប្បវេណីជប៉ុន ប៉ុន្តែ ខ្លឹមសារនៃចំណុចទី ៤ នៃមាត្រា ៣១១ នោះ ស្តីពី "កំហុសក្នុងការបំពេញការងាររបស់មន្ត្រីរាជការ" មិនបានបញ្ចូលក្នុងក្រមកម្ពុជានេះទេ ។ ចំពោះសំណងការខូចខាតដែលបង្កើតដោយមន្ត្រីរាជការ គួរតែបញ្ញត្តពិសេសផ្សេងពីនេះ (ច្បាប់ដូចជា "ច្បាប់ស្តីពីសំណងនៃការខូចខាតដោយរដ្ឋ" របស់ជប៉ុន) ។ លើសពីនេះ "ការស្នាក់នៅផ្ទះសំណាក់" (ចំណុចទី ២ មាត្រា ៣១១ និង មាត្រា ៣១៧ នៃក្រមរដ្ឋប្បវេណីជប៉ុន ) និង "ពលកម្មនៃវិស័យកសិកម្ម ឬ ឧស្សាហកម្ម" (ចំណុចទី ៨ មាត្រា ៣១១ និង មាត្រា ៣២៤ នៃក្រមរដ្ឋប្បវេណីជប៉ុន) ក៏មិនបានយកមកបញ្ចូលក្នុងមាត្រានេះដែរ ។ ផ្ទុយទៅវិញ ក្រៅពីសិទ្ធិលើបំណុលទាំងនេះនៅប្រទេសកម្ពុជា គេទិញពងត្រី ស៊ុតមាន់ ស៊ុតទា ជាដើម (ស៊ុតមានកូន) មកភ្ញាស់ដើម្បីចិញ្ចឹម ហេតុដូច្នេះមាត្រានេះទទួលស្គាល់ឯកសិទ្ធិចំពោះការផ្តល់ស៊ុត ជាអាទិ៍ ដូចករណីនៃដង្កូវនាងនៅប្រទេសជប៉ុន ។ នៅក្នុងចំណុច ង ក្រៅពីការផ្តល់គ្រាប់ពូជ កូនរុក្ខជាតិ ឬ ជីដែលច្បាប់ជប៉ុនក៏ទទួលស្គាល់នូវឯកសិទ្ធិ ឯកសិទ្ធិត្រូវបានទទួលស្គាល់ផងដែរចំពោះសិទ្ធិលើបំណុលដែលបានកើតឡើងដោយការផ្តល់ពូជ កូនសត្វ ឬ ចំណីសត្វ ។

ទោះបីជាយ៉ាងណាក៏ដោយ ថ្ងៃក្រោយច្បាស់ជាមានសិទ្ធិលើបំណុលជាច្រើនទៀត ដែលគួរតែគិតថា ត្រូវមានឯកសិទ្ធិលើសិទ្ធិទាំងនោះដែរ ។ ពាក់ព័ន្ធនឹងបញ្ហានេះ មិនគួររៀបរាប់ទាំងអស់នៅក្នុងក្រមរដ្ឋប្បវេណីទេ ដោយគួរតែបង្កើតច្បាប់ពិសេស ។ ក្នុងករណីនេះ ចាំបាច់ត្រូវមានបញ្ញត្តិស្តីពីអាទិភាពរវាងឯកសិទ្ធិដែលបានចែងក្នុងក្រមរដ្ឋប្បវេណី និងឯកសិទ្ធិដែលចែងក្នុងច្បាប់ពិសេសនោះ ។ ឧទាហរណ៍ ត្រូវបញ្ញត្តថា "ឯកសិទ្ធិលើ ០០ ដែលបានចែងក្នុងច្បាប់នេះមានលំដាប់ស្មើគ្នានឹងឯកសិទ្ធិដែលបានចែងនៅក្នុងចំណុច ០០ មាត្រា ៧៨៥ នៃក្រមរដ្ឋប្បវេណី" ។ ឧទាហរណ៍ ចំពោះ "ការស្នាក់នៅផ្ទះសំណាក់" ឬ "ពលកម្មនៃវិស័យកសិកម្ម ឬ ឧស្សាហកម្ម" ជាអាទិ៍ ដែលមិនបានចែងក្នុងក្រមរដ្ឋប្បវេណីកម្ពុជា នាពេលអនាគត ប្រសិនបើយល់ឃើញថា គួរតែទទួលស្គាល់នូវឯកសិទ្ធិលើសិទ្ធិទាំងនេះ អាចតាក់តែងច្បាប់បន្ថែមសិទ្ធិទាំងអស់នេះបាន ។

( មាត្រា ពាក់ព័ន្ធ)

មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណីជប៉ុន

## **មាត្រា ៧៨៩.-** ឯកសិទ្ធិចំពោះការជួលអចលនវត្ថុ

ឯកសិទ្ធិចំពោះការជួលអចលនវត្ថុ មានអត្ថិភាពលើចលនវត្ថុរបស់ភតិកៈ ចំពោះថ្លៃឈ្នួលអចលនវត្ថុ និង កាតព្វកិច្ចផ្សេងទៀតរបស់ភតិកៈដែលកើតឡើងដោយទំនាក់ទំនងនៃការជួលអចលនវត្ថុនោះ ។

(កំណត់)

មាត្រានេះចែងបញ្ជាក់អំពីសិទ្ធិលើបំណុលដែលត្រូវបានទទួលស្គាល់ឯកសិទ្ធិ ក្នុងចំណោមសិទ្ធិលើបំណុលដែលកើតឡើងពីភតិសន្យាអចលនវត្ថុ ព្រមទាំងបង្ហាញនូវវិសាលភាពនៃចលនវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣១២ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧៩០.–** ទំហំនៃវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិចំពោះការជួលអចលនវត្ថុ ក្នុងករណីធម្មតា

១-ឯកសិទ្ធិរបស់ភតិបតីនៃដី មានអត្ថិភាពទៅលើចលនវត្ថុដែលបានបំពាក់លើដីជួល ឬ នៅនឹងអាគារសម្រាប់ប្រើដីជួលនោះ ចលនវត្ថុដែលបានផ្តល់ប្រយោជន៍សម្រាប់ប្រើដីនោះ និង ផលនៃដីនោះដែលស្ថិតនៅក្រោមការកាន់កាប់របស់ភតិកៈ ។

២-ឯកសិទ្ធិរបស់ភតិបតីនៃអាគារ មានអត្ថិភាពលើចលនវត្ថុដែលភតិកៈបានបំពាក់នៅនឹងអាគារនោះ ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីវិសាលភាពនៃវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិចំពោះការជួលអចលនវត្ថុ ក្នុងករណីនៃភតិសន្យាធម្មតា ។ កថាខណ្ឌទី ១ មានបញ្ញត្តថា ចលនវត្ថុដែលបំពាក់ក្នុងអាគារដែលស្ថិតលើដីជួល ក៏ជាប់ឯកសិទ្ធិដែរ ។ ម្យ៉ាងទៀត តាមការបកស្រាយ សេះ គោ ក្របី ដែលប្រើសម្រាប់ភ្ជួររាស់ដីស្រែចំការ ក៏ត្រូវរួមបញ្ចូលក្នុង "ចលនវត្ថុដែលបានផ្តល់ប្រយោជន៍សម្រាប់ប្រើដី" ដែរ ។

បញ្ញត្តិនៃមាត្រានេះ ត្រូវបានរៀបចំឡើង ដោយយកលទ្ធភាពដែលភតិកៈនៃដីអាចសាងសង់អាគារលើដីជួលបាន មកធ្វើជាបុរេល័ក្ខខ័ណ្ឌ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣១៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧៩១.–** ទំហំនៃវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិចំពោះការជួលអចលនវត្ថុ

ក្នុងករណីអនុប្បទាននូវសិទ្ធិជួល ឬ ជួលបន្ត ឯកសិទ្ធិរបស់ភតិបតី មានអានុភាពលើចលនវត្ថុរបស់អនុប្បទានិក ឬ ភតិកៈបន្ត ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរចំពោះប្រាក់ដែលអនុប្បទាយី ឬភតិបតីបន្តទទួល ។[២]

(កំណត់)

មាត្រានេះចែងថា ក្នុងករណីដែលសិទ្ធិជួលត្រូវបានធ្វើអនុប្បទាន ឬ ត្រូវបានជួលបន្ត ចលនវត្ថុដែលអនុប្បទានិក ឬ ភតិកៈបន្តមានកម្មសិទ្ធិ ត្រូវក្លាយទៅជាកម្មវត្ថុនៃឯកសិទ្ធិរបស់ភតិបតី ។ មានន័យថា វិសាលភាពនៃវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិ ត្រូវបានពង្រីក ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣១៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧៩២.–** ទំហំនៃអានុភាពនៃឯកសិទ្ធិចំពោះការជួលអចលនវត្ថុ

ក្នុងករណីជម្រះបញ្ជីទ្រព្យសរុបទាំងអស់របស់ភតិកៈ ឯកសិទ្ធិរបស់ភតិបតីមានអត្ថិភាព លើថ្លៃជួល និង កាតព្វកិច្ចផ្សេងទៀតក្នុងគ្រាមុន គ្រាបច្ចុប្បន្ន និង គ្រាបន្ទាប់ និង សំណងនៃការខូចខាតដែលបានកើតមានឡើងក្នុងគ្រាមុន និង គ្រាបច្ចុប្បន្ន ។

(កំណត់)

មាត្រានេះចែងបញ្ជាក់អំពីវិសាលភាពនៃសិទ្ធិលើបំណុលដែលត្រូវបានការពារដោយឯកសិទ្ធិ ក្នុងករណីដែលភតិកៈក្ស័យធន ជាអាទិ៍ ។ មានន័យថា ត្រូវកម្រិតឯកសិទ្ធិខ្លះ ដើម្បីឱ្យមានសមភាពជាមួយនឹងម្ចាស់បំណុលផ្សេងទៀត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣១៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧៩៣.–** ឯកសិទ្ធិក្នុងការជួលអចលនវត្ថុ ក្នុងករណីដែលមានប្រាក់កក់ដើម្បីធានា

ក្នុងករណីដែលភតិបតីបានទទួលប្រាក់កក់ដើម្បីធានា ភតិបតីនោះមានឯកសិទ្ធិត្រឹមតែចំពោះផ្នែកនៃសិទ្ធិលើបំណុល
ដែលមិនអាចទទួលការសងដោយប្រាក់កក់ដើម្បី ធានានោះតែប៉ុណ្ណោះ ។

(កំណត់)

---

[២] មាត្រា ៧៩១ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

ក្នុងករណីដែលភតិបតីបានទទួលប្រាក់កក់ដើម្បីធានាពីភតិក: ជាបឋម ត្រូវកាត់កាតព្វកិច្ចនៃថ្លៃឈ្នួល ជាអាទិ៍ ដោយយកប្រាក់កក់នោះជាមុនសិន ហើយចំពោះភាគដែលនៅខ្វះ ត្រូវទទួលស្គាល់នូវឯកសិទ្ធិ ។ បញ្ញត្តិនេះត្រូវបានរៀបចំឡើងដោយយកការដែលមានទម្លាប់បង់ប្រាក់កក់ដើម្បីធានាមកធ្វើជាបុរេល័ក្ខខ័ណ្ឌ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣១៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧៩៤.–** ឯកសិទ្ធិចំពោះការដឹកជញ្ជូន

ឯកសិទ្ធិចំពោះការដឹកជញ្ជូន មានអត្ថិភាពលើវត្ថុដែលអ្នកដឹកជញ្ជូនកាន់កាប់ ចំពោះថ្លៃដឹកជញ្ជូនអ្នកដំណើរ ឬ វត្ថុ និង ថ្លៃសោហ៊ុយផ្សេងៗដែលទាក់ទងនឹងការដឹកជញ្ជូន ។

(កំណត់)

មាត្រានេះចែងបញ្ជាក់អំពីវិសាលភាពនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយឯកសិទ្ធិ និង អំពីវិសាលភាពនៃចលនវត្ថុដែលត្រូវក្លាយជាកម្មវត្ថុនៃឯកសិទ្ធិ ចំពោះការដឹកជញ្ជូន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣១៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧៩៥.–** លទ្ធកម្មដោយសុចរិត

បញ្ញត្តិនៃមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ ស្តីពីលទ្ធកម្មដោយសុចរិត ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះឯកសិទ្ធិដែលបានកំណត់ពីមាត្រា ៧៨៩ (ឯកសិទ្ធិចំពោះការជួលអចលនវត្ថុ) ដល់មាត្រា ៧៩៤ (ឯកសិទ្ធិចំពោះការដឹកជញ្ជូន) នៃក្រមនេះ ។

(កំណត់)

បញ្ញត្តិនេះចែងថា ចំពោះចលនវត្ថុដែលជាកម្មសិទ្ធិរបស់តតិយជនក្រៅពីកូនបំណុល ក្នុងករណីដែលម្ចាស់បំណុលពុំមានកំហុសក្នុងការជឿថា កូនបំណុលមានកម្មសិទ្ធិលើចលនវត្ថុនោះ ឯកសិទ្ធិនឹងកើតឡើងលើចលនវត្ថុនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣១៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧៩៦.–** ឯកសិទ្ធិចំពោះការរក្សាទុកចលនវត្ថុ

១-ឯកសិទ្ធិចំពោះការរក្សាទុកចលនវត្ថុ មានអត្ថិភាពលើចលនវត្ថុដែលត្រូវបានរក្សាទុក ចំពោះសោហ៊ុយសម្រាប់រក្សាទុកចលនវត្ថុនោះ ។

២-ឯកសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានអត្ថិភាពផងដែរ ចំពោះសោហ៊ុយចាំបាច់ដែលបានចេញដើម្បីឱ្យរក្សា ផ្តល់សច្ចានុមតិ ឬ អនុវត្តសិទ្ធិដែលទាក់ទងនឹងចលនវត្ថុនោះ ។

(កំណត់)

មាត្រានេះចែងទទួលស្គាល់នូវឯកសិទ្ធិលើចលនវត្ថុ ចំពោះសិទ្ធិលើបំណុលដែលកើតឡើងដើម្បីរក្សាទុកចលនវត្ថុ ។ តម្លៃនៃចលនវត្ថុត្រូវបានរក្សា ដោយសារសកម្មភាពរក្សាទុកចលនវត្ថុនោះ ហើយសកម្មភាពនេះមានផលប្រយោជន៍សម្រាប់ម្ចាស់បំណុលទាំងអស់ ដូច្នេះហើយត្រូវទទួលស្គាល់ឯកសិទ្ធិរបស់អ្នករក្សាទុក ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣២០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧៩៧.-** ឯកសិទ្ធិចំពោះការលក់ចលនវត្ថុ

ឯកសិទ្ធិចំពោះការលក់ចលនវត្ថុ មានអត្ថិភាពលើចលនវត្ថុនោះ ចំពោះប្រាក់ថ្លៃលក់ចលនវត្ថុនោះ និង ការប្រាក់ ។

(កំណត់)

មាត្រានេះបញ្ញត្តទទួលស្គាល់ថា ចំពោះថ្លៃលក់ចលនវត្ថុ និង ការប្រាក់ អ្នកលក់ចលនវត្ថុមានឯកសិទ្ធិលើចលនវត្ថុដែលបានលក់នោះ ។ ដោយសារចលនវត្ថុ និង ថ្លៃលក់នោះ មានទំនាក់ទំនងជាតម្លៃផ្ទួរ ហេតុនេះហើយការផ្តល់ឱ្យអ្នកលក់នូវឋានៈមួយដែលមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ជាការសមរម្យដើម្បីឱ្យមានសមភាពរវាងម្ចាស់បំណុលទាំងអស់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣២១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧៩៨.-** ឯកសិទ្ធិចំពោះការផ្តល់គ្រាប់ពូជ កូនរុក្ខជាតិ ឬ ជី និង ពូជ កូនសត្វ ឬ ចំណីសត្វ

១-ឯកសិទ្ធិចំពោះការផ្តល់គ្រាប់ពូជ កូនរុក្ខជាតិ ឬ ជី មានអត្ថិភាពលើផលដែលបានមកពីដី ក្នុង ១ (មួយ) ឆ្នាំ បន្ទាប់ពីបានប្រើគ្រាប់ពូជ កូនរុក្ខជាតិ ឬ ជីនោះ ចំពោះថ្លៃគ្រាប់ពូជ កូនរុក្ខជាតិ ឬ ជី និង ការប្រាក់ ។

២-ឯកសិទ្ធិចំពោះការផ្តល់ពូជ កូនសត្វ ឬ ចំណីសត្វ មានអត្ថិភាពលើសត្វ និង ផលដែលបានមកពីសត្វនោះ ក្នុង ១ (មួយ) ឆ្នាំ បន្ទាប់ពីបានប្រើសត្វ និង ចំណីដើម្បីចិញ្ចឹមសត្វនោះ ចំពោះថ្លៃពូជ កូនសត្វ និង ចំណីនោះ និង ការប្រាក់ ។

៣-ឯកសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ក៏មានអត្ថិភាពលើផលដែលបានមកពីពូជដង្កូវនាង ឬ ស្លឹកមន ចំពោះថ្លៃពូជដង្កូវនាង ឬ ស្លឹកមនដើម្បីចិញ្ចឹមដង្កូវនាងនោះផងដែរ ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះចែងថា ចំពោះថ្លៃទិញគ្រាប់ពូជ កូនរុក្ខជាតិ ឬ ជី ដែលអ្នកប្រើដីកសិកម្មត្រូវបង់ ឯកសិទ្ធិមានអត្ថិភាពលើកសិផលដែលបានដាំដុះលើដីនោះ ។

ដោយយោងតាមទំនៀមទម្លាប់នៃប្រទេសកម្ពុជា កថាខណ្ឌទី ២ ចែងទូលំទូលាយ ដើម្បីអនុវត្តមិនត្រឹមតែចំពោះករណីចិញ្ចឹមបសុសត្វទេ គឺរាប់បញ្ចូលផងដែរនូវករណីចិញ្ចឹមត្រី និង ទា ។ មានន័យថា ក្នុងករណីដែលចិញ្ចឹមសត្វ (ដោយរាប់បញ្ចូលបសុសត្វ) ឯកសិទ្ធិចំពោះការផ្តល់ពូជ កូនសត្វ ឬ ចំណីសត្វ មានអត្ថិភាពលើសត្វ និង ផលដែលបានមកពីសត្វនោះ ក្នុង ១ ឆ្នាំ (ពង ឬ កូនសត្វ ជាអាទិ៍) ចំពោះថ្លៃពូជ កូនសត្វ និង ចំណីនោះ ព្រមទាំងការប្រាក់ ។

កថាខណ្ឌទី ៣ ត្រូវបានរៀបចំឡើងដោយយោងតាមក្រមរដ្ឋប្បវេណីជប៉ុន ហើយចែងថា ឯកសិទ្ធិមានអត្ថិភាពលើផលដែលបានមកពីពូជដង្កូវនាង ឬ ស្លឹកមន ចំពោះថ្លៃពូជដង្កូវនាង ឬ ស្លឹកមនដើម្បីចិញ្ចឹមដង្កូវនាងនោះ ព្រមទាំងការប្រាក់ ។

នៅប្រទេសកម្ពុជា មានទម្លាប់លក់ទិញដង្កូវនាង ហើយក្នុងករណីនេះ អាចបកស្រាយបានថា អាចអនុវត្តកថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ បាន ។ នាពេលអនាគត ប្រសិនបើមានបញ្ហាកើតមានឡើង អាចធ្វើវិសោធនកម្មនូវកថាខណ្ឌទី ៣ ដោយចែងថា "ពូជដង្កូវនាង ដង្កូវនាង ឬ ស្លឹកមនដើម្បីចិញ្ចឹមដង្កូវនាង" ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣២២ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៤ ឯកសិទ្ធិលើអចលនវត្ថុ

**មាត្រា ៧៩៩.-** ឯកសិទ្ធិលើអចលនវត្ថុ

បុគ្គលដែលមានសិទ្ធិលើបំណុល ដែលកើតឡើងដោយសារមូលហេតុណាមួយដូចខាងក្រោមនេះ មានឯកសិទ្ធិលើអចលនវត្ថុដែលបានកំណត់ជាក់លាក់របស់កូនបំណុល :

ក-ការរក្សាទុកនូវអចលនវត្ថុ ។

ខ-ការងារលើអចលនវត្ថុ ។

គ-ការលក់អចលនវត្ថុ ។

(កំណត់)

មាត្រានេះរៀបរាប់អំពីសិទ្ធិលើបំណុលពាក់ព័ន្ធនឹងអចលនវត្ថុដែលត្រូវបានការពារដោយឯកសិទ្ធិ ។ ចំពោះការរក្សាទុកនូវអចលនវត្ថុ និង ការងារលើអចលនវត្ថុ ឯកសិទ្ធិត្រូវបានទទួលស្គាល់ ដោយសារតម្លៃនៃអចលវត្ថុនោះត្រូវបានរក្សា ឬ ត្រូវបានបន្ថែម ដោយសារសកម្មភាពរក្សាទុក ឬ ការងារនោះ ។ ចំពោះការលក់ទិញអចលនវត្ថុវិញ មានគំនិតដូចគ្នានឹងករណីលក់ទិញចលនវត្ថុដែរ (សូមមើលកំណត់នៃមាត្រា ៧៩៧ (ឯកសិទ្ធិចំពោះការលក់ចលនវត្ថុ)) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣២៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨០០.-** ឯកសិទ្ធិចំពោះការរក្សាទុកនូវអចលនវត្ថុ

១-ឯកសិទ្ធិចំពោះការរក្សាទុកនូវអចលនវត្ថុ មានអត្ថិភាពលើអចលនវត្ថុ ចំពោះសោហ៊ុយរក្សាទុកអចលនវត្ថុនោះ ។

២-ឯកសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក៏មានអត្ថិភាពផងដែរ ចំពោះសោហ៊ុយចាំបាច់ដែលបានចេញដើម្បីឱ្យរក្សា ផ្តល់សច្ចានុមតិ ឬ អនុវត្តសិទ្ធិដែលទាក់ទងនឹងអចលនវត្ថុនោះ ។

(កំណត់)

មាត្រានេះបានបញ្ជាក់ច្បាស់លាស់អំពីវិសាលភាពនៃសិទ្ធិលើបំណុល ដែលត្រូវបានការពារដោយឯកសិទ្ធិ ចំពោះការរក្សាទុកនូវអចលនវត្ថុ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣២៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨០១.-** ឯកសិទ្ធិចំពោះការងារលើអចលនវត្ថុ

១-ឯកសិទ្ធិចំពោះការងារលើអចលនវត្ថុ មានអត្ថិភាពលើអចលនវត្ថុរបស់កូនបំណុល ចំពោះសោហ៊ុយចំណាយសម្រាប់ការងារ ដែលបានធ្វើលើអចលនវត្ថុនោះដោយសិប្បករ អ្នកបច្ចេកទេស និង អ្នកម៉ៅការ ។

២-ឯកសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានអត្ថិភាព ចំពោះតែចំនួនប្រាក់កំណើនតម្លៃ ក្នុងករណីដែលកំណើនតម្លៃអចលនវត្ថុដោយការងារនោះ នៅតែមានប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះមានគោលបំណងបញ្ជាក់ឱ្យច្បាស់អំពីវិសាលភាពនៃសិទ្ធិលើបំណុល ដែលត្រូវបានការពារដោយឯកសិទ្ធិចំពោះការងារលើអចលនវត្ថុ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣២៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨០២.-** ឯកសិទ្ធិចំពោះការលក់អចលនវត្ថុ

ឯកសិទ្ធិចំពោះការលក់អចលនវត្ថុមានអត្ថិភាពលើអចលនវត្ថុ ចំពោះប្រាក់ថ្លៃលក់អចលនវត្ថុនោះ និង ការប្រាក់ ។

(កំណត់)

មាត្រានេះបានបញ្ជាក់ច្បាស់លាស់នូវវិសាលភាពនៃសិទ្ធិលើបំណុលដែលត្រូវបានការពារដោយឯកសិទ្ធិ ចំពោះការលក់អចលនវត្ថុ ។ សូមមើលកំណត់នៃមាត្រា ៧៩៧ (ឯកសិទ្ធិចំពោះការលក់ចលនវត្ថុ) ដែលពាក់ព័ន្ធនឹងការលក់ចលនវត្ថុ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣២៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៥ លំដាប់នៃឯកសិទ្ធិ

**មាត្រា ៨០៣.-** លំដាប់នៃឯកសិទ្ធិទូទៅ

១-ក្នុងករណីដែលឯកសិទ្ធិទូទៅប្រជែងគ្នា លំដាប់នៃឯកសិទ្ធិទាំងនោះត្រូវអនុលោមតាមលំដាប់ដែលបានកំណត់នៅក្នុងមាត្រា ៧៨៣ (អត្ថន័យនៃឯកសិទ្ធិទូទៅ) នៃក្រមនេះ ។

២-ប្រសិនបើឯកសិទ្ធិទូទៅប្រជែងគ្នានឹងឯកសិទ្ធិពិសេស ឯកសិទ្ធិពិសេសត្រូវមានអាទិភាពជាងឯកសិទ្ធិទូទៅ ។ ប៉ុន្តែ ឯកសិទ្ធិចំពោះសោហ៊ុយចំណាយសម្រាប់ប្រយោជន៍រួមវិញ មានអាទិភាពចំពោះម្ចាស់បំណុលទាំងឡាយដែលបានទទួលប្រយោជន៍នោះ ។

(កំណត់)

មាត្រានេះចែងអំពីលំដាប់អាទិភាពនៃឯកសិទ្ធិ ក្នុងករណីដែលមានឯកសិទ្ធិទូទៅច្រើនចំពោះកូនបំណុលម្នាក់ ។

កថាខណ្ឌទី ១ ចែងថា ក្នុងករណីដែលឯកសិទ្ធិទូទៅមានច្រើន នោះលំដាប់អាទិភាពនីមួយៗត្រូវអនុលោមតាមលំដាប់ដែលបានកំណត់នៅក្នុងមាត្រា ៧៨៣ ។ ឧទាហរណ៍ ក្នុងករណីដែលភាគី B មានសិទ្ធិលើបំណុលចំពោះសោហ៊ុយសម្រាប់ផលប្រយោជន៍រួម ភាគី C មានសិទ្ធិលើបំណុលចំពោះសោហ៊ុយសម្រាប់បុណ្យសព និង ភាគី D មានសិទ្ធិលើបំណុលចំពោះការផ្គត់ផ្គង់នូវវត្ថុសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ ចំពោះកូនបំណុល A ប្រសិនបើសិទ្ធិលើបំណុលទាំងនោះត្រូវបានសងដោយទ្រព្យសម្បត្តិទូទៅរបស់កូនបំណុល A (ដោយការដាក់លក់ទ្រព្យសម្បត្តិទូទៅទាំងនោះ ហើយចែកចំណែកនៃប្រាក់មកពីការលក់នោះដល់ម្ចាស់បំណុលទាំងអស់) ការសងត្រូវបានធ្វើឡើងតាមលំដាប់ : B C និង D (ហើយម្ចាស់បំណុលទាំង ៣ នាក់ មានអាទិភាពខ្ពស់ជាងម្ចាស់បំណុលទូទៅ) ។ បានសេចក្ដីថា ភាគី B ត្រូវទទួលបាននូវការសងមុនគេ បន្ទាប់មកភាគី C និង ក្រោយគេគឺភាគី D (ប្រសិនបើនៅមានសល់នោះ ត្រូវសងដោយស្មើភាគឱ្យទៅម្ចាស់បំណុលទូទៅដទៃទៀត) ។ ប្រសិនបើតម្លៃសរុបនៃទ្រព្យសម្បត្តិទូទៅទាំងអស់ មិនគ្រប់គ្រាន់ក្នុងការសងចំពោះសិទ្ធិលើបំណុលទាំងអស់ទេ (រាប់ទាំងសិទ្ធិលើបំណុលទូទៅ) នោះការសងត្រូវបានធ្វើទៅតាមលំដាប់អាទិភាពនេះ ហើយម្ចាស់បំណុលដែលមានអាទិភាពទាបមិនអាចទទួលបាននូវការសងទាំងមូល ឬ មួយភាគឡើយ ។ ឧទាហរណ៍ សិទ្ធិលើបំណុលរបស់ B មានចំនួនទឹកប្រាក់ ៣០,០០០ រៀល សិទ្ធិលើបំណុលរបស់ C មានចំនួន ២០,០០០ រៀល ហើយសិទ្ធិលើបំណុលរបស់ D មានចំនួន ១០,០០០ រៀល ចំណែកឯទ្រព្យសម្បត្តិទូទៅរបស់កូនបំណុល A មានតម្លៃត្រឹមតែ ៤០,០០០ រៀល ។ ក្នុងករណីនេះ ត្រូវធ្វើការសងឱ្យទៅភាគី B នូវចំនួនទឹកប្រាក់ ៣០,០០០ រៀល និង ភាគី C ចំនួន ទឹកប្រាក់ ១០,០០០ ចំណែកបំណុលនៅសល់ដែលត្រូវសងឱ្យទៅភាគី C ចំនួន ១០,០០០ រៀល និងទឹកប្រាក់សរុបនៃសិទ្ធិលើបំណុលរបស់ភាគី D ចំនួន ១០,០០០ រៀល មិនអាចធ្វើការសងបានឡើយ ។

វាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ២ ចែងថា ប្រសិនបើមានឯកសិទ្ធិទូទៅប្រជែងគ្នានឹងឯកសិទ្ធិពិសេស ឯកសិទ្ធិពិសេសនឹងមានអាទិភាពជាងឯកសិទ្ធិទូទៅ ។ ឧទាហរណ៍ ក្នុងករណីដែលភាគី B មានសិទ្ធិលើបំណុលចំពោះការផ្គត់ផ្គង់នូវវត្ថុសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ ភាគី C មានសិទ្ធិលើបំណុលចំពោះសោហ៊ុយសម្រាប់ការងារលើអចលនវត្ថុ ហើយភាគី D មានសិទ្ធិលើបំណុលចំពោះប្រាក់កម្ចី ចំពោះភាគី A ប្រសិនបើត្រូវធ្វើការសងដោយយកអចលនវត្ថុរបស់កូនបំណុល A (ដែលជាកម្មវត្ថុនៃឯកសិទ្ធិចំពោះការងារលើអចលនវត្ថុរបស់ C) (ដោយការដាក់លក់អចលនវត្ថុនោះ ហើយចែកចំណែកនៃប្រាក់មកពីការលក់នោះដល់ម្ចាស់បំណុលទាំងអស់) នោះត្រូវធ្វើការសងឱ្យទៅភាគី C B និង D តាមលំដាប់នេះ ។

វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ កំណត់អំពីករណីលើកលែងសម្រាប់ឯកសិទ្ធិទូទៅចំពោះសោហ៊ុយចំណាយសម្រាប់ប្រយោជន៍រួម ដោយចែងថា ឯកសិទ្ធិទូទៅចំពោះសោហ៊ុយចំណាយសម្រាប់ប្រយោជន៍រួម មានអាទិភាពលើម្ចាស់បំណុលដែលមានឯកសិទ្ធិពិសេស ។ ម្ចាស់បំណុលដែលមានឯកសិទ្ធិពិសេសក៏ទទួលនូវផលប្រយោជន៍ ពីសកម្មភាពរបស់ម្ចាស់បំណុលដែលបានចេញសោហ៊ុយចំណាយសម្រាប់ប្រយោជន៍រួមដែរ ហេតុដូច្នេះ ការផ្ដល់អាទិភាពឱ្យទៅម្ចាស់បំណុលដែលបានចេញសោហ៊ុយចំណាយសម្រាប់ប្រយោជន៍រួមនោះ សមស្របនឹងសមភាពរវាងភាគីទាំងអស់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣២៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨០៤.-** លំដាប់នៃឯកសិទ្ធិលើចលនវត្ថុ

១-ក្នុងករណីដែលមានឯកសិទ្ធិពិសេសប្រជែងគ្នាចំពោះចលនវត្ថុតែមួយ លំដាប់នៃឯកសិទ្ធិទាំងនោះត្រូវអនុលោមតាមលំដាប់ដូចខាងក្រោមនេះ :

ទី ១: ឯកសិទ្ធិចំពោះការជួលអចលនវត្ថុ និង ចំពោះការដឹកជញ្ជូន ។

ទី ២: ឯកសិទ្ធិចំពោះការរក្សាទុកនូវចលនវត្ថុ ប៉ុន្តែ ប្រសិនបើមានអ្នករក្សាច្រើននាក់ អ្នកដែលរក្សាក្រោយ មានអាទិភាពជាងអ្នករក្សាមុន ។

ទី ៣: ឯកសិទ្ធិចំពោះការលក់ចលនវត្ថុ ឯកសិទ្ធិចំពោះការផ្ដល់គ្រាប់ពូជ កូនរុក្ខជាតិ ឬ ជី និង ពូជ កូនសត្វ ឬ ចំណីសត្វ ។

២-ប្រសិនបើម្ចាស់ឯកសិទ្ធិដែលមានអាទិភាពក្នុងលំដាប់ទី ១ បានដឹងថា មានម្ចាស់ឯកសិទ្ធិដែលមានអាទិភាពក្នុងលំដាប់ទី ២ ឬ លំដាប់ទី ៣ នៅពេលដែលខ្លួនបានទទួលសិទ្ធិលើបំណុល ម្ចាស់ឯកសិទ្ធិដែលមានអាទិភាពក្នុងលំដាប់ទី ១ នោះត្រូវមានលំដាប់ក្រោយម្ចាស់ឯកសិទ្ធិទាំងអស់ដែលមានអាទិភាពក្នុងលំដាប់ទី ២ ឬ ទី ៣ នោះវិញ ។ ម្ចាស់ឯកសិទ្ធិដែលមានអាទិភាពក្នុងលំដាប់ទី ១ នោះ ក៏ត្រូវមានលំដាប់ក្រោយបុគ្គល ដែលរក្សាវត្ថុដើម្បីម្ចាស់ឯកសិទ្ធិនោះដែរ ។

៣-ចំពោះផល លំដាប់ទី ១ ធ្លាក់លើអ្នកផ្ដល់គ្រាប់ពូជ កូនរុក្ខជាតិ ឬ ជី ហើយលំដាប់ទី ២ ធ្លាក់លើភតិបតីនៃដី ។

(កំណត់)

មាត្រានេះចែងអំពីអាទិភាពនៃឯកសិទ្ធិលើចលនវត្ថុដែលមានអត្ថិភាពលើចលនវត្ថុតែមួយ ។

កថាខណ្ឌទី ១ ចាត់ថ្នាក់ឯកសិទ្ធិលើចលនវត្ថុ ៥ ប្រភេទ ជា ៣ ក្រុម ដែលមានលំដាប់អាទិភាពតាមក្រុមនីមួយៗ ។

ចំពោះឯកសិទ្ធិដែលមានលំដាប់ថ្នាក់ដូចគ្នា ត្រូវធ្វើការសងស្មើគ្នា ។ គំនិតជាមូលដ្ឋានគឺដូចគ្នាទៅនឹងលំដាប់នៃឯកសិទ្ធិទូទៅដែលបានចែងនៅក្នុងមាត្រា ៨០៣ ។ សូមមើលកំណត់ (រួមជាមួយឧទាហរណ៍) នៃមាត្រា ៨០៣ ។

កថាខណ្ឌទី ២ ចែងថា ប្រសិនបើម្ចាស់ឯកសិទ្ធិក្នុងលំដាប់ទី ១ បានដឹងថា មានវត្តមានរបស់ម្ចាស់ឯកសិទ្ធិណាម្នាក់ក្នុងលំដាប់ទី ២ ឬ លំដាប់ទី ៣ នោះម្ចាស់ឯកសិទ្ធិក្នុងលំដាប់ទី ១ នោះ ត្រូវមានលំដាប់ក្រោយម្ចាស់ឯកសិទ្ធិក្នុងលំដាប់ទី ២ និង លំដាប់ទី ៣ ទាំងអស់ ។ ក្នុងករណីនេះ ក្នុងចំណោមចំនួនទឹកប្រាក់សរុបដែលត្រូវបែងចែកទៅឱ្យម្ចាស់ឯកសិទ្ធិក្នុងលំដាប់ទី ១ និង ទៅឱ្យម្ចាស់ឯកសិទ្ធិក្នុងលំដាប់ទី ២ ឬ លំដាប់ទី ៣ ម្ចាស់ឯកសិទ្ធិក្នុងលំដាប់ទី ២ ឬ លំដាប់ទី ៣ នឹងមានអាទិភាពជាងម្ចាស់ឯកសិទ្ធិក្នុងលំដាប់ទី ១ ។ ឧទាហរណ៍ ក្នុងករណីដែលភាគី A ទិញចលនវត្ថុមួយ ពីភាគី B ហើយស្នើឱ្យភាគី C ដឹកជញ្ជូនចលនវត្ថុនោះ ភាគី B មានសិទ្ធិលើបំណុលចំពោះថ្លៃលក់ចលនវត្ថុនោះ ហើយភាគី C មានសិទ្ធិលើបំណុលចំពោះសោហ៊ុយដឹកជញ្ជូន ចំពោះភាគី A ដូច្នេះ ភាគី B និង C មានឯកសិទ្ធិលើចលនវត្ថុនោះ ។ ក្នុងករណីនេះ ប្រសិនបើការសងត្រូវបានធ្វើឡើងដោយយកចលនវត្ថុនោះ ជាគោលការណ៍ សិទ្ធិលើបំណុលរបស់ភាគី C នឹងមានអាទិភាពជាងសិទ្ធិលើបំណុលរបស់ភាគី B ។ ប៉ុន្តែ ប្រសិនបើភាគី C បានដឹងអំពីវត្តមានឯកសិទ្ធិចំពោះការលក់ចលនវត្ថុរបស់ភាគី B នោះសិទ្ធិលើបំណុលរបស់ភាគី B នឹងមានអាទិភាពជាងសិទ្ធិលើបំណុលរបស់ភាគី C ។

កថាខណ្ឌទី ៣ ចែងថា ចំពោះផល លំដាប់អាទិភាពមានលក្ខណៈខុសគ្នានឹងវត្ថុដើម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៣០ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៨០៥.- លំដាប់នៃឯកសិទ្ធិលើអចលនវត្ថុ

១-ក្នុងករណីដែលមានឯកសិទ្ធិពិសេសប្រជែងគ្នាចំពោះអចលនវត្ថុតែមួយ លំដាប់នៃឯកសិទ្ធិទាំងនោះត្រូវអនុលោមតាមលំដាប់ដែលបានកំណត់នៅក្នុងមាត្រា ៧៩៩ (ឯកសិទ្ធិលើអចលនវត្ថុ) នៃក្រមនេះ ។

២-ប្រសិនបើមានការលក់ជាបន្តបន្ទាប់ ចំពោះអចលនវត្ថុតែមួយ លំដាប់នៃសិទ្ធិអាទិភាពរបស់អ្នកលក់ទាំងនោះ ត្រូវគិតទៅតាមពេលវេលាមុន និង ក្រោយនៃការលក់នោះ ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះចែងអំពីលំដាប់អាទិភាពក្នុងចំណោមឯកសិទ្ធិលើចលនវត្ថុ ។ លំដាប់អាទិភាព មិនត្រូវបានកំណត់តាមរយៈលំដាប់កាលបរិច្ឆេទនៃការចុះបញ្ជីអំពីឯកសិទ្ធិទេ ប៉ុន្តែ ត្រូវបានកំណត់តាមប្រភេទនៃឯកសិទ្ធិ ។ ហេតុដូច្នេះ ទោះបីជាឯកសិទ្ធិចំពោះការរក្សាទុកអចលនវត្ថុ បានកើតឡើងក្រោយឯកសិទ្ធិចំពោះការងារ ឬ ឯកសិទ្ធិចំពោះការលក់អចលនវត្ថុក៏ដោយ ក៏ឯកសិទ្ធិចំពោះការរក្សាទុកអចលនវត្ថុនោះ នឹងមានអាទិភាពជាងឯកសិទ្ធិចំពោះការងារលើ

អចលនវត្ថុ និង ឯកសិទ្ធិចំពោះការលក់អចលនវត្ថុដែរ ។

កថាខណ្ឌទី ២ នៃមាត្រានេះចែងអំពីលំដាប់អាទិភាពនៃឯកសិទ្ធិរបស់អ្នកលក់ទី ១ និង អ្នកលក់ទី ២ (ដែលជាអ្នកទិញទី ១) ក្នុងករណីដែលអចលនវត្ថុត្រូវបានលក់បន្ត ។ បានសេចក្តីថា ឯកសិទ្ធិរបស់អ្នកលក់ទី ១ នឹងមានអាទិភាពជាងឯកសិទ្ធិរបស់អ្នកលក់ទី ២ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៣១ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៨០៦.- ឯកសិទ្ធិដែលមានអាទិភាពស្មើគ្នា

ក្នុងករណីដែលមានម្ចាស់ឯកសិទ្ធិច្រើននាក់ដែលមានអាទិភាពស្មើគ្នាលើវត្ថុដែលជាកម្មវត្ថុតែមួយ ម្ចាស់ឯកសិទ្ធិនីមួយៗ ត្រូវទទួលនូវការសង តាមសមាមាត្រនៃសិទ្ធិលើបំណុលរៀងៗខ្លួន ។

(កំណត់)

មាត្រានេះចែងថា ក្នុងចំណោមម្ចាស់ឯកសិទ្ធិច្រើននាក់ដែលមានលំដាប់អាទិភាពស្មើគ្នា គោលការណ៍សមភាពដែលជាគោលការណ៍ទូទៅរវាងម្ចាស់បំណុល ត្រូវយកមកអនុវត្ត ។ បានសេចក្តីថា ក្នុងករណីដែលតម្លៃនៃវត្ថុដែលជាកម្មវត្ថុមិនគ្រប់គ្រាន់ដើម្បីសងតម្លៃសរុបនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយឯកសិទ្ធិទេ ម្ចាស់ឯកសិទ្ធិនីមួយៗនឹងត្រូវទទួលការសង តាមសមាមាត្រនៃសិទ្ធិលើបំណុលរបស់ខ្លួនតែប៉ុណ្ណោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៣២ នៃក្រមរដ្ឋប្បវេណីជប៉ុន

# ផ្នែកទី ៦ អានុភាពនៃឯកសិទ្ធិ

## មាត្រា ៨០៧.- អានុភាពតាមចំពោះតតិយជនដែលបានធ្វើលទ្ធកម្ម

ក្រោយពេលដែលកូនបំណុលបានប្រគល់ចលនវត្ថុរបស់ខ្លួនដែលជាកម្មវត្ថុនៃឯកសិទ្ធិ ទៅឱ្យតតិយជនដែលបានធ្វើលទ្ធកម្មហើយ នោះម្ចាស់ឯកសិទ្ធិមិនអាចអនុវត្តឯកសិទ្ធិរបស់ខ្លួនចំពោះចលនវត្ថុនោះបានឡើយ ។

(កំណត់)

មាត្រានេះចែងថា ក្នុងករណីដែលចលនវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិ ត្រូវបានធ្វើអនុប្បទានទៅឱ្យតតិយជន ប្រសិនបើចលនវត្ថុនោះត្រូវបានប្រគល់ទៅឱ្យតតិយជននោះ ឯកសិទ្ធិលែងមានអានុភាពលើចលនវត្ថុនោះហើយ ។ ក្នុងករណី

នៃឯកសិទ្ធិទូទៅ កម្មវត្ថុនៃឯកសិទ្ធិទូទៅគឺជាទ្រព្យសម្បត្តិទូទៅរបស់កូនបំណុល ហេតុដូច្នេះ វាជាធម្មតាដែរដែលឯកសិទ្ធិមិនមានអានុភាពលើទ្រព្យសម្បត្តិដែលត្រូវបានធ្វើអនុប្បទានទៅឱ្យតតិយជន ប៉ុន្តែ មាត្រានេះបញ្ជាក់ច្បាស់ថា វិធាននេះនឹងត្រូវយកមកអនុវត្ត មិនមែនតែចំពោះឯកសិទ្ធិទូទៅប៉ុណ្ណោះទេ ព្រមទាំងចំពោះឯកសិទ្ធិពិសេសលើចលវត្ថុដែរ ។ មាត្រានេះប្រើពាក្យ "ចលនវត្ថុរបស់ខ្លួន" ជំនួសពាក្យ "ចលនវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិ" ដោយសារមានគោលបំណងបង្ហាញឱ្យច្បាស់ថា មាត្រានេះនឹងយកមកអនុវត្តចំពោះឯកសិទ្ធិទូទៅ និង ឯកសិទ្ធិលើចលនវត្ថុ ។ (ការប្រើពាក្យ "ចលនវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិ" អាចនាំឱ្យមានការភាន់ច្រឡំថា មាត្រានេះត្រូវយកមកអនុវត្តតែចំពោះឯកសិទ្ធិលើចលនវត្ថុប៉ុណ្ណោះ) ។

ជាធម្មតា ឯកសិទ្ធិគ្មានអានុភាពតាមចំពោះតតិយជនទេ ដោយសារម្ចាស់ឯកសិទ្ធិ មិនកាន់កាប់ (ឃាត់ទុក) វត្ថុដែលជាកម្មវត្ថុទេ ។ មាត្រានេះបង្ហាញច្បាស់ថា ឯកសិទ្ធិលែងមានអានុភាពតាម នៅពេលដែលចលនវត្ថុនោះត្រូវបានប្រគល់ទៅដល់តតិយជន ។ម្យ៉ាងទៀត ជាទូទៅ សិទ្ធិប្រាតិភោគប្រត្យក្ស មានអានុភាពតាមចំពោះតតិយជនដែលបានធ្វើលទ្ធកម្ម ដូចបានចែងនៅក្នុងបទប្បញ្ញត្តិទូទៅ (សូមមើលមាត្រា ៧៧២ (អានុភាពតាមនៃសិទ្ធិប្រាតិភោគប្រត្យក្ស)) ។

ក្នុងករណីដែលអលនវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិទូទៅត្រូវបានធ្វើអនុប្បទានទៅឱ្យតតិយជនណាមួយ នោះឯកសិទ្ធិទូទៅនឹងលែងមានអានុភាពលើអចលនវត្ថុនោះ ដោយមូលហេតុថា អចលនវត្ថុនោះបានចេញពីទ្រព្យសម្បត្តិទូទៅរបស់កូនបំណុលហើយ ។ ម្យ៉ាងទៀត ក្នុងករណីដែលអចលនវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិពិសេសលើអចលវត្ថុត្រូវបានធ្វើអនុប្បទានទៅឱ្យតតិយជន តាមវិធានទូទៅនៃច្បាប់ស្ដីពីសិទ្ធិប្រត្យក្ស ម្ចាស់ឯកសិទ្ធិមិនអាចយកឯកសិទ្ធិនោះមកតតាំងចំពោះតតិយជនបានឡើយ លើកលែងតែម្ចាស់ឯកសិទ្ធិនោះបានចុះបញ្ជី ។ ចំពោះបញ្ហានេះ មានបញ្ញត្តិដោយឡែក (មាត្រា ៨១១ មាត្រា ៨១២ និង មាត្រា ៨១៤) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៣៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៨០៨.– ទំនាក់ទំនងនឹងសិទ្ធិលើការបញ្ចាំចលនវត្ថុ

ក្នុងករណីដែលឯកសិទ្ធិប្រជែងជាមួយនឹងសិទ្ធិលើការបញ្ចាំចលនវត្ថុ ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុមានសិទ្ធិដូចគ្នានឹងម្ចាស់ឯកសិទ្ធិដែលមានអាទិភាពក្នុងលំដាប់ទី ១ ដែលបានកំណត់នៅក្នុងមាត្រា ៨០៤ (លំដាប់នៃឯកសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ ។

(កំណត់)

មាត្រានេះចែងថា ក្នុងករណីដែលឯកសិទ្ធិប្រជែងជាមួយនឹងសិទ្ធិលើការបញ្ចាំចលនវត្ថុ ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុនេះត្រូវមានសិទ្ធិដូចគ្នានឹងម្ចាស់ឯកសិទ្ធិពិសេសលើចលនវត្ថុដែលស្ថិតនៅក្នុងលំដាប់ទី ១ ។ ដោយហេតុថា

ឯកសិទ្ធិទូទៅ មានអាទិភាពទាបជាងឯកសិទ្ធិពិសេស (សូមមើលកថាខណ្ឌទី ២ នៃមាត្រា ៨០៣ (លំដាប់នៃឯកសិទ្ធិទូទៅ)) សិទ្ធិលើការបញ្ចាំចលនវត្ថុនេះមានអាទិភាពជាងឯកសិទ្ធិទូទៅ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៣៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨០៩.–** អានុភាពនៃឯកសិទ្ធិទូទៅ

១-ម្ចាស់ឯកសិទ្ធិទូទៅ មិនអាចទទួលការសងដោយអចលនវត្ថុបានទេ លើកលែងតែខ្លួនបានទទួលការសងដោយទ្រព្យផ្សេងទៀតក្រៅពីអចលនវត្ថុនោះជាមុនសិន ហើយនៅតែមិនគ្រប់ ។

២-ចំពោះអចលនវត្ថុ ម្ចាស់ឯកសិទ្ធិទូទៅត្រូវទទួលការសងដោយអចលនវត្ថុដែលមិនមែនជាកម្មវត្ថុនៃប្រាតិភោគពិសេស ជាមុនសិន ។

៣-ប្រសិនបើម្ចាស់ឯកសិទ្ធិទូទៅធ្វេសប្រហែសមិនបានចូលរួមក្នុងការចែកចំណែកតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះទេ ម្ចាស់ឯកសិទ្ធិទូទៅនោះមិនអាចអនុវត្តឯកសិទ្ធិនេះ ចំពោះតតិយជនដែលបានចុះបញ្ជីបានឡើយ ក្នុងកម្រិតនៃចំណែករបស់ខ្លួនដែលត្រូវបានទទួល ប្រសិនបើខ្លួនបានចូលរួមក្នុងការចែកចំណែកនោះ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ និង កថាខណ្ឌទី ៣ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការចែកចំណែកនូវប្រាក់ដែលជាតម្លៃនៃអចលនវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគពិសេសត្រូវបានធ្វើឡើង មុនការចែកចំណែកនូវប្រាក់ដែលជាតម្លៃនៃទ្រព្យក្រៅពីអចលនវត្ថុ ។

(កំណត់)

មាត្រានេះចែងអំពីអានុភាពនៃឯកសិទ្ធិទូទៅ ។

កថាខណ្ឌទី ១ ចែងថា ម្ចាស់ឯកសិទ្ធិទូទៅ ត្រូវទទួលការសង ដោយយកទ្រព្យសម្បត្តិផ្សេងពីអចលនវត្ថុជាមុនសិន ។

កថាខណ្ឌទី ២ ចែងថា ក្នុងករណីដែលការសងដែលបានទទួលពីទ្រព្យសម្បត្តិដែលមិនមែនជាអចលនវត្ថុ នៅមិនទាន់គ្រប់ចំនួននៃសិទ្ធិលើបំណុលទេ ម្ចាស់ឯកសិទ្ធិទូទៅអាចទទួលការសងពីអចលនវត្ថុបាន ប៉ុន្តែ ក្នុងករណីនេះ ម្ចាស់ឯកសិទ្ធិទូទៅនេះ ត្រូវទទួលការសងពីអចលនវត្ថុណាដែលមិនមែនជាកម្មវត្ថុនៃប្រាតិភោគពិសេស (ហ៊ីប៉ូតែក ជាអាទិ៍) របស់ម្ចាស់បំណុលដទៃទៀត ជាមុនសិន ។

កថាខណ្ឌទី ៣ គឺជាបញ្ញត្តិដែលមានគោលបំណងដើម្បីការពារមិនឱ្យមានការខូចខាតផលប្រយោជន៍ដល់ម្ចាស់សិទ្ធិ

ប្រាតិភោគផ្សេងទៀតដែលមានលំដាប់ទាបជាងម្ចាស់ឯកសិទ្ធិទូទៅ ក្នុងករណីដែលម្ចាស់ឯកសិទ្ធិទូទៅនោះខកខានមិនបានចូលរួមក្នុងការចែកចំណែក តាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ។

កថាខណ្ឌទី ៤ ចែងថា ម្ចាស់ឯកសិទ្ធិទូទៅនឹងទទួលចំណែកស្របទៅតាមលំដាប់ដើម ក្នុងករណីដែលអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគពិសេស ត្រូវបានលក់ដោយបង្ខំ (សូមមើលកំណត់នៃមាត្រា ៧៧៣) តាមការទាមទាររបស់ម្ចាស់បំណុលផ្សេងទៀត ជាអាទិ៍ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៣៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨១០.-** អានុភាពនៃឯកសិទ្ធិទូទៅចំពោះតតិយជន

ម្ចាស់ឯកសិទ្ធិទូទៅអាចយកឯកសិទ្ធិនេះទៅតតាំងចំពោះម្ចាស់បំណុលដែលគ្មានប្រាតិភោគពិសេសបាន ទោះជាពុំបានចុះបញ្ជីឯកសិទ្ធិចំពោះអចលនវត្ថុក៏ដោយ ។ ប៉ុន្តែចំពោះតតិយជនដែលបានចុះបញ្ជីវិញ ម្ចាស់ឯកសិទ្ធិទូទៅ ពុំអាចយកឯកសិទ្ធិនេះទៅតតាំងបានឡើយ ។

(កំណត់)

មាត្រានេះចែងអំពីទំនាក់ទំនងរវាងម្ចាស់ឯកសិទ្ធិទូទៅ និង តតិយជន (ជាពិសេស ម្ចាស់បំណុលផ្សេងទៀត) ។ ឯកសិទ្ធិគឺជាសិទ្ធិប្រាតិភោគប្រត្យក្សដែលកើតឡើងដោយបញ្ញត្តិនៃច្បាប់ ដូច្នេះហើយ ចំពោះអចលនវត្ថុ ម្ចាស់ឯកសិទ្ធិមានអាទិភាពជាងម្ចាស់បំណុលទូទៅដែលមិនមានសិទ្ធិប្រាតិភោគពិសេស ទោះបីជាឯកសិទ្ធិទូទៅនោះមិនត្រូវបានចុះបញ្ជីក៏ដោយ (វាក្យខណ្ឌទី ១) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨១១.-** អានុភាពចំពោះតតិយជននៃឯកសិទ្ធិចំពោះការរក្សាទុកអចលនវត្ថុ

១-ឯកសិទ្ធិចំពោះការរក្សាទុកអចលនវត្ថុ មិនអាចតតាំងចំពោះតតិយជនបានឡើយ បើពុំបានចុះបញ្ជីភ្លាមៗ ក្រោយពីបានបញ្ចប់សកម្មភាពរក្សាទុកទេ ។

២-កំណើនតម្លៃនៃអចលនវត្ថុដែលបានកើតឡើងដោយសារការរក្សាទុក ត្រូវធ្វើការវាយតម្លៃដោយអ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ នៅពេលចូលរួម ក្នុងការចែកចំណែក ។

( កំណត់ )

គោលបំណងនៃមាត្រានេះចែងអំពីភាពចាំបាច់ក្នុងការចុះបញ្ជីភ្លាមៗនូវឯកសិទ្ធិចំពោះការរក្សាទុកអចលនវត្ថុ ដើម្បីតតាំងឯកសិទ្ធិនោះចំពោះតតិយជន ទោះបីជាឯកសិទ្ធិនេះបានកើតឡើងដោយសកម្មភាពរក្សាទុកក៏ដោយ ។ ចំពោះលំដាប់អាទិភាពទាក់ទងនឹងហ៊ីប៉ូតែក ដូចមានបញ្ញត្តិនៅក្នុងមាត្រា ៨១៣ (ទំនាក់ទំនងរវាងឯកសិទ្ធិចំពោះការរក្សាទុកអចលនវត្ថុ ឯកសិទ្ធិចំពោះការងារលើអចលនវត្ថុ និង ហ៊ីប៉ូតែក) ឯកសិទ្ធិមានអាទិភាពជាងហ៊ីប៉ូតែកដែលត្រូវបានចុះបញ្ជីរួចហើយ ហេតុដូច្នេះ មាត្រានេះទាមទារឱ្យចុះបញ្ជីឯកសិទ្ធិ "ភ្លាមៗ" ។ ពាក្យថា "ភ្លាមៗ" នៅមាត្រានេះ មានន័យថាជាការតម្រូវឱ្យចុះបញ្ជីទាន់ពេលវេលាស្របតាមសកម្មភាពនៃការរក្សាទុក ទោះបីជាចំនួនថ្ងៃមានលក្ខណៈខុសគ្នាទៅតាមសកម្មភាពរក្សាទុកនេះក៏ដោយ ។

( មាត្រាពាក់ព័ន្ធ )

មាត្រា ៣៣៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨១២.-** អានុភាពចំពោះតតិយជននៃឯកសិទ្ធិចំពោះការងារលើអចលនវត្ថុ

១-ឯកសិទ្ធិចំពោះការងារលើអចលនវត្ថុ មិនអាចតតាំងចំពោះតតិយជនបានឡើយ បើមិនបានចុះបញ្ជីភ្លាមៗ ក្រោយពីបានបញ្ចប់ការងារនោះ ។

២-កំណើនតម្លៃនៃអចលនវត្ថុដែលបានកើតឡើងដោយសារការងារ ត្រូវធ្វើការវាយតម្លៃដោយអ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ នៅពេលចូលរួមក្នុងការចែកចំណែក ។

( កំណត់ )

កថាខណ្ឌទី ១ នៃមាត្រានេះចែងថា ឯកសិទ្ធិចំពោះការងារលើអចលនវត្ថុ ទទួលអានុភាពតតាំង នៅពេលដែល (ចំនួនទឹកប្រាក់នៃសោហ៊ុយការងារនោះ) ត្រូវបានចុះបញ្ជីបន្ទាប់បានបញ្ចប់ការងារនោះ ។ ដូចឯកសិទ្ធិចំពោះការរក្សាទុកអចលនវត្ថុ ឯកសិទ្ធិចំពោះការងារលើអចលនវត្ថុ ក៏បានកើតឡើងដោយសារការងារនោះដែរ ប៉ុន្តែ កថាខណ្ឌទី ១ នេះបញ្ជាក់ថា ដើម្បីតតាំងឯកសិទ្ធិ ចាំបាច់ចុះបញ្ជីភ្លាមៗ បន្ទាប់ពីបានបញ្ចប់ការងារនោះ ។ កថាខណ្ឌទី ២ គឺជាបញ្ញត្តិសម្រាប់ករណីដែលចាំបាច់គណនាចំនួនកំណើនតម្លៃអចលនវត្ថុដែលបានកើតឡើងដោយសារការងារ (សូមមើលកថាខណ្ឌទី ២ នៃមាត្រា ៨០១ (ឯកសិទ្ធិចំពោះការងារលើអចលនវត្ថុ)) ។

ម្យ៉ាងទៀត មាត្រានេះគឺទាក់ទងនឹងការដោះស្រាយបញ្ហាចុះបញ្ជីដីធ្លី និង ចុះបញ្ជីអាគារ ។

( មាត្រាពាក់ព័ន្ធ )

មាត្រា ៣៣៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨១៣.–** ទំនាក់ទំនងរវាងឯកសិទ្ធិចំពោះការរក្សាទុកអចលនវត្ថុ ឯកសិទ្ធិចំពោះការងារលើអចលនវត្ថុ និង ហ៊ីប៉ូតែក

ឯកសិទ្ធិដែលបានចុះបញ្ជី តាមបញ្ញត្តិនៃមាត្រា ៨១១ (អានុភាពចំពោះតតិយជននៃឯកសិទ្ធិចំពោះការរក្សាទុកអចលនវត្ថុ) និង មាត្រា ៨១២ (អានុភាពចំពោះតតិយជននៃឯកសិទ្ធិចំពោះការងារលើអចលនវត្ថុ) នៃក្រមនេះ អាចអនុវត្តដោយមានអាទិភាពជាងហ៊ីប៉ូតែកបាន ។

(កំណត់)

មាត្រានេះចែងថា នៅពេលដែលឯកសិទ្ធិចំពោះការរក្សាទុកអចលនវត្ថុ និង ឯកសិទ្ធិចំពោះការងារលើអចលនវត្ថុត្រូវបានចុះបញ្ជីរួច ឯកសិទ្ធិនេះនឹងមានអាទិភាពជាងហ៊ីប៉ូតែកដែលបានបង្កើតឡើងមុនការចុះបញ្ជីឯកសិទ្ធិនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៣៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨១៤.–** អានុភាពចំពោះតតិយជននៃឯកសិទ្ធិចំពោះការលក់អចលនវត្ថុ

ឯកសិទ្ធិចំពោះការលក់អចលនវត្ថុ មិនអាចតតាំងចំពោះតតិយជនបានឡើយ បើមិនបានចុះបញ្ជីបញ្ជាក់ថា មិនទាន់បានសងថ្លៃទិញ ឬ ការប្រាក់ ព្រមគ្នានឹងពេលធ្វើកិច្ចសន្យាលក់ទិញទេ ។

(កំណត់)

មាត្រានេះចែងថា ឯកសិទ្ធិចំពោះការលក់អចលនវត្ថុ ត្រូវទទួលអានុភាពតតាំង ដោយការចុះបញ្ជីឯកសិទ្ធិនោះ ។ បានសេចក្ដីថា ទោះបីជាឯកសិទ្ធិនោះបានកើតឡើងដោយសារការលក់អចលនវត្ថុក៏ដោយ ក៏ឯកសិទ្ធិនេះ ចាំបាច់ត្រូវបានចុះបញ្ជីផងដែរដើម្បីតតាំងឯកសិទ្ធិនោះ ។ ម្យ៉ាងទៀត ផ្ទុយពីឯកសិទ្ធិចំពោះការរក្សាទុកអចលនវត្ថុ និង ឯកសិទ្ធិចំពោះការងារលើអចលនវត្ថុ ឯកសិទ្ធិចំពោះការលក់អចលវត្ថុនេះ មិនមានអាទិភាពជាងហ៊ីប៉ូតែកដែលត្រូវបានចុះបញ្ជីនេះទេ (សូមមើលមាត្រា ៨១៣) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៤០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨១៥.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្ដីពីហ៊ីប៉ូតែក

ក្រៅពីបញ្ញត្តិក្នុងជំពូកទី ៣ (ឯកសិទ្ធិ) នេះ បញ្ញត្តិពីមាត្រា ៨៤៦ (ទំហំនៃអានុភាពហ៊ីប៉ូតែក) ដល់មាត្រា ៨៤៨ (អានុភាពនៃហ៊ីប៉ូតែក ចំពោះផល) បញ្ញត្តិនៃមាត្រា ៨៥១ (លំដាប់នៃហ៊ីប៉ូតែក) មាត្រា ៨៥២ (ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា) មាត្រា ៨៥៣ (ការលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែក) និង បញ្ញត្តិពីមាត្រា ៨៥៩ (ហ៊ីប៉ូតែកបន្ត) ដល់មាត្រា ៨៦៣ (លំដាប់នៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអានុភាពនៃឯកសិទ្ធិ ។

(កំណត់)

មាត្រានេះចែងថា បញ្ញត្តិស្តីពីហ៊ីប៉ូតែកត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះអានុភាពនៃឯកសិទ្ធិ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៤១ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ជំពូកទី ៤ សិទ្ធិលើការបញ្ចាំ

## ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ

**មាត្រា ៨១៦.–** អត្ថន័យនៃសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិកាន់កាប់វត្ថុដែលបានទទួលពីកូនបំណុល ឬ តតិយជនដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និង ទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពីវត្ថុនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ។

(កំណត់)

មាត្រានេះចែងអំពីនិយមន័យនៃសិទ្ធិលើការបញ្ចាំ ដែលបញ្ជាក់ថា ម្ចាស់សិទ្ធិលើការបញ្ចាំកាន់កាប់វត្ថុដែលបានទទួលពីកូនបំណុល និង អាចទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួន ពីតម្លៃថ្លៃនៃវត្ថុនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ។

ម្យ៉ាងទៀត ទោះបីជាមាត្រានេះប្រើពាក្យ "វត្ថុ" ជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំក៏ដោយ ក៏មាត្រានេះពុំមានបំណងដកចេញនូវសិទ្ធិលើការបញ្ចាំសិទ្ធិទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៤២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣២៨ (និយមន័យនៃសិទ្ធិលើការបញ្ចាំ) មាត្រា ១៣២៩ (ប្រភេទនៃសិទ្ធិការលើបញ្ចាំ : សិទ្ធិលើការបញ្ចាំចលនវត្ថុ និង សិទ្ធិលើការបញ្ចាំអចលនវត្ថុ) និង មាត្រា ១៣៥៣

(សិទ្ធិលើការបញ្ចាំអចលនវត្ថុ : សិទ្ធិទទួលការសងដោយមានអាទិភាព) នៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជា. មាត្រា ៦៤ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច របស់កម្ពុជា

**មាត្រា ៨១៧.–** ឧបាទេសកម្មលើវត្ថុ

១-សិទ្ធិលើការបញ្ចាំអាចអនុវត្តបានចំពោះទឹកប្រាក់ ឬ វត្ថុផ្សេងទៀតដែលអ្នកបង្កើតត្រូវទទួល ដោយការលក់ ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ។ ប៉ុន្តែ ម្ចាស់សិទ្ធិលើការបញ្ចាំពុំអាចអនុវត្តសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលទឹកប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងត្រូវបានប្រគល់ ទៅឱ្យអ្នកបង្កើត ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះតម្លៃថ្នូរនឹងសិទ្ធិប្រត្យក្សដែលបង្កើតឡើង ដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ លើវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ។

(កំណត់)

ដោយសារប្រភេទនៃវត្ថុដែលក្លាយជាកម្មវត្ថុនៃឧបាទេសកម្មលើវត្ថុ អាចប្រែប្រួលតាមប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្ស បញ្ញត្តិស្ដីពីឧបាទេសកម្មលើវត្ថុ ត្រូវបានរៀបចំឡើង តាមប្រភេទនីមួយៗនៃសិទ្ធិប្រាតិភោគប្រត្យក្ស ។ មាត្រានេះចែងអំពីលក្ខណៈនៃឧបាទេសកម្មលើវត្ថុចំពោះសិទ្ធិលើការបញ្ចាំ ។ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃមាត្រានេះ ចែងថា សិទ្ធិលើការបញ្ចាំ ត្រូវមានអានុភាពលើតម្លៃ ឬ វត្ថុដែលជំនួសជាសារធាតុនឹងវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣០៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨១៨.–** ការបង្កើតសិទ្ធិលើការបញ្ចាំ និង ការប្រគល់វត្ថុជាចាំបាច់

១-សិទ្ធិលើការបញ្ចាំត្រូវកើតឡើង ដោយកូនបំណុល ឬ តតិយជនដែលបង្កើតសិទ្ធិលើការបញ្ចាំនោះ ប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។

២-ការប្រគល់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរាប់បញ្ចូលទាំងការប្រគល់ដោយសង្ខេប ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ២២៩ (ការផ្ទេរការកាន់កាប់) នៃក្រមនេះ ។

(កំណត់)

មាត្រានេះចែងអំពីល័ក្ខខ័ណ្ឌនៃការប្រគល់វត្ថុសម្រាប់សិទ្ធិលើការបញ្ចាំ ។ មានន័យថា សិទ្ធិលើការបញ្ចាំមិនត្រូវកើតឡើងអានុភាពទេ បើវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំមិនត្រូវបានប្រគល់ឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។ មានន័យម្យ៉ាងទៀតថា គោលបំណងនៃមាត្រានេះ មិនអនុញ្ញាតឱ្យប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ តាមរយៈការប្តូរលក្ខណៈនៃការកាន់កាប់ទេ ។ ចំពោះបញ្ហាដែលពាក់ព័ន្ធនឹងកិច្ចសន្យាដើម្បីបង្កើតសិទ្ធិលើការបញ្ចាំ ក្រៅពីការប្រគល់នូវវត្ថុ មានបញ្ហាថា តើតម្រូវឱ្យមានកិច្ចសន្យាដើម្បីបង្កើតសិទ្ធិលើការបញ្ចាំជាលាយល័ក្ខណ៍អក្សរ ហើយប្រសិនបើ តម្រូវឱ្យមាន មានបញ្ហាថា តើតម្រូវឱ្យកិច្ចសន្យានោះស្របទៅតាមទម្រង់ណាមួយជាកំណត់ (ដូចជាលិខិតយថាភូត លិខិតដែលមានសេចក្តីបញ្ជាក់ដោយស្ថាប័នសាធារណៈ ឬ ជាលិខិតឯកជន) ឬយ៉ាងណា ។ ចំពោះបញ្ហានេះ ក្រមរដ្ឋប្បវេណីនេះមិនតម្រូវឱ្យមានទម្រង់ពិសេសណាមួយទេ ប៉ុន្តែ តម្រូវឱ្យមានការព្រមព្រៀងរបស់ភាគីតែប៉ុណ្ណោះ ។

ម្យ៉ាងទៀត ក្រមនេះមិនអនុញ្ញាតឱ្យមានសិទ្ធិលើការបញ្ចាំដោយមិនប្រគល់ការកាន់កាប់ (ការដាក់ធានា) ដែលតម្រូវឱ្យប្រគល់ប័ណ្ណជំនួសវត្ថុដែលជាកម្មសិទ្ធិ ដែលត្រូវបានទទួលស្គាល់ (ហើយត្រូវបានប្រើក្នុងការអនុវត្ត) តាមក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជា ។ មូលហេតុនៃការផ្លាស់ប្តូរនេះ គឺដោយសារសិទ្ធិលើការបញ្ចាំលើអចលនវត្ថុដោយមិនប្រគល់ការកាន់កាប់ អាចជំនួសដោយហ៊ីប៉ូតែកបាន រីឯសិទ្ធិលើការបញ្ចាំលើចលនវត្ថុដោយមិនប្រគល់ការកាន់កាប់ អាចជំនួសដោយប្រាតិភោគដោយអនុប្បទានបាន ។ ម្យ៉ាងទៀត អានុភាពសារធាតុស្រដៀងគ្នានឹងសិទ្ធិលើការបញ្ចាំដោយមិនប្រគល់ការកាន់កាប់ អាចត្រូវបានទទួលតាមរយៈការលោះ (ការទិញវិញ) បាន (សូមមើលបញ្ញត្តិទាក់ទងនឹងការលក់ទិញ) ។ សូមមើលផងដែរនូវសេចក្តីកំណត់នៃមាត្រា ៨១៩ ខាងក្រោម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៤៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣៣១ (សិទ្ធិលើការបញ្ចាំចលនវត្ថុ : ល័ក្ខខ័ណ្ឌនៃការប្រគល់នូវវត្ថុ) មាត្រា ១៣៤៨ (សិទ្ធិលើការបញ្ចាំអចលនវត្ថុ : ករណីដែលតម្រូវឱ្យប្រគល់នូវប័ណ្ណប៉ុណ្ណោះ) មាត្រា ១៣៣០ (សិទ្ធិលើការបញ្ចាំចលនវត្ថុ : កិច្ចសន្យាត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ) មាត្រា ១៣៤៤ (សិទ្ធិលើការបញ្ចាំអចលនវត្ថុ : កិច្ចសន្យាតាមរូបមន្តនៃលិខិតបញ្ជាក់) មាត្រា ១៣៤៥ (សិទ្ធិលើការបញ្ចាំអចលនវត្ថុ : ល័ក្ខខ័ណ្ឌតម្រូវឱ្យមានទម្រង់កំណត់) មាត្រា ១៣៣២ (សិទ្ធិលើការបញ្ចាំចលនវត្ថុ : ការបញ្ជាក់អំពីចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល និងវត្ថុបញ្ចាំ) និង មាត្រា ១៣៣៣ (សិទ្ធិលើការបញ្ចាំចលនវត្ថុ : គោលការណ៍មិនយកការប្រាក់ និង មានអំឡុងពេល ១ ឆ្នាំ) នៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជា, មាត្រា ៦៥ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច របស់ប្រទេសកម្ពុជា (ល័ក្ខខ័ណ្ឌឱ្យមានលិខិតកិច្ចសន្យាដើម្បីបង្កើតសិទ្ធិលើការបញ្ចាំ និង ល័ក្ខខ័ណ្ឌឱ្យមានការកាន់កាប់ដើម្បីមានសុពលភាព)

**មាត្រា ៨១៩.–** ការហាមការកាន់កាប់ដោយផ្ទាល់ ដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចឱ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះកាន់កាប់ដោយផ្ទាល់លើវត្ថុបញ្ចាំនោះបានឡើយ ។

(កំណត់)

មាត្រានេះហាមឃាត់មិនឱ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ជំនួសម្ចាស់សិទ្ធិលើការបញ្ចាំ ។ មានន័យថា ក្នុងករណីនៃសិទ្ធិលើការបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំ ឬ អ្នកតំណាងរបស់ម្ចាស់សិទ្ធិលើការបញ្ចាំនោះ (លើកលែងតែអ្នកបង្កើតសិទ្ធិលើការបញ្ចាំ) ចាំបាច់ត្រូវកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ។ គោលបំណងនៃមាត្រានេះ មិនអនុញ្ញាតឱ្យមានសិទ្ធិលើការបញ្ចាំ "ឥតប្រគល់ការកាន់កាប់" ដែលម្ចាស់សិទ្ធិលើការបញ្ចាំមិនកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទេ (ទាំងអចលនវត្ថុ និង ចលនវត្ថុ) ។

ចំណែកឯការបង្កើតសិទ្ធិប្រាតិភោគលើចលនវត្ថុ នៅខណៈពេលដែលកូនបំណុល (អ្នកបង្កើតសិទ្ធិលើការបញ្ចាំ) បន្តកាន់កាប់ចលនវត្ថុនោះ មានបញ្ញត្តិដាច់ដោយឡែកដែលទាក់ទងនឹងការលក់ ឬ ប្រាតិភោគដោយអនុប្បទាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៨២០.- ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

សិទ្ធិលើការបញ្ចាំត្រូវធានានូវ ប្រាក់ដើម ការប្រាក់ ប្រាក់ធានាសងក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ សោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុបញ្ចាំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានកំណត់ផ្សេង ក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំនោះ ។

(កំណត់)

មាត្រានេះចែងអំពីទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិលើការបញ្ចាំ ។ មិនដូចជាហ៊ីប៉ូតែកទេ ករណីដែលមានម្ចាស់បំណុលដែលមានលំដាប់ទាបជាងម្ចាស់សិទ្ធិលើការបញ្ចាំ ទំនងជាមានតិចតួច ។ ហេតុដូច្នេះ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិលើការបញ្ចាំ ធំជាងទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៤៦ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៦ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច របស់ប្រទេសកម្ពុជា

## មាត្រា ៨២១.- អានុភាពនៃការឃាត់ទុក

ម្ចាស់សិទ្ធិលើការបញ្ចាំអាចឃាត់ទុកវត្ថុបញ្ចាំបាន រហូតដល់ពេលដែលទទួលការសងចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងមាត្រា ៨២០ (ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា) ខាងលើនេះ ។ ប៉ុន្តែ សិទ្ធិនេះមិនអាចតតាំង ចំពោះម្ចាស់បំណុលដែលមានអាទិភាពជាងខ្លួនបានឡើយ ។

(កំណត់)

មាត្រានេះចែងថា ម្ចាស់សិទ្ធិលើការបញ្ចាំ នឹងរំលឹកកូនបំណុលដោយប្រយោលតាមរយៈអានុភាពឃាត់ទុកនៃសិទ្ធិលើការបញ្ចាំដើម្បីទទួលការសងចំពោះសិទ្ធិលើបំណុល ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៤៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨២២.-** សិទ្ធិទទួលការសងពីផលដោយមានអាទិភាព

១-ម្ចាស់សិទ្ធិលើការបញ្ចាំអាចទទួលផលដែលកើតពីវត្ថុបញ្ចាំ និង អាចយកផលនោះមកកាត់សិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន ។

២-ផលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុនសិន ហើយ ប្រសិនបើមានសំណល់ ត្រូវយកទៅកាត់ប្រាក់ដើម ។

(កំណត់)

មាត្រានេះចែងថា ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិទទួលផល ។ ប៉ុន្តែ មាត្រានេះចែងផងដែរថា ផលដែលកើតពីវត្ថុបញ្ចាំគួរត្រូវយកមកកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៥០ នៃក្រមរដ្ឋប្បវេណីជប៉ុន (ការអនុវត្តដូចគ្នាផងដែរតាមមាត្រា ២៩៧), មាត្រា ១៣៥៦ (អចលនវត្ថុ : ករណីយកិច្ចក្នុងការប្រគល់វិញនូវផល បន្ទាប់ពីការសងកាតព្វកិច្ច) និង មាត្រា ១៣៥៧ (អចលនវត្ថុ : ករណីដែលមិនមានអំឡុងពេលកំណត់) នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ៨២៣.-** ករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការរក្សាទុកនូវវត្ថុបញ្ចាំ

១-ម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវកាន់កាប់វត្ថុបញ្ចាំនោះដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលអាចទាមទាររំលត់សិទ្ធិលើការបញ្ចាំនោះបាន ។

(កំណត់)

មាត្រានេះចែងថា ម្ចាស់សិទ្ធិលើការបញ្ចាំមានករណីយកិច្ចធ្ងន់របស់ខ្លួនក្នុងការកាន់កាប់វត្ថុបញ្ចាំ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកថែរក្សាវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ។ ការប្រើប្រាស់ និង ការអាស្រ័យផលពីវត្ថុបញ្ចាំ ដោយម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវបានចែងក្នុងបទប្បញ្ញត្តិដាច់ដោយឡែកទាក់ទងនឹងសិទ្ធិលើការបញ្ចាំចលនវត្ថុ និង សិទ្ធិលើការបញ្ចាំអចលនវត្ថុ (មាត្រា ៨៣១ (ការប្រើប្រាស់ និង អាស្រ័យផលពីវត្ថុបញ្ចាំ ដោយម្ចាស់សិទ្ធិលើការបញ្ចាំ) ចំពោះការបញ្ចាំចលនវត្ថុ និង មាត្រា ៨៣៤ (សិទ្ធិប្រើប្រាស់ និង អាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ) ចំពោះការបញ្ចាំអចលវត្ថុ) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៥០ នៃក្រមរដ្ឋប្បវេណីជប៉ុន (ការអនុវត្តដូចគ្នាផងដែរតាមមាត្រា ២៩៨), មាត្រា ១៣៣៤ (សិទ្ធិលើការបញ្ចាំចលនវត្ថុ : ការហាមឃាត់ការប្រើប្រាស់ដោយម្ចាស់សិទ្ធិលើការបញ្ចាំ) មាត្រា ១៣៣៥ (សិទ្ធិលើការបញ្ចាំចលនវត្ថុ : ករណីយកិច្ចរក្សាទុក) មាត្រា ១៣៥៤ (សិទ្ធិលើការបញ្ចាំអចលនវត្ថុ : ករណីយកិច្ចរក្សាទុក និង សងសំណងការខូចខាត) និង មាត្រា ១៣៣៦ (សិទ្ធិលើការបញ្ចាំចលនវត្ថុ : ការទាមទារឱ្យរំលត់សិទ្ធិលើការបញ្ចាំ) នៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជា, មាត្រា ៦៧ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច (សិទ្ធិលើការបញ្ចាំ : ការហាមឃាត់ការប្រើប្រាស់ និង ការអាស្រ័យផល) ។

**មាត្រា ៨២៤.-** សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

១-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ ចំពោះវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយនោះវិញបាន ។

២-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយបង្កើនតម្លៃនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះអាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយទាំងអស់ដែលខ្លួនបានចេញ ឬ សងនូវតម្លៃប្រាក់ដែលកើននោះវិញ តាមការជ្រើសរើសរបស់ខ្លួនបាន ក្នុងករណីដែលកំណើនតម្លៃនោះនៅតែមាន ។ ប៉ុន្តែ តុលាការអាចកំណត់ពេលសមរម្យដើម្បីសង តាមការទាមទាររបស់កម្មសិទ្ធិករបាន ។

(កំណត់)

មាត្រានេះចែងថា ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិទាមទារឱ្យសងសោហ៊ុយសម្រាប់វត្ថុបញ្ចាំ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៥០ នៃក្រមរដ្ឋប្បវេណីជប៉ុន (ការអនុវត្តដូចគ្នាផងដែរតាមមាត្រា ២៩៩), មាត្រា ១៣៣៥ (សិទ្ធិលើការបញ្ចាំចលនវត្ថុ : សិទ្ធិទាមទារឱ្យសងសោហ៊ុយ) នៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជា ។

**មាត្រា ៨២៥.–** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ការប្រើសិទ្ធិលើការបញ្ចាំ មិនរារាំងដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ។

(កំណត់)

មាត្រានេះចែងថា ការប្រើសិទ្ធិលើការបញ្ចាំ នឹងមិនរារាំងដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទេ ។ នីតិវិធីផ្អាកត្រូវតែយកមកប្រើប្រាស់ដើម្បីឱ្យអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលផ្អាក ។

ពាក្យ "ការប្រើ" ត្រូវបានប្រើដើម្បីបញ្ជាក់ន័យថា កាន់កាប់វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ក្នុងនាមជាម្ចាស់សិទ្ធិលើការបញ្ចាំ" ហើយមានន័យខុសគ្នាពី "ការអនុវត្តសិទ្ធិលើការបញ្ចាំ" ។ ប្រសិនបើពាក្យនេះបង្កើតឱ្យមានការយល់ខុស ពាក្យនេះនឹងត្រូវប្តូរទៅជា "ការឃាត់ទុកវត្ថុដែលជាកម្មវត្ថុដោយសិទ្ធិលើការបញ្ចាំ" ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៥០ នៃក្រមរដ្ឋប្បវេណីជប៉ុន (ការអនុវត្តដូចគ្នាផងដែរតាមមាត្រា ៣០០)

**មាត្រា ៨២៦.–** ការបញ្ចាំបន្ត

១-ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀតបាន ដោយទទួលការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះ ដើម្បីធានានូវកាតព្វកិច្ចរបស់ខ្លួន ។

២-ក្នុងអំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំ ម្ចាស់សិទ្ធិនោះអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀត ក្រោមការទទួលខុសត្រូវរបស់ខ្លួនបាន ។ ក្នុងករណីនេះ ម្ចាស់សិទ្ធិលើការបញ្ចាំនោះក៏ត្រូវទទួលខុសត្រូវ ចំពោះការខូចខាតដោយប្រធានសក្តិដែលមិនអាចកើតមានឡើងប្រសិនបើមិនបានដាក់បញ្ចាំបន្តទេ ។

៣-នៅពេលចែកចំណែកថ្លៃលក់ដោយបង្ខំនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំបន្តអាចទទួលនូវការសងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនទាំងអស់ ដោយមានកម្រិត

នៃចំនួនទឹកប្រាក់ដែលត្រូវចែកចំណែកទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។ ប៉ុន្តែ ប្រសិនបើសិទ្ធិលើបំណុលរបស់ខ្លួន មិនទាន់ដល់ពេលកំណត់ត្រូវសងទេ ម្ចាស់សិទ្ធិលើការបញ្ចាំបន្តគ្រាន់តែអាចទាមទារឱ្យតម្កល់នូវចំនួនទឹកប្រាក់ដែលខ្លួនអាចទទួលការសងបានប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះចែងថា ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំដែលបានទទួលពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ទៅដាក់បញ្ចាំបន្តទៀតបាន ដើម្បីធានានូវកាតព្វកិច្ចរបស់ខ្លួន ។ កថាខណ្ឌទី ១ ចែងថា ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំទៅដាក់បញ្ចាំបន្តបាន ដោយទទួលការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះ (ការបញ្ចាំបន្តដោយមានការយល់ព្រម) ។ ក្នុងករណីនេះ អានុភាពនៃការបញ្ចាំបន្ត ត្រូវអាស្រ័យលើកិច្ចព្រមព្រៀងនោះ ហេតុដូច្នេះ មាត្រានេះមិនបានចែងអំពីខ្លឹមសារនៃអានុភាពនៃការបញ្ចាំបន្តទេ ។ កថាខណ្ឌទី ២ ចែងថា ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀត ក្រោមការទទួលខុសត្រូវរបស់ខ្លួនបាន ដោយពុំចាំបាច់មានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំទេ (ការបញ្ចាំបន្តដែលមានការទទួលខុសត្រូវ) ។ ក្នុងករណីនេះ ម្ចាស់សិទ្ធិលើការបញ្ចាំ (ដែលជាអ្នកបង្កើតសិទ្ធិលើការបញ្ចាំបន្ត)នឹងទទួលខុសត្រូវចំពោះការខូចខាតដោយករណីប្រធានសក្តិផងដែរ ។ ទំហំនៃការបញ្ចាំបន្តត្រូវបានបង្កើតដោយម្ចាស់សិទ្ធិលើការបញ្ចាំ នឹងត្រូវបានកម្រិតត្រឹមសិទ្ធិនៃការបញ្ចាំដើម ។ ទោះបីជាការបញ្ចាំបន្តត្រូវបានបង្កើតឡើងហួសពីទំហំនៃសិទ្ធិនៃការបញ្ចាំដើម ចំពោះអំឡុងពេល ឬ ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានា ជាអាទិ៍ ក៏ដោយ ក៏ការបញ្ចាំបន្តនោះមិនមែនមោឃៈឡើយ ប៉ុន្តែ អាចតតាំងចំពោះអ្នកបង្កើតសិទ្ធិលើការបញ្ចាំដើមត្រឹមទំហំនៃសិទ្ធិលើការបញ្ចាំដើមប៉ុណ្ណោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៤៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨២៧.–** ការហាមកិច្ចសន្យាបញ្ចាំផ្តាច់

បើពុំមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេងទៀតទេ អ្នកដែលបង្កើតសិទ្ធិលើការបញ្ចាំ មិនអាចព្រមព្រៀង ឱ្យម្ចាស់សិទ្ធិលើការបញ្ចាំទទួលកម្មសិទ្ធិលើវត្ថុបញ្ចាំ ឬ ចាត់ចែងវត្ថុបញ្ចាំ តាមវិធីផ្សេងពីវិធីដែលច្បាប់បានកំណត់ ដោយសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ឬ ដោយកិច្ចសន្យាដែលធ្វើមុនកំណត់ពេលត្រូវសងបានទេ ។

(កំណត់)

មាត្រានេះហាមឃាត់ម្ចាស់សិទ្ធិលើការបញ្ចាំ ធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ក្នុងករណីដែលកាតព្វកិច្ចមិនត្រូវបានសងទេ (ហៅថា "កិច្ចសន្យាបញ្ចាំផ្តាច់") ។ មាត្រានេះហាមឃាត់ម្ចាស់សិទ្ធិលើការបញ្ចាំផងដែរ

មិនឱ្យប្តូរវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំឱ្យទៅជាប្រាក់ដោយការអនុវត្តឯកជនឡើយ ។

ប៉ុន្តែ មាត្រានេះទទួលស្គាល់ផងដែរថា ការបញ្ចាំផ្តាច់អាចត្រូវបានអនុញ្ញាតតាមរយៈកិច្ចព្រមព្រៀង ដោយអនុលោមតាមក្រមរដ្ឋប្បវេណី និង ច្បាប់ផ្សេងទៀត (ឧទាហរណ៍ ដូចជាក្នុងករណីនៅប្រទេសជប៉ុន គេអាចអនុញ្ញាតឱ្យធ្វើកិច្ចសន្យាបញ្ចាំផ្តាច់ ចំពោះសិទ្ធិលើការបញ្ចាំពាណិជ្ជកម្ម សិទ្ធិលើការបញ្ចាំសាធារណៈ ជាអាទិ៍) ។ ក្នុងន័យនេះ បញ្ញត្តិនេះចែងអំពីគោលការណ៍ទូទៅ ។ ម្យ៉ាងវិញទៀត ចំពោះសិទ្ធិលើការបញ្ចាំចលនវត្ថុ មានបញ្ញត្តិដែលអនុញ្ញាតឱ្យអនុវត្តដោយសង្ខេប ត្រូវបានចែងដាច់ដោយឡែក ( មាត្រា ៨៣២ ( ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប) ) ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៣៤៩ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣៤០ (សិទ្ធិលើការបញ្ចាំចលវត្ថុ : ការបញ្ចាំផ្តាច់ត្រូវបានអនុញ្ញាតដោយមានកិច្ចព្រមព្រៀង ប្រសិនបើតម្លៃនៃវត្ថុបញ្ចាំមិនលើសពី ១០០ រៀល) និង មាត្រា ១៣៥២ (សិទ្ធិលើការបញ្ចាំអចលនវត្ថុ : ការហាមឃាត់ការបញ្ចាំផ្តាច់) នៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជា, មាត្រា ៧១ (ការហាមឃាត់ការបញ្ចាំផ្តាច់) នៃក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច របស់ប្រទេសកម្ពុជា

**មាត្រា ៨២៨.–** សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ

ប្រសិនបើអ្នកដែលបង្កើតសិទ្ធិលើការបញ្ចាំដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃ បានសងចំពោះកាតព្វកិច្ចនោះ ឬ បានបាត់បង់នូវកម្មសិទ្ធិលើវត្ថុបញ្ចាំ ដោយសារការអនុវត្តសិទ្ធិលើការបញ្ចាំនោះ អ្នកនោះត្រូវមានសិទ្ធិទាមទារសំណង ចំពោះកូនបំណុលដោយយោងទៅតាមបញ្ញត្តិស្តីពីការធានា ។

( កំណត់)

មាត្រានេះចែងថា ប្រសិនបើអ្នកដែលបង្កើតសិទ្ធិលើការបញ្ចាំដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃ បានសងចំពោះកាតព្វកិច្ចនោះ ឬ បានបាត់បង់នូវកម្មសិទ្ធិលើវត្ថុបញ្ចាំ ដោយសារការអនុវត្តសិទ្ធិលើការបញ្ចាំនោះ អ្នកដែលបង្កើតសិទ្ធិលើការបញ្ចាំនោះត្រូវមានសិទ្ធិទាមទារសំណងចំពោះកូនបំណុល (ដែលបានរួចផុតពីកាតព្វកិច្ចដោយមិនបានចេញចំណាយរបស់ ខ្លួន) ។ គោលបំណងនៃមាត្រានេះគឺដើម្បីការពារអ្នកដែលបង្កើតសិទ្ធិលើការបញ្ចាំឱ្យដូចជាអ្នកធានាដែរ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៣៥១ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ២ ការបញ្ចាំចលនវត្ថុ

**មាត្រា ៨២៩.–** ល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ មិនអាចតតាំងសិទ្ធិលើការបញ្ចាំនោះចំពោះតតិយ-ជនបានឡើយ ប្រសិនបើខ្លួនមិនបានកាន់កាប់ជានិរន្តរ៍នូវវត្ថុបញ្ចាំនោះ ។

(កំណត់)

មាត្រានេះចែងថា ម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវបន្តកាន់កាប់វត្ថុបញ្ចាំដើម្បីតតាំងសិទ្ធិលើការបញ្ចាំនោះ ចំពោះតតិយជន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៥២ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៨៣០.– ករណីដែលការកាន់កាប់ត្រូវបានដកយក

ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុត្រូវបានដកយកនូវការកាន់កាប់វត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះ អាចយកវត្ថុបញ្ចាំមកវិញបាន តាមរយៈបណ្តឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ តែប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះចែងថា ម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិធ្វើបណ្តឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ (បណ្តឹងទាមទារកាន់កាប់វិញ) ប្រសិនបើការកាន់កាប់វត្ថុបញ្ចាំត្រូវបានដកយក ហើយប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំ មិនអាចធ្វើបណ្តឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញទេ ម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចទាមទារឱ្យមានសិទ្ធិលើការបញ្ចាំនោះបានវិញឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៥៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៨៣១.– ការប្រើប្រាស់ និង អាស្រ័យផលពីវត្ថុបញ្ចាំ ដោយម្ចាស់សិទ្ធិលើការបញ្ចាំ

១-បើពុំមានការយល់ព្រមពីសំណាក់កូនបំណុលទេ ម្ចាស់សិទ្ធិលើការបញ្ចាំ មិនអាចប្រើប្រាស់ ឬ ជួលវត្ថុបញ្ចាំបានឡើយ ។ ប៉ុន្តែ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់បាន ត្រឹមតែកម្រិតដែលចាំបាច់ក្នុងការរក្សាវត្ថុបញ្ចាំនោះ ។

២-បើម្ចាស់សិទ្ធិលើការបញ្ចាំបានប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលអាចទាមទារឱ្យរំលត់សិទ្ធិលើការបញ្ចាំបាន ។

(កំណត់)

មាត្រានេះចែងថា ម្ចាស់សិទ្ធិលើការបញ្ចាំ មិនអាចប្រើប្រាស់ ឬ ជួលវត្ថុបញ្ចាំបានឡើយ បើពុំមានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៥០ នៃក្រមរដ្ឋប្បវេណីជប៉ុន (ការអនុវត្តដូចគ្នាផងដែរតាមមាត្រា ២៩៨), មាត្រា ១៣៣៤ (សិទ្ធិលើការបញ្ចាំចលនវត្ថុ : ការហាមឃាត់ការប្រើប្រាស់ដោយម្ចាស់សិទ្ធិលើការបញ្ចាំ) និង មាត្រា ១៣៣៦ (សិទ្ធិលើការបញ្ចាំចលនវត្ថុ : ការទាមទារឱ្យរំលត់សិទ្ធិលើការបញ្ចាំ) នៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជា, មាត្រា ៦៧ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច (សិទ្ធិលើការបញ្ចាំ : ការហាមឃាត់ការប្រើប្រាស់ និង ការអាស្រ័យផល) ។

**មាត្រា ៨៣២.-** ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប

១-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុមិនបានទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនទេ ម្ចាស់សិទ្ធិនោះអាចទាមទារទៅតុលាការឱ្យយកវត្ថុបញ្ចាំមកសងផ្ទាល់តែម្តង តាមការវាយតម្លៃរបស់អ្នកវាយតម្លៃបាន លុះត្រាតែមានមូលហេតុត្រឹមត្រូវ ។ ក្នុងករណីនេះ ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវជូនដំណឹងអំពីការទាមទារនោះទៅកូនបំណុលជាមុន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើចំនួនទឹកប្រាក់ដែលវាយតម្លៃដោយអ្នកវាយតម្លៃនោះ លើសពីចំនួននៃកាតព្វកិច្ចដែលត្រូវសងម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ ត្រូវសងនូវចំនួនទឹកប្រាក់ដែលនៅសល់ ទៅកម្មសិទ្ធិករនៃវត្ថុបញ្ចាំនោះវិញ ។

(កំណត់)

មាត្រានេះអនុញ្ញាតឱ្យមានការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប (ការបញ្ចាំផ្តាច់) ជំនួសឱ្យការអនុវត្តនីតិវិធីនៃការលក់ដោយបង្ខំ ។

កថាខណ្ឌទី ១ ចែងអំពីល័ក្ខខ័ណ្ឌយ៉ាងតឹងរ៉ឹង (មូលហេតុត្រឹមត្រូវ) និង នីតិវិធីតឹងរ៉ឹង (ការអនុញ្ញាតពីតុលាការ) ដោយអាស្រ័យហេតុផលថា ការអនុវត្តដោយសង្ខេបគឺជាករណីលើកលែង ។ ឧទាហរណ៍ ក្នុងករណីដែលមានម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគប្រត្យក្សដែលមានអាទិភាពជាងម្ចាស់សិទ្ធិលើការបញ្ចាំ នឹងត្រូវចាត់ទុកថា មិនមានមូលហេតុត្រឹមត្រូវទេ ។

កថាខណ្ឌទី ២ ចែងថា ប្រសិនបើមានភាពខុសគ្នារវាងតម្លៃនៃវត្ថុបញ្ចាំ និង ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល

ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ ត្រូវទទួលខុសត្រូវក្នុងការជម្រះបញ្ជីចំនួនទឹកប្រាក់ដែលខុសគ្នានោះ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣៤០ (សិទ្ធិលើការបញ្ចាំចលវត្ថុ : ការបញ្ចាំផ្តាច់ត្រូវបានអនុញ្ញាត ដោយមានកិច្ចព្រមព្រៀង) នៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជា ។

## មាត្រា ៨៣៣.- លំដាប់នៃសិទ្ធិលើការបញ្ចាំចលនវត្ថុ

ក្នុងករណីដែលបានបង្កើតសិទ្ធិលើការបញ្ចាំលើចលនវត្ថុតែមួយ ដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃសិទ្ធិលើការបញ្ចាំទាំងនោះត្រូវអនុលោមតាមពេលវេលាដែលបានបង្កើតនោះ ។

( កំណត់)

មាត្រានេះចែងអំពីលំដាប់នៃអាទិភាពនៃសិទ្ធិលើបំណុល ក្នុងករណីដែលសិទ្ធិលើការបញ្ចាំច្រើនត្រូវបានបង្កើតលើចលនវត្ថុតែមួយ ។ លំដាប់នៃសិទ្ធិលើការបញ្ចាំទាំងនោះ ត្រូវអនុលោមតាមពេលវេលាដែលបានបង្កើតសិទ្ធិលើការបញ្ចាំនោះ ។ ពាក្យថា "សិទ្ធិលើបំណុលច្រើន" មិនចាំបាច់មានន័យថា ត្រូវតែមានម្ចាស់បំណុលតែម្នាក់នោះទេ ដោយសារការកាន់កាប់តាមរយៈតំណាង (ការកាន់កាប់ដោយប្រយោល) ក៏ត្រូវបំពេញល័ក្ខខ័ណ្ឌសម្រាប់ម្ចាស់សិទ្ធិលើការបញ្ចាំដើម្បីបន្តកាន់កាប់ដែរ ។

បញ្ញត្តិនេះមិនត្រូវអនុវត្ត ចំពោះករណីដែលសិទ្ធិលើការបញ្ចាំមួយ ត្រូវបានបង្កើតឡើង ដើម្បីធានាសិទ្ធិលើបំណុលច្រើនទេ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៣៥៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

( កំណត់)

មាត្រាមួយចំនួនដែលមានក្នុងក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ប៉ុន្តែ មិនត្រូវបានយកមកចែងក្នុងក្រមរដ្ឋប្បវេណីថ្មីនេះ មាន :

**មាត្រា ១៣៣៩**

មាត្រានេះចែងថា ទោះបីជាសិទ្ធិលើបំណុលដែលត្រូវបានធានាបានរលត់ក៏ដោយ ក៏សិទ្ធិលើការបញ្ចាំចលនវត្ថុមិនត្រូវរលត់ឡើយ ប្រសិនបើមានសិទ្ធិលើបំណុលផ្សេងទៀតដែលអាចប្រមូលបាន ។ វាមានលក្ខណៈផ្ទុយគ្នា និង មិនត្រឹមត្រូវដែលចែងថា អានុភាពនៃសិទ្ធិលើការបញ្ចាំត្រូវមានលើសិទ្ធិលើបំណុលផ្សេងទៀត ដែលលើសពីទំហំនៃសិទ្ធិលើការបញ្ចាំ ពីព្រោះទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិលើការបញ្ចាំ ត្រូវបានកំណត់ ។

**មាត្រា ១៣៤១**

មាត្រានេះចែងថា ចំនួនទឹកប្រាក់សល់ពីប្រាក់ដែលបានមកពីការលក់វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើបញ្ចាំចលនវត្ថុ ក្រោយការសងទៅម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវប្រគល់ឱ្យកូនបំណុល ឬ ម្ចាស់បំណុលផ្សេងទៀត ហើយម្ចាស់បំណុលក្រៅពីម្ចាស់សិទ្ធិលើការបញ្ចាំត្រូវទទួលការសងស្មើគ្នា តាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួន ។ ខ្លឹមសារទាំងអស់នៃមាត្រានេះគឺជាការធម្មតា និង មិនចាំបាច់តម្រូវឱ្យចែងក្នុងបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីថ្មីនេះទេ ។

**មាត្រា ១៣៤២**

មាត្រានេះចែងថា ប្រសិនបើប្រាក់ដែលបានមកពីការលក់វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំចលនវត្ថុនោះ មិនគ្រប់គ្រាន់ដើម្បីសងចំនួនសរុបនៃកាតព្វកិច្ចទេ កូនបំណុលត្រូវសងកាតព្វកិច្ចដែលនៅសល់តទៅទៀត ។ ខ្លឹមសារទាំងអស់នៃមាត្រានេះគឺជាការធម្មតាផងដែរ ហេតុដូច្នេះ មិនចាំបាច់តម្រូវឱ្យមានចែងក្នុងបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីថ្មីនេះទេ ។

## ផ្នែកទី ៣ ការបញ្ចាំអចលនវត្ថុ

**មាត្រា ៨៣៤.–** សិទ្ធិប្រើប្រាស់ និង អាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

១-ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចប្រើប្រាស់ និង អាស្រ័យផលពីអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ តាមវិធីប្រើប្រាស់នៃអចលនវត្ថុនោះ ។

២-ចំពោះដីដែលសិទ្ធិលើការបញ្ចាំបានបង្កើតដើម្បីធានាសិទ្ធិលើបំណុលដែលគ្មានពេលកំណត់ ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំប្រើដីនោះដើម្បីធ្វើកសិកម្ម ទោះបីជាសិទ្ធិលើបំណុលរលត់ដោយការសងក៏ដោយ បើរដូវប្រមូលផលពីដំណាំដែលម្ចាស់សិទ្ធិបំណុលបានសាប ឬ ដាំពីមុន នឹងដល់ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក៏ម្ចាស់សិទ្ធិលើការបញ្ចាំ អាចប្រើដីនោះ រហូតដល់ពេលដល់រដូវប្រមូលផលនោះ ។

៣-ចំពោះដីដែលសិទ្ធិលើការបញ្ចាំបានបង្កើតដើម្បីធានាសិទ្ធិលើបំណុលដែលមានពេលកំណត់ ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំប្រើដីនោះដើម្បីធ្វើកសិកម្ម ទោះបីជាសិទ្ធិលើបំណុលរលត់ដោយការសងនៅមុនពេលកំណត់ក៏ដោយ បើរដូវប្រមូលផលពីដំណាំដែលម្ចាស់សិទ្ធិបំណុលបានសាប ឬ ដាំពីមុន នឹងដល់ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក៏ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើដីនោះ រហូតដល់ពេលដល់រដូវប្រមូលផលនោះ ។ ប៉ុន្តែ ទោះបីជារដូវប្រមូលផលនោះ នឹងដល់ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំក្រោយការសងនៅមុនពេលកំណត់ក៏ដោយ បើរដូវប្រមូលផលនោះ នឹងដល់ ក្រោយ

ពេលកំណត់នៃការសងកាតព្វកិច្ច ម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវប្រគល់ដីវិញភ្លាម ក្រោយពេលទទួលការសង ។

(កំណត់)

ជាគោលការណ៍ ម្ចាស់សិទ្ធិលើការបញ្ចាំពុំមានសិទ្ធិប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ប្រសិនបើគ្មានការយល់ព្រមពីកូនបំណុល ប៉ុន្តែ មាត្រានេះចែងថា ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចប្រើប្រាស់ និង អាស្រ័យផលពីអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ។ ពាក្យ "តាមវិធីប្រើប្រាស់នៃអចលនវត្ថុនោះ" រួមមានការជួលឱ្យតតិយជន ។ ការប្រើប្រាស់ និង អាស្រ័យផលដោយម្ចាស់សិទ្ធិលើការបញ្ចាំ អាចត្រូវបានចាត់ទុកថាជាតម្លៃថ្នូរនឹងការប្រាក់នៃសិទ្ធិលើបំណុល (សូមមើលមាត្រា ៨៣៦ (ការប្រាក់នៃសិទ្ធិលើបំណុល)) ។

ដោយសារម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចប្រើប្រាស់ និង អាស្រ័យផលបាន ជំនួសការទាមទារការប្រាក់នៃសិទ្ធិលើបំណុល ទោះបីជាក្រោយការសងក៏ដោយ ក៏ការផ្តល់សិទ្ធិឱ្យម្ចាស់បំណុលប្រើប្រាស់ និង អាស្រ័យផល រហូតដល់ការប្រមូលកសិផលពីដំណាំដែលម្ចាស់សិទ្ធិបំណុលបានសាប ឬ ដាំ សមស្របនឹងសមភាពដែរ ។ ហេតុដូច្នេះ មាត្រានេះត្រូវបានរៀបចំឡើងដោយផ្អែកលើទស្សនៈនេះ ។ ចំណែកឯថ្នាំជក់ និង រុក្ខជាតិប្រចាំឆ្នាំផ្សេងទៀតដែលអាចប្រមូលផលបានលើសពីមួយដងក្នុង ១ ឆ្នាំ ម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិប្រើប្រាស់ដីនេះរហូតដល់ ១ ឆ្នាំយ៉ាងយូរ ដោយអនុលោមតាមបញ្ញត្តិនេះ ។

បញ្ញត្តិនៃកថាខណ្ឌទី ២ កម្រិតការអនុវត្តចំពោះសិទ្ធិលើបំណុលដែលគ្មានពេលកំណត់ ។ ប្រសិនបើមានពេលកំណត់ សិទ្ធិលើបំណុលត្រូវបានសងតាមពេលកំណត់នេះ ហើយសិទ្ធិលើការបញ្ចាំត្រូវរលត់នៅពេលនោះ ហើយជាលទ្ធផល ម្ចាស់បំណុលគួរតែត្រៀមខ្លួនជាស្រេចដើម្បីប្រគល់ដីបញ្ចាំទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។ ផ្ទុយទៅវិញ ចំពោះសិទ្ធិលើបំណុលដែលមានពេលកំណត់ ប្រសិនបើកូនបំណុលសងមុនពេលកំណត់ ការបង្កើតឱ្យមានអានុភាពស្រដៀងគ្នានឹងកថាខណ្ឌទី ២ គឺជាការសមរម្យ ។ ហេតុដូច្នេះ កថាខណ្ឌទី ៣ ចែងអំពីខ្លឹមសារស្រដៀងគ្នានឹងកថាខណ្ឌទី ២ សម្រាប់សិទ្ធិលើបំណុលដែលមានពេលកំណត់ ។ ប៉ុន្តែ ក្នុងករណីនៃការសងមុនពេលកំណត់នេះ ប្រសិនបើអនុញ្ញាតឱ្យម្ចាស់សិទ្ធិលើការបញ្ចាំប្រើប្រាស់ដីបញ្ចាំ សូម្បីតែក្រោយពេលកំណត់សងដែលត្រូវបានកំណត់តាមពីដំបូង ការអនុញ្ញាតនេះមិនមានភាពត្រឹមត្រូវទេ ។ ហេតុដូច្នេះ វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ៣ នេះ ចែងថា ទោះបីជារដូវប្រមូលផលនោះ នឹងដល់នៅក្នុងអំឡុងពេល ១ ឆ្នាំ ក្រោយការសងនៅមុនពេលកំណត់ក៏ដោយ ប្រសិនបើរដូវប្រមូលផលនោះ នឹងដល់ ក្រោយពេលកំណត់នៃការសងកាតព្វកិច្ច សិទ្ធិលើការបញ្ចាំ ត្រូវរលត់នៅពេលសងកាតព្វកិច្ចមុនពេលកំណត់នោះ ហើយម្ចាស់សិទ្ធិលើការបញ្ចាំត្រូវប្រគល់ដីនោះវិញភ្លាម ។ ការចាត់ចែងបែបនេះក្នុងករណីនៃការសងកាតព្វកិច្ចមុនពេលកំណត់ នឹងបង្កើតឱ្យមានតុល្យភាពជាមួយនឹងករណីដែលសិទ្ធិលើបំណុលត្រូវបានសងតាមពេលកំណត់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៥៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៣៥.–** បន្ទុកសោហ៊ុយគ្រប់គ្រង

ម្ចាស់សិទ្ធិលើការបញ្ជាំអចលនវត្ថុត្រូវចេញសោហ៊ុយគ្រប់គ្រង និង ត្រូវទទួលបន្ទុកផ្សេងៗចំពោះអចលនវត្ថុនោះ ។

(កំណត់)

មាត្រានេះចែងថា ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុត្រូវទទួលបន្ទុកនូវសោហ៊ុយចំពោះអចលនវត្ថុ ដោយហេតុផលថា វាជាការសមហេតុសមផលដែលម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ ត្រូវចេញសោហ៊ុយ ព្រោះខ្លួនមានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលដែលកើតចេញពីអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះ ។ ប៉ុន្តែ មាត្រានេះមិនមានន័យថា ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវទទួលខុសត្រូវបង់ពន្ធដែលកម្មសិទ្ធិករនៃដីត្រូវទទួលបន្ទុក (ដូចជាពន្ធលើអចលនវត្ថុក្នុងប្រទេសជប៉ុន) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៥៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៣៦.–** ការប្រាក់នៃសិទ្ធិលើបំណុល

ម្ចាស់សិទ្ធិលើការបញ្ជាំអចលនវត្ថុ មិនអាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនបានទេ ។

(កំណត់)

មាត្រានេះចែងថា ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុមិនមានសិទ្ធិទាមទារការប្រាក់នៃសិទ្ធិលើបំណុលទេ ដោយសារខ្លួនអាចប្រើប្រាស់ និង អាស្រ័យផលដែលបានមកពីអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៥៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣៥៨ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា (ការប្រាក់មិនត្រូវកើតឡើងទេក្រោយការស្នើផ្តល់ការសងសិទ្ធិលើបំណុល) ។

**មាត្រា ៨៣៧.–** អានុភាពនៃការសន្យាពិសេស

បញ្ញត្តិនៃមាត្រា ៨៣៤ (សិទ្ធិប្រើប្រាស់ និង អាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ជាំ) មាត្រា ៨៣៥ (បន្ទុកសោហ៊ុយគ្រប់គ្រង) និង មាត្រា ៨៣៦ (ការប្រាក់នៃសិទ្ធិលើបំណុល) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការសន្យាពិសេសនៅក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ជាំ ។

(កំណត់)

គោលបំណងនៃមាត្រានេះអនុញ្ញាតឱ្យមានការធ្វើកិច្ចព្រមព្រៀងផ្សេងពីបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ទាក់ទងនឹងមាត្រាចំនួន ៣ ខាងលើ នៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ ។ ឧទាហរណ៍ ប្រសិនបើមានកិច្ចព្រមព្រៀងមួយដែលអនុញ្ញាតឱ្យម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ រួចផុតពីការចេញសោហ៊ុយគ្រប់គ្រង ឬ បន្ទុកផ្សេងទៀតទាក់ទងនឹងអចលនវត្ថុ បើទោះបីជាម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ មានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលពីអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំក៏ដោយ កិច្ចព្រមព្រៀងនោះត្រូវបានទទួលស្គាល់អានុភាព ហើយម្ចាស់បំណុល (ដែលជាម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ) មិនទទួលបន្ទុកនូវសោហ៊ុយនោះ (នៅពេលនេះ ជាលទ្ធផល កម្មសិទ្ធិករនៃដីត្រូវទទួលបន្ទុកនូវសោហ៊ុយ) ។ ម្យ៉ាងវិញទៀត ប្រសិនបើមានកិច្ចព្រមព្រៀងមួយដែលអនុញ្ញាតឱ្យម្ចាស់បំណុលទាមទារការប្រាក់នៃសិទ្ធិលើបំណុល ទោះបីជាម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ មានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលក៏ដោយ កិច្ចព្រមព្រៀងនោះត្រូវបានទទួលស្គាល់អានុភាព ហើយម្ចាស់បំណុល (ដែលជាម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ) អាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៥៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

## **មាត្រា ៨៣៨.–** អំឡុងពេលដែលមានអត្ថិភាព

១-អំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចលើសពី ៥ (ប្រាំ) ឆ្នាំបានឡើយ ។ ប្រសិនបើបានបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុលើសពីអំឡុងពេលនេះ អំឡុងពេលត្រូវបន្ថយមកត្រឹម ៥ (ប្រាំ) ឆ្នាំ ។

២-កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុអាចធ្វើបន្តទៀតបាន ។ ប៉ុន្តែអំឡុងពេលនៃការបន្តនេះមិនអាចធ្វើឱ្យលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលបន្តបានឡើយ ។

(កំណត់)

គោលបំណងសំខាន់នៃមាត្រានេះ គឺការកំណត់អំឡុងពេលនៃសិទ្ធិលើការបញ្ចាំដែលមានអំឡុងពេលយ៉ាងយូរ ៥ ឆ្នាំ ។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលធម្មតាមានអំឡុងពេល ៥ ឆ្នាំ (មាត្រា ៤៨២ (អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ)) ដូច្នេះ វាមិនទំនងទេដែលសិទ្ធិលើការបញ្ចាំនឹងរលត់មុនសិទ្ធិលើបំណុល ។ ក្នុងករណីដែលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវផ្អាក សិទ្ធិលើការបញ្ចាំអាចបន្តសាជាថ្មីបាន ដោយយោងតាមកថាខណ្ឌទី ២ ហេតុនេះហើយ ចំណុចនេះមិនមែនជាបញ្ហាអ្វីទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៦០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣៥០ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា (សិទ្ធិលើការបញ្ចាំ

អចលនវត្ថុ)

**មាត្រា ៨៣៩.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីហ៊ីប៉ូតែក

ក្រៅពីបញ្ញត្តិនៃផ្នែកទី ៣ (ការបញ្ចាំអចលនវត្ថុ) នេះ បញ្ញត្តិនៃជំពូកទី ៩ (ហ៊ីប៉ូតែក) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបញ្ចាំអចលនវត្ថុ ។

(កំណត់)

មាត្រានេះចែងថា បញ្ញត្តិពាក់ព័ន្ធនឹងហ៊ីប៉ូតែកត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិលើការបញ្ចាំអចលនវត្ថុ ។ ដើម្បីឱ្យជាក់ច្បាស់ថែមទៀតនោះ បញ្ញត្តិទាំងនោះរួមមានមាត្រា ៨៤៥ (ការតតាំងនៃហ៊ីប៉ូតែក) មាត្រា ៨៤៦ (ទំហំនៃអានុភាពហ៊ីប៉ូតែក) (មាត្រា ៣៧០ នៃក្រមរដ្ឋប្បវេណីជប៉ុន) មាត្រា ៨៥១ (លំដាប់នៃហ៊ីប៉ូតែក) (មាត្រា ៣៧៣ នៃក្រមរដ្ឋប្បវេណីជប៉ុន) និង មាត្រា ៨៥២ (ទំហំនៃសិទ្ធិលើបំណុលដែលត្រូវធានា) (មាត្រា ៣៧៤ នៃក្រមរដ្ឋប្បវេណីជប៉ុន) ជាអាទិ៍ ។ ចូរធ្វើការកត់ចំណាំជាពិសេសថា ជាលទ្ធផលនៃការអនុវត្តដូចគ្នាផងដែរនៃមាត្រា ៨៤៥ ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុមិនអាចយកសិទ្ធិលើការបញ្ចាំរបស់ខ្លួនមកតតាំងចំពោះតតិយជនបានឡើយ ប្រសិនបើមិនបានធ្វើកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ ដោយលិខិតយថាភូត និង មិនបានចុះបញ្ជីអំពីការបង្កើតសិទ្ធិបញ្ចាំនោះ ដូចករណីនៃហ៊ីប៉ូតែកដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៦១ នៃក្រមរដ្ឋប្បវេណីជប៉ុន

(កំណត់)

មាត្រាមួយចំនួនដែលមានក្នុងក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ប៉ុន្តែ មិនត្រូវបានយកមកចែងក្នុងក្រមរដ្ឋប្បវេណីថ្មីនេះ មាន :

**មាត្រា ១៣៤៦**

មាត្រានេះចែងថា សិទ្ធិលើការបញ្ចាំអចលនវត្ថុមិនត្រូវមានអានុភាព និង មិនអាចតតាំងចំពោះតតិយជនបានឡើយ ប្រសិនបើមិនត្រូវបានជូនដំណឹងជាសាធារណៈតាមរយៈការចុះបញ្ជីអចលនវត្ថុ ហើយប្រសិនបើគ្មានការចុះបញ្ជីទេ សិទ្ធិប្រាតិភោគប្រត្យក្សក៏គ្មានដែរ ហេតុដូច្នេះ ម្ចាស់បំណុលគ្រាន់តែអាចទាមទារឱ្យអនុវត្តការសងបំណុលប៉ុណ្ណោះ ។ ក្នុងក្រមនេះ បញ្ញត្តិទាក់ទងនឹងហ៊ីប៉ូតែក ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិលើការបញ្ចាំអចលនវត្ថុ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៨៣៩ ហើយសិទ្ធិលើការបញ្ចាំអចលនវត្ថុទាំងនេះ ត្រូវបានចាត់ទុកដូចគ្នានឹងហ៊ីប៉ូតែកដែរ (មានន័យថា ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចយកសិទ្ធិលើការបញ្ចាំរបស់ខ្លួនមកតតាំងចំពោះតតិយជន ប្រសិនបើមិនបានធ្វើកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ ដោយលិខិតយថាភូត និង មិនបានចុះបញ្ជីអំពីការបង្កើតសិទ្ធិលើការបញ្ចាំនោះ) ។ ដូច្នេះ បញ្ញត្តិនេះមិនចាំបាច់ទេ ។

**មាត្រា ១៣៨៧**

មាត្រានេះចែងថា សិទ្ធិលើការបញ្ចាំអចលនវត្ថុតែមួយអាចត្រូវបានបង្កើតដោយចំពោះម្ចាស់បំណុលតែម្នាក់ (ឬម្ចាស់បំណុលដោយសាមគ្គីភាពច្រើននាក់) ប៉ុណ្ណោះ ។ ប៉ុន្តែ ក្រមរដ្ឋប្បវេណីនេះអនុញ្ញាតឱ្យបង្កើតហ៊ីប៉ូតែកច្រើនលើអចលនវត្ថុតែមួយ ហើយបញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះសិទ្ធិលើការបញ្ចាំអចលនវត្ថុ ហេតុដូច្នេះបញ្ញត្តិនៃមាត្រានេះមិនចាំបាច់ទេ ។

**មាត្រា ១៣៨៨**

មាត្រានេះចែងថា អ្នកបង្កើតសិទ្ធិលើការបញ្ចាំងចលនវត្ថុគ្រាន់តែត្រូវប្រគល់ប័ណ្ណនៃអចលនវត្ថុ ដោយមិនចាំបាច់ប្រគល់អចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ (ការប្រគល់វត្ថុតាមការសន្មត) ។ ប៉ុន្តែ ក្រមរដ្ឋប្បវេណីថ្មីយកការប្រគល់ការកាន់កាប់លើវត្ថុបញ្ចាំ មកធ្វើជាល័ក្ខខ័ណ្ឌនៃការបង្កើតសិទ្ធិលើការបញ្ចាំ ហើយសិទ្ធិប្រាតិភោគដែលការកាន់កាប់វត្ថុមិនត្រូវបានផ្ទេរ ត្រូវបានចាត់ចែងជាហ៊ីប៉ូតែក (មានន័យថា ក្រមរដ្ឋប្បវេណីថ្មីនេះមិនអនុញ្ញាតឱ្យមានសិទ្ធិលើការបញ្ចាំដោយមិនប្រគល់ការកាន់កាប់ទេ) ។ ដូច្នេះ បញ្ញត្តិនេះមិនចាំបាច់ទេ ។

**មាត្រា ១៣៨៩**

មាត្រានេះចែងថា កិច្ចសន្យាបញ្ចាំអចលនវត្ថុត្រូវតែបញ្ជាក់ឱ្យច្បាស់ថា តើជាការប្រគល់វត្ថុបញ្ចាំពិតប្រាកដ ឬជាការប្រគល់វត្ថុតាមការសន្មត ។ ដូចដែលបានបញ្ជាក់ខាងលើហើយ ការបង្កើតសិទ្ធិលើការបញ្ចាំដោយការប្រគល់វត្ថុតាមការសន្មតមិនត្រូវបានអនុញ្ញាតឡើយ ហេតុដូច្នេះ បញ្ញត្តិនេះមិនចាំបាច់ទេ ។

**មាត្រា ១៣៩០**

មាត្រានេះចែងថា ក្នុងករណីដែលអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ត្រូវបានប្រគល់យ៉ាងជាក់លាក់ទៅឱ្យម្ចាស់បំណុល ប្រសិនបើសិទ្ធិលើបំណុលត្រូវបានសងរួចហើយ ម្ចាស់បំណុលត្រូវប្រគល់វត្ថុបញ្ចាំទៅឱ្យកូនបំណុលវិញ ។ ប្រសិនបើសិទ្ធិលើបំណុលទាំងអស់ត្រូវបានសងរួចហើយ សិទ្ធិលើបំណុលត្រូវរលត់ ហើយសិទ្ធិលើការបញ្ចាំក៏ត្រូវរលត់ដែរ ។ ហេតុដូច្នេះហើយ ម្ចាស់បំណុលត្រូវប្រគល់វត្ថុបញ្ចាំទៅឱ្យកូនបំណុលវិញ ។ នេះគឺជាការធម្មតាទេ ហើយមិនតម្រូវឱ្យមានបញ្ញត្តិពិសេសឡើយ ។ ប៉ុន្តែ មានការចែងអំពីបញ្ញត្តិលើកលែង (មាត្រា ៨៣៤) ។

**មាត្រា ១៣៩១**

មាត្រានេះចែងថា ក្នុងករណីដែលអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ត្រូវបានប្រគល់តាមការសន្មត កូនបំណុលមិនត្រូវបានលើកលែងឱ្យរួចពីកាតព្វកិច្ចទេ លើកលែងតែបានសងសិទ្ធិលើបំណុលសិន ។ មាត្រានេះមិនចាំបាច់ទេពីព្រោះការបង្កើតសិទ្ធិលើការបញ្ចាំតាមរយៈការប្រគល់វត្ថុតាមការសន្មតមិនត្រូវបានអនុញ្ញាតឡើយ ។

**មាត្រា ១៣៩៣**

មាត្រានេះចែងថា ម្ចាស់បំណុលត្រូវបំពេញតាមទម្រង់បែបបទ (ការបញ្ជាក់ ជាអាទិ៍) ដូចមានចែងនៅក្នុងមាត្រា ១៣៨៥ (ការបង្កើតសិទ្ធិលើការបញ្ចាំ) នៅពេលធ្វើលទ្ធកម្មតាមរយៈការទិញអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ។

ក្នុងករណីបែបនេះ ការអនុវត្តតាមទម្រង់បែបបទនៃកិច្ចសន្យាលក់ គឺជាការធម្មតាទេ ។ ហេតុដូច្នេះ វាគ្រប់គ្រាន់ហើយដែលចែងអំពីទម្រង់បែបបទតែនៅក្នុងបញ្ញត្តិទាក់ទងនឹងការលក់ទិញប៉ុណ្ណោះ ។

**មាត្រា ១៣៥៥**

មាត្រានេះចែងថា ម្ចាស់បំណុលត្រូវប្រគល់អចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ និង ទទួលខុសត្រូវចំពោះការខូចខាតដែលបណ្ដាលមកពីកំហុស នៅពេលសិទ្ធិលើបំណុលបានរលត់ ។ ចំណុចនេះជាការធម្មតា និង មិនតម្រូវឱ្យមានបញ្ញត្តិចែងឱ្យច្បាស់ទេ ។

**មាត្រា ១៣៥៩**

មាត្រានេះចែងថា កូនបំណុលត្រូវទទួលខុសត្រូវក្នុងការបង់ពន្ធ ។ ចំណុចនេះជាការធម្មតា និង មិនតម្រូវឱ្យមានបញ្ញត្តិចែងឱ្យច្បាស់ទេ ពីព្រោះកូនបំណុលដែលបង្កើតសិទ្ធិលើការបញ្ចាំ គឺជាកម្មសិទ្ធិករនៃអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ។

**មាត្រា ១៣៦០**

មាត្រានេះចែងថា ម្ចាស់បំណុលមិនអាចបដិសេធការប្រគល់អចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ដោយយកលេសថា កូនបំណុលមានកាតព្វកិច្ចផ្សេងទៀតក្រៅពីកាតព្វកិច្ចដែលត្រូវបានធានា ។ ចំណុចនេះជាការធម្មតា និង មិនតម្រូវឱ្យមានបញ្ញត្តិចែងឱ្យច្បាស់ទេ ពីព្រោះតែសិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនធានាកាតព្វកិច្ចក្រៅពីកាតព្វកិច្ចដែលត្រូវបានធានាឡើយ ។

**មាត្រា ១៣៦១**

មាត្រានេះចែងថា កូនបំណុលមានសិទ្ធិទាមទារពីទាយាទនៃម្ចាស់បំណុល ចំពោះសិទ្ធិដែលខ្លួនមានលើម្ចាស់បំណុល ។ ខ្លឹមសារនៃបញ្ញត្តិនេះគួរត្រូវបញ្ចូលទៅក្នុងបញ្ញត្តិស្ដីពីសន្តតិកម្ម ហើយមិនចាំបាច់ចែងនៅទីនេះទេ ។

**មាត្រា ១៣៦២**

មាត្រានេះចែងថា ទាយាទ និង សមាជិកនៃគ្រួសារ (ក្រុមគ្រួសារ) របស់កូនបំណុលអាចអនុវត្តសិទ្ធិដូចគ្នានឹងសិទ្ធិរបស់កូនបំណុល ។ ខ្លឹមសារនៃបញ្ញត្តិនេះគួរត្រូវបញ្ចូលទៅក្នុងបញ្ញត្តិស្ដីពីសន្តតិកម្ម ហើយមិនចាំបាច់ចែងនៅទីនេះទេ ។

## ផ្នែកទី ៤ ការបញ្ចាំសិទ្ធិ

**មាត្រា ៨៤០.–** កម្មវត្ថុនៃការបញ្ចាំសិទ្ធិ

១-សិទ្ធិលើការបញ្ចាំអាចមានកម្មវត្ថុជាសិទ្ធិលើទ្រព្យសម្បត្តិបាន ។

២-ក្រៅពីបញ្ញត្តិនៃផ្នែកទី ៤ (ការបញ្ចាំសិទ្ធិ) នេះ បញ្ញត្តិនៃផ្នែកទី ២ (ការបញ្ចាំចលនវត្ថុ) និង ផ្នែកទី ៣ (ការបញ្ចាំអចលនវត្ថុ) ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះសិទ្ធិលើការបញ្ចាំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

មាត្រានេះចែងថា សិទ្ធិលើការបញ្ចាំអាចបង្កើតបានមិនត្រឹមតែលើវត្ថុប៉ុណ្ណោះទេ ថែមទាំងលើសិទ្ធិលើទ្រព្យសម្បត្តិដូចជាសិទ្ធិលើបំណុលបានដែរ ។ ក្រៅពីសិទ្ធិលើបំណុល សិទ្ធិអ្នកនិពន្ធ និង កម្មសិទ្ធិបញ្ញាផ្សេងទៀត អាចត្រូវបានយកមកពិចារណាសម្រាប់ការបញ្ចាំសិទ្ធិ ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង សិទ្ធិលើបំណុលត្រូវបានយកមកធ្វើជាកម្មវត្ថុនៃការបញ្ចាំសិទ្ធិ ស្ទើរតែគ្រប់ករណីទាំងអស់ ។ បទប្បញ្ញត្តិបន្តបន្ទាប់នេះទាក់ទងតែសិទ្ធិលើបំណុលប៉ុណ្ណោះ ។

សិទ្ធិលើការបញ្ចាំសិទ្ធិលើបំណុលមានលក្ខណៈរួមច្រើនដូចគ្នានឹងអនុប្បទានសិទ្ធិលើបំណុល ដូច្នេះ បញ្ញត្តិស្តីពីសិទ្ធិលើការបញ្ចាំសិទ្ធិលើបំណុលនេះ ត្រូវស្របគ្នានឹងបញ្ញត្តិទាក់ទងនឹងអនុប្បទានសិទ្ធិលើបំណុលដែរ ។

ជាក់ស្តែង មានបញ្ញត្តិទាក់ទងនឹងល័ក្ខខ័ណ្ឌសម្រាប់ការតតាំង ក្នុងករណីសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ (សិទ្ធិលើបំណុលធម្មតាដែលកំណត់ម្ចាស់បំណុលជាក់លាក់) ។ ក្រមរដ្ឋប្បវេណីជប៉ុន មានបញ្ញត្តិទាក់ទងនឹងសិទ្ធិបំណុលដែលកំណត់ការបញ្ជា (សិទ្ធិលើបំណុលដែលម្ចាស់បំណុលត្រូវបានកំណត់ ដោយបុគ្គលជាក់លាក់ណាម្នាក់ ឬ ដោយអនុលោមតាមការបញ្ជារបស់បុគ្គលនោះ) ជាអាទិ៍ ដែរ (ឧ. មាត្រា ៣៦០) ។ ប៉ុន្តែ ចំពោះសិទ្ធិលើបំណុលដែលកំណត់ការបញ្ជានេះ មិនបានចែងក្នុងក្រមរដ្ឋប្បវេណីនេះទេ ពីព្រោះបញ្ញត្តិទាំងនេះ គួរតែស្ថិតនៅក្នុងច្បាប់ទាក់ទាងនឹងឧបករណ៍អាចជួញដូរបាន ។ បញ្ញត្តិទាំងនេះគួរត្រូវចែងក្នុងច្បាប់ផ្សេងទៀតនៅពេលអនាគត ក្រៅពីក្រមរដ្ឋប្បវេណី ជាពិសេសចំពោះភាគហ៊ុន ប័ណ្ណបំណុលនៃសហគ្រាស រូបិយាណត្តិ ប័ណ្ណសងតាមបញ្ជា និង មូលប្បទានប័ត្រ ជាដើម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៦២ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៤១.-** ល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ

១-ក្នុងករណីដែលយកសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ មកធ្វើជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ សិទ្ធិលើការបញ្ចាំនេះ មិនអាចតតាំងចំពោះកូនបំណុលទី ៣ និងតតិយជនផ្សេងទៀតបានឡើយ លើកលែងតែករណីដែលបានជូនដំណឹងអំពីការបង្កើតសិទ្ធិលើការបញ្ចាំដល់កូនបំណុលទី ៣ ឬ មានការយល់ព្រមពីកូនបំណុលទី ៣ នោះ ។

២-ការជូនដំណឹង ឬ ការយល់ព្រមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចតតាំងចំពោះតតិយជន ក្រៅពីកូនបំណុលទី ៣ បានឡើយ ប្រសិនបើមិនបានធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្លាពរ ។

(កំណត់)

មាត្រានេះយកការជូនដំណឹងដល់កូនបំណុលទី ៣ ឬ ការយល់ព្រមរបស់កូនបំណុលទី ៣ មកធ្វើជាល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ (សិទ្ធិលើបំណុលធម្មតាដែលកំណត់ម្ចាស់បំណុលជាក់លាក់) ។ ខ្លឹមសារនៃមាត្រានេះដូចគ្នានឹងបញ្ញត្តិស្តីពីល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែរ ។

ពាក្យ "លិខិតដែលមានកាលបរិច្ឆេទស្ថាពរ" មានន័យថា លិខិតបញ្ជាក់ដែលចេញដោយស្ថាប័នរដ្ឋ សារការី ជាអាទិ៍ ដែលនៅលើលិខិតនោះ កាលបរិច្ឆេទដែលធ្វើលិខិតនោះ ត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់ ។ នៅប្រទេសជប៉ុន មានឧទាហរណ៍ដូចជាលិខិតយថាភូត សំបុត្រអនុសិទ្ធិដែលបញ្ជាក់អំពីខ្លឹមសារ ជាអាទិ៍ ។ ចំពោះនិយមន័យកាលបរិច្ឆេទស្ថាពរ និង លិខិតយថាភូត សូមមើលច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ១ នៃមាត្រា ៣៦៤ នៃក្រមរដ្ឋប្បវេណីជប៉ុន (ដែលយកបញ្ញត្តិនៃមាត្រា ៤៦៧ ស្តីពីអនុប្បទាននៃសិទ្ធិលើបំណុលមកធ្វើជាមូលដ្ឋាន)

**មាត្រា ៨៤២.-** ការអនុវត្តសិទ្ធិលើការបញ្ចាំដោយប្រមូលសិទ្ធិលើបំណុល

១-ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រមូលសិទ្ធិលើបំណុលដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំបាន ។

២-ប្រសិនបើកម្មវត្ថុនៃសិទ្ធិលើបំណុលជាប្រាក់ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រមូលសិទ្ធិលើបំណុល ត្រឹមតែភាគដែលស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនប៉ុណ្ណោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើកំណត់ពេលត្រូវសងនៃសិទ្ធិលើបំណុលបានមកដល់ មុនកំណត់ពេលត្រូវសងនៃសិទ្ធិលើបំណុលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនេះ អាចឱ្យកូនបំណុលទី ៣ តម្កល់ប្រាក់សងនេះបាន ។ ក្នុងករណីនេះ សិទ្ធិលើការបញ្ចាំមានអត្ថិភាពលើប្រាក់តម្កល់នោះ ។

៤-ប្រសិនបើកម្មវត្ថុនៃសិទ្ធិលើបំណុលមិនមែនជាប្រាក់ទេ ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិលើការបញ្ចាំលើវត្ថុដែលខ្លួនបានទទួលជាការសង ។

(កំណត់)

មាត្រានេះចែងអំពីការអនុវត្តសិទ្ធិលើការបញ្ចាំសិទ្ធិលើបំណុល ។ មានន័យថា ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រមូលសិទ្ធិលើបំណុលដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំបាន ហើយសិទ្ធិលើការបញ្ចាំនោះ មានអត្ថិភាពលើប្រាក់ ឬ វត្ថុដែលត្រូវបានប្រមូល ។

កថាខណ្ឌទី ៣ ត្រូវបានរៀបចំឡើង ដោយយកការរៀបចំប្រព័ន្ធតម្កល់មកធ្វើជាបុរេល័ក្ខខ័ណ្ឌ ។ បញ្ញត្តិស្តីពីការ

តម្កល់ត្រូវបានបញ្ចូលនៅផ្នែកទាក់ទងនឹងការសង (មាត្រា ៤៥៧ (ការតម្កល់)) ហើយច្បាប់ និង បទដ្ឋានផ្សេងទាក់ទងនឹងនីតិវិធីនៃការតម្កល់ នឹងត្រូវបានបង្កើតឡើង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៦៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

# ជំពូកទី ៥ ហ៊ីប៉ូតែក

## ផ្នែកទី ១ អត្ថន័យនៃហ៊ីប៉ូតែក

**មាត្រា ៨៤៣.-** អត្ថន័យនៃហ៊ីប៉ូតែក

១-ម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ចំពោះអចលនវត្ថុដែលបានដាក់ជាប្រាតិភោគនៃកាតព្វកិច្ច ដោយកូនបំណុល ឬ តតិយជនមិនផ្ទេរការកាន់កាប់ ។

២-សិទ្ធិជួលអចិន្ត្រៃយ៍ និង ផលុបភោគ ក៏អាចយកមកធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែកបានដែរ ។ ក្នុងករណីនេះ បញ្ញត្តិនៃជំពូកទី ៥ (ហ៊ីប៉ូតែក) នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

៣-ក្នុងករណីដែលច្បាប់ពិសេសទទួលស្គាល់ការយកទ្រព្យសម្បត្តិផ្សេងក្រៅពីអចលនវត្ថុ មកធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែក បញ្ញត្តិនៃច្បាប់ពិសេសនោះត្រូវយកមកអនុវត្ត ។

(កំណត់)

កថាខណ្ឌទី ១ ដែលចែងអំពីនិយមន័យនៃហ៊ីប៉ូតែក បញ្ជាក់ថា កម្មវត្ថុនៃហ៊ីប៉ូតែកគឺជាអចលនវត្ថុ (មានន័យថា កម្មសិទ្ធិលើអចលនវត្ថុ) ។ ក្រមរដ្ឋប្បវេណីនេះមិនបានចាត់ទុកអាគារជាអចលនវត្ថុឯករាជ្យពីដីទេ (មាត្រា ១២២ (សមាសភាគនៃដី : គោលការណ៍) ហេតុដូច្នេះ ប្រសិនបើហ៊ីប៉ូតែកត្រូវបានបង្កើតលើដីមួយហើយ ជាគោលការណ៍ហ៊ីប៉ូតែកនោះត្រូវមានអានុភាពលើអាគារដែលមាននៅលើដីហ៊ីប៉ូតែក (សូមមើលមាត្រា ៨៤៦ (ទំហំនៃអានុភាពហ៊ីប៉ូតែក)) ។

កថាខណ្ឌទី ២ ចែងថា ហ៊ីប៉ូតែកអាចត្រូវបានបង្កើតមិនត្រឹមតែលើកម្មសិទ្ធិលើអចលនវត្ថុប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងលើសិទ្ធិជួលអចិន្ត្រៃយ៍ និង ផលុបភោគបានផងដែរ ដែលជាសិទ្ធិប្រើប្រាស់ដីដែលសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគត្រូវបានបង្កើត ។ ក្រមរដ្ឋប្បវេណីអនុញ្ញាតឱ្យមានកម្មសិទ្ធិលើអាគារ លើដីដែលជាកម្មសិទ្ធិរបស់អ្នកដទៃ តាមរយៈសិទ្ធិជួលអចិន្ត្រៃយ៍ (ដោយផ្អែកលើចំណុចនេះ មាត្រា ១២៣ (សមាសភាគនៃដី : ករណីលើកលែង) ចែងថា ក្នុងករណីដែល

ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍មានកម្មសិទ្ធិលើអាគារលើដីដែលត្រូវបានជួលអចិន្ត្រៃយ៍ អាគារនេះមិនត្រូវក្លាយ ជាសមាសភាគនៃដីឡើយ) ។ ក្នុងករណីដែលហ៊ីប៉ូតែកត្រូវបានបង្កើតលើសិទ្ធិជួលអចិន្ត្រៃយ៍ដែលជាសិទ្ធិប្រើប្រាស់ដី ហ៊ីប៉ូតែកនោះនឹងមានអានុភាពលើអាគារផងដែរ (សូមមើលមាត្រា ៨៤៦ (ទំហំនៃអានុភាពហ៊ីប៉ូតែក)) ។

កថាខណ្ឌទី ៣ ទទួលស្គាល់លទ្ធភាពនៃការបង្កើតឱ្យមានប្រព័ន្ធមួយតាមរយៈច្បាប់ពិសេសក្រៅពីក្រមរដ្ឋប្បវេណី ដែលអនុញ្ញាតឱ្យបង្កើតហ៊ីប៉ូតែកលើទ្រព្យសម្បត្តិផ្សេងក្រៅពីអចលនវត្ថុ (ឧទាហរណ៍ដូចជា រថយន្ត និង នាវា ជាអាទិ៍ ដែលមានប្រព័ន្ធចុះបញ្ជី) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៦៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ២ ការបង្កើតហ៊ីប៉ូតែក

### មាត្រា ៨៤៤.- ការបង្កើតហ៊ីប៉ូតែក

ហ៊ីប៉ូតែកនឹងត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និងកូនបំណុល ឬ តតិយជនដែលយកអចលនវត្ថុរបស់ខ្លួនមកដាក់ជាប្រាតិភោគ ។

(កំណត់)

មាត្រានេះ និង មាត្រាបន្ទាប់ចែងថា ហ៊ីប៉ូតែកនឹងត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងគ្នារវាងភាគីដែលពាក់ព័ន្ធ (គោលការណ៍នៃការបង្កើតដោយការព្រមព្រៀង) ប៉ុន្តែ មិនអាចយកមកតតាំងចំពោះតតិយជនបានឡើយ ប្រសិនបើមិនបានធ្វើកិច្ចសន្យាបង្កើតដោយលិខិតយថាភូត និងមិនបានចុះបញ្ជី ។ ចំពោះការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង ដូចជាការលក់ទិញ កម្មសិទ្ធិនោះនឹងមិនត្រូវបានផ្ទេរទេ ប្រសិនបើមិនបានចុះបញ្ជី ហេតុនេះហើយ ការចុះបញ្ជី គឺជាល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិ (មាត្រា ១៣៥ (ល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង)) ។ ប៉ុន្តែ ចំពោះការបង្កើតហ៊ីប៉ូតែកវិញ ការចុះបញ្ជី គឺជាល័ក្ខខ័ណ្ឌតតាំង ។

### មាត្រា ៨៤៥.- ការតតាំងនៃហ៊ីប៉ូតែក

ម្ចាស់បំណុលហ៊ីប៉ូតែកមិនអាចយកហ៊ីប៉ូតែកនោះមកតតាំងចំពោះតតិយជន ក្រៅពីអ្នកដែលបង្កើតហ៊ីប៉ូតែកបានឡើយ ប្រសិនបើមិនបានធ្វើកិច្ចសន្យាបង្កើតហ៊ីប៉ូតែកនោះដោយលិខិតយថាភូត និង មិនបានចុះបញ្ជីនៅក្នុងសៀវភៅបញ្ជីដីធ្លីទេ ។

(កំណត់)

កិច្ចសន្យាបង្កើតហ៊ីប៉ូតែក ត្រូវបង្កើតឡើងដោយកិច្ចព្រមព្រៀងរវាងអ្នកបង្កើតហ៊ីប៉ូតែក (ជាធម្មតា កូនបំណុល) និង ម្ចាស់បំណុល ។ ប៉ុន្តែ មាត្រានេះចែងថា ម្ចាស់បំណុលហ៊ីប៉ូតែកមិនអាចយកហ៊ីប៉ូតែកនោះមកតតាំងចំពោះតតិយជន ក្រៅពីកូនបំណុល និង អ្នកបង្កើតហ៊ីប៉ូតែកបានឡើយ ប្រសិនបើមិនបានធ្វើកិច្ចសន្យាបង្កើតហ៊ីប៉ូតែកជាទម្រង់នៃលិខិតយថាភូត និង មិនបានចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែកនោះនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីទេ ។ នីតិវិធីនៃការចុះបញ្ជីជាក់លាក់ មានចែងនៅក្នុងច្បាប់ពិសេស (ឧទាហរណ៍ ច្បាប់ភូមិបាល) ហើយច្បាប់ពិសេសនោះអាចចែងថា ចាំបាច់ដាក់លិខិតកិច្ចសន្យាបង្កើតហ៊ីប៉ូតែកដែលត្រូវបានធ្វើឡើងជាទម្រង់លិខិតយថាភូត ដើម្បីចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ។ សូមមើលសេចក្តីកំណត់នៃមាត្រា ៨៤៤ (ការបង្កើតហ៊ីប៉ូតែក) ។

## ផ្នែកទី ៣ អានុភាពនៃហ៊ីប៉ូតែក

### មាត្រា ៨៤៦.- ទំហំនៃអានុភាពហ៊ីប៉ូតែក

១-ហ៊ីប៉ូតែកមានអានុភាពលើវត្ថុដែលភ្ជាប់នឹងដីដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក និង ជាផ្នែកមួយនៃដីដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកនោះ នៅពេលបង្កើតហ៊ីប៉ូតែក រួមទាំងអាគារដែលមាននៅលើដីហ៊ីប៉ូតែកនោះ ។ អានុភាពនេះក៏មានលើវត្ថុ ដែលត្រូវបានភ្ជាប់នៅក្រោយពេលបង្កើតហ៊ីប៉ូតែកផងដែរ ។

២-ភាគីពុំអាចកំណត់ផ្សេងពីបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ នៅក្នុងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកបានឡើយ ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះ បញ្ជាក់យ៉ាងច្បាស់អំពីទំហំនៃអានុភាពហ៊ីប៉ូតែកដែលត្រូវបានបង្កើតឡើងលើដី ។ ពាក្យ "ហ៊ីប៉ូតែកមានអានុភាព" នៅក្នុងកថាខណ្ឌទី ១ នេះ មានន័យថា បញ្ជាក់អំពីទំហំនៃទឹកប្រាក់ដែលម្ចាស់បំណុលហ៊ីប៉ូតែកអាចទទួលការសងបានដោយមានអាទិភាព ពីប្រាក់ដែលបានមកពីការលក់ ក្នុងករណីដែលកូនបំណុលមិនបានសងបំណុល ហើយហ៊ីប៉ូតែកនឹងត្រូវបានអនុវត្ត តាមនីតិវិធីនៃការលក់ដោយបង្ខំ (រួមទាំងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកចូលរួមក្នុងការចែកចំណែក តាមនីតិវិធីនៃការលក់ដោយបង្ខំដែលត្រូវបានចាប់ផ្តើមតាមពាក្យសុំរបស់តតិយជន) ។ ប៉ុន្តែ អ្នកបង្កើតហ៊ីប៉ូតែក មានសិទ្ធិប្រើប្រាស់ និង អាស្រ័យផល ពីអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកនោះ ហេតុដូច្នេះ អ្នកនោះអាចសង់សំណង់អាគារ ឬ ដាំដំណាំ ជាអាទិ៍ ដោយសេរីបាន ក្នុងទំហំនៃសិទ្ធិប្រើប្រាស់ និង អាស្រ័យផលរបស់ខ្លួន ។ ក្នុងករណីនេះ បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ នេះចែងយ៉ាងច្បាស់ថា ហ៊ីប៉ូតែកត្រូវមានអានុភាពលើសំណង់អាគារដែលបានភ្ជាប់នឹងដី និង ដើមឈើដែលបានដាំលើដី ជាអាទិ៍ ក្រោយពេលបង្កើតហ៊ីប៉ូតែកផងដែរ ។ ប៉ុន្តែ អ្នកបង្កើតហ៊ីប៉ូតែក (ជាធម្មតា កម្មសិទ្ធិករនៃដី) មានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលពីអចលនវត្ថុដែលជាកម្មវត្ថុ

នៃហ៊ីប៉ូតែកនោះ ហេតុដូច្នេះ អ្នកបង្កើតហ៊ីប៉ូតែក អាចរុះរើសំណង់អាគារដែលបានភ្ជាប់នឹងដី ដើមឈើដែលបានដាំលើដីជាអាទិ៍ ហើយប្រមូលផលដំណាំបាន ដោយផ្អែកលើសិទ្ធិរបស់ខ្លួន ។

កថាខណ្ឌទី ២ ចែងថា ភាគីដែលពាក់ព័ន្ធមិនអាចកំណត់អំពីទំហំដែលហ៊ីប៉ូតែកមានអានុភាពផ្សេងពីបញ្ញត្តិនៃកថាខណ្ឌទី ១ ដោយការព្រមព្រៀងបានឡើយ ។ ក្រមរដ្ឋប្បវេណីជប៉ុនបានចាត់ទុកដី និង អាគារគឺជាអចលនវត្ថុផ្សេងគ្នា និង ឯករាជ្យពីគ្នា (មានន័យថា ហ៊ីប៉ូតែកលើដី និង ហ៊ីប៉ូតែកលើអាគារ គឺជាហ៊ីប៉ូតែកខុសគ្នា ដូច្នេះ ហ៊ីប៉ូតែកដែលបានបង្កើតលើដី មិនមានអានុភាពលើអាគារ ហើយហ៊ីប៉ូតែកលើអាគារ ក៏គ្មានអានុភាពលើដីដែរ) ហើយអនុញ្ញាតឱ្យភាគីអាចកំណត់ទំហំនៃអានុភាពហ៊ីប៉ូតែកតាមការព្រមព្រៀងបានផងដែរ ។ ប៉ុន្តែ ដើម្បីជៀសវាងភាពស្មុគស្មាញក្នុងទំនាក់ទំនងនៃសិទ្ធិ និង ករណីយកិច្ចរវាងភាគី ក្រមរដ្ឋប្បវេណីកម្ពុជានេះមិនទទួលស្គាល់ការព្រមព្រៀងបែបនេះរវាងភាគីទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៧០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៤៧.–** អានុភាពនៃហ៊ីប៉ូតែកលើដីចំពោះអាគារដែលជាកម្មសិទ្ធិរបស់តតិយជន

ក្នុងករណីដែលតតិយជនមានកម្មសិទ្ធិលើអាគារនៅលើដីដែលបានដាក់ជាហ៊ីប៉ូតែក ដោយផ្អែកលើសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬ សិទ្ធិជួល ហ៊ីប៉ូតែកនេះពុំមានអានុភាពលើអាគារនោះឡើយ ។

(កំណត់)

មាត្រានេះចែងថា ហ៊ីប៉ូតែកលើដី មិនមានអានុភាពលើអាគារនៅលើដីដែលបានដាក់ជាហ៊ីប៉ូតែក ដែលតតិយជនមានកម្មសិទ្ធិ ដោយផ្អែកលើសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្តឡើយ ។ សូមមើលមាត្រា ៨៤៣ (អត្ថន័យនៃហ៊ីប៉ូតែក) និង សេចក្តីកំណត់នៃមាត្រាមុន ។

**មាត្រា ៨៤៨.–** អានុភាពនៃហ៊ីប៉ូតែក ចំពោះផល

បញ្ញត្តិនៃមាត្រា ៨៤៦ (ទំហំនៃអានុភាពហ៊ីប៉ូតែក) ខាងលើនេះ មិនត្រូវយកមកអនុវត្តចំពោះផលឡើយ ។ ប៉ុន្តែ បញ្ញត្តិនៃវាក្យខណ្ឌទី ១ នេះមិនត្រូវយកមកអនុវត្តឡើយ នៅក្រោយពេលដែលអចលនវត្ថុហ៊ីប៉ូតែកនោះត្រូវបានរឹបអូស ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះចែងថា ហ៊ីប៉ូតែកមិនមានអានុភាពលើផលដែលកើតចេញពីវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកឡើយ (ឧទាហរណ៍ បន្លែដែលដាំលើដីដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ថ្លៃឈ្នួលក្នុងករណីជួលដីដែលជាកម្មវត្ថុនៃ

ហ៊ីប៉ូតែក ជាអាទិ៍) ។ ដោយហេតុផលថា អ្នកបង្កើតហ៊ីប៉ូតែក បន្តមានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលពីដី ក្រោយការបង្កើតហ៊ីប៉ូតែក កថាខណ្ឌទី ១ នេះចែងថា អានុភាពនៃហ៊ីប៉ូតែក មិនមានអានុភាពលើផលដែលបានបង្កើតដោយអនុលោមតាមសិទ្ធិប្រើប្រាស់ និង អាស្រ័យផលនោះទេ ។ ប៉ុន្តែ ក្នុងករណីដែលអចលនវត្ថុដែលបានដាក់ហ៊ីប៉ូតែកត្រូវបានលក់ ដោយការអនុវត្តហ៊ីប៉ូតែក អ្នកទិញនឹងធ្វើលទ្ធកម្មនូវកម្មសិទ្ធិពេញលេញ ហើយអ្នកបង្កើតហ៊ីប៉ូតែកនឹងត្រូវបាត់បង់កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុ ហេតុដូច្នេះ អ្នកបង្កើតហ៊ីប៉ូតែកត្រូវបាត់បង់សិទ្ធិប្រើប្រាស់ និង អាស្រ័យផលដោយស្វ័យប្រវត្តិផងដែរ ។ អាស្រ័យហេតុនេះ វាក្យខណ្ឌទី ២ កំណត់ថា ពេលដែលសិទ្ធិប្រើប្រាស់ និង អាស្រ័យផលរបស់អ្នកបង្កើតហ៊ីប៉ូតែក ត្រូវបានកម្រិត គឺជាពេលដែលអចលនវត្ថុត្រូវបានរឹបអូស (វាក្យខណ្ឌទី ២ នេះត្រូវបានរៀបចំឡើង ចំពោះករណីដែលម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលចំពោះអ្នកបង្កើតហ៊ីប៉ូតែក បានរឹបអូសអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក) ។ មានន័យថា ហ៊ីប៉ូតែកនឹងត្រូវមានអានុភាពលើផលដែលបានមកពីអចលនវត្ថុដែលដាក់ហ៊ីប៉ូតែកក្រោយពេលដែលអចលនវត្ថុនោះត្រូវបានរឹបអូស ។ ចំណុចនេះបានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រាបន្ទាប់ ។ នីតិវិធីអនុវត្តចំពោះផលក្រោយការរឹបអូសអចលនវត្ថុ បានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី (មាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ)) ។

**មាត្រា ៨៤៩.–** ឧបាទេសកម្មលើវត្ថុ

១-ហ៊ីប៉ូតែកអាចអនុវត្តបានចំពោះទឹកប្រាក់ ឬ វត្ថុផ្សេងទៀតដែលអ្នកបង្កើតហ៊ីប៉ូតែកត្រូវទទួល ដោយសារការលក់ ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកនោះ ។ ប៉ុន្តែ ម្ចាស់ហ៊ីប៉ូតែកពុំអាចអនុវត្តហ៊ីប៉ូតែករបស់ខ្លួនបានឡើយ នៅក្រោយពេលដែលប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងត្រូវបានប្រគល់ ទៅឱ្យអ្នកបង្កើត ។

២-ហ៊ីប៉ូតែកក៏អាចអនុវត្តបានផងដែរ ចំពោះផលដែលកើតឡើងក្រោយការរឹបអូសអចលនវត្ថុហ៊ីប៉ូតែកនោះ ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះចែងថា ហ៊ីប៉ូតែកមានអានុភាពលើទឹកប្រាក់ដែលអ្នកបង្កើតហ៊ីប៉ូតែក (ដែលជាអ្នកលក់) ត្រូវទទួល ក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកត្រូវបានលក់ទៅតតិយជន និង លើទឹកប្រាក់សំណងការខូចខាតដែលអ្នកបង្កើតហ៊ីប៉ូតែកត្រូវទទួល ដោយសារការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកនោះ ហើយម្ចាស់បំណុលហ៊ីប៉ូតែកអាចអនុវត្តហ៊ីប៉ូតែកចំពោះទឹកប្រាក់ទាំងនេះបាន ។ បញ្ញត្តិនេះមានមូលដ្ឋានលើទស្សនៈមួយដែលនាំឱ្យមានភាពយុត្តិធម៌សម្រាប់ភាគីដែលពាក់ព័ន្ធ ក្នុងការបង្កើតឱ្យមានអានុភាពនៃហ៊ីប៉ូតែកលើទឹកប្រាក់ទាំងនោះដោយឧបាទេសកម្ម ពីព្រោះទឹកប្រាក់ទាំងនោះអាចត្រូវបានចាត់ទុកថាជាប្រាក់ដែលបានមកពីការផ្លាស់ប្តូរនៃតម្លៃវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ។ កថាខណ្ឌទី ២ ចែងថា ហ៊ីប៉ូតែកក៏អាចអនុវត្តបានផងដែរ ចំពោះផលដែលកើតឡើងពីវត្ថុដែលជា

កម្មវត្ថុនៃហ៊ីប៉ូតែក ក្រោយការរឹបអូសអចលនវត្ថុហ៊ីប៉ូតែកនោះ ។ បញ្ញត្តិនេះត្រូវបានចែងឱ្យស្របតាមវាក្យខណ្ឌទី ២ នៃមាត្រាមុន ។

នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែកដោយអនុលោមតាមមាត្រានេះ បានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី (មាត្រា ៥០៦ (ការរឹបអូសសិទ្ធិលើបំណុលដោយផ្អែកលើឧបាទេសកម្មលើវត្ថុ)) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣០៤ នៃក្រមរដ្ឋប្បវេណីជប៉ុន (ការយកមកអនុវត្តដូចគ្នាផងដែរចំពោះហ៊ីប៉ូតែក ដោយយោងតាមមាត្រា ៣៧២)

## មាត្រា ៨៥០.- សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ

ប្រសិនបើអ្នកដែលបានបង្កើតហ៊ីប៉ូតែកដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃ បានសងចំពោះកាតព្វកិច្ចនោះ ឬ បានបាត់បង់នូវកម្មសិទ្ធិលើដីហ៊ីប៉ូតែក ដោយសារការអនុវត្តហ៊ីប៉ូតែកនោះ អ្នកនោះត្រូវមានសិទ្ធិទាមទារសំណងពីកូនបំណុល ដោយយោងទៅតាមបញ្ញត្តិស្ដីពីការធានា ។

(កំណត់)

មាត្រានេះចែងថា អ្នកធានាដោយវត្ថុមានសិទ្ធិទាមទារសំណងពីកូនបំណុល ប្រសិនបើអ្នកធានាដោយវត្ថុនោះបានសងចំពោះកាតព្វកិច្ចដែលត្រូវបានធានា ឬ បានបាត់បង់កម្មសិទ្ធិលើអចលនវត្ថុដែលដាក់ហ៊ីប៉ូតែក ដោយសារការអនុវត្តហ៊ីប៉ូតែក (ដោយថាហេតុ ករណីនេះនឹងនាំឱ្យមានលទ្ធផលដូចគ្នានឹងករណីដែលអ្នកធានាដោយវត្ថុបានសងកាតព្វកិច្ចដែលត្រូវបានធានា) ។ ការអនុញ្ញាតឱ្យអ្នកធានាដោយវត្ថុទាមទារសំណងពីកូនបំណុល គឺជាការធម្មតា ពីព្រោះកូនបំណុលបានរួចផុតពីកាតព្វកិច្ចដែលខ្លួនគួរទទួលបន្ទុក ដោយការសងរបស់អ្នកធានាដោយវត្ថុ ។ មាត្រានេះបញ្ជាក់យ៉ាងច្បាស់ថា បញ្ញត្តិទាក់ទងនឹងការទាមទារសំណង ក្នុងករណីដែលអ្នកធានាបានសងកាតព្វកិច្ចជំនួសកូនបំណុល ត្រូវយកមកអនុវត្តចំពោះករណីនេះដែរ ។ មានន័យថា បញ្ញត្តិចាប់ពីមាត្រា ៩១១ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកធានាដោយវត្ថុទាមទារសំណងពីកូនបំណុល ។ម្យ៉ាងទៀត បញ្ញត្តិទាក់ទងនឹងឧបាទេសកម្មដោយការសង ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ (បញ្ញត្តិចាប់ពីមាត្រា ៩១៦ និង បញ្ញត្តិចាប់ពីមាត្រា ៤៩៩) ។

## មាត្រា ៨៥១.- លំដាប់នៃហ៊ីប៉ូតែក

ក្នុងករណីដែលបានបង្កើតហ៊ីប៉ូតែកនៅលើអចលនវត្ថុតែមួយ ដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃហ៊ីប៉ូតែកនោះ ត្រូវអនុលោមតាមពេលវេលាដែលបានចុះបញ្ជី ។

(កំណត់)

មាត្រានេះចែងថា លំដាប់អាទិភាពនៃហ៊ីប៉ូតែកច្រើនដែលបង្កើតលើអចលនវត្ថុតែមួយ ត្រូវបានកំណត់ដោយអនុលោមតាមពេលវេលានៃការចុះបញ្ជីហ៊ីប៉ូតែក ។ ឧទាហរណ៍ ក្នុងករណីដែលហ៊ីប៉ូតែក A (ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានា មានចំនួន ១០០,០០០ រៀល) ហ៊ីប៉ូតែក B (ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានា មានចំនួន ៣០០,០០០ រៀល) និង ហ៊ីប៉ូតែក C (ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានា មានចំនួន ២០០,០០០ រៀល) ត្រូវបានចុះបញ្ជីតាមលំដាប់នេះចំពោះអចលនវត្ថុមួយ ប្រសិនបើហ៊ីប៉ូតែកត្រូវបានអនុវត្តនៅពេលអនាគត អានុភាពនៃហ៊ីប៉ូតែកចំពោះប្រាក់ដែលបានមកពីការលក់ ត្រូវអនុលោមតាមលំដាប់នៃហ៊ីប៉ូតែក A B និង C មានន័យថា អាចអនុវត្តសិទ្ធិទទួលការសងដោយមានអាទិភាព តាមលំដាប់នេះ ។ ប្រសិនបើចំនួនទឹកប្រាក់ដែលបានមកពីការលក់ មានចំនួន ៥០០,០០០ រៀល ទឹកប្រាក់ចំនួន ១០០,០០០ រៀល នឹងត្រូវចែកទៅឱ្យហ៊ីប៉ូតែក A មុន ទឹកប្រាក់ ចំនួន ៣០០,០០០ រៀល នឹងត្រូវចែកទៅឱ្យហ៊ីប៉ូតែក B ហើយ ទឹកប្រាក់ដែលនៅសល់ចំនួន ១០០,០០០ រៀល នឹងត្រូវចែកទៅឱ្យហ៊ីប៉ូតែកលំដាប់ទី ៣ គឺ C ។ ដូច្នេះ ចំពោះទឹកប្រាក់ដែលខ្វះចំនួន ១០០,០០០ រៀលទៀតក្នុងចំណោមសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក C ត្រូវប្រមូលពីទ្រព្យសម្បត្តិផ្សេងទៀតរបស់កូនបំណុល ។ ប្រសិនបើកូនបំណុលមិនមានទ្រព្យសម្បត្តិផ្សេងទៀតទេ ជាលទ្ធផល ហ៊ីប៉ូតែក C មិនត្រូវបានសងគ្រប់ចំនួនទេ ។

ចំពោះការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក ត្រូវបានចែងក្នុងផ្នែកទី ៥ ទាក់ទងនឹងការចាត់ចែងហ៊ីប៉ូតែក ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៧៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៥២.-** ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

១-ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទាមទារការប្រាក់ ឬ ធនលាភផ្សេងទៀត ម្ចាស់បំណុលហ៊ីប៉ូតែកអាចអនុវត្តហ៊ីប៉ូតែកនោះបានតែចំពោះចំនួននៃការសងដែលដល់កំណត់ពេលសម្រាប់អំឡុងពេល ២ (ពីរ) ឆ្នាំចុងក្រោយ តែប៉ុណ្ណោះ ។ ប៉ុន្តែ ចំពោះធនលាភដែលមានពីមុនមក ប្រសិនបើបានចុះបញ្ជីពិសេស ក្រោយពីបានដល់ពេលកំណត់ត្រូវសង ហ៊ីប៉ូតែកនេះអាចអនុវត្តបានចាប់ពីពេលដែលបានចុះបញ្ជីនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ត្រូវយកមកអនុវត្តផងដែរ ចំពោះប្រាក់ដែលត្រូវបង់សម្រាប់អំឡុងពេល ២ (ពីរ) ឆ្នាំចុងក្រោយ ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទាមទារឱ្យសងសំណងនៃការខូចខាត ដែលបានកើតឡើង ដោយការមិនអនុវត្តកាតព្វកិច្ច ។ ប៉ុន្តែ ក្នុងករណីនេះ ចំនួនសរុបនៃសំណងការខូចខាត ព្រមទាំង

ការប្រាក់ និង ផលលាភផ្សេងទៀត មិនអាចលើសចំនួនសរុបសម្រាប់អំឡុងពេល ២ (ពីរ) ឆ្នាំបានឡើយ ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះចែងអំពីទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក មានន័យថា ទំហំដែលអាចទទួលការសងដោយមានអាទិភាព ។ ជាគោលការណ៍ ទំហំដែលអាចទទួលការសងដោយមានអាទិភាព ត្រូវបានកម្រិតនូវសិទ្ធិលើបំណុលចំពោះប្រាក់ដើម ព្រមទាំងការប្រាក់ និង ប្រាក់សំណងការខូចខាត ជាអាទិ៍ ក្នុងអំឡុងពេល ២ ឆ្នាំចុងក្រោយតែប៉ុណ្ណោះ ។ ប្រសិនបើមានហ៊ីប៉ូតែកច្រើនបានបង្កើតលើអចលនវត្ថុតែមួយ លំដាប់នៃអានុភាពហ៊ីប៉ូតែកត្រូវអនុលោមតាមលំដាប់នៃពេលវេលានៃការចុះបញ្ជី (មាត្រា ៨៤៩) ។ បញ្ញត្តិនេះមានគោលបំណងសម្របសម្រួលផលប្រយោជន៍ក្នុងចំណោមហ៊ីប៉ូតែកច្រើននោះ ដោយកម្រិតទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ដែលអាចទទួលការសងដោយមានអាទិភាព ។ ឧទាហរណ៍ ប្រសិនបើអចលនវត្ថុដែលបានដាក់ហ៊ីប៉ូតែកមានតម្លៃគ្រប់គ្រាន់ដើម្បីដាក់ជាប្រាតិភោគផ្សេងទៀត (មានន័យថា តម្លៃនៃអចលនវត្ថុលើសពីចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានា) ហ៊ីប៉ូតែកបន្ថែមដែលមានលំដាប់ក្រោយ អាចត្រូវបានបង្កើតបាន ។ ប៉ុន្តែ តតិយជនមិនអាចបង្កើតហ៊ីប៉ូតែកដែលមានលំដាប់ទាបជាង ជាមួយកម្មសិទ្ធិករនៃអចលនវត្ថុនោះ និង ឱ្យខ្ចីប្រាក់បានឡើយ ប្រសិនបើមិនអាចព្យាករចំនួនការប្រាក់ និង ប្រាក់សំណងការខូចខាតដែលកើតឡើងពីសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដែលមានលំដាប់ខ្ពស់ជាង ។ ហេតុដូច្នេះ កថាខណ្ឌទី ១ នៃមាត្រានេះកម្រិតទំហំនៃការប្រាក់ និង ប្រាក់សំណងការខូចខាតដែលត្រូវបានធានាដោយហ៊ីប៉ូតែកដែលមានលំដាប់ខ្ពស់ជាង ក្នុងអំឡុងពេល ២ ឆ្នាំចុងក្រោយតែប៉ុណ្ណោះ ហើយតតិយជនដែលមានបំណងឱ្យខ្ចីប្រាក់ អាចធ្វើការវិនិច្ឆ័យអំពីភាពប្រាកដប្រជាថា តើអាចទទួលការសងដោយមានអាទិភាពបាន ឬ មិនបាន បើបង្កើតហ៊ីប៉ូតែកដែលមានលំដាប់ទាបជាង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៧៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៤ ការអនុវត្តហ៊ីប៉ូតែក

**មាត្រា ៨៥៣.–** ការលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែក

បើកាតព្វកិច្ចពុំបានអនុវត្តទេ ម្ចាស់បំណុលហ៊ីប៉ូតែកអាចដាក់ពាក្យសុំឱ្យលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែក ទៅតុលាការបាន ។

(កំណត់)

មាត្រានេះចែងថា ម្ចាស់បំណុលហ៊ីប៉ូតែក អាចអនុវត្តហ៊ីប៉ូតែកបាន ប្រសិនបើកាតព្វកិច្ចដែលត្រូវបានធានាពុំបានសង ។

មាត្រានេះបានចែងអំពីការពិតជាក់ស្តែង ។

**មាត្រា ៨៥៤.-** ការលក់ដោយបង្ខំនូវអាគារជាកម្មសិទ្ធិរបស់តតិយជន

១-បើអ្នកបង្កើតហ៊ីប៉ូតែក មានកម្មសិទ្ធិលើអាគារដែលអ្នកបង្កើតហ៊ីប៉ូតែកនោះ ឬ តតិយជនបានសាងសង់នៅលើដីហ៊ីប៉ូតែក នៅក្រោយពេលហ៊ីប៉ូតែកនោះត្រូវបានបង្កើត ហើយ ម្ចាស់បំណុលហ៊ីប៉ូតែកអាចលក់ដោយបង្ខំនូវអាគារនោះ ព្រមជាមួយនឹងដីហ៊ីប៉ូតែក នោះបាន ។ ប៉ុន្តែ បើចំនួនថ្លៃលក់ដី និង អាគារនោះ ទាបជាងថ្លៃលក់ដីដែលគ្មាន អាគារលើនោះ ម្ចាស់បំណុលហ៊ីប៉ូតែក អាចទាមទារឱ្យអ្នកបង្កើតហ៊ីប៉ូតែក រុះរើអាគារនោះ មុនពេលលក់ដោយបង្ខំ ។

២-ក្នុងករណីដែលតតិយជនមានកម្មសិទ្ធិលើអាគារលើដីហ៊ីប៉ូតែក ដោយផ្អែកលើ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬ សិទ្ធិជួល បើតតិយជននោះមិនអាចយកសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬ សិទ្ធិជួលរបស់ខ្លួន មកតតាំងចំពោះម្ចាស់បំណុលហ៊ីប៉ូតែក ម្ចាស់បំណុល ហ៊ីប៉ូតែកអាចលក់ដោយបង្ខំ នូវអាគារនោះ ព្រមជាមួយនឹងដីហ៊ីប៉ូតែកបាន ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះចែងថា ក្នុងករណីដែលអ្នកបង្កើតហ៊ីប៉ូតែក ឬ តតិយជនបានសាងសង់អាគារ នៅលើដីហ៊ីប៉ូតែក នៅក្រោយពេលហ៊ីប៉ូតែកនោះត្រូវបានបង្កើត ហើយអ្នកបង្កើតហ៊ីប៉ូតែកមានកម្មសិទ្ធិលើអាគារនោះ (សូមមើលវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ៨៤៦) ម្ចាស់បំណុលហ៊ីប៉ូតែកអាចលក់ដោយបង្ខំនូវអាគារនោះ ព្រមជាមួយនឹងដីហ៊ីប៉ូតែកបាន ហើយមានសិទ្ធិទទួលការសងដោយមានអាទិភាពចំពោះប្រាក់ដែលបានមកពីការលក់នោះ ។ មាត្រានេះអនុញ្ញាតឱ្យម្ចាស់បំណុលហ៊ីប៉ូតែករុះរើអាគារនោះ មុនពេលលក់ដោយបង្ខំផងដែរ ប្រសិនបើចំនួនថ្លៃលក់ដី និង អាគារនោះ ទាបជាងថ្លៃលក់ដីដែលគ្មានអាគារលើនោះ (ដីទទេ) ។ ម្យ៉ាងទៀត ក្នុងករណីដែលមានអាគារដែល អ្នកបង្កើតហ៊ីប៉ូតែកមានកម្មសិទ្ធិនៅលើដីរួចហើយ នៅពេលបង្កើតហ៊ីប៉ូតែក អានុភាពនៃហ៊ីប៉ូតែកត្រូវមានលើអាគារ ផងដែរ (សូមមើលវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រា ៨៤៦) ។ ក្នុងករណីនេះ ម្ចាស់បំណុលលក់ដោយបង្ខំនូវដី និង អាគារដែលមាននៅលើដីតាំងពីដើមដំបូងជាមួយគ្នា (ម្ចាស់បំណុលហ៊ីប៉ូតែកមិនត្រូវអនុញ្ញាតឱ្យទាមទារឱ្យរុះរើអាគារទេ) ហើយទទួលការសងដោយមានអាទិភាព ពីប្រាក់ដែលបានមកពីការលក់ដោយបង្ខំនូវដី និង អាគារនោះ។

ក្នុងករណីដែលតតិយជន ក្រៅពីកម្មសិទ្ធិករនៃដី មានកម្មសិទ្ធិលើអាគារលើដីហ៊ីប៉ូតែក ដោយផ្អែកលើសិទ្ធិដែលនាំឱ្យ មានមូលហេតុគតិយុត្ត ដូចជាសិទ្ធិជួលអចិន្ត្រៃយ៍ ហ៊ីប៉ូតែកមិនត្រូវមានអានុភាពលើអាគារនោះឡើយ (សូមមើលសេចក្តី កំណត់នៃមាត្រា ៨៤៦) ។ ប៉ុន្តែ កថាខណ្ឌទី ២ នៃមាត្រានេះចែងថា ម្ចាស់បំណុលហ៊ីប៉ូតែកអាចលក់ដោយបង្ខំទាំងដី និង

អាគារបាន ប្រសិនបើកម្មសិទ្ធិករនៃអាគារ មិនអាចតតាំងសិទ្ធិរបស់ខ្លួនចំពោះម្ចាស់បំណុលហ៊ីប៉ូតែកបានទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៨៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៥៥.–** ការស្នើសុំទិញដោយតតិយជនដែលបានធ្វើលទ្ធកម្ម

តតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែក អាចក្លាយជាអ្នកទិញក្នុងការលក់ដោយបង្ខំបាន ។

(កំណត់)

ជាធម្មតា កម្មសិទ្ធិករនៃវត្ថុណាមួយ មិនអាចក្លាយជាអ្នកទិញវត្ថុនោះបានឡើយ ។ ប៉ុន្តែ ក្នុងករណីនៃការលក់ដោយបង្ខំ សិទ្ធិរបស់តតិយជនដែលបានធ្វើលទ្ធកម្ម ដែលមិនអាចតតាំងចំពោះម្ចាស់បំណុលហ៊ីប៉ូតែក ត្រូវរលត់ ដូច្នេះ តតិយជនដែលបានធ្វើលទ្ធកម្ម មានផលប្រយោជន៍ក្នុងការទិញវត្ថុនោះ ហើយធ្វើលទ្ធកម្មកម្មសិទ្ធិ តាមស្ថានភាពមុនការបង្កើតហ៊ីប៉ូតែក ។ មាត្រានេះចែងសម្រាប់ករណីបែបនេះ ។

ម្យ៉ាងទៀត កូនបំណុលមិនអាចក្លាយជាអ្នកទិញបានទេ ប៉ុន្តែ ចំណុចនេះមិនបានបញ្ញត្តពិសេស ដោយសារវាជាការធម្មតា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៥៦.–** សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់តតិយជនដែលបានធ្វើលទ្ធកម្ម

ក្នុងករណីដែលតតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែក បានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ ឬ ចំណាយបង្កើនតម្លៃ ចំពោះអចលនវត្ថុហ៊ីប៉ូតែកនោះ តតិយជននោះអាចទទួលសំណងនៃចំណាយនោះ ពីថ្លៃលក់ដោយបង្ខំនូវអចលនវត្ថុនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលហ៊ីប៉ូតែក ។

(កំណត់)

មាត្រានេះមានគោលបំណងសម្របសម្រួលផលប្រយោជន៍រវាងតតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុដែលដាក់ហ៊ីប៉ូតែក និង ម្ចាស់បំណុលហ៊ីប៉ូតែក ។ មានន័យថា អាចបកស្រាយថា តម្លៃនៃអចលនវត្ថុត្រូវបានរក្សាទុក ដោយសារតតិយជនដែលបានធ្វើលទ្ធកម្ម បានចេញចំណាយដែលចាំបាច់សម្រប់ការគ្រប់គ្រង និង ថែរក្សា ឬ ចំណាយបង្កើនតម្លៃ ហេតុដូច្នេះ ចំណាយទាំងនេះ អាចចាត់ទុកដូចជាសោហ៊ុយចំណាយសម្រាប់ប្រយោជន៍រួមដែលត្រូវបានទទួលស្គាល់ឯកសិទ្ធិបាន ។ ដោយហេតុនេះហើយ មាត្រានេះចែងថា តតិយជនដែលបានធ្វើលទ្ធកម្ម មានសិទ្ធិទទួលសំណងចំពោះចំណាយនោះ

ពីថ្លៃលក់អចលនវត្ថុដែលដាក់ហ៊ីប៉ូតែក ដោយមានអាទិភាពជាងម្ចាស់បំណុលហ៊ីប៉ូតែក ។ ចំណែកឯចំណាយចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សា និង ចំណាយបង្កើនតម្លៃ ដែលកូនបំណុល ឬ អ្នកធានាដោយវត្ថុដែលបានបង្កើតហ៊ីប៉ូតែកបានចេញ នៅពេលដែលកូនបំណុល ឬ អ្នកធានាដោយវត្ថុនោះមានកម្មសិទ្ធិលើអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកនោះ ត្រូវបានបកស្រាយថា កូនបំណុល ឬ អ្នកធានាដោយវត្ថុនោះមិនអាចទាមទារឱ្យសងចំណាយទាំងនោះបានទេ នៅពេលអនុវត្តហ៊ីប៉ូតែក ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩១ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៨៥៧.- ការចែកចំណែកព្រមគ្នា និង ការចែកចំណែកមិនព្រមគ្នា ក្នុងករណីនៃហ៊ីប៉ូតែករួម

១-ក្នុងករណីដែលម្ចាស់បំណុលមានហ៊ីប៉ូតែកលើអចលនវត្ថុច្រើនដើម្បីធានាសិទ្ធិលើបំណុលតែមួយ បើចែកចំណែកនូវប្រាក់ដែលបានមកពីការលក់ដោយបង្ខំនៅពេលជាមួយគ្នា បន្ទុកនៃសិទ្ធិលើបំណុលត្រូវចែក ទៅតាមសមាមាត្រនៃតម្លៃអចលនវត្ថុនីមួយៗនោះ ។

២-បើចែកចំណែកតែប្រាក់ដែលបានពីការលក់ដោយបង្ខំនូវអចលនវត្ថុណាមួយ ម្ចាស់បំណុលហ៊ីប៉ូតែកអាចទទួលការសង ចំពោះសិទ្ធិលើបំណុលទាំងអស់ ដោយប្រាក់ដែលបានមកពីការលក់ដោយបង្ខំនោះបាន ។ ក្នុងករណីនេះ ម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់បន្ទាប់ អាចអនុវត្តហ៊ីប៉ូតែករបស់ម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់នៅខាងលើ ដោយឧបាទេសកម្មបាន រហូតដល់ចំនួនទឹកប្រាក់ដែលម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់ខ្ពស់ជាងនោះ ត្រូវទទួលការសងចំពោះអចលនវត្ថុផ្សេងទៀត ដោយយោងទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះចែងថា ក្នុងករណីដែលមានហ៊ីប៉ូតែកមួយលើអចលនវត្ថុច្រើន ដើម្បីធានាសិទ្ធិលើបំណុលតែមួយ (ហៅថា ហ៊ីប៉ូតែករួម) ប្រសិនបើអចលនវត្ថុទាំងអស់ត្រូវបានលក់ដោយបង្ខំ ហើយប្រាក់ដែលបានមកពីការលក់អចលនវត្ថុទាំងអស់ ត្រូវបានចែកចំណែក បន្ទុកនៃសិទ្ធិលើបំណុលត្រូវចែក ទៅតាមសមាមាត្រនៃតម្លៃអចលនវត្ថុនីមួយៗនោះ ។ បញ្ញត្តិនេះមានសារៈសំខាន់ណាស់ក្នុងករណីដែលមានម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់ទាបជាង ក្នុងចំណោមអចលនវត្ថុមួយចំនួនដែលមានហ៊ីប៉ូតែករួម ។ ឧទាហរណ៍ សន្មតថា ភាគី A មានសិទ្ធិលើបំណុលលើភាគី B ចំនួន

៦ លានរៀល ហើយហ៊ីប៉ូតែកត្រូវបានបង្កើតលើអចលនវត្ថុជាច្រើន ។ អចលនវត្ថុ **ក** (មានតម្លៃ ៦ លានរៀល តាមតម្លៃទីផ្សារ) អចលនវត្ថុ **ខ** (មានតម្លៃ ៤ លានរៀល តាមតម្លៃទីផ្សារ)និង អចលនវត្ថុ **គ** (មានតម្លៃ ២ លានរៀល តាមតម្លៃទីផ្សារ) ។ ប្រសិនបើអចលនវត្ថុទាំងអស់ ត្រូវបានលក់ដោយបង្ខំ ហើយប្រាក់ដែលបានមកពីការលក់ទាំងអស់ មានតម្លៃ ១២ លានរៀល នោះបន្ទុកនៃសិទ្ធិលើបំណុលរបស់ភាគី A លើអចលនវត្ថុ **ក** អចលនវត្ថុ **ខ** និង អចលនវត្ថុ **គ** គឺមានចំនួន ៣ លានរៀល ២ លានរៀល និង ១ លានរៀល លើអចលនវត្ថុនីមួយៗរៀងៗខ្លួន ។ ប៉ុន្តែ ក្នុងកាលៈទេសៈដូចគ្នានេះដែរ ប្រសិនបើភាគី C មានហ៊ីប៉ូតែកដែលមានលំដាប់ទី ២ លើអចលនវត្ថុ **ក** ដើម្បីធានាសិទ្ធិលើបំណុលចំនួន ៣ លានរៀល ភាគី C អាចទទួលបានចំណែក ៣ លានរៀល ដែលយកចេញពីប្រាក់ ៣ លានរៀល ដែលនៅសល់ពីតម្លៃនៃអចលនវត្ថុ **ក** ។ ម្យ៉ាងវិញទៀត ប្រសិនបើតម្លៃនៃសិទ្ធិលើបំណុលរបស់ភាគី C លើសពីតម្លៃនៃអចលនវត្ថុ **ក** ដែលនៅសល់ចំនួន ៣ លានរៀល (ឧ. ៤ លានរៀល) ភាគី C អាចទទួលការសងពីប្រាក់ដែលបានមកពីការលក់ដោយមានអាទិភាព តែចំនួន ៣ លានរៀលប៉ុណ្ណោះ ចំណែកឯចំនួនដែលនៅសល់នៃសិទ្ធិលើបំណុល (ឧ. ១ លានរៀល) នឹងត្រូវធ្វើតាមរបៀប និង លំដាប់ដូចគ្នានឹងម្ចាស់បំណុលធម្មតាផ្សេងទៀត ដែលពុំមានសិទ្ធិទទួលការសងដោយមានអាទិភាពដែរ ។

កថាខណ្ឌទី ២ ចែងថា ក្នុងករណីដែលអចលនវត្ថុមួយ ក្នុងចំណោមអចលនវត្ថុច្រើនដែលដាក់ហ៊ីប៉ូតែករួម ត្រូវបានលក់ដោយបង្ខំ ហើយម្ចាស់បំណុលហ៊ីប៉ូតែករួមទទួលការសងពីប្រាក់ដែលបានមកពីការលក់អចលនវត្ថុនោះ ម្ចាស់បំណុលហ៊ីប៉ូតែករួមអាចទទួលការសងចំនួនទឹកប្រាក់ទាំងអស់នៃសិទ្ធិលើបំណុល ពីប្រាក់ដែលបានមកពីការលក់អចលនវត្ថុនោះបាន ហើយក្នុងករណីនេះ ម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់ទាបជាងលើអចលនវត្ថុនោះ មានសិទ្ធិធ្វើឧបាទេសកម្មចំពោះហ៊ីប៉ូតែករបស់ម្ចាស់បំណុលហ៊ីប៉ូតែករួមលើអចលនវត្ថុផ្សេងទៀត ។ នៅក្នុងឧទាហរណ៍ខាងលើនេះ ប្រសិនបើមានតែអចលនវត្ថុ **ក** តែមួយគត់ត្រូវបានលក់ដោយបង្ខំ ភាគី A អាចទទួលចំនួនទឹកប្រាក់ទាំងអស់នៃសិទ្ធិលើបំណុល ៦ លានរៀល ពីប្រាក់ដែលបានមកពីការលក់អចលនវត្ថុ **ក** ដែលមានតម្លៃចំនួន ៦ លានរៀលបាន ។ ជាលទ្ធផល ភាគី C ដែលជាម្ចាស់បំណុលហ៊ីប៉ូតែកក្នុងលំដាប់ទី ២ លើអចលនវត្ថុ **ក** នឹងមិនអាចទទួលបានសំណងអ្វីទាំងអស់ ពីប្រាក់ដែលបានមកពីការលក់អចលនវត្ថុ **ក** ប៉ុន្តែ ភាគី C អាចអនុវត្តសិទ្ធិហ៊ីប៉ូតែករបស់ភាគី A លើអចលនវត្ថុ **ខ** និង អចលនវត្ថុ **គ** ដោយឱ្យបាទេសកម្មបាន ចំពោះសិទ្ធិលើបំណុលរបស់ខ្លួនចំនួន ៣ លានរៀល ដែលភាគី C អាចទទួលបានពីប្រាក់ដែលបានមកពីការលក់អចលនវត្ថុ **ក** ។ ហេតុដូច្នេះហើយ ប្រសិនបើអចលនវត្ថុ **ខ** និង អចលនវត្ថុ **គ** ត្រូវបានលក់ដោយបង្ខំ ភាគី C អាចទទួលសិទ្ធិលើបំណុលចំនួន ៣ លានរៀល ពីប្រាក់ដែលបានមកពីការលក់អចលនវត្ថុ **ខ** និង អចលនវត្ថុ **គ** ចំនួន ៦ លាន រៀល ។ ក្នុងករណីនេះ សិទ្ធិលើបំណុលចំនួន ៣ លានរៀល របស់ភាគី C នេះ ត្រូវយកចេញពីអចលនវត្ថុ **ខ** និង អចលនវត្ថុ **គ** ចំនួន ២ លានរៀល និង ១ លានរៀល លើអចលនវត្ថុនីមួយៗរៀងៗខ្លួន តាមសមាមាត្រនៃតម្លៃរបស់ចលនវត្ថុនីមួយៗ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩២ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៥៨.–** ហ៊ីប៉ូតែករួម - ការចុះបញ្ជីឧបាទេសកម្ម

អ្នកដែលអនុវត្តហ៊ីប៉ូតែកដោយឧបាទេសកម្ម ដោយយោងទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៨៥៧ (ការចែកចំណែកព្រមគ្នា និង ការចែកចំណែកមិនព្រមគ្នា ក្នុងករណីនៃហ៊ីប៉ូតែករួម) ខាងលើនេះ ត្រូវចុះបញ្ជីអំពីឧបាទេសកម្មនេះ នៅក្នុងបញ្ជីដែលចុះហ៊ីប៉ូតែក ។

(កំណត់)

មាត្រានេះចែងថា ប្រសិនបើចែកចំណែកប្រាក់ដែលបានមកពីការលក់អចលនវត្ថុណាមួយចំនួន ក្នុងចំណោមអចលនវត្ថុច្រើនដែលត្រូវបានបង្កើតហ៊ីប៉ូតែករួម ហើយម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់ទាបជាង ធ្វើឧបាទេសកម្មចំពោះហ៊ីប៉ូតែកលើអចលនវត្ថុផ្សេងទៀត ដោយយោងតាមបញ្ញត្តិនៃមាត្រាមុន ម្ចាស់បំណុលហ៊ីប៉ូតែកនោះ ត្រូវចុះបញ្ជីបន្ថែមអំពីឧបាទេសកម្មរបស់ខ្លួន នៅក្នុងបញ្ជីដែលចុះហ៊ីប៉ូតែកដែលពាក់ព័ន្ធ ។ ហេតុដូច្នេះ ច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀតដែលទាក់ទងនឹងការចុះបញ្ជីអចលនវត្ថុ ត្រូវបានតម្រូវឱ្យមានបញ្ញត្តិដែលអាចចុះបញ្ជីបន្ថែមអំពីឧបាទេសកម្មនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៣ នៃក្រមរដ្ឋប្បវេណីជប៉ុន ។

## ផ្នែកទី ៥ ការបាត់បង់ហ៊ីប៉ូតែក

**មាត្រា ៨៥៩.–** ហ៊ីប៉ូតែកបន្ត

១-ម្ចាស់បំណុលហ៊ីប៉ូតែកអាចយកហ៊ីប៉ូតែកនេះធ្វើជាប្រាតិភោគសម្រាប់កាតព្វកិច្ចរបស់ខ្លួន ឬ តតិយជនបាន ។ ករណីនេះហៅថាហ៊ីប៉ូតែកបន្ត ។

២-នៅពេលចែកចំណែកនូវប្រាក់ដែលបានមកពីការលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែកបន្ត អាចទទួលការសងចំពោះសិទ្ធិលើបំណុលទាំងអស់បាន ត្រឹមកម្រិតនៃចំនួនទឹកប្រាក់នៃចំណែកដែលត្រូវចែកទៅឱ្យម្ចាស់បំណុលហ៊ីប៉ូតែក ។ ប៉ុន្តែ បើសិទ្ធិលើបំណុលនោះមិនទាន់ដល់កំណត់ពេលត្រូវសងទេ ម្ចាស់បំណុលហ៊ីប៉ូតែកបន្ត គ្រាន់តែអាចទាមទារឱ្យតម្កល់ចំនួនទឹកប្រាក់ដែលខ្លួនអាចទទួលការសងនោះប៉ុណ្ណោះ ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះចែងអំពីនិយមន័យនៃហ៊ីប៉ូតែកបន្ត ។ ហ៊ីប៉ូតែកបន្តមានន័យថា ម្ចាស់បំណុលហ៊ីប៉ូតែក

យកហ៊ីប៉ូតែករបស់ខ្លួនធ្វើជាប្រាតិភោគដើម្បីធានាកាតព្វកិច្ចរបស់ខ្លួន ឬ តតិយជន ។ ហ៊ីប៉ូតែកបន្តមានលក្ខណៈស្រដៀងគ្នានឹងការបញ្ចាំបន្ត ទាក់ទងនឹងសិទ្ធិលើការបញ្ចាំ ។ ក្នុងករណីនេះ ហ៊ីប៉ូតែក និង ហ៊ីប៉ូតែកបន្ត ត្រូវបានបង្កើតលើអចលនវត្ថុមួយ ហេតុដូច្នេះ ចាំបាច់ត្រូវបញ្ជាក់ឱ្យច្បាស់អំពីទំនាក់ទំនងរវាងហ៊ីប៉ូតែក និង ហ៊ីប៉ូតែកបន្ត ។ ក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម និង សិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកបន្តទាំងពីរនេះ ដល់ពេលកំណត់ត្រូវសង ប្រសិនបើហ៊ីប៉ូតែកត្រូវបានអនុវត្ត ប្រាក់ដែលបានមកពីការលក់អចលនវត្ថុ ត្រូវបានចែកជាមុនទៅឱ្យម្ចាស់បំណុលហ៊ីប៉ូតែកបន្ត ក្នុងទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម ហើយប្រសិនបើមានប្រាក់នៅសល់ ត្រូវបានចែកឱ្យម្ចាស់បំណុលហ៊ីប៉ូតែក ។ ចំណុចនេះមិនបានចែងក្នុងបញ្ញត្តិនេះទេ ដោយសារវាជាការធម្មតា ។ ទោះបីជាយ៉ាងនេះក៏ដោយ សិទ្ធិទទួលការសងដោយមានអាទិភាពរបស់ម្ចាស់បំណុលហ៊ីប៉ូតែកបន្ត មិនត្រូវលើសពីទំហំនៃសិទ្ធិលើបំណុលដែលត្រូវធានាដោយហ៊ីប៉ូតែកដើមឡើយ ។ ម្យ៉ាងវិញទៀត កថាខណ្ឌទី ២ នៃមាត្រានេះចែងអំពីខ្លឹមសារនៃសិទ្ធិរបស់ម្ចាស់បំណុលហ៊ីប៉ូតែកបន្ត ក្នុងទំហំមួយដែលមិនអាចធ្វើឱ្យកូនបំណុលដើម (អ្នកបង្កើតហ៊ីប៉ូតែកដើម) បាត់បង់ផលប្រយោជន៍ ដោយសារការបង្កើតហ៊ីប៉ូតែកបន្ត ក្នុងករណីដែលហ៊ីប៉ូតែកត្រូវបានអនុវត្តនៅពេលដែលសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកបន្ត មិនទាន់ដល់ពេលកំណត់ត្រូវសង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៧៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៦០.-** អនុប្បទាន ឬ ការបោះបង់នូវហ៊ីប៉ូតែក

១-ម្ចាស់បំណុលហ៊ីប៉ូតែក អាចធ្វើអនុប្បទាន ឬ បោះបង់នូវហ៊ីប៉ូតែកបាន ដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលផ្សេងទៀតចំពោះកូនបំណុលតែម្នាក់ ។

២-អនុប្បទានិកនៃហ៊ីប៉ូតែក អាចអនុវត្តហ៊ីប៉ូតែកដែលខ្លួនបានទទួល ដោយយកមកធ្វើជាប្រាតិភោគនៃសិទ្ធិលើបំណុលរបស់ខ្លួនបាន ។ ក្នុងករណីនេះ បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៨៥៩ (ហ៊ីប៉ូតែកបន្ត) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

៣-បុគ្គលដែលបានបោះបង់ហ៊ីប៉ូតែក ពុំអាចអះអាងអានុភាពនៃហ៊ីប៉ូតែកនោះចំពោះបុគ្គលដែលបានទទួលនូវការបោះបង់នោះឡើយ ។

(កំណត់)

បញ្ញត្តិនៃមាត្រានេះអនុញ្ញាតឱ្យម្ចាស់បំណុលហ៊ីប៉ូតែកធ្វើអនុប្បទាន និង បោះបង់នូវហ៊ីប៉ូតែករបស់ខ្លួន សម្រាប់ប្រយោជន៍ដល់ម្ចាស់បំណុលផ្សេងទៀតដែលមានកូនបំណុលដូចគ្នា ។

ប្រសិនបើមានការធ្វើអនុប្បទានហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែកដែលបានធ្វើអនុប្បទានហ៊ីប៉ូតែកនោះ នឹងក្លាយជាម្ចាស់បំណុលដែលគ្មានហ៊ីប៉ូតែក ចំណែកឯម្ចាស់បំណុលដែលបានទទួលអនុប្បទានហ៊ីប៉ូតែក នឹងក្លាយជាម្ចាស់បំណុលដែល

មានហ៊ីប៉ូតែក ។ និយាយឱ្យខ្លី រវាងភាគីនៃអនុប្បទានហ៊ីប៉ូតែក សិទ្ធិលើបំណុលរបស់អនុប្បទានិក មានអាទិភាពជាង សិទ្ធិលើបំណុលរបស់អនុប្បទាយី ។ ទំនាក់ទំនងនេះ ស្រដៀងគ្នានឹងទំនាក់ទំនងរវាងហ៊ីប៉ូតែកបន្ត និង ហ៊ីប៉ូតែកដើម ក្នុងករណីនៃហ៊ីប៉ូតែកបន្ត ។ ដូច្នេះ កថាខណ្ឌទី ២ ចែងថា បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៨៥៥ ទាក់ទងនឹងហ៊ីប៉ូតែកបន្ត ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីនេះ ។

ម្ចាស់បំណុលដែលបានបោះបង់ហ៊ីប៉ូតែក មិនអាចអះអាងហ៊ីប៉ូតែក ចំពោះម្ចាស់បំណុលដែលជាភាគីម្ខាងទៀតនៃការបោះបង់ហ៊ីប៉ូតែកបានឡើយ ។ ចំណុចនេះមានចែងក្នុងកថាខណ្ឌទី ៣ នៃមាត្រានេះ ។ មានន័យថា រវាងគូភាគីនៃការបោះបង់ហ៊ីប៉ូតែក ភាគីសងខាងមិនអាចអះអាងពីសិទ្ធិអាទិភាពទៅវិញទៅមកបានឡើយ ។

ម្យ៉ាងទៀត ទាំងការធ្វើអនុប្បទាន និង ការបោះបង់នូវហ៊ីប៉ូតែក នឹងមានអានុភាពរវាងភាគីពាក់ព័ន្ធតែប៉ុណ្ណោះ ហើយគ្មានឥទ្ធិពលលើម្ចាស់បំណុលផ្សេងទៀតដែលមានកូនបំណុលដូចគ្នាទេ (ជាពិសេស ម្ចាស់បំណុលដែលមានអាទិភាពទាបជាងម្ចាស់ហ៊ីប៉ូតែក) ។ ឧទាហរណ៍ A មានសិទ្ធិលើបំណុលចំពោះ B ចំនួន ១ លានរៀល ហើយមានហ៊ីប៉ូតែកក្នុងលំដាប់ទី ១ ដើម្បីធានាសិទ្ធិលើបំណុលនោះ លើអចលនវត្ថុមួយ (ដែលមានតម្លៃ ៣.៥ លានរៀល តាមតម្លៃទីផ្សារ) ដែលជាកម្មសិទ្ធិរបស់ B ។ C មានសិទ្ធិលើបំណុលចំពោះ B ចំនួន ២ លានរៀល ហើយមានហ៊ីប៉ូតែក ក្នុងលំដាប់ទី ២ ដើម្បីធានាសិទ្ធិលើបំណុល លើអចលនវត្ថុដដែលដែលជាកម្មសិទ្ធិរបស់ B ។ D មានសិទ្ធិលើបំណុលចំពោះ B ចំនួន ១ លានរៀល ប៉ុន្តែ ពុំមានហ៊ីប៉ូតែកដើម្បីធានាសិទ្ធិលើបំណុលទេ ។ ប្រសិនបើហ៊ីប៉ូតែកត្រូវបានអនុវត្ត ហើយទឹកប្រាក់ដែលបានមកពីការលក់អចលនវត្ថុហ៊ីប៉ូតែកចំនួន ៣.៥ លានរៀល នឹងត្រូវបានចែកចំណែក A នឹងទទួលបានទឹកប្រាក់ចំនួន ១ លានរៀល C នឹងទទួលបានទឹកប្រាក់ចំនួន ២ លានរៀល ហើយ D នឹងទទួលបានទឹកប្រាក់ដែលនៅសល់ចំនួន ៥០០,០០០ រៀល ។ ក្នុងករណីនេះ ប្រសិនបើ A បានធ្វើអនុប្បទានហ៊ីប៉ូតែករបស់ខ្លួន ទៅឱ្យ D វិញនោះ D នឹងទទួលបានទឹកប្រាក់ចំនួន ១ លានរៀល ជាមុន ហើយបន្ទាប់មក C នឹងទទួលបានទឹកប្រាក់ចំនួន ២ លានរៀល ហើយ A នឹងទទួលបានទឹកប្រាក់ដែលនៅសល់ចំនួន ៥០០,០០០ រៀល ។ ម្យ៉ាងវិញទៀត ប្រសិនបើ A បានបោះបង់ហ៊ីប៉ូតែករបស់ខ្លួនដើម្បីជាប្រយោជន៍របស់ D វិញនោះ ចំណែកនៃទឹកប្រាក់ចំនួន ១ លានរៀលដែលត្រូវចែកចំណែកឱ្យ A នោះត្រូវយកមកចែកតាមសមាមាត្រនឹងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ A និង D (ក្នុងករណីនេះ ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ A និង D ស្មើគ្នា ហេតុដូច្នេះ ចំនួនទឹកប្រាក់ដែលត្រូវចែកឱ្យ A និង D គឺ ៥០០,០០០ រៀលក្នុងម្នាក់) ។ បន្ទាប់មកទៀត ទឹកប្រាក់ចំនួន ២ លានរៀល ត្រូវផ្តល់ឱ្យ C ហើយចំណែកដែលនៅសល់ ៥០០,០០០ រៀល នឹងត្រូវចែកម្តងទៀតទៅឱ្យ A និង D តាមសមាមាត្រនឹងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល (ក្នុងករណីនេះក៏ដូចគ្នាដែរ ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ A និង D ស្មើគ្នា ហេតុដូច្នេះ ចំនួនទឹកប្រាក់ដែលត្រូវចែកឱ្យ A និង D គឺ ២៥០,០០០ រៀលក្នុងម្នាក់) ។ នៅទីបញ្ចប់ A និង D នឹងទទួលបានទឹកប្រាក់ចំនួន ៧៥០,០០០ រៀលក្នុងម្នាក់ ។ ក្នុងករណីណាមួយ C ដែលមិនពាក់ព័ន្ធក្នុងការធ្វើអនុប្បទាន ឬ ការបោះបង់ហ៊ីប៉ូតែក មិនទទួលឥទ្ធិពលអ្វីឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៧៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៦១.–** អនុប្បទាន ឬ ការបោះបង់ និង ការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក

១-ម្ចាស់បំណុលហ៊ីប៉ូតែក អាចធ្វើអនុប្បទាន ឬ បោះបង់លំដាប់នៃហ៊ីប៉ូតែកបាន ដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលហ៊ីប៉ូតែលផ្សេងទៀតចំពោះកូនបំណុលតែម្នាក់ ។ ម្ចាស់បំណុលហ៊ីប៉ូតែក ក៏អាចផ្លាស់ប្តូរលំដាប់នៃហ៊ីប៉ូតែកនោះបាន ដោយការព្រមព្រៀងជាមួយម្ចាស់បំណុលហ៊ីប៉ូតែកផ្សេងទៀត ។[៣] ប៉ុន្តែ បើមានបុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ចំពោះការផ្លាស់ប្តូរនោះ ម្ចាស់បំណុលហ៊ីប៉ូតែកត្រូវទទួលការយល់ព្រមអំពីបុគ្គលនោះ ។

២-ម្ចាស់បំណុលហ៊ីប៉ូតែកដែលទទួលអនុប្បទាននូវលំដាប់នៃហ៊ីប៉ូតែក អាចទទួលការសង ដោយមានអាទិភាពជាងម្ចាស់បំណុលហ៊ីប៉ូតែកដែលបានធ្វើអនុប្បទាននូវលំដាប់នោះ នូវចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលទាំងអស់ ពីប្រាក់ដែលបានមកពីការលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែកនោះ ត្រឹមកម្រិតនៃចំនួនទឹកប្រាក់សរុបនៃចំណែកដែលត្រូវចែកឱ្យទៅម្ចាស់បំណុលហ៊ីប៉ូតែកទាំងពីរនោះ ។

៣-ម្ចាស់បំណុលហ៊ីប៉ូតែកដែលទទួលនូវការបោះបង់លំដាប់នៃហ៊ីប៉ូតែក អាចទទួលការសងដោយមានសមភាពជាមួយម្ចាស់បំណុលដែលបានលះបង់លំដាប់ហ៊ីប៉ូតែកនោះ តាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល នៅក្នុងទំហំនៃចំនួនទឹកប្រាក់សរុបនៃចំណែកដែលត្រូវចែកឱ្យទៅម្ចាស់បំណុលហ៊ីប៉ូតែកទាំងពីរនោះ ។

៤-ម្ចាស់បំណុលហ៊ីប៉ូតែកដែលបានព្រមព្រៀងក្នុងការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែក អាចអនុវត្តហ៊ីប៉ូតែកបាន តាមការព្រមព្រៀងនោះ ។

(កំណត់)

មាត្រានេះចែងអំពីអនុប្បទាន ឬ ការបោះបង់ និង ការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក ។ កថាខណ្ឌទី ១ ចែងថា ក្នុងករណីដែលមានម្ចាស់បំណុលហ៊ីប៉ូតែកច្រើនលើអចលនវត្ថុតែមួយ ការធ្វើអនុប្បទាន ការបោះបង់ និង ការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក ត្រូវបានអនុញ្ញាត តាមការព្រមព្រៀងរវាងម្ចាស់បំណុលហ៊ីប៉ូតែក ។ កថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ ចែងអំពីអានុភាពនៃអនុប្បទាន ការបោះបង់ និង ការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែករៀង១ខ្លួន ។

---

[៣] វាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រា ៨៦១ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

ឧទាហរណ៍ B មានសិទ្ធិលើបំណុលចំពោះ A ចំនួន ១ លានរៀល ហើយមានហ៊ីប៉ូតែកក្នុងលំដាប់ទី ១ B មានសិទ្ធិលើបំណុលចំពោះ A ចំនួន ២ លានរៀល ហើយមានហ៊ីប៉ូតែកក្នុងលំដាប់ទី ២ ចំណែកឯ D មានសិទ្ធិលើបំណុលចំពោះ A ចំនួន ១ លានរៀល ហើយមានហ៊ីប៉ូតែកក្នុងលំដាប់ទី ៣ លើអចលនវត្ថុមួយ (ដែលមានតម្លៃ ៣.៥ លានរៀល តាមតម្លៃទីផ្សារ) ដែលជាកម្មសិទ្ធិរបស់ A ដើម្បីធានាសិទ្ធិលើបំណុលទាំងអស់ ។ ប្រសិនបើហ៊ីប៉ូតែកត្រូវបានអនុវត្ត ហើយអចលនវត្ថុត្រូវបានលក់ដោយបង្ខំក្នុងតម្លៃ ៣.៥ លានរៀល ទឹកប្រាក់ដែលបានមកពីការលក់អចលនវត្ថុហ៊ីប៉ូតែក ចំនួន ៣.៥ លានរៀលនោះ នឹងត្រូវធ្វើការចែកចំណែកដូចតទៅ : B នឹងទទួលបានទឹកប្រាក់ចំនួន ១ លានរៀល C នឹងទទួលបានទឹកប្រាក់ចំនួន ២ លានរៀល ហើយ D នឹងទទួលបានទឹកប្រាក់ដែលនៅសល់ចំនួន ៥០០,០០០ រៀល (ទឹកប្រាក់ដែលបានពីការលក់វត្ថុនោះមិនគ្រប់គ្រាន់សម្រាប់សងសិទ្ធិលើបំណុលរបស់ D ចំនួន ៥០០,០០០ រៀល ដោយមានអាទិភាពទេ ហើយ D គ្រាន់តែអាចទទួលការសងចំនួនសិទ្ធិលើបំណុលមិនគ្រប់នេះ ពីទ្រព្យសម្បត្តិផ្សេងទៀតរបស់ A ដោយស្មើគ្នាជាមួយនឹងម្ចាស់បំណុលធម្មតា) ។

កថាខណ្ឌទី ២ ចែងថា ប្រសិនបើមានអនុប្បទាននូវលំដាប់នៃហ៊ីប៉ូតែក អនុប្បទានិកដែលទទួលអនុប្បទានលំដាប់ហ៊ីប៉ូតែក មានសិទ្ធិទទួលការសងដោយមានអាទិភាពជាងអនុប្បទាយី ។ ក្នុងឧទាហរណ៍ខាងលើ ប្រសិនបើ B ធ្វើអនុប្បទានលំដាប់នៃហ៊ីប៉ូតែករបស់ខ្លួន ទៅឱ្យ D នោះ D អាចទទួលការសងដោយមានអាទិភាពបាន ក្នុងទំហំនៃចំនួនទឹកប្រាក់សរុបនៃចំនួន ១ លានរៀល ដែលត្រូវចែកឱ្យ A បន្ថែមលើទឹកប្រាក់ចំនួន ៥០០,០០០ រៀល ដែលត្រូវចែកឱ្យ D ។ ហេតុដូច្នេះ D នឹងទទួលបានទឹកប្រាក់ចំនួន ១ លានរៀល នៃសិទ្ធិលើបំណុលទាំងមូល ចំណែកឯចំនួនទឹកប្រាក់ ៥០០,០០០ រៀល ដែលនៅសល់ ត្រូវបង្វិលទៅ A វិញ ។ ចំពោះ C ដែលមិនពាក់ព័ន្ធក្នុងការធ្វើអនុប្បទាននៃលំដាប់ហ៊ីប៉ូតែក មិនទទួលឥទ្ធិពលអ្វីឡើយ ហើយនឹងទទួលបានចំណែកចំនួន ២ លានរៀល ។

កថាខណ្ឌទី ៣ ចែងថា ប្រសិនបើមានការបោះបង់នូវលំដាប់នៃហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែកដែលបានបោះបង់លំដាប់ អាចទទួលការសងដោយមានអាទិភាព ក្នុងលំដាប់ស្មើគ្នានឹងម្ចាស់បំណុលហ៊ីប៉ូតែកដែលជាភាគីម្ខាងទៀតនៃការបោះបង់ ។ ក្នុងឧទាហរណ៍ខាងលើ ប្រសិនបើ B បានបោះបង់លំដាប់នៃហ៊ីប៉ូតែករបស់ខ្លួន ដើម្បីជាប្រយោជន៍របស់ D នោះ B និង D មានសិទ្ធិទទួលការសងដោយមានអាទិភាព តាមលំដាប់ដូចគ្នា ចំពោះប្រាក់សរុបចំនួន ១.៥ លានរៀល ដែលបានមកពីទឹកប្រាក់ចំនួន ១ លានរៀល ដែលត្រូវចែកឱ្យ B និង ទឹកប្រាក់ចំនួន ៥០០,០០០ រៀល ដែលត្រូវផ្តល់ឱ្យ D ។ ហេតុដូច្នេះ B និង D នឹងទទួលបានទឹកប្រាក់ចំនួន ៧៥០,០០០ រៀល ក្នុងម្នាក់ ។ ហើយដូចគ្នានឹងករណីនៃអនុប្បទានដែរ C ដែលមិនពាក់ព័ន្ធក្នុងការបោះបង់លំដាប់ហ៊ីប៉ូតែក មិនទទួលឥទ្ធិពលអ្វីទេ ហេតុដូច្នេះ នឹងទទួលបានចំណែកចំនួន ២ លានរៀល ។

កថាខណ្ឌទី ៤ ចែងថា ប្រសិនបើម្ចាស់បំណុលហ៊ីប៉ូតែក ព្រមព្រៀងផ្លាស់ប្តូរលំដាប់នៃហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែកនីមួយៗ នឹងទទួលបានការសងដោយមានអាទិភាពតាមលំដាប់ដែលត្រូវបានព្រមព្រៀងនោះ ។ ក្នុងឧទាហរណ៍ខាងលើ ប្រសិនបើ B C និង D ព្រមព្រៀងផ្លាស់ប្តូរលំដាប់នៃហ៊ីប៉ូតែកទៅជា "D B និង C" នោះ D នឹងទទួលចំណែក

ចំនួន ២ លានរៀល ជាមុន ហើយ B ក្នុងលំដាប់ទី ២ នឹងទទួលចំណែកចំនួន ១ លានរៀល ។ នៅទីបញ្ចប់ ទឹកប្រាក់ដែលនៅសល់ចំនួន ៥០០,០០០ រៀល ដែលបានមកពីការលក់អចលនវត្ថុដែលដាក់ហ៊ីប៉ូតែក នឹងត្រូវបានចែកទៅឱ្យ C ។ ជាលទ្ធផល C មិនអាចទទួលការសងដោយមានអាទិភាពបាន ចំពោះទឹកប្រាក់ ៥០០,០០០ រៀល នៃសិទ្ធិលើបំណុលរបស់ខ្លួនបានឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៧៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៦២.–** អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក

១-ការចាត់ចែងហ៊ីប៉ូតែកដែលបានកំណត់នៅក្នុងមាត្រា ៨៥៩ (ហ៊ីប៉ូតែកបន្ត) មាត្រា ៨៦០ (អនុប្បទាន ឬ ការបោះបង់នូវហ៊ីប៉ូតែក) និង មាត្រា ៨៦១ (អនុប្បទាន ឬ ការបោះបង់ និង ការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក) ខាងលើនេះ មិនមានអានុភាពឡើយ បើមិនធ្វើឡើងដោយលិខិតយថាភូត និង មិនបានចុះបញ្ជីបន្ថែមអំពីការចាត់ចែងនោះ ។

២-ការចាត់ចែងហ៊ីប៉ូតែកមិនអាចតតាំងចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង អ្នកធានា អ្នកបង្កើតហ៊ីប៉ូតែក និង ប្រតិសិទ្ធិរបស់ជនទាំងនោះបានឡើយ បើម្ចាស់បំណុលហ៊ីប៉ូតែកមិនបានជូនដំណឹងទៅកូនបំណុលដែលមានកាតព្វកិច្ចចម្បង ឬ ទទួលការយល់ព្រមពីកូនបំណុលនោះទេ ។

៣-បើកូនបំណុលដែលមានកាតព្វកិច្ចចម្បងបានទទួលដំណឹង ឬ ផ្តល់ការយល់ព្រម ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ការសងដែលបានធ្វើឡើងចំពោះអ្នកចាត់ចែងហ៊ីប៉ូតែក ដោយគ្មានការយល់ព្រមពីអ្នកដែលទទួលផលប្រយោជន៍ពីការចាត់ចែងហ៊ីប៉ូតែក មិនអាចតតាំងចំពោះអ្នកដែលទទួលផលប្រយោជន៍បានឡើយ ។

(កំណត់)

មាត្រានេះចែងអំពីអានុភាពនៃការចាត់ចែងហ៊ីប៉ូតែក ដោយអនុលោមតាមបញ្ញត្តិចាប់ពីមាត្រា ៨៥៩ ដល់មាត្រា ៨៦១ ។

កថាខណ្ឌទី ១ បញ្ជាក់អំពីល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពដែលចែងថា ការចាត់ចែងហ៊ីប៉ូតែកមិនមានអានុភាពឡើយ ប្រសិនបើការចាត់ចែងនោះមិនធ្វើឡើង ដោយលិខិតយថាភូត និង មិនបានចុះបញ្ជីបន្ថែមអំពីហ៊ីប៉ូតែកនោះ ។

កថាខណ្ឌទី ២ ចែងថា ដើម្បីតតាំងការចាត់ចែងហ៊ីប៉ូតែក ចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង ជាអាទិ៍ ចាំបាច់ធ្វើការជូនដំណឹងទៅកូនបំណុលដែលមានកាតព្វកិច្ចចម្បង ឬ ទទួលការយល់ព្រមពីកូនបំណុលដែលមានកាតព្វកិច្ច

ចម្បង ។ ការចាត់ចែងហ៊ីប៉ូតែក ត្រូវបានធ្វើឡើងរវាងម្ចាស់បំណុលដែលមានហ៊ីប៉ូតែក និង តតិយជន (ក្នុងករណីជាច្រើន ម្ចាស់បំណុលផ្សេងទៀត) ហើយអាចមានករណីច្រើនដែលអ្នកដែលទទួលបន្ទុកនូវកាតព្វកិច្ច ដូចជាកូនបំណុលដែលមានកាតព្វកិច្ចចម្បង អ្នកធានា ជាអាទិ៍ ឬ អ្នកដែលទទួលបន្ទុកនូវហ៊ីប៉ូតែក មិនដឹងអំពីការចាត់ចែងនោះទេ ។ ដូច្នេះហើយ បញ្ញត្តិនេះចែងអំពីល័ក្ខខ័ណ្ឌតតាំងការចាត់ចែងហ៊ីប៉ូតែកចំពោះអ្នកទាំងនោះ ។

កថាខណ្ឌទី ៣ ចែងថា ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចចម្បង ត្រូវបានជូនដំណឹងអំពីការចាត់ចែងហ៊ីប៉ូតែក ឬ ផ្តល់ការយល់ព្រមចំពោះការចាត់ចែងហ៊ីប៉ូតែក ប៉ុន្តែ កូនបំណុលដែលមានកាតព្វកិច្ចចម្បង បានសងកាតព្វកិច្ច ដោយគ្មានការយល់ព្រមពីអ្នកដែលទទួលផលប្រយោជន៍ពីការចាត់ចែងហ៊ីប៉ូតែក (ឧ. ម្ចាស់បំណុលផ្សេងទៀតដែលទទួលអនុប្បទាននូវហ៊ីប៉ូតែក) កូនបំណុលដែលមានកាតព្វកិច្ចចម្បងមិនអាចតតាំងការសងកាតព្វកិច្ចនោះ ចំពោះអ្នកដែលទទួលផលប្រយោជន៍បានឡើយ ។ មាត្រានេះមានគោលបំណងការពារអ្នកដែលទទួលផលប្រយោជន៍ ពីការខូចខាតដែលមិនអាចព្យាករបាន ដោយសារការសងកាតព្វកិច្ចដោយកូនបំណុល ដោយគ្មានការដឹងមុនដោយអ្នកដែលទទួលផលប្រយោជន៍ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៧៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៨៦៣.– លំដាប់នៃការចាត់ចែងហ៊ីប៉ូតែក

ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ៨៥៩ (ហ៊ីប៉ូតែកបន្ត) មាត្រា ៨៦០ (អនុប្បទាន ឬ ការបោះបង់នូវហ៊ីប៉ូតែក) និង មាត្រា ៨៦១ (អនុប្បទាន ឬ ការបោះបង់ និង ការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក) ខាងលើនេះ បើម្ចាស់បំណុលហ៊ីប៉ូតែក បានចាត់ចែងហ៊ីប៉ូតែកសម្រាប់បុគ្គលច្រើននាក់ លំដាប់នៃសិទ្ធិរបស់បុគ្គលដែលទទួលផលប្រយោជន៍ពីការចាត់ចែងនោះ ត្រូវអនុលោមទៅតាមពេលវេលានៃការចុះបញ្ជីបន្ថែមនៅក្នុងបញ្ជីដែលចុះហ៊ីប៉ូតែកនោះ ។

(កំណត់)

មាត្រានេះចែងថា ប្រសិនបើមានបុគ្គលច្រើននាក់ទទួលផលប្រយោជន៍ពីការចាត់ចែងហ៊ីប៉ូតែក លំដាប់នៃសិទ្ធិរបស់បុគ្គលទាំងនោះ ត្រូវសម្រេចដោយអនុលោមតាមពេលវេលានៃការចុះបញ្ជីបន្ថែមអំពីសិទ្ធិរបស់ខ្លួន នៅក្នុងបញ្ជីដែលចុះហ៊ីប៉ូតែក ។ បញ្ញត្តិនេះស្របតាមគោលការណ៍ទូទៅពាក់ព័ន្ធនឹងការចុះបញ្ជីអចលនវត្ថុ ដែលលំដាប់នៃសិទ្ធិត្រូវកំណត់តាមពេលវេលានៃការចុះបញ្ជី ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ២ មាត្រា ៣៧៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៦ ការរលត់នៃហ៊ីប៉ូតែក

(កំណត់)

ចំពោះការរលត់នៃហ៊ីប៉ូតែក ក្រមរដ្ឋប្បវេណីជប៉ុនបានចែងអំពីប្រព័ន្ធនៃការសងដោយថ្លៃលក់ ដែលជានីតិវិធីដើម្បីជួយសម្រួលការរលត់នៃហ៊ីប៉ូតែក ដោយការទាមទាររបស់ម្ចាស់បំណុលហ៊ីប៉ូតែក ហើយក្រៅពីប្រព័ន្ធនេះ តាមក្រមរដ្ឋប្បវេណីបារាំង ក្រមរដ្ឋប្បវេណីជប៉ុនបានចែងផងដែរអំពីប្រព័ន្ធវិសុទ្ធកម្ម (purge) ដែលជានីតិវិធីដើម្បីជួយសម្រួលការរលត់នៃហ៊ីប៉ូតែក ដោយតតិយជនដែលបានធ្វើលទ្ធកម្មអចលនវត្ថុដែលបានដាក់ហ៊ីប៉ូតែក ។ ប៉ុន្តែ ចំពោះប្រព័ន្ធវិសុទ្ធកម្ម មានបញ្ហាមួយចំនួន ដូចជាការដាក់បន្ទុកខ្លាំងលើម្ចាស់បំណុលហ៊ីប៉ូតែក ហេតុដូច្នេះ ក្រមរដ្ឋប្បវេណីជប៉ុននោះត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ ២០០៣ ដើម្បីបង្កើតប្រព័ន្ធនៃការទាមទារឱ្យរលត់ហ៊ីប៉ូតែក ជំនួសវិសុទ្ធកម្ម ។

ចំណែកឯក្រមរដ្ឋប្បវេណីកម្ពុជាវិញ សម្រេចជ្រើសរើសយកប្រព័ន្ធនៃការសងដោយថ្លៃលក់តែប៉ុណ្ណោះ ហើយប្រព័ន្ធនៃការទាមទារឱ្យរលត់ហ៊ីប៉ូតែក ដោយតតិយជនដែលបានធ្វើលទ្ធកម្មអចលនវត្ថុដែលបានដាក់ហ៊ីប៉ូតែក មិនត្រូវបានអនុម័តយកទេ ។ ប៉ុន្តែ តតិយជនដែលបានធ្វើលទ្ធកម្មអចលនវត្ថុដែលបានដាក់ហ៊ីប៉ូតែក និង ម្ចាស់បំណុលហ៊ីប៉ូតែកអាចរំលត់ហ៊ីប៉ូតែកដោយសេរី តាមការព្រមព្រៀងគ្នាទៅវិញទៅមកបាន ។

### កថាភាគទី ១ ការរលត់ដោយការទាមទារ

**មាត្រា ៨៦៤.-** ការសងដោយថ្លៃលក់

ក្នុងករណីដែលតតិយជនដែលទិញកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ចំពោះអចលនវត្ថុហ៊ីប៉ូតែក បានសងថ្លៃលក់នោះទៅម្ចាស់បំណុលហ៊ីប៉ូតែក តាមការទាមទាររបស់ម្ចាស់បំណុលហ៊ីប៉ូតែកហើយ ហ៊ីប៉ូតែកត្រូវរលត់សម្រាប់តតិយជននោះ ។

(កំណត់)

មាត្រានេះចែងថា ហ៊ីប៉ូតែកនឹងត្រូវរលត់ ប្រសិនបើតតិយជនដែលបានធ្វើលទ្ធកម្មនៃអចលនវត្ថុហ៊ីប៉ូតែក សងថ្លៃលក់អចលនវត្ថុដែលខ្លួនត្រូវបង់ដើម្បីធ្វើលទ្ធកម្មអចលនវត្ថុនោះ តាមការទាមទាររបស់ម្ចាស់បំណុលហ៊ីប៉ូតែក ។ មានន័យថា ហ៊ីប៉ូតែកនឹងត្រូវរលត់ ប្រសិនបើម្ចាស់បំណុលហ៊ីប៉ូតែកទាមទារឱ្យតតិយជនដែលបានធ្វើលទ្ធកម្ម សងថ្លៃលក់អចលនវត្ថុ ហើយតតិយជនដែលបានធ្វើលទ្ធកម្មនោះបានសងថ្លៃលក់តាមការទាមទារនោះ ។ ម្ចាស់បំណុលហ៊ីប៉ូតែកអាចតតាំងហ៊ីប៉ូតែកចំពោះតតិយជនដែលបានធ្វើលទ្ធកម្មអចលនវត្ថុហ៊ីប៉ូតែកបាន ប្រសិនបើបានចុះបញ្ជីហ៊ីប៉ូតែកនោះ ហេតុដូច្នេះ ម្ចាស់បំណុលហ៊ីប៉ូតែកមិនចាំបាច់ត្រូវទាមទារឱ្យសងថ្លៃលក់ជានិច្ចកាលទេ ។ ហេតុដូច្នេះ ម្ចាស់បំណុលហ៊ីប៉ូតែកអាចទាមទារឱ្យសងថ្លៃលក់បាន នៅពេលណាដែលខ្លួនយល់ឃើញថា អាចប្រមូលសិទ្ធិលើបំណុលរបស់ខ្លួនបាន តាមការសងថ្លៃលក់នេះ ។

ក្នុងកាលៈទេសៈធម្មតា អចលនវត្ថុដែលដាក់ហ៊ីប៉ូតែក ត្រូវបានលក់ទិញ បន្ទាប់ពីរំលត់ហ៊ីប៉ូតែក និង លុបចោលការចុះបញ្ជី (តាមការអនុវត្តជាក់ស្តែង អ្នកលក់ដែលជាកូនបំណុល យកប្រាក់ដែលទទួលពីអ្នកទិញ មកសងកាតព្វកិច្ចក្នុងគោលបំណងដើម្បីរំលត់ហ៊ីប៉ូតែក) ។ ក្នុងករណីនេះ បញ្ហានៃការសងថ្លៃលក់ហ៊ីប៉ូតែកនេះ នឹងមិនកើតឡើងឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៧៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

## កថាភាគទី ២ ការរលត់ដោយអាជ្ញាយុកាល

**មាត្រា ៨៦៥.–** អាជ្ញាយុកាលនៃការរំលត់ហ៊ីប៉ូតែក

ហ៊ីប៉ូតែកមិនត្រូវរលត់ដោយអាជ្ញាយុកាល ចំពោះកូនបំណុល និង អ្នកដែលបានបង្កើតហ៊ីប៉ូតែកឡើយ ប្រសិនបើសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកនោះមិនរលត់ព្រមគ្នាទេ ។

(កំណត់)

ចំពោះអាជ្ញាយុកាលនៃការរំលត់ហ៊ីប៉ូតែក មាត្រានេះចែងថា ហ៊ីប៉ូតែកមិនត្រូវរលត់ដោយអាជ្ញាយុកាល ដោយឯករាជ្យពីសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកនោះឡើយ ។ មានន័យថា ប្រសិនបើម្ចាស់បំណុលហ៊ីប៉ូតែកបានធ្វើនីតិវិធីផ្អាកអាជ្ញាយុកាល ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានា (សូមមើលមាត្រា ៤៨៩) ទោះបីជាម្ចាស់បំណុលមិនបានធ្វើនីតិវិធីផ្អាកអាជ្ញាយុកាលចំពោះហ៊ីប៉ូតែកក៏ដោយ ក៏ហ៊ីប៉ូតែកមិនត្រូវរលត់ឡើយ ។ បញ្ញត្តិនេះមានអត្ថប្រយោជន៍ ក្នុងករណីដែលកូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា មិនដូចគ្នានឹងអ្នកដែលទទួលបន្ទុកនូវហ៊ីប៉ូតែក (ឧ. កម្មសិទ្ធិករនៃដីដែលហ៊ីប៉ូតែកត្រូវបានបង្កើត ជាអាទិ៍) ។ ក្នុងករណីនេះ ម្ចាស់បំណុលហ៊ីប៉ូតែកគ្រាន់តែធ្វើនីតិវិធីផ្អាកអាជ្ញាយុកាល ចំពោះកូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៦៦.–** ការរលត់ហ៊ីប៉ូតែកដោយលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែកដោយអាជ្ញាយុកាល

ពេលដែលបុគ្គលក្រៅពីកូនបំណុល ឬ ក្រៅពីអ្នកដែលបានបង្កើតហ៊ីប៉ូតែក បានកាន់កាប់អចលនវត្ថុហ៊ីប៉ូតែក ដោយមានល័ក្ខខ័ណ្ឌចាំបាច់សម្រាប់អាជ្ញាយុកាលនៃការទទួលសិទ្ធិ ហ៊ីប៉ូតែកនោះត្រូវរលត់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះ

ករណីដែលតតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែកនោះ បានដឹងនៅពេលដែលខ្លួនបានធ្វើលទ្ធកម្មថា ហ៊ីប៉ូតែកត្រូវបានបង្កើតលើអចលនវត្ថុនោះ ។

(កំណត់)

វាក្យខណ្ឌទី ១ នៃមាត្រានេះចែងថា ហ៊ីប៉ូតែកត្រូវរលត់ ប្រសិនបើតតិយជនក្រៅពីកូនបំណុល ឬ អ្នកបង្កើតហ៊ីប៉ូតែក បានបំពេញល័ក្ខខ័ណ្ឌសម្រាប់អាជ្ញាយុកាលនៃលទ្ធកម្ម ចំពោះអចលនវត្ថុហ៊ីប៉ូតែក ។ បញ្ញត្តិនេះត្រូវបានរៀបចំឡើង ដោយសារលទ្ធកម្មនៃកម្មសិទ្ធិដោយអាជ្ញាយុកាល គឺមិនមែនជាលទ្ធកម្មបន្តទេ តែគឺជាលទ្ធកម្មកម្មសិទ្ធិដំបូង ។ មានន័យថា កម្មសិទ្ធិដែលត្រូវបានធ្វើលទ្ធកម្មដំបូង គឺជាកម្មសិទ្ធិពេញលេញដោយគ្មានបន្ទុក ។ ចំណែកឯចំពោះលទ្ធកម្មបន្ត ដូចជាលទ្ធកម្មកម្មសិទ្ធិតាមរយៈការលក់ទិញ អ្នកទិញធ្វើលទ្ធកម្មបន្តនូវកម្មសិទ្ធិរបស់អ្នកលក់ ហេតុដូច្នេះប្រសិនបើអ្នកទិញបានទិញដីដែលមានបន្ទុកហ៊ីប៉ូតែក អ្នកទិញនោះធ្វើលទ្ធកម្មនូវកម្មសិទ្ធិដែលមានបន្ទុកហ៊ីប៉ូតែក ។ម្យ៉ាងទៀត ហ៊ីប៉ូតែក គឺជាសិទ្ធិប្រត្យក្ស ហើយហ៊ីប៉ូតែកអាចត្រូវបានយកមកតតាំងចំពោះតតិយជននៅពេលចុះបញ្ជី ហេតុដូច្នេះ ទោះបីជាអ្នកទិញមិនបានដឹងអំពីអត្ថិភាពនៃហ៊ីប៉ូតែកក៏ដោយ ក៏ម្ចាស់បំណុលហ៊ីប៉ូតែក អាចអះអាងហ៊ីប៉ូតែករបស់ខ្លួន ចំពោះអ្នកទិញអចលនវត្ថុដែលបានដាក់ហ៊ីប៉ូតែកបានដែរ ។ ប៉ុន្តែ អាចមានករណីដែលបុគ្គលដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិតាមរយៈការលក់ទិញ ឬ ប្រទានកម្ម ជាអាទិ៍ មិនអាចបញ្ជាក់អំពីមូលហេតុនៃលទ្ធកម្ម ហើយអះអាងអំពីលទ្ធកម្មកម្មសិទ្ធិដោយអាជ្ញាយុកាល ជំនួសការលក់ទិញ ឬ ប្រទានកម្ម ។ ដូច្នេះ វាក្យខណ្ឌទី ២ នៃមាត្រានេះចែងយ៉ាងច្បាស់ថា ហ៊ីប៉ូតែកមិនត្រូវរលត់ទេ ប្រសិនបើតតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែក បានដឹងថា ហ៊ីប៉ូតែកត្រូវបានបង្កើតឡើងលើអចលនវត្ថុនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៧ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត

**មាត្រា ៨៦៧.–** និយមន័យនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

១-ហ៊ីប៉ូតែកអាចបង្កើតដើម្បីធានាកាតព្វកិច្ចមិនកំណត់ ដែលអាចកើតមានឡើងរវាងម្ចាស់បំណុល និង កូនបំណុល ដោយសារការជួញដូរជានិរន្តរ៍ដែលមានប្រភេទជាកំណត់ ក្នុងកម្រិតនៃចំនួនអតិបរមាបាន ។ ហ៊ីប៉ូតែកបែបនេះ ត្រូវហៅថា ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។

២-ចំពោះទំហំនៃសិទ្ធិលើបំណុលមិនកំណត់ ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ដើម្បីធានាបំណុលអណ្តែត ត្រូវកំណត់នៅក្នុងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។

(កំណត់)

មាត្រានេះចែងអំពីនិយមន័យនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ហើយបញ្ជាក់ថា ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត គឺជាប្រភេទមួយនៃហ៊ីប៉ូតែកដែលត្រូវបានបង្កើតឡើង សម្រាប់គោលបំណងធានាសិទ្ធិលើបំណុលដែលកើតឡើងពីការជួញដូរជានិរន្តរ៍ ក្នុងកម្រិតមួយជាក់លាក់ (កម្រិតនៃចំនួនទឹកប្រាក់ដែលត្រូវធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវហៅថា "ចំនួនអតិបរមា") ។ ហ៊ីប៉ូតែកធម្មតា ត្រូវបានបង្កើតឡើង ដើម្បីធានាសិទ្ធិលើបំណុលដែលមានជាក់លាក់ (ទោះបីជាសិទ្ធិលើបំណុល និង ហ៊ីប៉ូតែកត្រូវបានបង្កើតដំណាលគ្នាក្នុងករណីជាច្រើន ដូចជាការខ្ចីប្រាក់ដោយការបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុក៏ដោយ) ។ ប៉ុន្តែ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវបានបង្កើតឡើងដើម្បីធានាសិទ្ធិលើបំណុលដែលនឹងកើតឡើងនៅពេលអនាគតដែលកើតឡើងពីការជួញដូរជានិរន្តរ៍ (ជួនកាល ហៅថា "កិច្ចសន្យាមូលដ្ឋាន") ។ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត គឺជាករណីលើកលែងនៃភាពបន្ទាប់បន្សំនៃសិទ្ធិប្រាតិភោគប្រត្យក្ស (មាត្រា ៧៦៩ នៃក្រមរដ្ឋប្បវេណី) ។

ដូចដែលបានរៀបរាប់ខាងលើ សិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត នឹងកើតឡើង និង រលត់ដោយការសង ជាអាទិ៍ ក្នុងដំណើរការជួញដូរជានិរន្តរ៍ ប៉ុន្តែ នៅពេលដែលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតត្រូវបានអនុវត្ត (មានន័យថា ក្នុងករណីដែលអចលនវត្ថុនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវបានលក់ ហើយម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ទទួលការសងដោយមានអាទិភាពពីប្រាក់ដែលបានមកពីការលក់) មានភាពចាំបាច់ត្រូវកំណត់សិទ្ធិលើបំណុលដែលអាចទទួលការសងដោយមានអាទិភាព ពីប្រាក់ដែលបានមកពីការលក់អចលនវត្ថុនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។ ហេតុដូច្នេះ ដើម្បីអនុវត្តហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត សិទ្ធិលើបំណុលដែលអាចទទួលការសងជាអាទិភាពត្រូវតែកំណត់ឱ្យបានច្បាស់លាស់ ។ នីតិវិធីនេះហៅថា "ការកំណត់ប្រាក់ដើមជាស្ថាពរ" ។ សិទ្ធិលើបំណុលដែលកើតឡើងក្រោយពេលដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ នឹងមិនត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតឡើយ ទោះបីជាសិទ្ធិលើបំណុលទាំងនោះ បានកើតឡើងពីការជួញដូរជានិរន្តរ៍ដែលជាកម្មវត្ថុនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតក៏ដោយ ។

ចំពោះការកំណត់ប្រាក់ដើមជាស្ថាពរ មានបញ្ញត្តិក្នុងមាត្រាជាបន្តបន្ទាប់ (មាត្រា ៨៧១ មាត្រា ៨៨៤ និង មាត្រា ៨៨៥ នៃក្រមរដ្ឋប្បវេណី) ។ នៅពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវបានចាត់ទុកដូចគ្នានឹងហ៊ីប៉ូតែកធម្មតាដែលបានបង្កើតឡើងដើម្បីធានាសិទ្ធិលើបំណុលជាក់លាក់ដែរ ។

ដោយសារហ៊ីប៉ូតែកធម្មតាត្រូវបានបង្កើតឡើងដើម្បីធានាសិទ្ធិលើបំណុលជាក់លាក់ ហ៊ីប៉ូតែកនេះត្រូវរលត់នៅពេល

ដែលសិទ្ធិលើបំណុលដែលត្រូវបានធានាត្រូវបានសង ។ ហេតុដូច្នេះ ប្រសិនបើមានតែហ៊ីប៉ូតែកធម្មតា ក្នុងករណីដែលសហគ្រាសមួយខ្ចីលុយដដែលៗពីធនាគារក្នុងដំណើរការអាជីវកម្មរបស់ខ្លួន រៀងរាល់ពេលដែលសហគ្រាសនោះខ្ចីប្រាក់ សហគ្រាសនោះត្រូវបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុ ចុះបញ្ជីហ៊ីប៉ូតែក និង លុបការចុះបញ្ជីហ៊ីប៉ូតែកនៅពេលដែលសហគ្រាសបានសងបំណុលនីមួយៗ ។ នីតិវិធីនេះមានការពិបាក និង ស្មុគស្មាញដោយគ្មានមន្ទិលសង្ស័យ ។ ដូចគ្នានេះដែរ អាចមានករណីដែលសហគ្រាសនេះទទួលបាននូវហ៊ីប៉ូតែកលំដាប់ទី ១ នៅពេលដែលធនាគារឱ្យប្រាក់កម្ចីលើកទី ១ ប៉ុន្តែ អាចទទួលបានទេហ៊ីប៉ូតែកលំដាប់ទី ២ ឬ ទាបជាងនោះ ចំពោះប្រាក់កម្ចីនៅពេលបន្ទាប់ ។ ហេតុដូច្នេះ ក្នុងករណីដែលសិទ្ធិលើបំណុលបានកើតឡើង និង រលត់ នៅពេលដែលសិទ្ធិលើបំណុលនោះត្រូវបានសងជាបន្តបន្ទាប់ ដោយសារការជួញដូរជានិរន្តរ៍នោះ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចធានាសិទ្ធិលើបំណុលទាំងនេះ ដោយបង្កើតហ៊ីប៉ូតែកតែមួយប៉ុណ្ណោះនៅពេលនោះ ។ នៅក្នុងប្រទេសជប៉ុន ប្រភេទនៃហ៊ីប៉ូតែកមានប្រភពចេញពីតម្រូវការក្នុងប្រតិបត្តិការជំនួញ ប៉ុន្តែ ឥឡូវនេះ ហ៊ីប៉ូតែកប្រភេទនេះមានក្នុងក្រមរដ្ឋប្បវេណីជប៉ុនដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-២ នៃក្រមរដ្ឋប្បវេណីជប៉ុន

## **មាត្រា ៨៦៨.–** ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចអនុវត្តហ៊ីប៉ូតែកនោះ ក្នុងកម្រិតនៃចំនួនអតិបរមាបាន ចំពោះប្រាក់ដើមដែលបានកំណត់ជាស្ថាពរ ការប្រាក់ និង ធនលាភផ្សេង និង សំណងការខូចខាតទាំងអស់ដែលបានកើតឡើង ដោយសារការមិនអនុវត្តកាតព្វកិច្ច ។

(កំណត់)

មាត្រានេះចែងអំពីទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា មានន័យថា ទំហំនៃសិទ្ធិលើបំណុលដែលម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចទទួលការសងដោយមានអាទិភាពលើម្ចាស់បំណុលផ្សេងទៀត ។

ដោយសារសិទ្ធិលើបំណុលដែលត្រូវបានធានា មិនទាន់កើតឡើងនៅពេលបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត មានចាំបាច់ត្រូវកំណត់ជាមុននូវទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ក្នុងកម្រិតនៃចំនួនអតិបរមាដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។ កម្រិតនៃចំនួនអតិបរមា រួមមានមិនត្រឹមតែប្រាក់ដើមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការប្រាក់ និង ធនលាភផ្សេងៗផងដែរ ។ ក្នុងករណីហ៊ីប៉ូតែកធម្មតា ចំនួនប្រាក់ដើមនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ត្រូវបានកំណត់រួចជាស្រេចនៅពេលបង្កើតហ៊ីប៉ូតែក ប៉ុន្តែ សិទ្ធិក្នុងការទទួលការសងដោយមានអាទិភាពអាចអនុវត្តបានចំពោះតែប្រាក់ដើម និង ការប្រាក់ ឬ ធនលាភផ្សេងៗ ដែលដល់កំណត់ពេលសម្រាប់អំឡុងពេល ២ ឆ្នាំ

ចុងក្រោយប៉ុណ្ណោះ (មាត្រា ៨៥២ នៃក្រមរដ្ឋប្បវេណី) ។ ការប្រាក់ និង ប្រាក់សំណងការខូចខាត ក្រៅពីទំហំនេះ មិនត្រូវបានធានាដោយហ៊ីប៉ូតែកឡើយ ។ ផ្ទុយទៅវិញ ក្នុងករណីនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត អាចទទួលការសងដោយមានអាទិភាព ចំពោះការប្រាក់ និង ប្រាក់សំណងការខូចខាតទាំងអស់ ដោយគ្មានកម្រិតអំឡុងពេល ២ ឆ្នាំ ចុងក្រោយទេ ប៉ុន្តែ ចំនួនប្រាក់ដើម និង ការប្រាក់ និង ប្រាក់សំណងការខូចខាតនោះ ត្រូវស្ថិតនៅក្រោមចំនួនអតិបរមា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៨៦៩.- ការកែប្រែទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

១-ក្នុងចន្លោះពេលទៅទល់នឹងពេលដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ភាគីនៃកិច្ចសន្យាបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត អាចកែប្រែទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត តាមការព្រមព្រៀងបាន ។

២-ដើម្បីធ្វើការកែប្រែដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំចាំបាច់ទទួលការយល់ព្រមពីម្ចាស់បំណុលហ៊ីប៉ូតែកដែលមានអាទិភាពទាបជាង និង តតិយជនឯទៀតឡើយ ។

៣-ការកែប្រែដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចុះបញ្ជីនៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះចែងថា ភាគីនៃកិច្ចសន្យាបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត អាចកែប្រែទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត តាមការព្រមព្រៀងបាន មុនពេលដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ។ កថាខណ្ឌនេះអាចអនុវត្ត ចំពោះករណីដែលទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាត្រូវបានកែប្រែ ដោយសារការកែប្រែខ្លឹមសារនៃការជួញដូរជានិរន្តរ៍ ។ ប៉ុន្តែ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត ត្រូវបានចាត់ទុកដូចគ្នានឹងហ៊ីប៉ូតែកធម្មតា នៅពេលដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ហេតុដូច្នេះ ក្រោយពេលនោះ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត មិនអាចកែប្រែបានទេ ។

កថាខណ្ឌទី ២ ចែងថា ក្នុងករណីដែលរៀបរាប់ខាងលើនេះ ពុំចាំបាច់ទទួលការយល់ព្រមពីម្ចាស់បំណុលហ៊ីប៉ូតែកដែលមានអាទិភាពទាបជាងទេ ។ ការកំណត់បែបនេះ ពីព្រោះតែម្ចាស់បំណុលហ៊ីប៉ូតែកដែលមានអាទិភាពទាបជាង គួរតែត្រៀមខ្លួនជាស្រេចថា ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត ត្រូវមានអាទិភាព ក្នុងទំហំនៃចំនួនអតិបរមា

នៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ហើយមិនត្រូវទទួលរងការខូចខាតណាមួយទេ បើទោះបីជាមានការកែប្រែទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដែលមានអាទិភាពខ្ពស់ជាងក៏ដោយ ។ ប៉ុន្តែ ក្នុងករណីដែលកែប្រែចំនួនអតិបរមា (ជាពិសេស ការកើនឡើងនូវចំនួនទឹកប្រាក់) អាចធ្វើឱ្យម្ចាស់បំណុលហ៊ីប៉ូតែកដែលមានអាទិភាពទាបជាង ខូចខាតផលប្រយោជន៍ ។ ហេតុដូច្នេះ មាត្រាបន្ទាប់ចែងថា ការកែប្រែចំនួនអតិបរមា តម្រូវឱ្យមានការយល់ព្រមពីម្ចាស់បំណុលហ៊ីប៉ូតែកដែលមានអាទិភាពទាបជាង ។

កថាខណ្ឌទី ៣ ចែងថា ការកែប្រែទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា តម្រូវឱ្យមានការចុះបញ្ជី នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៨៧០.- ការកែប្រែចំនួនអតិបរមា

១-ភាគីនៃកិច្ចសន្យាបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចកែប្រែចំនួនអតិបរមានៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត តាមការព្រមព្រៀងបាន ។

២-ដើម្បីធ្វើការកែប្រែដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវទទួលការយល់ព្រមពីសំណាក់ជនដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ ។

៣-ការកែប្រែដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំអាចតតាំងជាមួយនឹងតតិយជនក្រៅពីជនដែលបានយល់ព្រមតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះឡើយ បើមិនបានចុះបញ្ជី ។

(កំណត់)

មាត្រានេះចែងថា ភាគីនៃកិច្ចសន្យាបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចកែប្រែចំនួនអតិបរមានៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតបាន ហើយមាត្រានេះក៏បានចែងអំពីនីតិវិធីនៃការកែប្រែដែរ ។ ប៉ុន្តែ ការកែប្រែចំនួនអតិបរមា អាចធ្វើឱ្យប៉ះពាល់ដល់តតិយជន ហេតុដូច្នេះ កថាខណ្ឌទី ២ ចែងថា ការកែប្រែនេះ ចាំបាច់ត្រូវទទួលការយល់ព្រមពីសំណាក់ជនដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ ។ ជនដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ ក្នុងករណីដែលកើនឡើងនូវចំនួនអតិបរមា រួមមានម្ចាស់បំណុលហ៊ីប៉ូតែកដែលមានអាទិភាពទាបជាង និង ម្ចាស់បំណុលដែលបានរឹបអូសអចលនវត្ថុហ៊ីប៉ូតែក ជាអាទិ៍ ចំណែកឯក្នុងករណីដែលបន្ថយចំនួនអតិបរមា ជនដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ មានដូចជាម្ចាស់បំណុលហ៊ីប៉ូតែកបន្ត (មាត្រា ៨៥៩ នៃក្រមរដ្ឋប្បវេណី) ជាអាទិ៍ ។

កថាខណ្ឌទី ៣ ចែងថា ការកែប្រែដែលចំនួនអតិបរមា ពុំអាចតតាំងជាមួយនឹងតតិយជនក្រៅពីជនដែលបានយល់ព្រមតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ឡើយ បើមិនបានចុះបញ្ជី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៧១.–** កាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ

១-ចំពោះប្រាក់ដើមដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចកំណត់កាលបរិច្ឆេទដែលប្រាក់ដើមនោះត្រូវបានកំណត់ជាស្ថាពរ ហើយក៏អាចប្តូរកាលបរិច្ឆេទដែលត្រូវបានកំណត់រួចហើយនោះបានដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៨៦៩ (ការកែប្រែទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៣-កាលបរិច្ឆេទដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវស្ថិតនៅក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃដែលបានកំណត់ ឬ ប្តូរកាលបរិច្ឆេទនោះ ។

៤-ចំពោះការប្តូរកាលបរិច្ឆេទដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចុះបញ្ជីនៅមុនកាលបរិច្ឆេទនោះ ។

(កំណត់)

**១. កាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ**

ដូចដែលបានបង្ហាញខាងលើ (សូមមើលសេចក្តីកំណត់នៃមាត្រា ៨៦៧) ការកំណត់ប្រាក់ដើមជាស្ថាពរ គឺជាការចាំបាច់ដើម្បីអនុវត្តហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។ កថាខណ្ឌទី ១ នៃមាត្រានេះចែងថា ភាគីពាក់ព័ន្ធអាចកំណត់កាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ជាមុន តាមការព្រមព្រៀងបាន (កាលបរិច្ឆេទមិនចាំបាច់ដូចគ្នានឹងកាលបរិច្ឆេទដើម្បីបញ្ចប់ការជួញដូរជានិរន្តរ៍ ដែលជាមូលដ្ឋាននៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតទេ) ។ ជាការពិតណាស់ ភាគីពាក់ព័ន្ធក៏អាចបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដោយមិនកំណត់កាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរបានដែរ ។ ក្នុងករណីនេះ ប្រាក់ដើមនឹងត្រូវបានកំណត់ជាស្ថាពរ តាមការទាមទារឱ្យកំណត់ប្រាក់ដើម ឬនៅពេលដែលមូលហេតុជាក់លាក់កើតឡើង (មាត្រា ៨៨៤ និង មាត្រា ៨៨៥ នៃក្រមរដ្ឋប្បវេណី) ។ ក្នុងករណីដែលភាគីកំណត់កាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ តាមការព្រមព្រៀង កាលបរិច្ឆេទនោះត្រូវស្ថិតនៅក្នុងអំឡុងពេល ៥ ឆ្នាំ គិតចាប់ពីថ្ងៃដែលបានកំណត់កាលបរិច្ឆេទនោះ (កថាខណ្ឌទី ៣ នៃមាត្រានេះ) ។ គោលបំណងនៃកថាខណ្ឌនេះ គឺដើម្បីជៀសវាងការចងបន្ទុករយៈពេលយូរពេក ។

**២.ការប្តូរកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ**

កាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ដែលត្រូវបានកំណត់ដោយភាគី អាចប្តូរបានតាមការព្រមព្រៀង ។ ក្នុងករណីនេះ កាលបរិច្ឆេទដែលបានប្តូរនោះក៏ត្រូវស្ថិតនៅក្នុងអំឡុងពេល ៥ ឆ្នាំ គិតចាប់ពីថ្ងៃដែលបានប្តូរកាលបរិច្ឆេទនោះដែរ ។ នៅពេលប្តូរកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ភាគីពាក់ព័ន្ធត្រូវចុះបញ្ជីនៅមុនកាលបរិច្ឆេទដើមដែលបានប្តូរនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៧២.–** អនុប្បទានសិទ្ធិលើបំណុលដែលត្រូវបានធានា ឬ ការទទួលកាតព្វកិច្ច

១-ជនដែលបានធ្វើលទ្ធកម្មនូវសិទ្ធិលើបំណុលពីម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ពុំអាចអនុវត្តហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតចំពោះសិទ្ធិលើបំណុលនោះបានឡើយ ។ ជនដែលបានសងដើម្បីកូនបំណុល ឬ ជំនួសកូនបំណុល នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ក៏ពុំអាចអនុវត្តហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដោយឧបាទេសកម្មដោយការសងបានឡើយ ។

២-បើមានការទទួលកាតព្វកិច្ចមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ពុំអាចអនុវត្តហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះ ចំពោះកាតព្វកិច្ចរបស់អ្នកទទួលបានឡើយ ។

(កំណត់)

មាត្រានេះចែងថា ភាពទៅជាមួយគ្នាដែលត្រូវបានទទួលស្គាល់ជាលក្ខណៈទូទៅនៃប្រាតិភោគ (នៅពេលសិទ្ធិលើបំណុលដែលត្រូវបានធានាដោយប្រាតិភោគត្រូវបានផ្ទេរ ប្រាតិភោគនោះក៏ត្រូវបានផ្ទេរដែរ) មិនត្រូវបានទទួលស្គាល់ចំពោះហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតឡើយ ។ ភាពទៅជាមួយគ្នាត្រូវបានបដិសេធ សម្រាប់ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដើម្បីជៀសវាងបង្កទំនាក់ទំនងស្មុគស្មាញក្នុងចំណោមភាគីដែលពាក់ព័ន្ធ ។

កថាខណ្ឌទី ១ ចែងថា ក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានា ត្រូវបានធ្វើអនុប្បទាន នៅមុនពេលដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ អនុប្បទានិកនៃសិទ្ធិលើបំណុលនោះ មិនអាចអនុវត្តហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតបានឡើយ ។ ក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកធម្មតា ត្រូវបានធ្វើអនុប្បទានហ៊ីប៉ូតែកត្រូវបានផ្ទេរទៅអនុប្បទានិកជាមួយគ្នានឹងសិទ្ធិលើបំណុលដែលត្រូវបានធានា (ហៅថា ភាពទៅជាមួយគ្នា) ហើយជាគោលការណ៍ អនុប្បទានិកនៃសិទ្ធិលើបំណុល អាចអនុវត្តហ៊ីប៉ូតែកបាន (ប៉ុន្តែ ភាគីនៃអនុប្បទាននៃសិទ្ធិលើបំណុល

អាចបែងចែកសិទ្ធិលើបំណុល ចេញពីហ៊ីប៉ូតែក ហើយធ្វើអនុប្បទានតែសិទ្ធិលើបំណុលប៉ុណ្ណោះ តាមការព្រមព្រៀងបាន) ។ កថាខណ្ឌនេះចែងថា ភាពទៅជាមួយគ្នានឹងមិនអាចទទួលយកបានទេ ក្នុងករណីនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។

បន្ថែមពីនេះ ក្នុងករណីដែលតតិយជនក្រៅពីកូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា សងកាតព្វកិច្ច នៅមុនពេលដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ហើយធ្វើឧបាទេសកម្មចំពោះម្ចាស់បំណុល (ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត) (មាត្រា ៤៥៩ នៃក្រមរដ្ឋប្បវេណី) តតិយជននោះក៏មិនត្រូវបានអនុញ្ញាតឱ្យអនុវត្តហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតបានឡើយ ។ ការកំណត់បែបនេះ ពីព្រោះតែឧបាទេសិកដោយការសង ស្ថិតនៅក្នុងឋានៈសារធាតុ ដូចគ្នានឹងអនុប្បទានិកនៃសិទ្ធិលើបំណុល ។

កថាខណ្ឌទី ២ ចែងថា ប្រសិនបើតតិយជនបានក្លាយជាកូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ដោយទទួលកាតព្វកិច្ច នៅមុនពេលដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត មិនអាចអនុវត្តចំពោះកាតព្វកិច្ចរបស់តតិយជនដែលទទួលកាតព្វកិច្ចបានឡើយ ។ ការកំណត់បែបនេះ ពីព្រោះតែបុគ្គលដែលទទួលកាតព្វកិច្ច មានឋានៈដូចគ្នានឹងតតិយជនដែលសងកាតព្វកិច្ចជំនួសកូនបំណុល ។ កថាខណ្ឌនេះអនុវត្តចំពោះការទទួលកាតព្វកិច្ចដែលឱ្យកូនបំណុលដើមរួចផុតពីកាតព្វកិច្ចផង (កូនបំណុលដើមរួចផុតពីកាតព្វកិច្ច) ការទទួលកាតព្វកិច្ចដំណាលគ្នាផង (កូនបំណុលដើមមិនរួចផុតពីកាតព្វកិច្ច ហើយបន្តទទួលបន្ទុកនូវកាតព្វកិច្ចជាមួយគ្នានឹងបុគ្គលដែលបានទទួលកាតព្វកិច្ចនោះ) ។

ដូចដែលបានបង្ហាញខាងលើ ករណីដែលភាពទៅជាមួយគ្នាមិនត្រូវបានទទួលស្គាល់ គឺជាករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានាត្រូវបានធ្វើអនុប្បទាន និង កាតព្វកិច្ចត្រូវបានទទួល នៅមុនពេលដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ។ ផ្ទុយទៅវិញ នៅពេលដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ សិទ្ធិលើបំណុលដែលត្រូវបានធានាត្រូវបានបញ្ជាក់ឱ្យបានច្បាស់ ហេតុដូច្នេះ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតក្រោយពេលដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ មានភាពទៅជាមួយគ្នា ដូចហ៊ីប៉ូតែកធម្មតា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-៧ នៃក្រមរដ្ឋប្បវេណីជប៉ុន ។

## មាត្រា ៨៧៣.– សន្តតិកម្មពីម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ឬ កូនបំណុល

១-បើសន្តតិកម្មបានចាប់ផ្តើមចំពោះម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះ ត្រូវធានានូវសិទ្ធិលើបំណុលដែលមានអត្ថិភាពនៅពេលសន្តតិកម្មបានចាប់ផ្តើម ។ម្យ៉ាងទៀត ហ៊ីប៉ូតែកនោះត្រូវធានានូវសិទ្ធិលើបំណុលដែលនឹងត្រូវបានធ្វើលទ្ធកម្ម

នៅក្រោយពេលសន្តតិកម្មបានចាប់ផ្តើម ដោយសន្តតិជនដែលត្រូវបានកំណត់តាមការព្រមព្រៀងរវាងសន្តតិជន និង អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។

២-បើសន្តតិកម្មបានចាប់ផ្តើមចំពោះកូនបំណុល នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះ ត្រូវធានានូវកាតព្វកិច្ចដែលមានអត្ថិភាពនៅពេលសន្តតិកម្មបានចាប់ផ្តើម ។ ម្យ៉ាងទៀត ហ៊ីប៉ូតែកនោះ ត្រូវធានានូវកាតព្វកិច្ចដែលនឹងត្រូវបានទទួលបន្ទុក នៅក្រោយពេលសន្តតិកម្មបានចាប់ផ្តើម ដោយសន្តតិជនដែលត្រូវបានកំណត់តាមការព្រមព្រៀងរវាងម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត និង អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៨៦៩ (ការកែប្រែទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលធ្វើការព្រមព្រៀងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ។

៤-ចំពោះការព្រមព្រៀងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ បើមិនបានចុះបញ្ជីក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ក្រោយពេលសន្តតិកម្មបានចាប់ផ្តើមទេ ប្រាក់ដើមដែលត្រូវបានធានា ត្រូវចាត់ទុកថា បានកំណត់ជាស្ថាពរ នៅពេលសន្តតិកម្មបានចាប់ផ្តើម ។

(កំណត់)

មាត្រានេះពាក់ព័ន្ធនឹងប្រតិបត្តិការនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ឬ កូនបំណុលបានទទួលមរណភាព ហើយសន្តតិកម្មបានចាប់ផ្តើមចំពោះជននោះ មុនពេលការកំណត់ប្រាក់ដើមជាស្ថាពរ ។

កថាខណ្ឌទី ១ ចែងថា ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានទទួលមរណភាព ហើយសន្តតិកម្មបានចាប់ផ្តើម ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះ នឹងត្រូវធានាសិទ្ធិលើបំណុលដែលមានអត្ថិភាព នៅពេលដែលសន្តតិកម្មបានចាប់ផ្តើម ។ កថាខណ្ឌនេះចែងផងដែរថា ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះត្រូវធានានូវសិទ្ធិលើបំណុលដែលនឹងត្រូវបានធ្វើលទ្ធកម្ម នៅក្រោយពេលសន្តតិកម្មបានចាប់ផ្តើម ដោយសន្តតិជនដែលត្រូវបានកំណត់ (ឧទាហរណ៍ សន្តតិជនដែលទទួលបន្តនូវជំនួញជានិរន្តរ៍) តាមការព្រមព្រៀងរវាងសន្តតិជន (ត្រូវបានបកស្រាយថាជាសហសន្តតិជនទាំងអស់) និង អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។

កថាខណ្ឌទី ២ ចែងថា ក្នុងករណីដែលអ្នកដែលបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានទទួលមរណភាព

ហើយសន្តតិកម្មបានចាប់ផ្តើម ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះ នឹងត្រូវធានានូវសិទ្ធិលើបំណុលដែលមានអត្ថិភាពនៅពេលសន្តតិកម្មបានចាប់ផ្តើម ។ កថាខណ្ឌនេះចែងផងដែរថា ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះត្រូវធានានូវសិទ្ធិលើបំណុលដែលនឹងត្រូវបានធ្វើលទ្ធកម្ម នៅក្រោយពេលសន្តតិកម្មបានចាប់ផ្តើម ដោយសន្តតិជនដែលត្រូវបានកំណត់ (ឧទាហរណ៍ សន្តតិជនដែលទទួលបន្តនូវជំនួញជានិរន្តរ៍) តាមការព្រមព្រៀងរវាងម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត និង សន្តតិជន (ត្រូវបានបកស្រាយថាជា សហសន្តតិជនទាំងអស់) ។

កថាខណ្ឌទី ៣ ចែងថា បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៨៦៩ ស្តីពីការកែប្រែទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ត្រូវយកមកអនុវត្តដូចគ្នាផងដែរ មានន័យថា ការព្រមព្រៀងទាំងនេះមិនចាំបាច់ទទួលបានការយល់ព្រមពីតតិយជនទេ ។

កថាខណ្ឌទី ៤ ចែងថា កិច្ចព្រមព្រៀងទាំងនេះតម្រូវឱ្យមានការចុះបញ្ជីក្នុងអំឡុងពេល ៦ ខែ ហើយប្រសិនបើកិច្ចព្រមព្រៀងទាំងនេះមិនបានចុះបញ្ជីក្នុងអំឡុងពេល ៦ ខែ ទេ ប្រាក់ដើមត្រូវចាត់ទុកថា ត្រូវបានកំណត់ជាស្ថាពរនៅពេលសន្តតិកម្មបានចាប់ផ្តើម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៧៤.-** ការរួមបញ្ចូលម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ឬ កូនបំណុល

១-បើមានការរួមបញ្ចូលម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដែលជានីតិបុគ្គល នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវធានានូវសិទ្ធិលើបំណុលដែលមានអត្ថិភាពនៅពេលរួមបញ្ចូល ហើយក្រៅពីនោះ ត្រូវធានានូវសិទ្ធិលើបំណុលដែលនឹងត្រូវបានធ្វើលទ្ធកម្មនៅក្រោយការរួមបញ្ចូលដោយនីតិបុគ្គលដែលបន្តអត្ថិភាពក្រោយការរួមបញ្ចូល ឬ នីតិបុគ្គលដែលត្រូវបានបង្កើតឡើងដោយការរួមបញ្ចូល ។

២-បើមានការរួមបញ្ចូលកូនបំណុលដែលជានីតិបុគ្គល នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវធានានូវកាតព្វកិច្ចដែលមានអត្ថិភាពនៅពេលរួមបញ្ចូល ហើយក្រៅពីនោះ ត្រូវធានានូវកាតព្វកិច្ចដែលនឹងត្រូវទទួលបន្ទុកនៅក្រោយការរួមបញ្ចូល ដោយនីតិបុគ្គលដែលបន្តអត្ថិភាពក្រោយការរួមបញ្ចូល ឬ នីតិបុគ្គលដែលត្រូវបានបង្កើតឡើងដោយការរួមបញ្ចូល ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចទាមទារឱ្យកំណត់ប្រាក់ដើមដែលត្រូវបានធានាជាស្ថាពរបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ហើយកូនបំណុលនោះ ជាអ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។

៤-បើមានការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ប្រាក់ដើមដែលត្រូវបានធានា ត្រូវចាត់ទុកថា បានកំណត់ជាស្ថាពរនៅពេលរួមបញ្ចូល ។

៥-ការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ មិនអាចធ្វើបានឡើយ បើអំឡុងពេល ២ (ពីរ) សប្តាហ៍ បានកន្លងហួស គិតចាប់ពីថ្ងៃដែលអ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានដឹងអំពីការរួមបញ្ចូលនោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអំឡុងពេល ១ (មួយ) ខែ បានកន្លងហួសគិតចាប់ពីថ្ងៃរួមបញ្ចូល ។

(កំណត់)

មាត្រានេះចែងអំពីការរួមបញ្ចូលគ្នារបស់នីតិបុគ្គល មុនការកំណត់ប្រាក់ដើមជាស្ថាពរ ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ឬ កូនបំណុល គឺជានីតិបុគ្គល ។ ឧទាហរណ៍ ប្រសិនបើនីតិបុគ្គលពីរ រួមបញ្ចូលគ្នាទៅជានីតិបុគ្គលតែមួយ ករណីនេះត្រូវបានបកស្រាយថា នីតិបុគ្គលក្រោយការរួមបញ្ចូលនោះ នឹងត្រូវទទួលបន្តដោយសាកលនូវសិទ្ធិលើបំណុល និង កាតព្វកិច្ច របស់នីតិបុគ្គលពីរដំបូង ។ បានសេចក្តីថា នីតិបុគ្គលថ្មីត្រូវបានចាត់ទុកថា មាននីតិបុគ្គលិកលក្ខណៈដូចគ្នានឹងនីតិបុគ្គលពីរដំបូងដែរ ។ ក្នុងន័យនេះ ការរួមបញ្ចូលនីតិបុគ្គលមានលក្ខណៈស្រដៀងគ្នានឹងសន្តតិកម្ម ។

កថាខណ្ឌទី ១ ចែងអំពីករណីនៃការរួមបញ្ចូលម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។ ប្រសិនបើម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដែលជានីតិបុគ្គលមួយ រួមបញ្ចូលជាមួយនីតិបុគ្គលមួយទៀត នៅមុនពេលដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត នឹងត្រូវធានាសិទ្ធិលើបំណុលដែលមានអត្ថិភាពនៅពេលរួមបញ្ចូល ព្រមទាំងសិទ្ធិលើបំណុលដែលនីតិបុគ្គលដែលបន្តអត្ថិភាពក្រោយការរួមបញ្ចូល ឬ នីតិបុគ្គលដែលត្រូវបានបង្កើតដោយការរួមបញ្ចូល នឹងធ្វើលទ្ធកម្ម នៅក្រោយការរួមបញ្ចូលផងដែរ ។

កថាខណ្ឌទី ២ ចែងអំពីការរួមបញ្ចូលនៃកូនបំណុល ។ ប្រសិនបើមានការរួមបញ្ចូលកូនបំណុលដែលជានីតិបុគ្គលនៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវធានានូវកាតព្វកិច្ចដែលមាន

អត្ថិភាព នៅពេលរួមបញ្ចូល ព្រមទាំងកាតព្វកិច្ចដែលនីតិបុគ្គលដែលបន្តអត្ថិភាពក្រោយការរួមបញ្ចូល ឬ នីតិបុគ្គលដែលត្រូវបានបង្កើតដោយការរួមបញ្ចូល នឹងត្រូវទទួលបន្ទុក នៅក្រោយការរួមបញ្ចូល ។

កថាខណ្ឌទី ៣ ចែងថា ក្នុងករណីខាងលើនេះ អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត អាចទាមទារឱ្យកំណត់ជាស្ថាពរនូវប្រាក់ដើមដែលត្រូវបានធានាបាន ។ ប៉ុន្តែ ប្រសិនបើកូនបំណុលដែលត្រូវបានរួមបញ្ចូល ជាអ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត (ក្នុងករណីច្រើន កូនបំណុលគឺជាអ្នកបង្កើតហ៊ីប៉ូតែក) បុគ្គលនោះមិនអាចទាមទារឱ្យកំណត់ប្រាក់ដើមជាស្ថាពរបានឡើយ ។

កថាខណ្ឌទី ៤ ចែងថា ប្រសិនបើមានការទាមទារឱ្យកំណត់ប្រាក់ដើមជាស្ថាពរដូចនៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ប្រាក់ដើមដែលត្រូវបានធានា ត្រូវចាត់ទុកថា បានកំណត់នៅពេលរួមបញ្ចូល ។

កថាខណ្ឌទី ៥ ចែងថា ការទាមទារឱ្យកំណត់ប្រាក់ដើមជាស្ថាពរដូចនៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ សប្ដាហ៍ គិតចាប់ពីថ្ងៃដែលអ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត បានដឹងអំពីការរួមបញ្ចូលនោះ ហើយមិនអាចធ្វើបានឡើយ បើអំឡុងពេល ២ សប្ដាហ៍ បានកន្លងហួស ។ ម្យ៉ាងទៀត ប្រសិនបើអំឡុងពេល ១ ខែ បានកន្លងហួស គិតចាប់ពីថ្ងៃរួមបញ្ចូល អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត មិនអាចទាមទារឱ្យកំណត់ប្រាក់ដើមជាស្ថាពរបានឡើយ ទោះបីជាមិនបានដឹងអំពីការរួមបញ្ចូលក៏ដោយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៧៥.–** ការបំបែកម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត ឬ កូនបំណុល

១-បើមានការបំបែកម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតដែលជានីតិបុគ្គល នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត ត្រូវធានានូវសិទ្ធិលើបំណុលដែលមានអត្ថិភាពនៅពេលបំបែក ហើយក្រៅពីនោះ ត្រូវធានានូវសិទ្ធិលើបំណុលដែលនឹងត្រូវបានធ្វើលទ្ធកម្មនៅក្រោយការបំបែក ដោយនីតិបុគ្គលដែលត្រូវបានបំបែក និង នីតិបុគ្គលដែលត្រូវបានបង្កើតឡើងដោយការបំបែក ឬ ដោយនីតិបុគ្គលដែលត្រូវបានបំបែក និង នីតិបុគ្គលដែលទទួលបន្តអាជីវកម្ម ។

២-បើមានការបំបែកកូនបំណុលដែលជានីតិបុគ្គល នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត ត្រូវធានានូវកាតព្វកិច្ចដែលមានអត្ថិភាពនៅពេលបំបែក ហើយក្រៅពីនោះ ត្រូវធានានូវកាតព្វកិច្ចដែលនឹងត្រូវទទួលបន្ទុក

នៅក្រោយការបំបែក ដោយនីតិបុគ្គលដែលត្រូវបានបំបែក និង នីតិបុគ្គលដែលត្រូវបានបង្កើតឡើង ដោយការបំបែក ឬ ដោយនីតិបុគ្គលដែលត្រូវបានបំបែក និង នីតិបុគ្គលដែលទទួលបន្តអាជីវកម្ម ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ៣ ទី ៤ និង ទី ៥ នៃមាត្រា ៨៧៤ (ការរួមបញ្ចូលម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត ឬ កូនបំណុល) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបញ្ញត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ នៃមាត្រានេះ ។

(កំណត់)

ផ្ទុយពីមាត្រាមុន មាត្រានេះចែងអំពីករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត ឬ កូនបំណុល គឺជានីតិបុគ្គល ហើយនីតិបុគ្គលនេះត្រូវបានបំបែក មុនពេលកំណត់ប្រាក់ដើមជាស្ថាពរ ។ ដូចជាក្នុងករណីការរួមបញ្ចូលនៃនីតិបុគ្គលដែរ នីតិបុគ្គលទាំងពីរក្រោយការបំបែកពីគ្នានឹងត្រូវទទួលបន្តដោយសាកលនូវសិទ្ធិលើបំណុល និង កាតព្វកិច្ចរបស់នីតិបុគ្គលដំបូង ហើយត្រូវបានចាត់ទុកថា មាននីតិបុគ្គលិកលក្ខណៈដូចគ្នា ។

ជាធម្មតា ទោះបីជានីតិបុគ្គលត្រូវបានបំបែកក៏ដោយ ក៏ការជួញដូរជានិរន្តរ៍ដែលនីតិបុគ្គលដើមបានធ្វើ នឹងត្រូវទទួលបន្តដោយនីតិបុគ្គលថ្មីដែរ ហេតុដូច្នេះ មាត្រានេះចែងថា ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត ត្រូវធានាសិទ្ធិលើបំណុល (កាតព្វកិច្ច) ដែលកើតឡើងក្រោយការបំបែក (កថាខណ្ឌទី ១ និង កថាខណ្ឌទី ២) ហើយអ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត (លើកលែងតែករណីដែលអ្នកបង្កើតហ៊ីប៉ូតែកជាកូនបំណុល) អាចទាមទារឱ្យកំណត់ប្រាក់ដើមជាស្ថាពរបាន (ការយកមកអនុវត្តដូចគ្នាផងដែរនៃកថាខណ្ឌទី ៣ និង កថាខណ្ឌទី ៤ នៃមាត្រាមុន ដោយយោងតាមកថាខណ្ឌទី ៣ នៃមាត្រានេះ) ។ ចំពោះនីតិវិធីចុះបញ្ជី ក៏ដូចគ្នានឹងករណីនៃការរួមបញ្ចូល (ការយកមកអនុវត្តដូចគ្នាផងដែរនៃកថាខណ្ឌទី ៥ នៃមាត្រាមុន ដោយយោងតាមកថាខណ្ឌទី ៣ នៃមាត្រានេះ ) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-១០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៧៦.–** ការចាត់ចែងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត

១-នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត មិនអាចធ្វើការចាត់ចែងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៨៦០ (អនុប្បទាន ឬ ការបោះបង់នូវហ៊ីប៉ូតែក) ឬ កថាខណ្ឌទី ១ នៃមាត្រា ៨៦១ (អនុប្បទាន ឬ ការបោះបង់ និង ការផ្លាស់ប្ដូរនូវលំដាប់នៃហ៊ីប៉ូតែក) ខាងលើនេះឡើយ ។

ប៉ុន្តែ បញ្ញត្តិនេះមិនរារាំងក្នុងការធ្វើការចាត់ចែងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៨៥៩ (ហ៊ីប៉ូតែកបន្ត) នៃក្រមនេះឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ៨៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះការសងដែលបានធ្វើឡើងមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ នៅក្នុងករណីដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រានេះ ។

(កំណត់)

ជាមួយមាត្រា ៨៧៧ និង មាត្រា ៨៧៨ មាត្រានេះចែងអំពីការចាត់ចែងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។ ដូចដែលបានចែងក្នុងមាត្រា ៨៥៩ មាត្រា ៨៦៩ និង មាត្រា ៨៦១ ការចាត់ចែងហ៊ីប៉ូតែកធម្មតា ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ។ ផ្ទុយទៅវិញ ចំពោះការចាត់ចែងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត មាត្រានេះ និង មាត្រា ៨៧៧ បានទទួលស្គាល់តែហ៊ីប៉ូតែកបន្ត និង អនុប្បទានប៉ុណ្ណោះ ហើយមិនអនុញ្ញាតឱ្យមានការចាត់ចែងផ្សេងទៀត (ឧទាហរណ៍ អនុប្បទានលំដាប់ ជាអាទិ៍) ទេ ។

កថាខណ្ឌទី ២ ចែងថា បញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ៨៦២ ទាក់ទងនឹងការចាត់ចែងហ៊ីប៉ូតែកធម្មតា មិនត្រូវយកមកអនុវត្តចំពោះហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតឡើយ ប្រសិនបើត្រូវបានធ្វើហ៊ីប៉ូតែកបន្ត ។ មានន័យថា ទោះបីជាម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានធ្វើហ៊ីប៉ូតែកបន្តនូវហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតរបស់ខ្លួនក៏ដោយ ក៏កូនបំណុលនៃហ៊ីប៉ូតែដើម្បីធានាបំណុលអណ្តែត អាចសងកាតព្វកិច្ចបានដែរ ។ ចំពោះការសងកាតព្វកិច្ចនេះ កាតព្វកិច្ចនឹងត្រូវរលត់ ដោយគ្មានការយល់ព្រមពីម្ចាស់បំណុលហ៊ីប៉ូតែកបន្តឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-១១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៧៧.–** អនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

១-នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចធ្វើអនុប្បទាននូវហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះ ដោយទទួលការយល់ព្រមពីអ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតបាន ។

២-ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចបែងចែកហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះជាពីរផ្នែក ហើយអាចធ្វើអនុប្បទានផ្នែកណាមួយ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។ ក្នុងករណីនេះ ប្រសិនបើហ៊ីប៉ូតែកដើម្បីធានា

បំណុលអណ្ណែតនោះ ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន សិទ្ធិរបស់តតិយជននោះ ត្រូវរលត់ចំពោះផ្នែកនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលត្រូវបានធ្វើអនុប្បទាន ។

៣-ដើម្បីធ្វើអនុប្បទានដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវទទួលការយល់ព្រមពីតតិយជនដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី២ នៃកថាខណ្ឌទី២ ដដែលនេះ ។

(កំណត់)

មាត្រានេះចែងអំពីអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។

កថាខណ្ឌទី ១ ចែងថា ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចធ្វើអនុប្បទាននូវហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតទាំងមូល ដោយបំបែកចេញពីសិទ្ធិលើបំណុលដែលត្រូវបានធានាបាន នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ដោយទទួលការយល់ព្រមពីអ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត (ឬ តតិយជនដែលបានធ្វើលទ្ធកម្មក្នុងករណីដែលអចលនវត្ថុហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតត្រូវបានធ្វើអនុប្បទានទៅតតិយជន) ។ អនុប្បទានិកអាចប្រើប្រាស់តម្លៃប្រាតិភោគនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដោយការផ្លាស់ប្តូរទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា (មាត្រា ៨៦៩ នៃក្រមរដ្ឋប្បវេណី) ជាអាទិ៍ ។

កថាខណ្ឌទី ២ ទទួលស្គាល់ការបែងចែកហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតជាពីរ ហើយធ្វើអនុប្បទានណាមួយ ។ ក្នុងករណីនេះ កថាខណ្ឌនេះចែងថា ប្រសិនបើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត គឺជាកម្មវត្ថុនៃសិទ្ធិផ្សេងទៀត (ឧទាហរណ៍ ក្នុងករណីហ៊ីប៉ូតែកបន្ត) សិទ្ធិរបស់តតិយជន ត្រូវរលត់ ចំពោះផ្នែកនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដែលត្រូវបានធ្វើអនុប្បទាន ។

គួរបកស្រាយថា អនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតទាំងមូល និង អនុប្បទានមួយផ្នែកនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត មិនអាចតតាំងចំពោះតតិយជនបានទេ ប្រសិនបើអនុប្បទាននោះមិនបានចុះបញ្ជី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-១២ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៧៨.–** អនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតមួយផ្នែក

នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចធ្វើអនុប្បទាននូវហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតមួយផ្នែក ដោយទទួលការយល់ព្រមពីអ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ហើយអាចធ្វើជាម្ចាស់សិទ្ធិរួមជាមួយអនុប្បទានិកបាន ។

(កំណត់)

មាត្រានេះចែងអំពីអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតមួយផ្នែក ។ កថាខណ្ឌទី ២ នៃមាត្រាមុនចែងអំពីការបែងចែកហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតមួយទៅជាពីរផ្នែក ហើយអនុប្បទានមួយផ្នែក ដូច្នេះ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតដែលបានបែងចែកទាំងពីរ នឹងត្រូវខុសគ្នា និង ឯករាជ្យពីគ្នា ។ ផ្ទុយទៅវិញ មាត្រានេះទទួលស្គាល់អនុប្បទានមួយផ្នែកនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតមួយ ។ ក្នុងករណីនេះ ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតពីរនាក់ បានធ្វើជាម្ចាស់រួមគ្នាលើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតមួយ និង ប្រើប្រាស់ហ៊ីប៉ូតែកនោះរួមគ្នា ។ ទំនាក់ទំនងនៃសិទ្ធិរួមនេះ ត្រូវបានចែងក្នុងមាត្រា ៨៧៩ ខាងក្រោម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-១៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៧៩.–** សិទ្ធិរួមលើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត

១-ម្ចាស់សិទ្ធិរួមលើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត ត្រូវទទួលនូវការសងតាមសមាមាត្រនៃសិទ្ធិលើបំណុលនីមួយៗ ។ ប៉ុន្តែ បើកំណត់ចំណែកភាគផ្សេងពីករណីខាងលើមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ឬ បើកំណត់ថា ជនណាម្នាក់អាចទទួលការសង ដោយមានអាទិភាពជាងជនឯទៀត ត្រូវអនុលោមតាមការកំណត់នោះ ។

២-ម្ចាស់សិទ្ធិរួមលើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត អាចធ្វើអនុប្បទាននូវសិទ្ធិរបស់ខ្លួន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៨៧៧ (អនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត) ខាងលើនេះ ដោយទទួលការយល់ព្រមពីម្ចាស់សិទ្ធិរួមឯទៀត ។

(កំណត់)

មាត្រានេះចែងអំពីទំនាក់ទំនងក្នុងចំណោមភាគីពីរ ឬ ច្រើន ដែលជាម្ចាស់សិទ្ធិរួមលើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតមួយ ។ សភាពនៃសិទ្ធិរួមលើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតមួយបានកើតឡើងមិនគ្រាន់តែក្នុងករណីនៃអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតមួយផ្នែកដែលបានចែងក្នុងមាត្រាមុនប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងកើតឡើងផងដែរ ជាឧទាហរណ៍ នៅពេលដែលភាគីជាច្រើនធ្វើលទ្ធកម្មរួមគ្នាលើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតមួយ និង នៅពេលដែលម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតមួយបានទទួលមរណភាព ហើយសហសន្តតិជនជាច្រើនទទួលបន្តនូវហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត (ប៉ុន្តែ សូមមើលមាត្រា ៨៧៣) ។

កថាខណ្ឌទី ១ ចែងថា ជាគោលការណ៍ ម្ចាស់សិទ្ធិរួមម្នាក់ៗ អាចទទួលការសងដោយមានអាទិភាពបាន ក្នុងកម្រិតអតិបរមា តាមសមាមាត្រនៃសិទ្ធិលើបំណុលដែលខ្លួនមាន ។ ឧទាហរណ៍ យើងសន្មតថា A និង B ជាម្ចាស់សិទ្ធិរួមលើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតមួយដែលមានចំនួនអតិបរមា ១០០,០០០ រៀល ហើយចំនួននៃសិទ្ធិលើបំណុលរបស់

A នៅពេលចែកចំណែក គឺ ៣០,០០០ រៀល និង ចំនួននៃសិទ្ធិលើបំណុលរបស់ B នៅពេលចែកចំណែក គឺ ១២០,០០០ រៀល ។ ក្នុងករណីនេះ A អាចទទួលការសងចំនួន ២០,០០០ រៀល ហើយ B អាចទទួលបាននូវ ៨០,០០០ រៀល ។ ប៉ុន្តែ ម្ចាស់សិទ្ធិរួមអាចកំណត់សមាមាត្រផ្សេងពីនេះ ឬ កំណត់ផ្តល់ឱ្យម្ចាស់សិទ្ធិរួមមួយទទួលការសងដោយមានអាទិភាពលើម្ចាស់សិទ្ធិរួមផ្សេងទៀត តាមការព្រមព្រៀង មុនពេលកំណត់ប្រាក់ដើមជាស្ថាពរ ។

កថាខណ្ឌទី ២ ចែងថា ម្ចាស់សិទ្ធិរួមមួយអាចធ្វើអនុប្បទានចំណែកនៃសិទ្ធិរួមរបស់ខ្លួន ដោយទទួលការយល់ព្រមពីម្ចាស់សិទ្ធិរួមផ្សេងទៀត ដោយអនុលោមតាមបញ្ញត្តិនៃមាត្រា ៨៧៧ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-១៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៨០.–** អានុភាពនៃអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដោយម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដែលបានទទួលអនុប្បទាន ឬ ការបោះបង់លំដាប់នៃហ៊ីប៉ូតែក

បើម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដែលបានទទួលអនុប្បទាន ឬ ការបោះបង់លំដាប់នៃហ៊ីប៉ូតែក បានធ្វើអនុប្បទាននូវហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះទាំងស្រុង ឬ មួយផ្នែក អនុប្បទានិកត្រូវទទួលផលប្រយោជន៍នៃអនុប្បទាន ឬ ការបោះបង់លំដាប់នោះ ។

(កំណត់)

ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត មិនអាចធ្វើការចាត់ចែងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៨៦០ (អនុប្បទាន ឬ ការបោះបង់នូវហ៊ីប៉ូតែក) ឬ កថាខណ្ឌទី ១ នៃមាត្រា ៨៦១ (អនុប្បទាន ឬ ការបោះបង់ និង ការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក) មុនពេលកំណត់ប្រាក់ដើមជាស្ថាពរឡើយ (មាត្រា ៨៧៦ នៃក្រមរដ្ឋប្បវេណី) ប៉ុន្តែ ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចទទួលអនុប្បទាន ឬ ការបោះបង់នៃលំដាប់នៃហ៊ីប៉ូតែកពីម្ចាស់បំណុលហ៊ីប៉ូតែកធម្មតាបាន ។ មាត្រានេះចែងថា ប្រសិនបើម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានទទួលអនុប្បទាន ឬ ការបោះបង់លំដាប់នៃហ៊ីប៉ូតែកធម្មតា ហើយបានធ្វើអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតទាំងមូល ឬ មួយផ្នែក នៅពេលក្រោយមក អនុប្បទានិកនឹងត្រូវទទួលផលប្រយោជន៍ពីអនុប្បទាន ឬ ការបោះបង់លំដាប់នៃហ៊ីប៉ូតែកនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-១៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៨១.–** ហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត

បញ្ញត្តិនៃមាត្រា ៨៩៧ (ការចែកចំណែកព្រមគ្នា និង ការចែកចំណែកមិនព្រមគ្នាក្នុងករណីនៃហ៊ីប៉ូតែករួម) និង មាត្រា ៨៩៨ (ហ៊ីប៉ូតែករួម - ការចុះបញ្ជីឱ្យបាទេសកម្ម) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត តែក្នុងករណីដែលបានចុះបញ្ជីអំពីការណ៍ដែលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវបានបង្កើតលើអចលនវត្ថុច្រើនដើម្បីធានាសិទ្ធិលើបំណុលតែមួយ ព្រមគ្នានឹងពេលបង្កើតហ៊ីប៉ូតែកនោះ ។

(កំណត់)

មាត្រានេះចែងអំពីករណីដែលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតត្រូវបានបង្កើតលើអចលវត្ថុជាច្រើន (ហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត) ។ បញ្ញត្តិនៃមាត្រា ៨៩៧ និង មាត្រា ៨៩៨ ដែលចែងអំពីហ៊ីប៉ូតែករួមធម្មតា ត្រូវយកមកអនុវត្ត តែក្នុងករណីដែលល័ក្ខខ័ណ្ឌពីរត្រូវបានបំពេញ : (១) ហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត ត្រូវបានបង្កើតឡើង "ដើម្បីធានាសិទ្ធិលើបំណុលតែមួយ (ដូចគ្នា)" និង (២) ការចុះបញ្ជីត្រូវបានធ្វើឡើងដើម្បីបង្ហាញថា ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតត្រូវបានបង្កើតឡើងលើអចលនវត្ថុជាច្រើនដើម្បីធានាសិទ្ធិលើបំណុលដូចគ្នា "ព្រមគ្នានឹងពេលបង្កើតហ៊ីប៉ូតែកនោះ" ។ ពាក្យ "ដើម្បីធានាសិទ្ធិលើបំណុលតែមួយ" ក្នុងមាត្រានេះ មានន័យថា ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា កូនបំណុល និង កម្រិតនៃចំនួនអតិបរមា ដូចគ្នា ។

ទោះបីជាហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតត្រូវបានបង្កើតឡើងលើអចលនវត្ថុជាច្រើន ដើម្បីធានាសិទ្ធិលើបំណុលដូចគ្នាក៏ដោយ ប្រសិនបើមិនបានចុះបញ្ជីថា ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតត្រូវបានបង្កើតឡើងលើអចលនវត្ថុជាច្រើន ដើម្បីធានាសិទ្ធិលើបំណុលដូចគ្នាទេ បញ្ញត្តិនៃមាត្រា ៨៨៣ នៃក្រមរដ្ឋប្បវេណីនឹងត្រូវយកមកអនុវត្ត ដោយចាត់ទុកថា ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះ គឺជាហ៊ីប៉ូតែកតម្រួតដើម្បីធានាបំណុលអណ្តែត ។ ក្នុងករណីនៃហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែតដែលត្រូវយកមកអនុវត្តតាមមាត្រា ៨៩៧ និង មាត្រា ៨៩៨ នោះ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវបានយកមកអនុវត្តលើអចលនវត្ថុនីមួយៗ ដូចហ៊ីប៉ូតែករួមក្នុងករណីហ៊ីប៉ូតែកធម្មតាដែរ ។ ឧទាហរណ៍ ប្រសិនបើធ្វើការចែកចំណែកព្រមគ្នាចំពោះអចលនវត្ថុជាច្រើន ម្ចាស់បំណុលហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត អាចទទួលការសងនូវចំនួនដែលត្រូវបានកំណត់តាមសមាមាត្រនឹងតម្លៃនៃអចលនវត្ថុនីមួយៗបាន ក្នុងកម្រិតនៃចំនួនអតិបរមា ។ ផ្ទុយទៅវិញ ក្នុងករណីនៃហ៊ីប៉ូតែកតម្រួតដើម្បីធានាបំណុលអណ្តែត ម្ចាស់បំណុលហ៊ីប៉ូតែកតម្រួតដើម្បីធានាបំណុលអណ្តែត អាចទទួលការសងសិទ្ធិលើបំណុលរហូតដល់កម្រិតនៃចំនួនអតិបរមា ពីអចលនវត្ថុនីមួយៗបាន ។ ឧទាហរណ៍ A មានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតមួយ ដែលមានចំនួនអតិបរមា ១៥០,០០០ រៀល លើអចលនវត្ថុ X (ដែលមានតម្លៃ ១០០,០០០ រៀល) អចលនវត្ថុ Y (ដែលមានតម្លៃ ២០០,០០០ រៀល) និង អចលនវត្ថុ Z (ដែល

មានតម្លៃ ២០០,០០០ រៀល) ហើយសិទ្ធិលើបំណុលរបស់ A (ដែលត្រូវបានកំណត់ជាស្ថាពរ) មានចំនួន ២០០,០០០ រៀល ។ (សន្មតផងដែរថា មានម្ចាស់បំណុលហ៊ីប៉ូតែកបន្តជាច្រើនលើអចលនវត្ថុនីមួយ) ។ ប្រសិនបើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនេះ គឺជាហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត A គ្រាន់តែអាចទទួលការសងដោយមានអាទិភាពនូវចំនួន ៣០,០០០ រៀល ចេញពីអចលនវត្ថុ X ៦០,០០០ រៀលចេញពីអចលនវត្ថុ Y និង ៦០,០០០ រៀល ចេញពីអចលនវត្ថុ Z (សរុប ១៥០,០០០ រៀល) ប៉ុណ្ណោះ ។ ប៉ុន្តែ ប្រសិនបើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះ គឺជាហ៊ីប៉ូតែកតម្រួតដើម្បីធានាបំណុលអណ្តែត A អាចទទួលបានការសងដោយមានអាទិភាព រហូតដល់កម្រិតនៃចំនួនអតិបរមា ១៥០,០០០ រៀល ពីអចលនវត្ថុណាមួយក្នុងចំណោមអចលនវត្ថុ X អចលនវត្ថុ និង អចលនវត្ថុ Z ហេតុដូច្នេះអាចទទួលបានចំនួនសរុបនៃសិទ្ធិលើបំណុល (២០០,០០០ រៀល) ដោយមានអាទិភាព ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-១៦ នៃក្រមរដ្ឋប្បវេណីជប៉ុន ។

## មាត្រា ៨៨២.– ការកែប្រែ អនុប្បទាន និង ការកំណត់ជាស្ថាពរ នូវហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត

១-ការកែប្រែទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលមានការចុះបញ្ជីដែលបានកំណត់នៅក្នុងមាត្រា ៨៨១ (ហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត) ខាងលើនេះ ការផ្លាស់ប្តូរកូនបំណុល ការកែប្រែចំនួនអតិបរមា ឬ អនុប្បទានហ៊ីប៉ូតែកនោះទាំងស្រុង ឬ មួយផ្នែក មិនត្រូវបង្កើតអានុភាពឡើយ បើមិនបានចុះបញ្ជីអំពីការកែប្រែ ឬ អនុប្បទាននោះ ចំពោះអចលនវត្ថុទាំងអស់ទេ ។

២-ប្រាក់ដើមដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដែលមានការចុះបញ្ជីដែលបានកំណត់នៅក្នុងមាត្រា ៨៨១ (ហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត) ខាងលើនេះ ត្រូវកំណត់ជាស្ថាពរដែរ ទោះបីជាហេតុដែលនាំឱ្យកំណត់ប្រាក់ដើមជាស្ថាពរ បានកើតឡើងចំពោះអចលនវត្ថុតែមួយក៏ដោយ ។

(កំណត់)

មាត្រានេះគឺជាបញ្ញត្តិពិសេសអំពីការកែប្រែ អនុប្បទាន និង ការកំណត់ជាស្ថាពរនូវហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែតដែលបានចែងក្នុងមាត្រា ៨៨១ ។ កថាខណ្ឌទី ១ ចែងថា ប្រសិនបើទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា កូនបំណុល ឬ ចំនួនអតិបរិមាត្រូវបានកែប្រែ ឬ ហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត ត្រូវបានធ្វើអនុប្បទានទាំងមូល ឬ មួយផ្នែក ការកែប្រែ ឬ អនុប្បទាននេះ នឹងមិនត្រូវមានអានុភាពទេ ប្រសិនបើមិនបានចុះបញ្ជីចំពោះអចលនវត្ថុដែល

ពាក់ព័ន្ធទាំងអស់ ។

កថាខណ្ឌទី ២ ចែងថា ប្រាក់ដើមត្រូវតែកំណត់ជាស្ថាពរ ទោះបីជាហេតុដែលនាំឱ្យកំណត់ប្រាក់ដើមជាស្ថាពរ បានកើតឡើងចំពោះអចលនវត្ថុតែមួយក៏ដោយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-១៧ នៃក្រមរដ្ឋប្បវេណីជប៉ុន ។

### **មាត្រា ៨៨៣.–** ហ៊ីប៉ូតែកតម្រួតដើម្បីធានាបំណុលអណ្ដែត

ជនដែលមានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតលើអចលនវត្ថុច្រើន អាចអនុវត្តសិទ្ធិអាទិភាពចំពោះប្រាក់ថ្លៃលក់នៃអចលនវត្ថុនីមួយៗ រហូតដល់ចំនួនអតិបរមានីមួយៗបាន លើកលែងតែករណីដែលបានកំណត់នៅក្នុងមាត្រា ៨៨១ (ហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្ដែត) ខាងលើនេះ ។

(កំណត់)

មាត្រានេះចែងអំពីករណីដែលមានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតលើអចលនវត្ថុច្រើន ហើយបញ្ញត្តិនៃមាត្រា ៨៨១ មិនត្រូវយកមកអនុវត្តទេ ។ ក្នុងករណីនេះ ម្ចាស់បំណុលហ៊ីប៉ូតែកតម្រួតដើម្បីធានាបំណុលអណ្ដែត អាចអនុវត្តសិទ្ធិជាអាទិភាពបាន (អាចទទួលការសងដោយមានអាទិភាពបាន) រហូតដល់ចំនួនអតិបរមាសម្រាប់អចលនវត្ថុនីមួយៗ ពីទឹកប្រាក់ដែលបានមកពីអចលនវត្ថុនីមួយៗ ។ ឧទាហរណ៍ជាក់ស្តែង សូមមើលសេចក្តីកំណត់នៃមាត្រា ៨៨១ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-១៨ នៃក្រមរដ្ឋប្បវេណីជប៉ុន ។

### **មាត្រា ៨៨៤.–** ការទាមទារឱ្យកំណត់ប្រាក់ដើមជាស្ថាពរ

១-បើអំឡុងពេល ៣ (បី) ឆ្នាំបានកន្លងហួស គិតចាប់ពីពេលដែលបានបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត អាចទាមទារឱ្យកំណត់ប្រាក់ដើមដែលត្រូវបានធានាជាស្ថាពរបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការកំណត់អំពីកាលបរិច្ឆេទដែលត្រូវកំណត់ប្រាក់ដើមជាស្ថាពរ ។

២-បើប្រាក់ដើមដែលត្រូវបានធានាលែងកើតមានទៀត ដោយសារការផ្លាស់ប្ដូរទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ការបញ្ចប់ការជួញដូរ ឬ ហេតុផ្សេងទៀត

អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចទាមទារឱ្យកំណត់ប្រាក់ដើមដែលត្រូវបានធានាជាស្ថាពរបាន ។

៣-ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចទាមទារឱ្យកំណត់ប្រាក់ដើមដែលត្រូវបានធានាជាស្ថាពរបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលមានការកំណត់អំពីកាលបរិច្ឆេទដែលត្រូវកំណត់ប្រាក់ដើមជាស្ថាពរ ។

៤-បើមានការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ទី ២ ឬ ទី ៣ ខាងលើនេះ ប្រាក់ដើមដែលត្រូវបានធានា ត្រូវកំណត់ជាស្ថាពរ នៅពេលដែលអំឡុងពេល ២ (ពីរ) សប្តាហ៍ បានកន្លងផុត គិតចាប់ពីពេលទាមទារនោះ ។

(កំណត់)

មាត្រានេះចែងថា អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ឬ ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចទាមទារឱ្យកំណត់ប្រាក់ដើមជាស្ថាពរបាន ។

កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ចែងអំពីករណីដែលអ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចទាមទារឱ្យកំណត់ប្រាក់ដើមជាស្ថាពរបាន ។ ប្រសិនបើកាលបរិច្ឆេទកំណត់ប្រាក់ដើមជាស្ថាពរមិនត្រូវបានកំណត់ទេ អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចទាមទារឱ្យកំណត់ប្រាក់ដើមជាស្ថាពរនៅពេលណាក៏បាន ក្រោយអំឡុងពេល ៣ ឆ្នាំ បានកន្លងហួស គិតចាប់ពីការបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត (កថាខណ្ឌទី ១) ។ បន្ថែមពីនេះ ក្នុងករណីដែលប្រាក់ដើមដែលត្រូវបានធានា លែងកើតឡើង ដោយសារការកែប្រែនូវទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ការបញ្ចប់ការជួញដូរ ឬ ហេតុផ្សេងទៀត អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចទាមទារឱ្យកំណត់ប្រាក់ដើមដែលត្រូវបានធានានោះជាស្ថាពរបាន (កថាខណ្ឌទី ២) ។

កថាខណ្ឌទី ៣ ចែងអំពីករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចទាមទារឱ្យកំណត់ប្រាក់ដើមជាស្ថាពរបាន ។ ប្រសិនបើកាលបរិច្ឆេទកំណត់ប្រាក់ដើមជាស្ថាពរមិនត្រូវបានកំណត់ទេ ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចទាមទារឱ្យកំណត់ប្រាក់ដើមនៅពេលណាក៏បាន ។ មិនដូចជាករណីអ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតទេ មិនមានល័ក្ខខ័ណ្ឌដែលអំឡុងពេល ៣ ឆ្នាំ ត្រូវតែកន្លងហួស គិតចាប់ពីការបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតឡើយ ។

ប្រសិនបើមានការទាមទារឱ្យកំណត់ប្រាក់ដើមជាស្ថាពរ ប្រាក់ដើមត្រូវកំណត់ជាស្ថាពរ នៅពេលដែលអំឡុងពេល ២ សប្តាហ៍ បានកន្លងផុត គិតចាប់ពីពេលទាមទារនោះ ។

ពាក់ព័ន្ធនឹងកថាខណ្ឌទី ២ ក្រមរដ្ឋប្បវេណីជប៉ុន បានចែងថា ហេតុទាំងនេះគឺជាហេតុដែលនាំឱ្យកំណត់ប្រាក់ដើមជាស្ថាពរ ដោយមិនបាច់មានការទាមទារ (ចំណុចទី ១ កថាខណ្ឌទី ១ នៃ មាត្រា ៣៩៨-២០ (មុនវិសោធនកម្មឆ្នាំ

២០០៣)) ប៉ុន្តែ កថាខណ្ឌទី ២ នៃមាត្រានេះ ចែងថាជាហេតុដែលនាំឱ្យកំណត់ប្រាក់ដើមជាស្ថាពរតាមរយៈការទាមទារ ។
(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-១៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៨៨៥.-** ហេតុដែលនាំឱ្យកំណត់ប្រាក់ដើមជាស្ថាពរ

១-ក្រៅពីករណីដែលមានការទាមទារឱ្យកំណត់ប្រាក់ដើមជាស្ថាពរ តាមបញ្ញត្តិនៃមាត្រា ៨៨៤ (ការទាមទារឱ្យកំណត់ប្រាក់ដើមជាស្ថាពរ) ខាងលើ ប្រាក់ដើមដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវកំណត់ជាស្ថាពរ ក្នុងករណីដូចខាងក្រោមនេះ :

ក-បើម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានដាក់ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុដែលបានដាក់ជាហ៊ីប៉ូតែក ។ ប៉ុន្តែ បញ្ញត្តិនេះត្រូវយកមកអនុវត្ត ចំពោះតែករណីដែលនីតិវិធីនៃការលក់ដោយបង្ខំ បានចាប់ផ្តើមប៉ុណ្ណោះ ។

ខ-បើម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានរឹបអូសចំពោះអចលនវត្ថុហ៊ីប៉ូតែក ដោយយោងតាមការចាត់ចែងចំពោះពន្ធតឹងទារ ។

គ-បើអំឡុងពេល ២ (ពីរ) សប្តាហ៍កន្លងហួស ចាប់ពីពេលដែលម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានដឹងអំពីការចាប់ផ្តើមនីតិវិធីនៃការលក់ដោយបង្ខំ ឬ ការរឹបអូសដោយយោងតាមការចាត់ចែងចំពោះពន្ធតឹងទារ ចំពោះអចលនវត្ថុហ៊ីប៉ូ-តែក ។

ឃ-បើកូនបំណុល ឬ អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានទទួលសេចក្តីប្រកាសអំពីធនក្ស័យ ។

២-បើអានុភាពនៃនីតិវិធីលក់ដោយបង្ខំ ឬ ការរឹបអូសដែលបានកំណត់នៅក្នុងចំណុច គ នៃកថាខណ្ឌទី ១ ខាងលើនេះ ឬ អានុភាពនៃសេចក្តីប្រកាសអំពីធនក្ស័យដែលបានកំណត់នៅក្នុងចំណុច ឃ នៃកថាខណ្ឌដដែលបានរលត់ ប្រាក់ដើមដែលត្រូវបានធានា ត្រូវចាត់ទុកថាពុំបានកំណត់ជាស្ថាពរឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានបុគ្គល ដែលបានទទួលហ៊ីប៉ូតែកដើម្បីធានាបំណុល

អណ្តែតនោះ ឬ សិទ្ធិដែលយកហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះជាកម្មវត្ថុ ដោយឈរលើមូលដ្ឋានថា ប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ។

(កំណត់)

មាត្រានេះចែងថា ក្រៅពីករណីដែលកាលបរិច្ឆេទនៃការកំណត់ប្រាក់ដើមជាស្ថាពរត្រូវបានកំណត់ និង ករណីដែលមានការទាមទារឱ្យកំណត់ប្រាក់ដើមជាស្ថាពរ ដោយអ្នកដែលបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ឬ ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ប្រសិនបើហេតុផលជាក់លាក់មួយចំនួនបានកើតឡើង ។ ហេតុផលជាក់លាក់នោះ ត្រូវបានរៀបរាប់ចាប់ពីចំណុច ក ដល់ចំណុច ឃ នៃកថាខណ្ឌទី ១ : (១) បើម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានដាក់ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុដែលបានដាក់ជាហ៊ីប៉ូតែក (២) បើម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានរឹបអូសចំពោះអចលនវត្ថុហ៊ីប៉ូតែក ដោយយោងតាមការចាត់ចែងចំពោះពន្ធតឹងទារ (៣) បើអំឡុងពេល ២ សប្តាហ៍ កន្លងហួស ចាប់ពីពេលដែលម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានដឹងអំពីការចាប់ផ្តើមនីតិវិធីនៃការលក់ដោយបង្ខំ ឬ ការរឹបអូសដោយយោងតាមការចាត់ចែងចំពោះពន្ធតឹងទារ ចំពោះអចលនវត្ថុហ៊ីប៉ូតែក និង (៤) បើកូនបំណុល ឬ អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតបានទទួលសេចក្តីប្រកាសអំពីធនក្ស័យ ។

ចំពោះនីតិវិធីអនុវត្តដោយបង្ខំរបស់កម្ពុជា អនុម័តយកគោលការណ៍ទទួលបន្ត (ប្រព័ន្ធនៃនីតិវិធីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ដែលបន្ទុកលើអចលនវត្ថុដែលមានអាទិភាពលើម្ចាស់បំណុលនៃការអនុវត្ត នឹងមិនត្រូវរលត់ដោយការលក់ទេ ប៉ុន្តែ ត្រូវបានទទួលបន្តដោយអ្នកទិញ) ដែលខុសពីនីតិវិធីអនុវត្តនៅក្នុងក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុនដែលអនុម័តយកគោលការណ៍លុបចេញ (ប្រព័ន្ធនៃនីតិវិធីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ដែលបន្ទុកលើអចលនវត្ថុដែលមានអាទិភាពលើម្ចាស់បំណុលនៃការអនុវត្ត នឹងត្រូវរលត់ដោយការលក់) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-២០ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៨៨៦.- ការទាមទារបន្ថយចំនួនអតិបរមា

១-នៅក្រោយពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចទាមទារឱ្យបន្ថយចំនួនអតិបរមានៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះ មកត្រឹមចំនួននៃកាតព្វកិច្ចដែលមានអត្ថិភាពបច្ចុប្បន្ន បូកនឹងចំនួននៃការប្រាក់ និង ធនលាភផ្សេងទៀត ព្រមទាំងចំនួននៃសំណងការខូចខាតដោយសារការមិន

អនុវត្តកាតព្វកិច្ច ដែលត្រូវកើតឡើងក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ក្រោយពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ។

២-ចំពោះការបន្ថយចំនួនអតិបរមានៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលមានការចុះបញ្ជីដែលបានកំណត់នៅក្នុងមាត្រា ៨៨១ (ហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត) នៃក្រមនេះ ការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ គ្រាន់តែធ្វើឡើងចំពោះអចលនវត្ថុតែមួយ ជាការគ្រប់គ្រាន់ ។

(កំណត់)

មាត្រានេះចែងថា នៅក្រោយពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរហើយ អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចទាមទារឱ្យបន្ថយចំនួនអតិបរមានៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតបាន ។ ក្នុងករណីដែលចំនួនអតិបរមាមានចំនួនច្រើន ដោយប្រៀបធៀបជាមួយប្រាក់ដើមដែលត្រូវបានកំណត់ជាស្ថាពររួចហើយ ទោះបីជាចំនួនអតិបរមាត្រូវបានកាត់បន្ថយក៏ដោយ ក៏ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតមិនទទួលរងនូវការខូចខាតច្រើនឡើយ នៅខណៈពេលដែលអ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចទទួលបានផលប្រយោជន៍ ពីការកើនឡើងតម្លៃប្រាតិភោគនៃអចលនវត្ថុ ។ មាត្រានេះចែងផងដែរថា ដោយសារប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ការកាត់បន្ថយនេះអាចធ្វើឡើងត្រឹមទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកធម្មតា ។

កថាខណ្ឌទី ២ ចែងថា ក្នុងករណីដែលហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែតដូចបានចែងក្នុងមាត្រា ៨៨១ នៃក្រមរដ្ឋប្បវេណីនេះ ត្រូវបានបង្កើតលើអចលនវត្ថុជាច្រើន ប្រសិនបើមានការទាមទារឱ្យកាត់បន្ថយចំនួនអតិបរមាចំពោះអចលនវត្ថុតែមួយ ការទាមទារនោះត្រូវចាត់ទុកថា ការទាមទារពាក់ព័ន្ធនឹងអចលនវត្ថុទាំងអស់ ត្រូវបានធ្វើឡើង ។

ម្យ៉ាងទៀត ប្រសិនបើការកាត់បន្ថយចំនួនអតិបរមាត្រូវបានទទួលស្គាល់ ការកាត់បន្ថយនោះត្រូវបានចុះបញ្ជី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-២១ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៨៨៧.- ការទាមទារឱ្យរំលត់ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

១-បើចំនួននៃកាតព្វកិច្ចដែលមានអត្ថិភាពនៅក្រោយពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ លើសពីចំនួនអតិបរមានៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អ្នកដែលបានបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដើម្បីធានាកាតព្វកិច្ចរបស់ជនដទៃ ឬ តតិយជនដែលបានធ្វើលទ្ធកម្មនូវកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ សិទ្ធិជួលដែលអាចតតាំងនឹងតតិយជន ចំពោះអចលនវត្ថុហ៊ីប៉ូតែក អាចទាមទារឱ្យរំលត់ហ៊ីប៉ូតែកដើម្បីធានាបំណុល

អណ្តែតនោះ ដោយបង់ជាប្រាក់ដែលស្មើនឹងចំនួនអតិបរមានោះ ឬ ដោយតម្កល់ប្រាក់នោះបាន ។ ក្នុងករណីនេះ ការបង់ ឬ ការតម្កល់នោះ មានអានុភាពជាការសង ។

២-ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដែលមានការចុះបញ្ជីដែលបានកំណត់នៅក្នុងមាត្រា ៨៨១ (ហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត) នៃក្រមនេះ ត្រូវរលត់នៅពេលដែលមានការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះអចលនវត្ថុមួយ ។

៣-កូនបំណុលដែលមានកាតព្វកិច្ចចម្បង អ្នកធានា និង ប្រតិសិទ្ធិ មិនអាចធ្វើការទាមទារឱ្យរលត់ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបានឡើយ ។

៤-តតិយជនដែលបានធ្វើលទ្ធកម្មនូវកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀត ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយភ្ជាប់នឹងល័ក្ខខ័ណ្ឌបង្អង់ មិនអាចធ្វើការទាមទារឱ្យរលត់ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះបានឡើយ នៅក្នុងពេលដែលពុំដឹងថាល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ឬ មិនទាន់បានបំពេញ ។

(កំណត់)

មាត្រានេះចែងថា បើចំនួននៃកាតព្វកិច្ចនៅក្រោយពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ លើសពីចំនួនអតិបរមានៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អ្នកដែលបានធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុដែលបានបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ឬ តតិយជនដែលបានធ្វើលទ្ធកម្មនូវសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សិទ្ធិជួលដែលអាចតតាំងនឹងតតិយជន ចំពោះអចលនវត្ថុហ៊ីប៉ូតែក អាចទាមទារឱ្យរំលត់ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះបាន ដោយបង់ជាប្រាក់ដែលស្មើនឹងចំនួនអតិបរមានោះ ឬ ដោយតម្កល់ប្រាក់នោះបាន ។

ប៉ុន្តែ កូនបំណុលដែលមានកាតព្វកិច្ចចម្បង អ្នកធានា ជាអាទិ៍ មិនត្រូវបានអនុញ្ញាតឱ្យទាមទាររំលត់ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតឡើយ ដោយហេតុថា បុគ្គលទាំងនេះមានករណីយកិច្ចក្នុងការសងកាតព្វកិច្ច ។ តាមគោលការណ៍ទទួលបន្តពាក់ព័ន្ធនឹងនីតិវិធីអនុវត្តដោយបង្ខំ អ្នកទិញដែលបានទិញអចលនវត្ថុ ដោយអនុលោមតាមនីតិវិធីនៃការលក់ដោយបង្ខំ តាមពាក្យសុំរបស់បុគ្គលដែលមិនអាចតតាំងចំពោះហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតបាន ត្រូវទទួលយកសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ហើយក្លាយជាកូនបំណុល ដូច្នេះហើយ បញ្ញត្តិនៃកថាខណ្ឌទី ៣ ត្រូវយកមកអនុវត្តចំពោះករណីនេះ មានន័យថា អ្នកទិញនោះ មិនអាចទាមទារឱ្យរំលត់នូវហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដូចបានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី ១ ឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩៨-២២ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ជំពូកទី ៦ ប្រាតិភោគដោយអនុប្បទាន

(កំណត់)

ជំពូកនេះបង្កើតមូលដ្ឋានគតិយុត្ត ដើម្បីបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះចលនវត្ថុ មានន័យថា បង្កើតសិទ្ធិប្រាតិភោគ ដោយឱ្យអ្នកបង្កើតសិទ្ធិប្រាតិភោគនោះបន្តកាន់កាប់ចលនវត្ថុ តាមទម្រង់នៃការផ្ទេរកម្មសិទ្ធិ ។ ក្នុងករណីនៃសិទ្ធិលើការបញ្ចាំចលនវត្ថុ អ្នកបង្កើតសិទ្ធិលើការបញ្ចាំ មិនត្រូវបានអនុញ្ញាតឱ្យបន្តកាន់កាប់ចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំនោះទេ ។ ប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើងដើម្បីសម្រួលបញ្ហាលំបាកនេះ ។ ប៉ុន្តែនេះមិនចាំបាច់មានន័យថា បដិសេធមិនឱ្យផ្ទេរការកាន់កាប់នៃវត្ថុដែលជាកម្មវត្ថុទៅម្ចាស់បំណុលទេ (សូមមើលមាត្រា ៨៩០ នៃក្រមរដ្ឋប្បវេណី) ។

ជាទ្រឹស្តី ប្រាតិភោគដោយអនុប្បទាន អាចត្រូវបានបង្កើតបាន លើទ្រព្យក្រៅពីចលនវត្ថុ (ជាពិសេស អចលនវត្ថុ) ។ ប៉ុន្តែ ជំពូកនេះចែងអំពីចលនវត្ថុតែប៉ុណ្ណោះ ។ សម្រាប់អចលនវត្ថុវិញ មានហ៊ីប៉ូតែកដែលជាសិទ្ធិប្រាតិភោគប្រត្យក្សដែលមិនចាំបាច់ផ្ទេរការកាន់កាប់ ។

### ផ្នែកទី ១ និយមន័យនៃប្រាតិភោគដោយអនុប្បទាន

**មាត្រា ៨៨៨.–** និយមន័យនៃប្រាតិភោគដោយអនុប្បទាន

១-ប្រាតិភោគដោយអនុប្បទាន សំដៅទៅលើការណ៍ដែលកូនបំណុល ឬ តតិយជន ធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជាកំណត់ ទៅឱ្យម្ចាស់បំណុល ដើម្បីធានាកាតព្វកិច្ច ។ ក្នុងករណីនេះ បើកាតព្វកិច្ចត្រូវបានសងរួចហើយ កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុ ត្រូវផ្ទេរទៅអ្នកបង្កើត ។

២-ចលនវត្ថុច្រើន ដែលត្រូវបានកំណត់ទំហំតាមមាត្រដ្ឋាន ដូចជាប្រភេទ ឬ កន្លែងស្ថិតនៅនៃចលនវត្ថុ អាចយកមកធ្វើជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ដោយចាត់ទុកជាចលនវត្ថុផ្តុំគ្នាតែមួយបាន ទោះបីជាចលនវត្ថុនីមួយៗដែលផ្តុំគ្នានោះ មានការប្រែប្រួលក៏ដោយ ។

(កំណត់)

កថាខណ្ឌទី ១ ចែងអំពីនិយមន័យនៃប្រាតិភោគដោយអនុប្បទាន ។ ពាក្យ "អនុប្បទាន" ត្រូវបានប្រើនៅក្នុងកថាខណ្ឌនេះ ដោយហេតុថា កម្មសិទ្ធិត្រូវបានផ្ទេរដើម្បីបង្កើតសិទ្ធិប្រត្យក្ស ហើយចែងផងដែរថា កម្មសិទ្ធិត្រូវផ្ទេរទៅ

កូនបំណុល ដោយការសងកាតព្វកិច្ច ។

កថាខណ្ឌទី ២ ចែងថា ប្រាតិភោគដោយអនុប្បទាន អាចបង្កើតលើចលនវត្ថុផ្គុំគ្នាបាន ។ ចំណុចនេះអាចត្រូវបានបកស្រាយ ប៉ុន្តែ កថាខណ្ឌនេះចែងឡើងដើម្បីជៀងវាងបញ្ហាដែលនឹងកើតឡើង ។

## ផ្នែកទី ២ ការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

**មាត្រា ៨៨៩.–** ការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងរវាងម្ចាស់បំណុល និង កូនបំណុល ឬ តតិយជន ដែលផ្តល់ចលនវត្ថុសម្រាប់ប្រាតិភោគដោយអនុប្បទាន ។

(កំណត់)

មាត្រានេះចែងថា ប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើង រវាងភាគី ដោយការព្រមព្រៀង (គោលការណ៍នៃការបង្កើតកិច្ចសន្យាដោយការព្រមព្រៀង) ។ ចំពោះល័ក្ខខ័ណ្ឌតតាំង សូមមើលមាត្រាបន្ទាប់ ។

ពាក់ព័ន្ធនឹងកិច្ចសន្យាដើម្បីបង្កើតប្រាតិភោគដោយអនុប្បទានដែលមានអានុភាព អាចពិចារណាអំពីការតម្រូវឱ្យមានលិខិតយថាភូត (ឬ "លិខិតយថាភូត ឬ លិខិតឯកជន") បានដែរ ។ ប៉ុន្តែ មាត្រានេះចែងអំពីការបង្កើតប្រាតិភោគដោយអនុប្បទាន ក្នុងទម្រង់ដូចគ្នានឹងសិទ្ធិប្រាតិភោគប្រត្យក្សផ្សេងទៀតដែរ ។

**មាត្រា ៨៩០.–** អានុភាពតតាំងនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចតតាំងសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ ចំពោះតតិយជនក្រៅពីអ្នកបង្កើតបានឡើយ បើមិនបានទទួលការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយយោងតាមបញ្ញត្តិនៃមាត្រា ២២៩ (ការផ្ទេរការកាន់កាប់) នៃក្រមនេះទេ ។

(កំណត់)

មាត្រានេះចែងថា ដើម្បីតតាំងប្រាតិភោគដោយអនុប្បទានដែលត្រូវបានបង្កើតតាមកិច្ចព្រមព្រៀងរវាងភាគី ចំពោះតតិយជន ចាំបាច់ត្រូវផ្ទេរការកាន់កាប់នៃវត្ថុដែលជាកម្មវត្ថុ ។ ពាក្យថា "ការផ្ទេរការកាន់កាប់" មានន័យថា ធ្វើតាមវិធីណាមួយដែលបានចែងក្នុងមាត្រា ២២៩ នៃក្រមរដ្ឋប្បវេណី ។ ជាពិសេស បើយោងតាម "ការប្តូរលក្ខណៈនៃការកាន់កាប់" (កថាខណ្ឌទី ២ នៃមាត្រាដូចគ្នា) កូនបំណុលអាចដាក់ចលនវត្ថុជាប្រាតិភោគ ដោយបន្តកាន់កាប់ និង ប្រើប្រាស់ចលនវត្ថុដែលជាកម្មវត្ថុនោះ ។

## ផ្នែកទី ៣ អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

**មាត្រា ៨៩១.-** ទំហំដែលមានអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

១-សិទ្ធិប្រាតិភោគដោយអនុប្បទាន មានអានុភាពលើវត្ថុដែលភ្ជាប់នឹងវត្ថុដែលជាកម្មវត្ថុ និង ជាផ្នែកមួយនៃវត្ថុដែលជាកម្មវត្ថុនោះ នៅពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ។ អានុភាពនេះក៏មានលើវត្ថុដែលត្រូវបានភ្ជាប់នៅក្រោយពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានផងដែរ ។

២-ភាគីអាចកំណត់ផ្សេងពីបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបាន នៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ។

(កំណត់)

មាត្រានេះគឺជាបញ្ញត្តិស្រដៀងគ្នានឹងបញ្ញត្តិស្ដីពីទំហំនៃអានុភាពហ៊ីប៉ូតែក (មាត្រា ៨៤៦) ។ ប៉ុន្តែ កថាខណ្ឌទី ២ នៃមាត្រានេះចែងថា ទំហំនៃអានុភាពនោះអាចកែប្រែបាន តាមការព្រមព្រៀង ។ ក្នុងន័យនេះ លក្ខណៈនៃទំហំ ខុសគ្នាពីលក្ខណៈនៃទំហំនៃអានុភាពហ៊ីប៉ូតែក (ចំពោះចំណុចនេះ ក្រមនេះមិនអនុញ្ញាតឱ្យបង្កើតហ៊ីប៉ូតែកលើដីតែមួយដោយមិនរាប់បញ្ចូលអាគារដែលនៅលើដីនោះទេ ដូច្នេះ មិនអនុញ្ញាតឱ្យកែប្រែទំហំនៃអានុភាពហ៊ីប៉ូតែក តាមការព្រមព្រៀងរបស់ភាគីឡើយ) ។

**មាត្រា ៨៩២.-** អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះផល

១-ក្នុងករណីដែលអ្នកបង្កើត ឬ តតិយជនដែលបានទទួលការបញ្ជាពីអ្នកបង្កើតនោះ កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ បញ្ញត្តិនៃមាត្រា ៨៩១ (ទំហំដែលមានអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន) ខាងលើនេះ មិនត្រូវយកមកអនុវត្តចំពោះផលឡើយ ។ ប៉ុន្តែ បញ្ញត្តិនៃវាក្យខណ្ឌទី ១ នេះមិនត្រូវយកមកអនុវត្តឡើយ នៅក្រោយពេលដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន បានទាមទារឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៨៩៨ (ការចាត់ចែងប្ដូរជាប្រាក់ ឬ អនុប្បទានជាស្ថាពរ) នៃក្រមនេះ ។

២-ក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជាពីម្ចាស់សិទ្ធិនោះ កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ បញ្ញត្តិនៃមាត្រា

៨២២ (សិទ្ធិទទួលការសងពីផលដោយមានអាទិភាព) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះផលដែលកើតឡើងពីវត្ថុដែលជាកម្មវត្ថុនោះ ។

(កំណត់)

មាត្រានេះចែងអំពីអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះផល ។

កថាខណ្ឌទី ១ ចែងពីករណីដែលអ្នកបង្កើតប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលទទួលការបញ្ជាពីអ្នកបង្កើត កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ ។ ក្នុងករណីនេះ យើងអាចគិតថា អ្នកបង្កើតប្រាតិភោគ មានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលពីវត្ថុដែលជាកម្មវត្ថុនោះ ហេតុដូច្នេះ កថាខណ្ឌនេះចែងថា ចាត់ចែងដូចគ្នានឹងហ៊ីប៉ូតែក (សូមមើលមាត្រា ៨៤៨) ។

កថាខណ្ឌទី ២ ចែងអំពីករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជាពីម្ចាស់សិទ្ធិនោះ កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ ។ ក្នុងករណីនេះ អ្នកបង្កើតប្រាតិភោគដោយអនុប្បទាន មិនមានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលពីវត្ថុដែលកម្មវត្ថុ ហេតុដូច្នេះ កថាខណ្ឌនេះចែងថា ចាត់ចែងដូចគ្នានឹងសិទ្ធិលើការបញ្ចាំ ។ ដោយសារប្រាតិភោគដោយអនុប្បទាន មានទម្រង់ជាការផ្ទេរកម្មសិទ្ធិ គេអាចគិតថា ប្រសិនបើម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ ម្ចាស់សិទ្ធិនេះមានសិទ្ធិទទួលផលដែលកើតឡើងពីវត្ថុដែលជាកម្មវត្ថុ ហើយមិនចាំបាច់យកផលនោះមកកាត់សិទ្ធិលើបំណុលឡើយ (ក្នុងករណីនេះ ម្ចាស់សិទ្ធិមិនអាចទាមទារការប្រាក់ទេ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះជាពិសេស) ។ ប៉ុន្តែ ផ្អែកលើជំនឿថា ប្រាតិភោគដោយអនុប្បទាន គួរត្រូវបានចាត់ទុកដូចជាសិទ្ធិប្រាតិភោគសាមញ្ញ ឱ្យបានច្រើនតាមដែលអាចធ្វើបាន រវាងភាគី ហេតុដូច្នេះ កថាខណ្ឌទី ២ ត្រូវបានរៀបចំឡើង ។

## មាត្រា ៨៩៣.- ឧបាទេសកម្មលើវត្ថុ

១-ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចអនុវត្តសិទ្ធិរបស់ខ្លួនបាន ចំពោះទឹកប្រាក់ ឬ វត្ថុផ្សេង ដែលអ្នកបង្កើតត្រូវទទួល ដោយការលក់ ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុ ។ ប៉ុន្តែ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចអនុវត្តសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងត្រូវបានប្រគល់ទៅឱ្យអ្នកបង្កើត ។

២-ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បើវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ជាចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៨៨៨ (និយមន័យនៃប្រាតិភោគដោយអនុប្បទាន) នៃក្រមនេះ ហើយបើអ្នកបង្កើត

មានគម្រោងនឹងលក់វត្ថុដែលជាកម្មវត្ថុនេះទៅជនដទៃ សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចអនុវត្តចំពោះទឹកប្រាក់ដែលបានមកពីការលក់នោះឡើយ ។

(កំណត់)

មាត្រានេះចែងអំពីឧបាទេសកម្មលើវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ។

កថាខណ្ឌទី ១ ចែងអំពីគោលការណ៍ដែលអានុភាពនៃប្រាតិភោគដោយអនុប្បទាន នឹងត្រូវមានអានុភាពចំពោះតម្លៃនៃវត្ថុជំនួសសម្រាប់វត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ។

កថាខណ្ឌទី ២ ចែងថា ចំពោះចលនវត្ថុផ្គុំគ្នា អ្នកបង្កើតប្រាតិភោគដោយអនុប្បទាន មានគម្រោង តាំងពីដំបូងដើម្បីលក់ចលនវត្ថុទៅអ្នកផ្សេង ហើយគ្មានអានុភាពតាម ហេតុដូច្នេះ គ្មានអានុភាពនៃឧបាទេសកម្មលើវត្ថុផងដែរ ។

**មាត្រា ៨៩៤.-** ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកបង្កើត

១-បើអ្នកបង្កើតដែលបន្តការកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន នៅក្រោយពេលបង្កើតសិទ្ធិនោះ បានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ប្រសិនបើតតិយជននោះបំពេញគ្រប់ល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ តតិយជននោះអាចយកសិទ្ធិរបស់ខ្លួន ទៅតតាំងចំពោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន ។

២-ចំពោះចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៨៨៨ (និយមន័យនៃប្រាតិភោគដោយអនុប្បទាន) នៃក្រមនេះ ហើយដែលអ្នកបង្កើតមានគម្រោងនឹងលក់ទៅជនដទៃ ក្នុងករណីដែលអ្នកបង្កើតដែលបន្តការកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ នៅក្រោយពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន បានលក់វត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចយកសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ ទៅតតាំងចំពោះតតិយជននោះ បានឡើយ ទោះបីជាតតិយជននោះបំពេញ ឬ មិនបំពេញគ្រប់ល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ ក៏ដោយ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដទៃដែលទទួលការបញ្ជាពីអ្នកបង្កើត បន្តការកាន់កាប់ដោយ

ចំពោះ នូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន នៅក្រោយពេលបង្កើតសិទ្ធិនោះ ហើយអ្នកបង្កើតបានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ។

(កំណត់)

មាត្រានេះចែងអំពីបញ្ហាថា តើម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចអះអាងសិទ្ធិរបស់ខ្លួនបាន ឬ មិនបាន ក្នុងករណីដែលអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានបានចាត់ចែងវត្ថុដែលជាកម្មវត្ថុ ។ កថាខណ្ឌទី ១ ចែងអំពីគោលការណ៍ទូទៅ ដោយបញ្ជាក់ថា តតិយជនដែលបានធ្វើលទ្ធកម្មការកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយសុចរិត និង គ្មានកំហុស អាចតតាំងសិទ្ធិរបស់ខ្លួនចំពោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន ។ ក្នុងករណីក្រៅពីនេះ តតិយជនដែលបានធ្វើលទ្ធកម្ម មិនអាចតតាំងសិទ្ធិរបស់ខ្លួនចំពោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបានឡើយ ។ ហេតុដែលតតិយជនដែលបានធ្វើលទ្ធកម្ម មិនអាចតតាំងសិទ្ធិរបស់ខ្លួន មានន័យថា ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចទាមទារឱ្យប្រគល់នូវវត្ថុដែលជាកម្មវត្ថុ ប្រសិនបើកូនបំណុលខកខានក្នុងការសងកាតព្វកិច្ច ។

ក្នុងករណីដែលចលនវត្ថុមួយត្រូវបានផ្តល់ជាប្រាតិភោគដោយអនុប្បទានលើសពីមួយ បុគ្គលដែលបានធ្វើលទ្ធកម្មនូវប្រាតិភោគដោយអនុប្បទាន នៅពេលក្រោយ មិនអាចតតាំងសិទ្ធិរបស់ខ្លួនចំពោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានទីមួយបានទេ ប្រសិនបើមិនបានបំពេញល័ក្ខខ័ណ្ឌនៃលទ្ធកម្មដោយសុចរិតនៃចលនវត្ថុ ។ ប៉ុន្តែ ប្រសិនបើល័ក្ខខ័ណ្ឌត្រូវបានបំពេញ អ្នកធ្វើលទ្ធកម្មទីមួយត្រូវមានឋានៈទាបជាងអ្នកធ្វើលទ្ធកម្មទីពីរ ។

ប្រសិនបើតតិយជន (ម្ចាស់បំណុលនៃអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន) បានរឹបអូសវត្ថុដែលជាកម្មវត្ថុ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចធ្វើបណ្តឹងតវ៉ារបស់តតិយជនបាន ។ ប៉ុន្តែ ចំណុចនេះហាក់មិនតម្រូវឱ្យចែងច្បាស់លាស់ ដោយសារមានករណីស្រដៀងគ្នាជាច្រើន ប៉ុន្តែ មិនបានចែងច្បាស់លាស់ក្នុងក្រមរដ្ឋប្បវេណីទេ ។

**មាត្រា ៨៩៥.–** ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវធានានូវប្រាក់ដើម ការប្រាក់ ប្រាក់ធានាសង ក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន សោហ៊ុយដើម្បីថែរក្សាវត្ថុដែលជាកម្មវត្ថុ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុដែលជាកម្មវត្ថុ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានកំណត់ផ្សេង ក្នុងសកម្មភាពបង្កើតនោះ ។

(កំណត់)

មាត្រានេះចែងអំពីទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយប្រាតិភោគដោយអនុប្បទាន ។ តាមការអនុវត្ត សិទ្ធិប្រាតិភោគដោយអនុប្បទាន ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន នឹងធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុជាស្ថាពរ ហេតុដូច្នេះ មិនចាំបាច់ដាក់កម្រិត ដូចក្នុងករណីនៃហ៊ីប៉ូតែកទេ (សូមមើលមាត្រា ៨៥២) ហើយបញ្ញត្តិនៃមាត្រានេះ ស្រដៀងនឹងបញ្ញត្តិអំពីសិទ្ធិលើការបញ្ចាំ (សូមមើលមាត្រា ៨២០) ។

## មាត្រា ៨៩៦.- បញ្ញត្តិពិសេសក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន កាន់កាប់វត្ថុដែលជាកម្មវត្ថុ

បញ្ញត្តិនៃមាត្រា ៨២១ (អានុភាពនៃការឃាត់ទុក) មាត្រា ៨២៣ (ករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការរក្សាទុកនូវវត្ថុបញ្ចាំ) និង មាត្រា ៨២៤ (សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ញាពីម្ចាស់សិទ្ធិនោះ កាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ ។

(កំណត់)

មាត្រានេះចែងថា បញ្ញត្តិអំពីសិទ្ធិលើការបញ្ចាំ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន កាន់កាប់នូវវត្ថុដែលជាកម្មវត្ថុ ពីព្រោះទំនាក់ទំនងរវាងម្ចាស់សិទ្ធិ និង វត្ថុដែលជាកម្មវត្ថុ គឺស្រដៀងគ្នានឹងទំនាក់ទំនងរវាងម្ចាស់សិទ្ធិលើការបញ្ចាំ និង វត្ថុដែលជាកម្មវត្ថុ ។

## មាត្រា ៨៩៧.- ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

១-បើម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដែលកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ បានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ប្រសិនបើតតិយជននោះ បំពេញគ្រប់ល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ តតិយជននោះអាចយកសិទ្ធិរបស់ខ្លួន ទៅតតាំងចំពោះអ្នកបង្កើតបាន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដទៃដែលទទួលការបញ្ញាពីម្ចាស់សិទ្ធិប្រាតិភោគ កាន់កាប់ដោយចំពោះនូវ

វត្ថុដែលជាកម្មវត្ថុ ហើយម្ចាស់សិទ្ធិនោះបានធ្វើអនុប្បទានទូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ។

(កំណត់)

ដោយសារមានគោលបំណងនៃការបង្កើតប្រាតិភោគដោយអនុប្បទាន ជាសិទ្ធិប្រាតិភោគដល់ទំហំអតិបរមា ប្រសិនបើម្ចាស់បំណុលនៃម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបានរឹបអូសវត្ថុដែលជាកម្មវត្ថុ អ្នកបង្កើតប្រាតិភោគអាចដាក់ពាក្យបណ្ដឹងតវ៉ារបស់តតិយជនបាន (ទោះបីជាចំណុចនេះមិនត្រូវបានចែងច្បាស់ក៏ដោយ ក៏មានភាពច្បាស់លាស់ដែរ) ។ ផ្អែកលើការបកស្រាយនេះ កថាខណ្ឌទី ១ ទទួលស្គាល់ថា តតិយជនអាចតតាំងលទ្ធកម្មដោយសុចរិតនៃវត្ថុដែលជាកម្មវត្ថុបាន ។

ក្នុងករណីដែលអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានមិនអាចតតាំងសិទ្ធិប្រាតិភោគនោះចំពោះតតិយជន អ្នកបង្កើតសិទ្ធិប្រាតិភោគនោះមិនអាចអនុវត្តសិទ្ធិទទួលយកមកវិញចំពោះតតិយជនបានឡើយ (សូមមើលមាត្រា ៨៩៩) ។

## ផ្នែកទី ៤ ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន

**មាត្រា ៨៩៨.-** ការចាត់ចែងប្ដូរជាប្រាក់ ឬ អនុប្បទានជាស្ថាពរ

១-បើកាតព្វកិច្ចពុំត្រូវបានអនុវត្ត ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចប្ដូរវត្ថុដែលជាកម្មវត្ថុនោះជាប្រាក់ ដោយផ្ទាល់ខ្លួន ឬ ធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុជាស្ថាពរបាន ដោយជូនដំណឹងទៅអ្នកបង្កើត ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជាពីអ្នកបង្កើតនេះកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចទាមទារឱ្យជននោះប្រគល់វត្ថុដែលជាកម្មវត្ថុនោះបាន ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើតម្លៃនៃវត្ថុដែលជាកម្មវត្ថុមានចំនួនលើសពីចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសង ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវបង់ចំនួនទឹកប្រាក់ដែលលើសនោះ ទៅឱ្យអ្នកបង្កើត ដោយចាត់ជាប្រាក់ជម្រះ ។

(កំណត់)

មាត្រានេះចែងអំពីករណីដែលកូនបំណុលខកខានក្នុងការសងកាតព្វកិច្ច ហើយម្ចាស់បំណុលប្ដូរវត្ថុដែលជាកម្មវត្ថុនៃ

ប្រាតិភោគដោយអនុប្បទាន ទៅជាប្រាក់ ឬ ធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុជាស្ថាពរ ។

កថាខណ្ឌទី ១ ចែងអំពីនីតិវិធីនៃការប្តូរទៅជាប្រាក់ ឬ ការធ្វើលទ្ធកម្មជាស្ថាពរ ដោយបញ្ជាក់ថា ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន តម្រូវឱ្យជូនដំណឹងទៅអ្នកបង្កើតប្រាតិភោគអំពីការប្តូរជាប្រាក់ ឬ លទ្ធកម្មកម្មសិទ្ធិនោះ ។

កថាខណ្ឌទី ២ ចែងថា ប្រសិនបើអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជាពីអ្នកបង្កើតនេះ កាន់កាប់វត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចទាមទារឱ្យជននោះប្រគល់នូវវត្ថុដែលជាកម្មវត្ថុនោះបាន ។

កថាខណ្ឌទី ៣ ចែងថា ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន មានករណីយកិច្ចសងប្រាក់ជម្រះ ដើម្បីកុំឱ្យម្ចាស់សិទ្ធិនោះទទួលចំណេញហួសហេតុ ដោយធ្វើលទ្ធកម្មនូវវត្ថុដែលជាកម្មវត្ថុដែលមានតម្លៃថ្លៃជាងតម្លៃនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ។

## មាត្រា ៨៩៩.– សិទ្ធិទទួលយកមកវិញរបស់អ្នកបង្កើត

ទោះបីជាពេលកំណត់ត្រូវសងកាតព្វកិច្ចបានកន្លងផុតក៏ដោយ ក៏អ្នកបង្កើតអាចទទួលយកមកវិញនូវវត្ថុដែលជាកម្មវត្ថុ ដោយផ្តល់នូវកាតព្វកិច្ចគ្រប់ចំនួន និង បង្ហាញអំពីការផ្តល់នោះទៅម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន នៅមុនពេលមានការផ្តល់ប្រាក់ជម្រះដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៨៩៨ (ការចាត់ចែងប្តូរជាប្រាក់ ឬ អនុប្បទានជាស្ថាពរ) ខាងលើនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីតម្លៃវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ មិនលើសពីចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសង ក្រោយពេលដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន បានជូនដំណឹងអំពីចំនួនដែលមិនលើសនោះ ទៅឱ្យអ្នកបង្កើតហើយ ។

(កំណត់)

មាត្រានេះ មានគោលបំណងបញ្ជាក់ឱ្យច្បាស់អំពីអំឡុងពេលដែលកូនបំណុលមានសិទ្ធិទទួលយកមកវិញនូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ដោយការសងកាតព្វកិច្ចរបស់ខ្លួន (ដែលហៅថា សិទ្ធិទទួលយកមកវិញ) ។ បញ្ញត្តិនេះទទួលស្គាល់ថា អ្នកបង្កើតប្រាតិភោគដោយអនុប្បទានអាចអនុវត្តសិទ្ធិទទួលយកមកវិញ ដោយផ្តល់នូវចំនួនសរុបនៃកាតព្វកិច្ចបាន មុនពេលមានការស្នើផ្តល់ប្រាក់ជម្រះដែលបានចែងក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៨៩៨ ទោះបីជាពេលកំណត់ត្រូវសងកាតព្វកិច្ចបានកន្លងហួសក៏ដោយ ។ គោលបំណងនៃមាត្រានេះ គឺដើម្បីការពារអ្នកបង្កើតប្រាតិភោគដោយអនុប្បទានឱ្យបានច្រើនដែលអាចធ្វើបាន ក្នុងទំហំដែលមិនធ្វើឱ្យខូចខាតដល់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ។ ម្យ៉ាងទៀត វាក្យខណ្ឌទី ២ ចែងថា ក្នុងករណីដែលមិនមានប្រាក់ជម្រះទេ អ្នកបង្កើតប្រាតិភោគដោយអនុប្បទានមិនអាច

អនុវត្តសិទ្ធិទទួលយកមកវិញបានឡើង ក្រោយពេលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបានជូនដំណឹងអំពីហេតុដែលមិនមានប្រាក់ជម្រះ ។

## ជំពូកទី ៧ ការធានា

## ផ្នែកទី ១ ការបង្កើតកិច្ចសន្យាធានា

**មាត្រា ៩០០.-** ការបង្កើតកិច្ចសន្យាធានា

១-កិច្ចសន្យាធានាត្រូវបង្កើតឡើង ដោយសារបុគ្គលដែលមានបំណងធ្វើជាអ្នកធានា បានសន្យាជាមួយនឹងម្ចាស់បំណុលថា ខ្លួននឹងអនុវត្តកាតព្វកិច្ចមួយផ្នែក ឬ ទាំងមូល ជាមួយនឹងកូនបំណុលដែលមានកាតព្វកិច្ចចម្បង នៅក្នុងករណីដែលកូនបំណុលមានកាតព្វកិច្ចចម្បងនោះពុំអនុវត្តកាតព្វកិច្ចរបស់ខ្លួន ហើយម្ចាស់បំណុលបានយល់ព្រមអំពីការសន្យានោះ ។

២-ក្នុងកិច្ចសន្យាធានា ភាគីអាចធ្វើការសន្យាពិសេសដែលធានាការខូចខាត ដែលអ្នកធានាត្រូវទទួលបន្ទុកនូវកាតព្វកិច្ចធានាឯករាជ្យពីកាតព្វកិច្ចចម្បងបាន ។ ប៉ុន្តែ កាតព្វកិច្ចនៃការសន្យាពិសេសដែលធានាការខូចខាត អាចកើតបាន លុះត្រាតែអ្នកដែលទទួលបន្ទុកកាតព្វកិច្ចនៃការសន្យាពិសេសដែលធានាការខូចខាតនោះ មានអាជីវកម្មរបស់ខ្លួនជាការធានាការខូចខាត ឬ ការធានា ។

៣-ក្នុងករណីដែលអ្នកដែលមានបំណងធ្វើជាអ្នកធានា មិនមែនជាអ្នកដែលមានអាជីវកម្មធានា ម្ចាស់បំណុលត្រូវផ្តល់នូវព័ត៌មានសំខាន់ៗ ស្តីពីការណ៍ដែលអ្នកនោះក្លាយជាអ្នកធានា ទៅឱ្យអ្នកដែលមានបំណងធ្វើជាអ្នកធានានោះ និង ត្រូវផ្តល់ឱកាសឱ្យអ្នកនោះគិតពិចារណាឱ្យបានហ្មត់ចត់ ។

៤-ក្នុងករណីដែលម្ចាស់បំណុលប្រព្រឹត្តផ្ទុយនឹងកថាខណ្ឌទី ៣ ខាងលើនេះ អ្នកធានាអាចលុបចោលនូវកិច្ចសន្យាធានានោះបាន ។

(កំណត់)

កថាខណ្ឌទី ១ បញ្ជាក់ថា ការធានាត្រូវបានបង្កើតឡើង ដោយកិច្ចសន្យាដែលបង្កើតអានុភាព តាមការព្រមព្រៀងរវាងអ្នកធានា និង ម្ចាស់បំណុល ។

កថាខណ្ឌទី ២ បញ្ជាក់ថា មានកិច្ចសន្យាធានាការខូចខាត ដែលកាតព្វកិច្ចធានា គ្មានភាពបន្ទាប់បន្សំនៃកាតព្វកិច្ចចម្បង ។ ក៏ប៉ុន្តែ ការទទួលបន្ទុកនូវកាតព្វកិច្ចធានាការខូចខាត អាចជាបន្ទុកមួយដ៏ធ្ងន់របស់អ្នកធានា ហេតុនេះហើយ ការសន្យាពិសេសរបៀបនេះអាចធ្វើឡើងបាន លុះត្រាតែអ្នកធានាកាតព្វកិច្ចធានាការខូចខាតនោះ មានអាជីវកម្មរបស់ខ្លួនជាការធានា (វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២) ។ ហេតុដូច្នេះ ទោះជាអ្នកដែលមិនប្រកបអាជីវកម្មប្រភេទនេះ បានបង្កើតកិច្ចសន្យាពិសេសធានាការខូចខាតក៏ដោយ ក៏ការសន្យាពិសេសនោះគ្មានអានុភាពដែរ ហើយការធានានោះ ត្រូវចាត់ទុកជាការធានាធម្មតាវិញ ។

ក្នុងករណីដែលអ្នកធានាជាអ្នកប្រើប្រាស់ទេវិញ ត្រូវផ្តល់ព័ត៌មានគ្រប់គ្រាន់ដើម្បីឱ្យអ្នកធានានោះមានឱកាសគិតពិចារណាឱ្យបានហ្មត់ចត់ ដើម្បីបង្ការកុំឱ្យមានបន្ទុកនៃការធានាដែលគិតមិនបានដិតដល់ (កថាខណ្ឌទី ៣) ។ ហើយ ប្រសិនបើម្ចាស់បំណុលមិនបានធ្វើតាមបញ្ញត្តិនេះទេ មាត្រានេះទទួលស្គាល់នូវសិទ្ធិលុបចោលកិច្ចសន្យាធានារបស់អ្នកធានា (កថាខណ្ឌទី ៤) ។

**មាត្រា ៩០១.–** ទម្រង់ចាំបាច់នៃកិច្ចសន្យាធានា

១-ការធានាដោយគ្មានលិខិតជាលាយល័ក្ខណ៍អក្សរ អាចដកវិញនៅពេលណាក៏បាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកធានាបានចាប់ផ្តើមអនុវត្តកាតព្វកិច្ចធានានោះដោយស្ម័គ្រចិត្ត ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាដែរ ចំពោះករណីដែលចំនួនទឹកប្រាក់នៃកាតព្វកិច្ចធានា មិនត្រូវបានសរសេរជាអក្សរដោយផ្ទាល់ដៃរបស់អ្នកធានា ក្នុងការធានាកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ ។

៣-លិខិតជាលាយល័ក្ខណ៍អក្សរនៃការធានា ត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីខ្លឹមសារនៃកាតព្វកិច្ចធានា ។

(កំណត់)

មានពេលខ្លះ កិច្ចសន្យាធានាត្រូវបានធ្វើឡើងដោយសារមនោសញ្ចេតនា ឬ ដោយមិនបានគិតពិចារណាដោយហ្មត់ចត់ ហើយឱ្យអ្នកធានាទទួលនូវលទ្ធផលដ៏ធ្ងន់ធ្ងរ ។ ដើម្បីឱ្យកិច្ចសន្យាធានានោះធ្វើឡើងដោយមានការប្រុងប្រយ័ត្ន និងដោយការគិតយ៉ាងហ្មត់ចត់ ការបញ្ញត្តឱ្យកិច្ចសន្យាធានាដែលមិនធ្វើឡើងជាលាយល័ក្ខណ៍អក្សរ មានចំណងស្រាលជាដំណោះស្រាយមួយដែរ ។

មាត្រា ៩០០ បញ្ញត្តថា កិច្ចសន្យាធានា គឺជាកិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយការព្រមព្រៀង ហេតុដូច្នេះ មាត្រានេះចែងថា ប្រសិនបើមិនបានធ្វើឡើងជាលាយល័ក្ខណ៍អក្សរទេ កិច្ចសន្យាធានានេះអាចដកវិញបាន (កថាខណ្ឌទី

១) ។ក៏ប៉ុន្តែ ប្រសិនបើអនុញ្ញាតឱ្យអ្នកធានាអាចដកកិច្ចសន្យាវិញ ក្នុងករណីដែលអ្នកធានាបានចាប់ផ្តើមអនុវត្តកាតព្វកិច្ចធានាដោយស្ម័គ្រចិត្ត នឹងធ្វើឱ្យមានភាពស្មុគស្មាញដល់ទំនាក់ទំនងគតិយុត្ត ហេតុនេះហើយបានជាមិនអាចទទួលស្គាល់បានទេ (វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១) ។

រីឯចំនួនប្រាក់នៃកាតព្វកិច្ចធានាវិញ ដើម្បីបង្ហាញនូវការសម្រេចដោយបានគិតហ្មត់ចត់របស់អ្នកធានា ត្រូវទាមទារឱ្យសរសេរចំនួនទឹកប្រាក់ដោយផ្ទាល់ដៃ ហើយនេះជាកត្តាដ៏សំខាន់មួយដើម្បីទទួលស្គាល់នូវចំណងនៃកិច្ចសន្យាធានានោះ ។ ដូច្នេះ ក្នុងករណីនៃការធានាកាតព្វកិច្ចជាទឹកប្រាក់ ប្រសិនបើអ្នកធានាមិនបានសរសេរដោយដៃនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចធានានោះទេ អ្នកធានាអាចដកកិច្ចសន្យាធានានោះបាន (កថាខណ្ឌទី ២) ។ ហើយអំឡុងពេលដែលអាចដកកិច្ចសន្យាធានានោះបាន គឺត្រឹមមុនពេលចាប់ផ្តើមអនុវត្តការធានានោះ ដោយសារតែមានមូលហេតុដូចដែលបានពន្យល់ក្នុងកថាខណ្ឌទី ១ ដែរ ។

នៅក្នុងលិខិតកិច្ចសន្យាធានា ចាំបាច់ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវខ្លឹមសារនៃកាតព្វកិច្ចធានា ដើម្បីកុំឱ្យលទ្ធផលដ៏ធ្ងន់ធ្ងរអាចកើតឡើងចំពោះអ្នកធានា ។

**មាត្រា ៩០២.–** ការធានាបំណុលអណ្តែត

១-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៩០១ (ទម្រង់ចាំបាច់នៃកិច្ចសន្យាធានា) ខាងលើនេះ ក៏ដោយ ក៏កិច្ចសន្យាធានាបំណុលអណ្តែត ដែលធានាកាតព្វកិច្ចមិនកំណត់ដែលអាចកើតមានឡើងនៅពេលអនាគត ដោយសារទំនាក់ទំនងគតិយុត្តជានិរន្តរ៍ណាមួយនោះ នឹងមានសុពលភាព លុះត្រាតែបញ្ជាក់ច្បាស់នូវទំនាក់ទំនងគតិយុត្តជានិរន្តរ៍ ដែលជាមូលដ្ឋាននៃការបង្កើតកាតព្វកិច្ចចម្បង ។

២-បើកិច្ចសន្យាធានាបំណុលអណ្តែត មិនបានកំណត់អំឡុងពេលនៃការធានាទេ អ្នកធានាបំណុលអណ្តែតអាចរំលាយកិច្ចសន្យាធានាបំណុលអណ្តែតនោះឆ្ពោះទៅអនាគតបាន ក្រោយពីហួសអំឡុងពេលសមរម្យចាប់តាំងពីពេលដែលបានបង្កើតកិច្ចសន្យានោះ ។

៣-ចំពោះកិច្ចសន្យាធានាបំណុលអណ្តែត នៅក្នុងករណីដែលស្ថានភាពនៃកិច្ចការជំនួញ ឬ ទ្រព្យសម្បត្តិរបស់កូនបំណុល ដែលមានកាតព្វកិច្ចចម្បងធ្លាក់អន់ថយយ៉ាងខ្លាំងបើប្រៀបធៀបទៅនឹងពេលបង្កើតកិច្ចសន្យាធានាបំណុលអណ្តែតនោះ អ្នកធានាបំណុលអណ្តែត អាចរំលាយកិច្ចសន្យាធានាបំណុលអណ្តែតនោះឆ្ពោះទៅអនាគតដោយភ្លាមៗបាន ។

៤-ចំពោះកិច្ចសន្យាធានាបំណុលអណ្តែត បើអ្នកធានាបំណុលអណ្តែតបានទទួល

មរណភាព មានតែកាតព្វកិច្ចធានាបំណុលអណ្ដែត ចំពោះកាតព្វកិច្ចចម្បងដែលបានកើតឡើងមកត្រឹមពេលអ្នកធានានោះទទួលមរណភាពទេ ទើបត្រូវបន្តដោយសន្តតិកម្ម ។

(កំណត់)

ការធានាបំណុលអណ្ដែតអាចបង្កើតនូវស្ថានភាពដ៏ធ្ងន់ធ្ងរមួយចំពោះអ្នកធានា ជាងការធានាធម្មតា ។ ហេតុនេះហើយ ចាំបាច់ត្រូវធ្វើកុំឱ្យបន្ទុកនៃការធានាបំណុលអណ្ដែតក្លាយទៅជាធ្ងន់ធ្ងរ ។

មាត្រានេះតម្រូវឱ្យបញ្ជាក់ឱ្យបានច្បាស់លាស់នូវទំនាក់ទំនងគតិយុត្តជានិរន្តរ៍ ដែលជាមូលដ្ឋាននៃការបង្កើតកាតព្វកិច្ចចម្បង ហើយប្រសិនបើខុសនឹងល័ក្ខខ័ណ្ឌនេះ ត្រូវចាត់ទុកកិច្ចសន្យាធានាបំណុលអណ្ដែតនោះជាមោឃៈ (កថាខណ្ឌទី ១) ។ នៅមានបញ្ហាមួយទៀតដែលគួរគិតដែរថា តើគួរទទួលស្គាល់នូវកិច្ចសន្យាធានាបំណុលអណ្ដែតសកលដែរ ឬទេ ។ ចំពោះបញ្ហានេះ ត្រូវពិនិត្យមើលដែរថា តើស្ថានភាពប្រើកិច្ចសន្យាប្រភេទនេះមានយ៉ាងណាដែរ នៅក្នុងការជួញដូរជាក់ស្ដែង ក៏ប៉ុន្តែ ការចាត់ទុកជាមោឃៈទាំងអស់ ក៏ជាការមួយដែលគួរពិចារណាឱ្យបានហ្មត់ចត់ដែរ ។ ជំនួសគំនិតនេះ ដើម្បីបន្ធូរនូវបន្ទុកធ្ងន់ជ្រុលពេករបស់អ្នកធានាបំណុលអណ្ដែតសកល មាត្រានេះទទួលស្គាល់នូវសិទ្ធិជូនដំណឹងអំពីការរំលាយកិច្ចសន្យាឆ្ពោះទៅអនាគត (កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣) ។

ក្នុងករណីដែលមិនបានកំណត់អំឡុងពេលធានាទេ បន្ទុករបស់អ្នកធានាបំណុលអណ្ដែតនឹងអាចកើតឡើងយ៉ាងធ្ងន់ធ្ងរដោយគ្មានព្រំដែន ។ ហេតុដូច្នេះ ដោយគិតពិចារណានូវស្ថានភាពផ្សេងៗនៅជុំវិញកិច្ចសន្យាធានាបំណុលអណ្ដែតនោះ មាត្រានេះអនុញ្ញាតឱ្យអ្នកធានាបំណុលអណ្ដែតនោះ អាចជូនដំណឹងអំពីការរំលាយកិច្ចសន្យាធានានោះឆ្ពោះទៅអនាគតបន្ទាប់ពីអំឡុងពេលសមរម្យមួយបានកន្លងផុតទៅ (កថាខណ្ឌទី ២) ។

ក្នុងករណីដែលស្ថានភាពទ្រព្យសម្បត្តិ ឬ ស្ថានភាពកិច្ចការជំនួញរបស់កូនបំណុលដែលមានកាតព្វកិច្ចចម្បង បានធ្លាក់អន់ថយយ៉ាងខ្លាំងហួសពីការព្យាករនៅពេលធ្វើកិច្ចសន្យាធានាបំណុលអណ្ដែតនោះ មាត្រានេះទទួលស្គាល់ឱ្យអ្នកធានាបំណុលអណ្ដែតនោះ ជូនដំណឹងអំពីការរំលាយកិច្ចសន្យាធានាបំណុលណ្ដែតឆ្ពោះទៅអនាគត ហើយធ្វើការកំណត់នូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចធានានៅពេលនោះ ហើយអ្នកធានាទទួលបន្ទុកត្រឹមកម្រិតដែលត្រូវបានកំណត់នោះ (កថាខណ្ឌទី ៣) ។

ឋានៈរបស់អ្នកធានាបំណុលអណ្ដែតមិនត្រូវទទួលបន្តដោយសន្តតិកម្មទេ (កថាខណ្ឌទី ៤) ។

## ផ្នែកទី ២ អានុភាពនៃការធានា

**មាត្រា ៩០៣.-** ទំហំនៃកាតព្វកិច្ចធានា

១-កាតព្វកិច្ចធានាត្រូវរាប់បញ្ចូល ទាំងការប្រាក់ ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា និង សំណងការខូចខាត ដែលទាក់ទងនឹងកាតព្វកិច្ចចម្បង និង អ្វីដែល

កើតឡើងបន្ទាប់បន្សំ ពីកាតព្វកិច្ចចម្បងនោះ ។[4]

២-កិច្ចសន្យាធានា អាចកំណត់នូវចំនួនទឹកប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ឬ ប្រាក់សំណងការខូចខាត ចំពោះការមិនអនុវត្តកាតព្វកិច្ចធានាបាន ។

(កំណត់)

អ្នកធានាត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចចម្បង ព្រមទាំងកាតព្វកិច្ចបន្ទាប់បន្សំដែលកើតឡើងដោយកាតព្វកិច្ចចម្បងនោះ (កថាខណ្ឌទី ១) ។ ជាគោលការណ៍ ទំហំនៃកាតព្វកិច្ចធានាត្រូវកំណត់ដោយឆន្ទៈរបស់ភាគី ក្នុងកិច្ចសន្យាធានា ។ ក៏ប៉ុន្តែ ប្រសិនបើគ្មានការសន្យាពិសេសទេ តាមទំនៀមទម្លាប់នៃកិច្ចការជំនួញ ឆន្ទៈរបស់ភាគីអាចត្រូវបានសន្មតបានថា ធានានូវកាតព្វកិច្ចចំពោះប្រាក់ដើមដែលកូនបំណុលដែលមានកាតព្វកិច្ចចម្បងទទួលបន្ទុក ព្រមទាំងកាតព្វកិច្ចបន្ទាប់បន្សំ ដូចជាការប្រាក់ ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា សំណងនៃការខូចខាត ជាអាទិ៍ ។ មាត្រានេះចែងអំពីចំណុចនេះ ។ ប្រសិនបើភាគីបានធ្វើការសន្យាពិសេសផ្សេងទៀត ត្រូវអនុលោមតាមការសន្យាពិសេសនោះ ។

ម្យ៉ាងទៀត ចំពោះកិច្ចសន្យាធានាការខូចខាត តាមធម្មតា ក្នុងកិច្ចសន្យា មានការកំណត់ច្បាស់លាស់អំពីទំហំនៃការធានា ហេតុនេះហើយបញ្ញត្តិនៃមាត្រានេះមិនត្រូវយកមកអនុវត្តចំពោះកិច្ចសន្យាធានាការខូចខាតឡើយ ។ ប៉ុន្តែនៅដំណាក់កាលបកស្រាយកិច្ចសន្យា អាចមានករណីដែលឆន្ទៈដូចមាត្រានេះត្រូវបានយល់ឃើញដែរ ។

ប្រសិនបើមានការកំណត់នូវសំណងនៃការខូចខាតពាក់ព័ន្ធនឹងការបំពានកិច្ចសន្យាធានា ក្នុងកិច្ចសន្យាធានា ដោយយោងតាមគោលការណ៍សេរីភាពក្នុងការធ្វើកិច្ចសន្យា អានុភាពនៃការពិសេសនេះត្រូវបានទទួលស្គាល់ដែរ (កថាខណ្ឌទី ២) ។

ម្យ៉ាងទៀត វិធានការដើម្បីធានានូវភាពសមរម្យនៃប្រាក់សំណងក្នុងករណីបំពានកិច្ចសន្យា ឬ ការកំណត់ជាមុននូវចំនួននៃសំណងការខូចខាត ត្រូវចែងដោយឡែកផ្សេងទៀត ។

## មាត្រា ៩០៤.- លក្ខណៈនៃការធានា

១-កិច្ចសន្យាធានាមិនអាចកើតឡើងបានឡើយ នៅក្នុងករណីដែលគ្មានកាតព្វកិច្ចចម្បងទេ ។ ប៉ុន្តែ កិច្ចសន្យាធានាអាចកើតឡើងបាន ចំពោះកាតព្វកិច្ចដែលនឹងកើតមានឡើងនៅពេលអនាគត ឬ កាតព្វកិច្ចដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ ។

២-ក្នុងករណីដែលបន្ទុករបស់អ្នកធានាធ្ងន់ជាងកាតព្វកិច្ចចម្បង ដោយគិតទាំងកម្មវត្ថុ ឬ ល័ក្ខខ័ណ្ឌ នោះត្រូវបន្ថយបន្ទុករបស់អ្នកធានាត្រឹមកម្រិតនៃកាតព្វកិច្ចចម្បង ។

---

[4] កថាខណ្ឌទី ១ នៃមាត្រា ៩០៣ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

៣-ក្នុងករណីដែលកាតព្វកិច្ចចម្បងរលត់ កាតព្វកិច្ចធានាក៏ត្រូវរលត់ផងដែរ ។

៤-ការផ្អាកអាជ្ញាយុកាលដោយការទាមទារចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង ឬ ដោយមូលហេតុផ្សេងៗទៀត ក៏មានអានុភាពចំពោះអ្នកធានាផងដែរ ។

៥-ក្នុងករណីដែលសិទ្ធិលើបំណុលចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង ត្រូវបានធ្វើអនុប្បទាន នោះសិទ្ធិលើបំណុល ចំពោះអ្នកធានាក៏ត្រូវចាត់ទុកថា បានធ្វើអនុប្បទានផងដែរ លើកលែងតែមានការសន្យាពិសេស ។

(កំណត់)

មាត្រានេះបញ្ជាក់ច្បាស់លាស់អំពីលទ្ធផលមួយចំនួនដែលកើតឡើងដោយសារលក្ខណៈនៃកាតព្វកិច្ចធានា ដែលជាកាតព្វកិច្ចបន្ទាប់បន្សំនៃកាតព្វកិច្ចចម្បង (ភាពបន្ទាប់បន្សំ) ។ ម្យ៉ាងទៀត ចំពោះកិច្ចសន្យាធានាការខូចខាតដែលមិនទទួលស្គាល់នូវភាពបន្ទាប់បន្សំវិញ មានច្រើនបែបយ៉ាង ហេតុដូច្នេះ ដោយយោងតាមគោលការណ៍សេរីភាពក្នុងការធ្វើកិច្ចសន្យា មិនចាំបាច់ចែងក្នុងក្រមរដ្ឋប្បវេណីទេ ទុកឱ្យស្វ័យភាពនៃភាគី ជាការប្រសើរ ។

ប្រសិនជាគ្មានកាតព្វកិច្ចចម្បងទេ កាតព្វកិច្ចធានាក៏មិនអាចកើតឡើងដែរ (កថាខណ្ឌទី ១) ។

អ្នកធានាមិនត្រូវទទួលបន្ទុកនូវកាតព្វកិច្ចធ្ងន់ជាងកូនបំណុលដែលមានកាតព្វកិច្ចចម្បងឡើយ (កថាខណ្ឌទី ២) ។

ខ្លឹមសារនៃកាតព្វកិច្ចធានា គឺជាការអនុវត្តនូវកាតព្វកិច្ចចម្បង ហេតុនេះហើយប្រសិនបើកាតព្វកិច្ចចម្បងរលត់ដោយសារមូលហេតុអ្វីមួយ កាតព្វកិច្ចធានាក៏ត្រូវរលត់ដែរ (កថាខណ្ឌទី ៣) ។

ដើម្បីកុំឱ្យកាតព្វកិច្ចធានារលត់មុនការរលត់កាតព្វកិច្ចចម្បង ហើយដើម្បីឱ្យអាចប្រមូលសិទ្ធិលើបំណុលបាន ការផ្អាកអាជ្ញាយុកាលចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង ដូចជាការទាមទារឱ្យកូនបំណុលអនុវត្ត ក៏មានអានុភាពចំពោះអ្នកធានាដែរ (កថាខណ្ឌទី ៤) ។

ក្នុងករណីដែលសិទ្ធិលើបំណុលចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង ត្រូវបានធ្វើអនុប្បទាន ការចាត់ចែងចំពោះសិទ្ធិលើបំណុលចំពោះអ្នកធានា ត្រូវអនុលោមតាមឆន្ទៈរបស់ភាគីនៃកិច្ចសន្យាអនុប្បទានសិទ្ធិលើបំណុលនោះ ។ តាមទំនៀមទម្លាប់នៃកិច្ចការជំនួញ ការធ្វើអនុប្បទានសិទ្ធិលើបំណុល ក៏ជាការធ្វើអនុប្បទានព្រមគ្នានូវសិទ្ធិលើបំណុលចំពោះអ្នកធានាដែលជាសិទ្ធិបន្ទាប់បន្សំដែរ ។ ហេតុដូច្នេះ មាត្រានេះចែងថា នៅពេលដែលសិទ្ធិលើបំណុលចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បងត្រូវបានធ្វើអនុប្បទាន សិទ្ធិលើបំណុលចំពោះអ្នកធានាក៏ត្រូវចាត់ទុកថា ត្រូវបានធ្វើអនុប្បទានដែរ (កថាខណ្ឌទី ៥) ។ ចំណុចនេះ ត្រូវហៅថា ភាពទៅជាមួយគ្នានៃកាតព្វកិច្ចធានា ដែលជាផ្នែកមួយនៃខ្លឹមសារនៃភាពបន្ទាប់បន្សំនៃកាតព្វកិច្ចធានា ។

**មាត្រា ៩០៥.-** សិទ្ធិរបស់អ្នកធានា

១-អ្នកធានាអាចលើកឡើងអំពីការរលត់កាតព្វកិច្ចចម្បង ដោយអាជ្ញាយុកាល

បាន ។

២-បើកូនបំណុលដែលមានកាតព្វកិច្ចចម្បង បានបោះបង់ចោលផលប្រយោជន៍នៃអាជ្ញាយុកាល អានុភាពនេះពុំមានចំពោះអ្នកធានាឡើយ ។

៣-អ្នកធានាអាចលើកឡើងនូវសិទ្ធិតវ៉ារបស់កូនបំណុលដែលមានកាតព្វកិច្ចចម្បងមកប្រើបាន ។

៤-បើកូនបំណុលដែលមានកាតព្វកិច្ចចម្បង មានសិទ្ធិលុបចោល ឬ សិទ្ធិរំលាយ នោះអ្នកធានាអាចបដិសេធនូវការអនុវត្តកាតព្វកិច្ចធានាបាន ។

៥-បើកូនបំណុលដែលមានកាតព្វកិច្ចចម្បង ស្ថិតនៅក្នុងឋានៈដែលខ្លួនអាចទូទាត់កាតព្វកិច្ចរបស់ខ្លួន ដោយយកសិទ្ធិលើបំណុល ចំពោះម្ចាស់បំណុលបាន នោះអ្នកធានាអាចបដិសេធនូវការអនុវត្តកាតព្វកិច្ចធានាបាន ត្រឹមតែកម្រិតដែលកាតព្វកិច្ចចម្បងត្រូវរលត់ ដោយសារការទូទាត់នោះ ។

(កំណត់)

ដោយសារកាតព្វកិច្ចធានាគឺជាកាតព្វកិច្ចបន្ទាប់បន្សំ អ្នកធានាមានសិទ្ធិតវ៉ាផ្សេងៗ ចំពោះហេតុដែលកើតឡើងចំពោះកាតព្វកិច្ចចម្បង ។ មាត្រានេះចែងអំពីឧទាហរណ៍ជាក់ស្តែងនៃសិទ្ធិតវ៉ានោះ ។

អ្នកធានាអាចលើកឡើងអំពីការរលត់កាតព្វកិច្ចចម្បងដោយអាជ្ញាយុកាលបាន (កថាខណ្ឌទី ១) ។

ការបោះបង់ចោលផលប្រយោជន៍នៃអាជ្ញាយុកាលដោយកូនបំណុលដែលមានកាតពកិច្ចចម្បង គ្រាន់តែមានអានុភាពមិនដាច់ខាតប៉ុណ្ណោះ ហេតុនេះហើយ ទោះបីជាកូនបំណុលដែលមានកាតព្វកិច្ចចម្បងបានបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលក៏ដោយ ក៏អ្នកធានាអាចលើកឡើងអំពីការរលត់កាតព្វកិច្ចចម្បងដោយអាជ្ញាយុកាលដោយខ្លួនឯងបានដែរ (កថាខណ្ឌទី ២) ។

អ្នកធានាអាចលើកឡើងនូវសិទ្ធិតវ៉ានៃការអនុវត្តព្រមគ្នា សិទ្ធិតវ៉ានៃការអនុគ្រោះនូវពេលកំណត់ របស់កូនបំណុលដែលមានកាតព្វកិច្ចចម្បងបាន (កថាខណ្ឌទី ៣) ។

ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចចម្បងមានសិទ្ធិលុបចោល ឬ សិទ្ធិរំលាយ កាតព្វកិច្ចចម្បងនោះ នឹងមិនទាន់កំណត់ច្បាស់លាស់ទេ ហេតុដូច្នេះ ក្នុងអំឡុងពេលនោះ អ្នកធានាអាចបដិសេធនូវការអនុវត្តកាតព្វកិច្ចធានារបស់ខ្លួនបាន (កថាខណ្ឌទី ៤) ។

ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចចម្បងមានសិទ្ធិទូទាត់ នៅប្រទេសជប៉ុន អ្នកធានាអាចអនុវត្តសិទ្ធិទូទាត់បាន (កថាខណ្ឌទី ២ នៃមាត្រា ៤៥៧ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មតិយោបល់ទូទៅ, កថាខណ្ឌទី ១ មាត្រា ១២៩៤ នៃក្រមរដ្ឋប្បវេណីបារាំង ចែងដូចក្រមរដ្ឋប្បវេណីជប៉ុនដែរ) ។ ក៏ប៉ុន្តែ ការទទួលស្គាល់រហូតឱ្យអ្នកធានា

អាចចាត់ចែងសិទ្ធិលើបំណុលរបស់កូនបំណុលដែលមានកាតព្វកិច្ចចម្បង គឺជាការទទួលស្គាល់ជ្រុលពេក ហេតុនេះហើយ បានជាក្នុងក្រមនេះបញ្ញត្តឱ្យអ្នកធានាមានសិទ្ធិត្រឹមតែបដិសេធការអនុវត្តតែប៉ុណ្ណោះ ដូចកថាខណ្ឌទី ២ មាត្រា ៧៧០ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ដែរ (កថាខណ្ឌទី ៥) ។

**មាត្រា ៩០៦.-** ការធានាចំពោះកាតព្វកិច្ចដែលអាចលុបចោលបាន

ក្នុងករណីដែលអ្នកធានាដែលមានអាជីវកម្មរបស់ខ្លួន ជាការធានាការខូចខាត ឬ ការធានា បានធានាកាតព្វកិច្ចដែលអាចលុបចោលបាន ដោយបានដឹងអំពីមូលហេតុនៃការលុបចោល អ្នកធានានោះត្រូវបានសន្មតថា បានទទួលបន្ទុកនូវកាតព្វកិច្ចឯករាជ្យមួយផ្សេង ដែលមានគោលបំណងដូចគ្នានឹងកាតព្វកិច្ចចម្បង ។

(កំណត់)

មាត្រានេះទទួលស្គាល់នូវការបង្កើតកាតព្វកិច្ចធានាការខូចខាត ដោយយោងទៅតាមការបកស្រាយឆន្ទៈរបស់ភាគី ។

ក្នុងករណីដែលបុគ្គលដែលដឹងថា កាតព្វកិច្ចចម្បងអាចត្រូវបានលុបចោលបាន បានធ្វើកិច្ចសន្យាធានា ទោះបីជាកាតព្វកិច្ចចម្បងនោះបានរលត់ដោយសារការលុបចោលក៏ដោយ តាមធម្មតាត្រូវគិតថា ការរំលត់កាតព្វកិច្ចធានាដោយយកមូលហេតុនៃភាពបន្ទាប់បន្សំ មិនស្របនឹងឆន្ទៈរបស់ភាគីទេ ។ ហេតុនេះហើយ មាត្រានេះសន្មតថា កិច្ចសន្យាធានានេះ ត្រូវបានបង្កើតឡើងជាកិច្ចសន្យាធានាការខូចខាត ។ ក៏ប៉ុន្តែ ការឱ្យអ្នកប្រើប្រាស់ធម្មតាទទួលបន្ទុកធ្ងន់នូវកាតព្វកិច្ចធានាការខូចខាត មិនមែនជាការសមរម្យទេ ហេតុនេះហើយបានជាមាត្រានេះសន្មតការធានាការខូចខាត ដោយត្រឹមតែបុគ្គលដែលមានអាជីវកម្មជាការធានាការខូចខាត ឬ ការធានាប៉ុណ្ណោះ (វាក្យខណ្ឌទី ២) ដើម្បីឱ្យមានតុល្យភាពនឹងកថាខណ្ឌទី ២ នៃមាត្រា ៩០០ ។ម្យ៉ាងទៀត តាមធម្មតា ករណីដែលសន្មតថាជាកិច្ចសន្យាធានា ការខូចខាត គឺពេលដែលអ្នកធានាជាអ្នកតំណាងដែលច្បាប់បានកំណត់សម្រាប់បុគ្គលដែលត្រូវបានកម្រិតសមត្ថភាព ។ ក៏ប៉ុន្តែ ក្នុងករណីនេះ យើងអាចសន្និដ្ឋានថា អ្នកតំណាងដែលច្បាប់បានកំណត់ ព្រមធ្វើជាអ្នកធានា ដោយផ្តល់សច្ចានុមតិ ឬ ការយល់ព្រមចំពោះកិច្ចសន្យាដែលជាមូលដ្ឋាននៃការបង្កើតកាតព្វកិច្ចចម្បង ហេតុដូច្នេះ តាមការពិត អ្នកតំណាងនេះមិនអាចលុបចោលនូវកិច្ចសន្យាដែលជាមូលហេតុនៃការបង្កើតកាតព្វកិច្ចចម្បងទេ ។ ហេតុនេះហើយ ការកម្រិតនូវការសន្មតដោយមាត្រានេះ ចំពោះតែបុគ្គលដែលមានអាជីវកម្មជាការធានាការខូចខាត ឬ ការធានានេះ មិនមានអ្វីជាបញ្ហាទេ ។

ដោយសារតែអាចធ្វើឱ្យខូចដល់ភាពបន្ទាប់បន្សំនៃការធានា ក្រមរដ្ឋប្បវេណីជប៉ុន ទទួលស្គាល់ការចាត់ចែងខាងលើនេះ តែក្នុងករណីដែលមូលហេតុនៃការលុបចោលជាអសមត្ថភាពប៉ុណ្ណោះ ។ ក៏ប៉ុន្តែ បើគិតទៅដល់បញ្ហាដែលបានរៀបរាប់ពីលើមក មិនចាំបាច់ធ្វើការកម្រិតបែបនេះក៏បានដែរ ។ ម្យ៉ាងទៀត ករណីដែលអ្នកធានាមានភាពទុច្ចរិតចំពោះមូលហេតុនៃការលុបចោល ក្រៅពីការកម្រិតសមត្ថភាព មានតិចតួចណាស់ ។

**មាត្រា ៩០៧.–** លក្ខណសម្បត្តិរបស់អ្នកធានា

១-ក្នុងករណីដែលកូនបំណុលទទួលបន្ទុកនូវករណីយកិច្ចត្រូវរកអ្នកធានា អ្នកធានានោះត្រូវតែជាសមត្ថជន និង ត្រូវមានសាធនភាពដើម្បីសងបំណុល ។

២-ក្នុងករណីដែលអ្នកធានាបានបាត់បង់នូវលក្ខណសម្បត្តិ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលរកអ្នកធានាផ្សេងទៀត ដែលមានលក្ខណសម្បត្តិ ដូចបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ មកជំនួសបាន ។

៣-ក្នុងករណីដែលកូនបំណុលមិនអាចរកអ្នកធានាដែលមានលក្ខណសម្បត្តិ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបានទេ ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលដាក់ប្រាតិភោគផ្សេងទៀតបាន ។

៤-បញ្ញត្តិនៃមាត្រានេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលម្ចាស់បំណុលបានជ្រើសតាំងអ្នកធានា ។

(កំណត់)

ចំពោះលក្ខណសម្បត្តិរបស់អ្នកធានា ជាគោលការណ៍ គ្មានកម្រិតទេ ។ នេះគឺជាបញ្ហាឯកជនផ្ទាល់ខ្លួនរវាងម្ចាស់បំណុល និង អ្នកធានា ។ ក៏ប៉ុន្តែ ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចចម្បង មានករណីយកិច្ចរកអ្នកធានា កូនបំណុលនោះត្រូវរកអ្នកធានាដែលសមរម្យជាអ្នកធានា ។

ដើម្បីបំពេញនូវតម្រូវការនៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល ចាំបាច់ត្រូវរកអ្នកធានាដែលមានសិទ្ធិគ្រប់គ្រង និងសិទ្ធិចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន ព្រមទាំងមានទ្រព្យសម្បត្តិគ្រប់គ្រាន់ផងដែរ ។ ដូច្នេះ កូនបំណុលត្រូវរកអ្នកធានាដែលជាសមត្ថជន ហើយសាធនភាពគ្រប់គ្រាន់ដើម្បីសង (កថាខណ្ឌទី ១) ។

ចំណុចខ្សោយនៃប្រាតិភោគដោយការធានា មានត្រង់ចំណុចថា ស្ថានភាពទ្រព្យសម្បត្តិរបស់អ្នកធានាមានការផ្លាស់ប្តូរ ហើយអាចធ្លាក់ទៅជាអសាធនភាព ។ ក្នុងករណីដែលត្រូវការឱ្យមានអ្នកធានា ជាការល្អ គួរឱ្យម្ចាស់បំណុលអាចទាមទារឱ្យមានភាពជាក់ច្បាស់ក្នុងការធានាបំណុលនោះជានិរន្តរ៍ ។ ដូច្នេះ ប្រសិនបើអ្នកធានាបាត់បង់នូវលក្ខណសម្បត្តិដូចខាងលើនេះ កូនបំណុលត្រូវរកអ្នកធានាណាផ្សេងដែលមានលក្ខណសម្បត្តិជាអ្នកធានាមកធានាជំនួសវិញ (កថាខណ្ឌ ទី ២) ហើយប្រសិនបើមិនអាចរកអ្នកធានាផ្សេងមកជំនួសវិញទេ ត្រូវផ្តល់ប្រាតិភោគផ្សេងជំនួសវិញ (កថាខណ្ឌទី ៣) ។

ប៉ុន្តែ ក្នុងករណីដែលម្ចាស់បំណុលបានជ្រើសតាំងអ្នកធានា ម្ចាស់បំណុលត្រូវទទួលបន្ទុកនូវហានិភ័យនៃអសាធនភាពរបស់អ្នកធានា ។ ដូច្នេះហើយក្នុងករណីដែលម្ចាស់បំណុលបានជ្រើសតាំងអ្នកធានា មិនចាំបាច់តម្រូវឱ្យអ្នកធានាមាន

លក្ខណសម្បត្តិដូចខាងលើនេះទេ (កថាខណ្ឌទី ៤) ។

**មាត្រា ៩០៨.–** អត្ថន័យនៃការធានាដោយសាមគ្គីភាព និង គោលការណ៍នៃការធានាដោយសាមគ្គីភាព

១-បុគ្គលដែលទទួលបន្ទុកកាតព្វកិច្ចត្រូវធានាដោយសាមគ្គីភាពជាមួយនឹងកូនបំណុលដែលមានកាតព្វកិច្ចចម្បង មិនអាចទាមទារឱ្យម្ចាស់បំណុលទាមទារពីកូនបំណុលដែលមានកាតព្វកិច្ចចម្បងជាមុនសិន ឬ មិនអាចរួចផុតពីការអនុវត្តចំពោះខ្លួនផ្ទាល់ដោយសំអាងថា កូនបំណុលមានសាធនភាពគ្រប់គ្រាន់ដើម្បីសង និង អាចអនុវត្តចំពោះកូនបំណុលនោះដោយងាយស្រួលបានឡើយ ។

២-អ្នកធានាមានកាតព្វកិច្ចត្រូវធានាដោយសាមគ្គីភាពជាមួយនឹងកូនបំណុល លើកលែងតែមានការព្រមព្រៀងពិសេស ។

(កំណត់)

ជាគោលការណ៍ ការធានាគឺជាការធានាដោយសាមគ្គីភាព ។

ក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច និង សេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ជ្រើសរើសយកគោលការណ៍នៃការធានាដោយសាមគ្គីភាព ហេតុនេះហើយបានជាក្រមនេះបានជ្រើសរើសយកគោលការណ៍នៃការធានាដោយសាមគ្គីភាពដែរ ។ នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន ការធានាដោយសាមគ្គីភាពត្រូវបានទទួលស្គាល់ ក្នុងករណីដែលមានការសន្យាពិសេសតែប៉ុណ្ណោះ ។

**មាត្រា ៩០៩.–** អានុភាពនៃហេតុដែលកើតឡើងចំពោះអ្នកធានា

ហេតុទាំងឡាយដែលកើតឡើងចំពោះអ្នកធានា ពុំមានអានុភាពចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បងឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះការទាមទារ ឬ ហេតុផ្សេងនៃការផ្អាកអាជ្ញាយុកាល ចំពោះអ្នកធានាដែលទទួលអាណត្តិពីកូនបំណុលដែលមានកាតព្វកិច្ចចម្បង ។

(កំណត់)

ដោយសារការធានាជាការធានាដោយសាមគ្គីភាព មានភាពចាំបាច់ត្រូវចាត់ចែងឱ្យមានភាពរលូននឹងកាតព្វកិច្ចដោយសាមគ្គីភាព ។ ចំពោះកាតព្វកិច្ចដោយសាមគ្គីភាព ក្រមនេះតម្រូវឱ្យមានឆន្ទៈសាមគ្គីភាពរួមគ្នាទៅវិញទៅមកក្នុងចំណោមកូនបំណុល ហេតុដូច្នេះ ចំពោះការធានាដោយសាមគ្គីភាព ក៏ចាំបាច់ត្រូវគិតដូចគ្នាដែរ ។ ហេតុនេះហើយ មាត្រានេះ

ត្រូវបានបញ្ញត្តឡើងដោយគោលគំនិតនេះ ។

ចំពោះការទាមទារចំពោះអ្នកធានាដែលទទួលអាណត្តិពីកូនបំណុលដែលមានកាតព្វកិច្ចចម្បង ឬ ហេតុផ្សេងទៀតនៃការផ្អាកអាជ្ញាយុកាល ចំណុចដែលហេតុទាំងនេះមានអានុភាពលើកូនបំណុលដែលមានកាតព្វកិច្ចចម្បង មិនមានបញ្ហាអ្វីពិសេសទេ ។ ក្រៅពីនេះ គួរជជែកគ្នាមើលដែរថា តើមានហេតុដែលត្រូវទទួលស្គាល់នូវអានុភាពដាច់ខាតនៃហេតុដែលកើតឡើង ចំពោះអ្នកធានាដែលទទួលអាណត្តិដែរ ឬទេ ។ ពេលនោះត្រូវគិតអំពីនវកម្ម និង ព្យាកុលភាព ។ ក្នុងករណីដែលនវកម្មត្រូវបានធ្វើឡើងរវាងម្ចាស់បំណុល និង អ្នកធានា ប្រសិនបើបញ្ញត្តិចែងថា សិទ្ធិលើបំណុលត្រូវរលត់ចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង តើបញ្ញត្តិនេះពុំមានភាពសមរម្យដែរ ឬទេនោះ ជាបញ្ហាមួយដែលត្រូវគិតឱ្យបានច្បាស់លាស់ ។ ឬ ត្រូវដោះស្រាយបញ្ហានេះដោយឧបាទេសកម្មដោយការសង ? ម្យ៉ាងទៀត ចំពោះព្យាកុលភាពវិញ មិនចាំបាច់ទទួលស្គាល់នូវអានុភាពដាច់ខាតជាពិសេសទេ ដោយសារអ្នកធានានឹងអាចរួចផុតពីកាតព្វកិច្ចធានា ហើយក្លាយទៅជាម្ចាស់បំណុលទេវិញបាន ។ លទ្ធផលនេះមានដូចជាការទទួលស្គាល់នូវអានុភាពដាច់ខាតដែរ ។

ផ្ទុយទៅវិញ ប្រសិនបើទទួលស្គាល់អានុភាពនៃហេតុដែលកើតឡើងចំពោះអ្នកធានាដែលគ្មានអាណត្តិពីកូនបំណុលដែលមានកាតព្វកិច្ចចម្បង លើកូនបំណុលដែលមានកាតព្វកិច្ចចម្បង នឹងនាំឱ្យមានបញ្ហា ។ នេះគឺដោយសារការមិនសូវមានឆន្ទៈសាមគ្គីភាពរួមគ្នា ។ ដូច្នេះហើយបានជាមាត្រានេះមិនទទួលស្គាល់នូវអានុភាពដាច់ខាតនេះ ។

## មាត្រា ៩១០.- ការធានារួម

១-ក្នុងកិច្ចសន្យាដែលមានអ្នកធានាច្រើននាក់ អ្នកធានាម្នាក់ៗមានករណីយកិច្ចចំពោះចំនួនទឹកប្រាក់ទាំងអស់នៃកាតព្វកិច្ចចម្បង ។

២-ភាគនៃបន្ទុករបស់អ្នកធានារួមដែលគ្មានការសន្យាពិសេសអំពីការបែងចែកបន្ទុក ត្រូវបានសន្មតថាស្មើគ្នា ។

(កំណត់)

ប្រសិនបើយកគោលករណ៍នៃការធានាដោយសាមគ្គីភាព ក្នុងករណីនៃការធានារួម គ្មានអត្ថិភាពនៃផលប្រយោជន៍នៃការបែងចែកបន្ទុកទេ ។ មាត្រានេះចែងអំពីចំណុចនេះដើម្បីឱ្យប្រយ័ត្ន ។ ក៏ប៉ុន្តែ មិនមែនមានន័យថា ហាមមិនឱ្យធ្វើការសន្យាពិសេស ក្នុងការធានារួមដែលមិនមែនជាការធានាដោយសាមគ្គីភាព ហើយមានផលប្រយោជន៍នៃការបែងចែកបន្ទុក ឬ ការធានារួមដែលមានមួយផ្នែកជាការធានាដោយសាមគ្គីភាព ជាអាទិ៍ នោះទេ ។

# ផ្នែកទី ៣ សិទ្ធិទាមទារសំណង

## មាត្រា ៩១១.- សិទ្ធិទាមទារសំណងរបស់អ្នកធានាដែលទទួលអាណត្តិ

១-ក្នុងករណីដែលអ្នកធានាបានធានាដោយទទួលអាណត្តិពីកូនបំណុលដែលមានកាតព្វកិច្ចចម្បង ប្រសិនបើអ្នកធានាបានធ្វើឱ្យរលត់នូវកាតព្វកិច្ច ដោយបានសង ឬ បានចេញចំណាយផ្សេងទៀតរបស់ខ្លួន ជំនួសកូនបំណុលដែលមានកាតព្វកិច្ចចម្បង នោះអ្នកធានាត្រូវទទួលសិទ្ធិទាមទារឱ្យកូនបំណុលដែលមានកាតព្វកិច្ចចម្បងសងសំណងមកខ្លួនវិញ ។

២-អ្នកធានាដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចទាមទារសំណងនូវចំនួនទឹកប្រាក់ដែលខ្លួនបានចេញចំណាយ និង ចំនួនការប្រាក់លើប្រាក់ចំណាយដែលខ្លួនបានចេញ ដោយគិតពីថ្ងៃដែលខ្លួនបានចេញ និង ចំនួនប្រាក់នៃការខូចខាតបាន ។

៣-អ្នកធានាដែលបានទទួលអាណត្តិពីកូនបំណុលដែលមានកាតព្វកិច្ចចម្បង អាចទាមទារសំណងជាមុនបាន ក្នុងករណីដូចខាងក្រោមនេះ :

ក-អ្នកធានាបានទទួលសាលក្រម ឬ សាលដីកាដែលបង្គាប់ឱ្យអ្នកធានាសងទៅម្ចាស់បំណុល ដោយគ្មានកំហុស ហើយសាលក្រម ឬ សាលដីកានោះបានចូលជាស្ថាពរ ។

ខ-កូនបំណុលដែលមានកាតព្វកិច្ចចម្បងបានក្ស័យធន ហើយម្ចាស់បំណុលពុំបានចូលរួមក្នុងការចែកចំណែក ។

គ-កាតព្វកិច្ចចម្បងដល់ពេលកំណត់ត្រូវសង ។

ឃ-ពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ចចម្បងនោះមិនច្បាស់លាស់ ហើយមិនអាចកំណត់បានអំពីរយៈពេលដែលវែងជាងគេ និង អំឡុងពេល ៩ (ប្រាំ) ឆ្នាំ បានកន្លងហួសគិតពីថ្ងៃដែលបានធ្វើកិច្ចសន្យាធានា ។

៤-ក្នុងករណីដែលម្ចាស់បំណុលមិនទាន់បានទទួលសំណងទាំងអស់នៅឡើយ នោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង ដែលទទួលការទាមទារសំណងពីអ្នកធានាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចទាមទារឱ្យអ្នកធានាដាក់ប្រាតិភោគ ឬ អាចទាមទារឱ្យខ្លួនរួចផុតពីកាតព្វកិច្ចបាន ។

៥-ក្នុងករណីដែលបានកំណត់នៅកថាខណ្ឌទី ៤ ខាងលើនេះ កូនបំណុលដែលមានកាតព្វកិច្ចចម្បង អាចរួចផុតពីការទាមទារសំណងបាន ដោយតម្កល់ ឬ ដាក់ប្រាតិភោគទៅឱ្យអ្នកធានា ឬ ធ្វើឱ្យអ្នកធានារួចផុតពីកាតព្វកិច្ច ។

(កំណត់)

អ្នកធានាត្រូវសងកាតព្វកិច្ចធានាដែលជាកាតព្វកិច្ចរបស់ខ្លួន ក៏ប៉ុន្តែ ចំពោះទំនាក់ទំនងជាមួយនឹងកូនបំណុលដែលមានកាតព្វកិច្ចចម្បងវិញ ជាសារធាតុ អ្នកធានានេះសងកាតព្វកិច្ចរបស់អ្នកផ្សេង ។

អ្នកធានាដែលទទួលអាណត្តិពីកូនបំណុល សងកាតព្វកិច្ចក្នុងនាមជាការចាត់ចែងកិច្ចការអាណត្តិ ហេតុនេះហើយ អ្នកធានាអាចទាមទារឱ្យកូនបំណុលដែលមានកាតព្វកិច្ចចម្បងដែលជាអាណត្តិទាយក សងមកវិញនូវសោហ៊ុយសម្រាប់ការចាត់ចែងកិច្ចការអាណត្តិបាន ។ មានន័យថា សិទ្ធិទាមទារសំណងរបស់អ្នកធានាដែលទទួលអាណត្តិពីកូនបំណុលដែលមានកាតព្វកិច្ចចម្បង មានលក្ខណៈជាការទាមទារឱ្យសងមកវិញនូវសោហ៊ុយសម្រាប់ធ្វើការចាត់ចែងកិច្ចការអាណត្តិ ។ ម្យ៉ាងទៀត អាណត្តិគាហកត្រូវបានអនុញ្ញាតឱ្យអាចទាមទារឱ្យអាណត្តិទាយកបង់ជាមុននូវសោហ៊ុយសម្រាប់ចាត់ចែងកិច្ចការអាណត្តិបាន ក៏ប៉ុន្តែ ចំពោះអ្នកធានាដែលទទួលអាណត្តិវិញ ប្រសិនបើទទួលស្គាល់ការទាមទារមុននេះទៅ នឹងបាត់បង់នូវអត្ថន័យនៃការធានាដែលជាការផ្តល់នូវទំនុកទុកចិត្តជាមុនដល់កូនបំណុល ហេតុនេះហើយ ការទាមទារសំណងជាមុន ត្រូវបានទទួលស្គាល់ក្នុងករណីពិសេសតែប៉ុណ្ណោះ ។

ទំហំនៃការទាមទារសំណង មានដូចករណីនៃការទាមទារសំណងនៃសោហ៊ុយសម្រាប់ចាត់ចែងកិច្ចការអាណត្តិដែរ ។

សិទ្ធិទាមទារសំណងជាមុន អាចទទួលស្គាល់បានតែចំពោះករណីដែលអ្នកធានាមិនអាចទទួលនូវលទ្ធផលល្អក្នុងការទាមទារនូវសំណងក្រោយការចាត់ចែងប៉ុណ្ណោះ ។

ក្នុងករណីនៃការសងមួយភាគ ជាអាទិ៍ កូនបំណុលដែលមានកាតព្វកិច្ចចម្បង អាចទាមទារឱ្យអ្នកធានាដែលទាមទារសំណងដាក់ប្រាតិភោគរហូតដល់ពេលបានសងសិទ្ធិលើបំណុលទាំងអស់ដាច់ស្រេច ឬ ទាមទារឱ្យខ្លួនរួចផុតពីកាតព្វកិច្ចបាន ។

ចំពោះការទាមទារសំណងក្នុងករណីនៃការសងមួយភាគ ជាអាទិ៍ កូនបំណុលដែលមានកាតព្វកិច្ចចម្បងអាចរួចផុតពីការទាមទារសំណងនេះបាន ដោយតម្កល់ ដាក់ប្រាតិភោគ ឬ ធ្វើឱ្យអ្នកធានារួចផុតពីកាតព្វកិច្ច ។

## មាត្រា ៩១២.- សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយគ្មានអាណត្តិ

ក្នុងករណីដែលការធានាពុំមានអាណត្តិពីកូនបំណុលដែលមានកាតព្វកិច្ចចម្បងទេ តែអ្នកធានានោះបានធ្វើឱ្យកូនបំណុលដែលមានកាតព្វកិច្ចចម្បង រួចផុតពីកាតព្វកិច្ចនោះ ដោយបានសងជំនួសកូនបំណុល ឬ ចេញចំណាយផ្សេងទៀតរបស់ខ្លួន កូនបំណុលនោះត្រូវសង តាមការទាមទារសំណង ត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលខ្លួនបានទទួល ។

ប៉ុន្តែ ប្រសិនបើការធានានេះត្រូវបានធ្វើឡើងដោយផ្ទុយពីឆន្ទៈរបស់កូនបំណុលដែលមានកាតព្វកិច្ចចម្បង កូនបំណុលគ្រាន់តែត្រូវសង តាមការទាមទារសំណង ត្រឹមតែកម្រិតនៃផលប្រយោជន៍ជាក់ស្តែងដែលនៅតែមានប៉ុណ្ណោះ ។

(កំណត់)

ប្រសិនបើអ្នកធានាដែលមិនបានទទួលអាណត្តិពីកូនបំណុលដែលមានកាតព្វកិច្ចចម្បង បានចេញចំណាយ ដូចជាការសង ជាអាទិ៍ អ្នកធានានោះអាចទាមទារសំណងក្នុងនាមជាការទាមទារសងមកវិញនូវសោហ៊ុយការគ្រប់គ្រងដោយឈឺឆ្អាលបាន ។

ទំហំនៃការទាមទារសំណងត្រូវគិតផ្សេងគ្នា ចំពោះករណីធានាដោយផ្ទុយពីឆន្ទៈរបស់កូនបំណុលដែលមានកាតព្វកិច្ចចម្បង និង ករណីផ្សេងពីនេះ ។ ក៏ប៉ុន្តែ តាមការពិត មិនសូវមានករណីខុសគ្នាប៉ុន្មានទេ ។

**មាត្រា ៩១៣.–** ល័ក្ខខ័ណ្ឌនៃការទាមទារសំណង

១-ក្នុងករណីដែលអ្នកធានាបានរួចផុតពីកាតព្វកិច្ចដោយបានសងជំនួសកូនបំណុល ឬ ចេញចំណាយផ្សេងទៀតរបស់ខ្លួន ដោយពុំបានឱ្យដំណឹងទៅកូនបំណុលដែលមានកាតព្វកិច្ចចម្បង អំពីការណ៍ដែលខ្លួនបានទទួលការទាមទារ ពីម្ចាស់បំណុលទេ ហើយប្រសិនបើកូនបំណុលដែលមានកាតព្វកិច្ចចម្បង មានហេតុណាមួយដែលអាចតតាំងជាមួយនឹងម្ចាស់បំណុល នោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង អាចយកហេតុនោះទៅតតាំងនឹងការទាមទាររបស់អ្នកធានាបាន ។ ប៉ុន្តែ បើហេតុនោះជាការទូទាត់ អ្នកធានាអាចទាមទារឱ្យម្ចាស់បំណុលអនុវត្តកាតព្វកិច្ចដែលនឹងត្រូវរលត់ ដោយសារការទូទាត់នេះបាន ។

២-ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចចម្បងបានសងទៅម្ចាស់បំណុល ឬ រួចផុតពីកាតព្វកិច្ចដោយចេញចំណាយផ្សេងទៀត ដោយសុចរិត ដោយហេតុថា អ្នកធានាធ្វេសប្រហែសពុំបានឱ្យដំណឹងទៅកូនបំណុលថា ខ្លួនបានរួចផុតពីកាតព្វកិច្ចដោយចេញចំណាយរបស់ខ្លួនផ្ទាល់ទេ កូនបំណុលដែលមានកាតព្វកិច្ចចម្បងអាចចាត់ទុកថា សំណងរបស់ខ្លួន ឬ ការរួចផុតពីកាតព្វកិច្ចនោះមានសុពលភាពបាន ។

(កំណត់)

រវាងកូនបំណុលដែលមានកាតព្វកិច្ចចម្បងដែលត្រូវសងចំពោះម្ចាស់បំណុល និង អ្នកធានា ចាំបាច់ត្រៀមនូវវិធីតិវិធី

ដើម្បីការពារកុំឱ្យការសងត្រួតគ្នាកើតឡើង ។ មាត្រានេះត្រូវបានបញ្ញត្តឡើងក្នុងគោលគំនិតនេះ ។

ក្នុងករណីដែលចេ្ញសប្រហែសមិនបានជូនដំណឹងជាមុន មាត្រានេះបញ្ញត្តថា កូនបំណុលដែលមានកាតព្វកិច្ចចម្បង អាចយកសិទ្ធិតវ៉ាចំពោះម្ចាស់បំណុលទៅតតាំងចំពោះសិទ្ធិទាមទារសំណងរបស់អ្នកធានាបាន (កថាខណ្ឌទី ១) ។ ម្យ៉ាងទៀត ក្នុងករណីដែលហេតុតវ៉ាជាការទូទាត់វិញ អ្នកធានាដែលទទួលការតតាំងដោយការតវ៉ានេះ អាចអនុវត្តសិទ្ធិលើបំណុលដែលកូនបំណុលមានកាតព្វកិច្ចចម្បងនេះមាន បាន (វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១) ។

ក្នុងករណីដែលចេ្ញសប្រហែសមិនជូនដំណឹងក្រោយការចេញចំណាយ កូនបំណុលដែលមានកាតព្វកិច្ចចម្បង អាចអះអាងថា ការសងដោយខ្លួនឯងមានសុពលភាព (កថាខណ្ឌទី ២) ។

## មាត្រា ៩១៤.- សិទ្ធិទាមទារសំណងរបស់អ្នកធានាចំពោះកូនបំណុលម្នាក់ក្នុងចំណោមកូនបំណុលច្រើន

អ្នកដែលបានធានាកូនបំណុលតែម្នាក់ក្នុងចំណោមកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាព ឬ កាតព្វកិច្ចអវិភាគីយ៍ អាចទាមទារសំណងពីកូនបំណុលផ្សេងទៀតបាន ត្រឹមតែចំណែកជាបន្ទុករបស់កូនបំណុលផ្សេងនោះប៉ុណ្ណោះ ។

(កំណត់)

ក្នុងករណីដែលបានធានាចំពោះកូនបំណុលម្នាក់ក្នុងចំណោមកូនបំណុលច្រើននាក់ ប្រសិនបើអ្នកធានាសងកាតព្វកិច្ចនោះ អ្នកធានាអាចទាមទារសំណងទាំងអស់ចំពោះកូនបំណុលដែលខ្លួនធានាបាន ព្រមទាំងអាចទាមទារឱ្យកូនបំណុលផ្សេងទៀតសងនូវភាគដែលកូនបំណុលនីមួយៗទទួលបន្ទុកបាន លើកលែងតែកាតព្វកិច្ចចម្បងនោះជាកាតព្វកិច្ចវិភាគីយ៍ ។

ក្នុងករណីនេះ ចំពោះកូនបំណុលផ្សេងទៀត (ក្រៅពីកូនបំណុលដែលខ្លួនបានធានា) អ្នកធានាបានធ្វើការសងដោយតតិយជន ហេតុនេះហើយ ការទទួលស្គាល់ឱ្យទាមទារដោយចំពោះ ជាការមួយដែលមានមូលហេតុសមរម្យ ។

ចំពោះម្ចាស់បំណុលផ្សេងទៀត ទំហំដែលអាចទាមទារសំណងត្រូវបានកម្រិតត្រឹមចំណែកជាបន្ទុករបស់កូនបំណុលនីមួយៗនោះ ។

ម្យ៉ាងទៀត អាចមានគោលគំនិតថា ដោយសារធ្វើការសងដោយតតិយជន អាចទទួលស្គាល់នូវការទាមទារឱ្យសំណងនូវចំនួនទឹកប្រាក់ទាំងអស់នៃកាតព្វកិច្ចដែលបានរួចផុត ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចចម្បងបានសងតាមការទាមទារសំណង កូនបំណុលដែលមានកាតព្វកិច្ចចម្បងនោះគ្រាន់តែអាចទាមទារឱ្យកូនបំណុលផ្សេងទៀតនូវសំណងត្រឹមចំណែកជាបន្ទុករបស់កូនបំណុលនោះប៉ុណ្ណោះ ។ ក្នុងក្រមរដ្ឋប្បវេណីជប៉ុន មានបញ្ញត្តិដើម្បីសម្របសម្រួលទំនាក់ទំនងរវាងអ្នកទាំងពីរនេះ (មាត្រា ៤៦៤) ។ មាត្រានេះបញ្ញត្តតាមមាត្រា ៤៦៤ នៃក្រមរដ្ឋប្បវេណីជប៉ុននេះ ។

**មាត្រា ៩១៥.–** សិទ្ធិទាមទារសំណងរបស់អ្នកធានារួម

១-ក្នុងករណីដែលអ្នកធានារួមម្នាក់ក្នុងចំណោមអ្នកធានារួម បានរួចផុតពីកាតព្វកិច្ច ហើយធ្វើឱ្យអ្នកធានារួមផ្សេងទៀត បានរួចផុតពីកាតព្វកិច្ច ដោយបានសង ឬ បានចេញចំណាយផ្សេងទៀតរបស់ខ្លួន អ្នកធានានោះអាចទាមទារឱ្យអ្នកធានារួមផ្សេងទៀតសងសំណងតាមចំណែកជាបន្ទុករៀងៗខ្លួន មកខ្លួនវិញបាន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកធានានោះអាចទាមទារឱ្យអ្នកធានារួមឯទៀតៗ សងនូវប្រាក់ដែលខ្លួនបានចេញចំណាយ ការប្រាក់ និង ការខូចខាតបាន ។

៣-បញ្ញត្តិនៃមាត្រា ៩១២ (សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយគ្មានអាណត្តិ) មាត្រា ៩១៣ (ល័ក្ខខ័ណ្ឌនៃការទាមទារសំណង) និង មាត្រា ៩១៤ (សិទ្ធិទាមទារសំណងរបស់អ្នកធានាចំពោះកូនបំណុលម្នាក់ក្នុងចំណោមកូនបំណុលច្រើន) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការធានារួមមានភ្ជាប់ជាមួយនឹងការសន្យាពិសេសអំពីការបែងចែកបន្ទុក ហើយមានអ្នកធានារួមណាម្នាក់បានរួចផុតពីកាតព្វកិច្ច ហើយធ្វើឱ្យអ្នកធានារួមផ្សេងទៀតបានរួចផុតពីកាតព្វកិច្ច ដោយបានសង ឬ បានចេញចំណាយផ្សេងទៀត លើសពីចំណែកជាបន្ទុករបស់ខ្លួន ។

(កំណត់)

ក្នុងករណីដែលបុគ្គលម្នាក់ក្នុងចំណោមអ្នកធានារួម បានរួចផុតពីកាតព្វកិច្ច ដោយចេញចំណាយខ្លួនឯង ហើយធ្វើឱ្យអ្នកធានារួមផ្សេងទៀតក៏រួចពីកាតព្វកិច្ចដែរ អ្នកធានារួមដែលចេញចំណាយនោះអាចទាមទារឱ្យអ្នកធានារួមផ្សេងទៀតសងសំណង តាមចំណែកជាបន្ទុករបស់អ្នកធានារួមរៀងៗខ្លួនបាន ។ នេះគឺជាការងាយស្រួល ហើយមានសមភាពផងដែរ ។

ក្នុងករណីដែលជាការធានារួមដោយគ្មានផលប្រយោជន៍ដោយការបែងចែកនូវបន្ទុក តើគួរទទួលស្គាល់នូវការទាមទារសំណង តែចំពោះករណីដែលអ្នកធានារួមធ្វើការសង ឬ ធ្វើសកម្មភាពផ្សេងទៀតដែលឱ្យរួចផុតពីកាតព្វកិច្ច ដោយលើសចំណែកជាបន្ទុករបស់ខ្លួនប៉ុណ្ណោះ ឬ ទទួលស្គាល់នូវការទាមទារសំណង ទាំងករណីដែលមិនលើសចំណែកជានៃបន្ទុក ? ចំណុចនេះមានការជជែកគ្នាច្រើន ។ ក្រមរដ្ឋប្បវេណីជប៉ុន ទទួលស្គាល់នូវការទាមទារសំណងតែក្នុងករណីដែលការសងជាអាទិ៍ នោះ លើសចំណែកជាបន្ទុកប៉ុណ្ណោះ (កថាខណ្ឌទី ១ នៃមាត្រា ៤៦៥) ។ ក៏ប៉ុន្តែ ប្រសិនបើគិតអំពីសមភាពរវាងអ្នកធានាទៅវិញ មិនគួរទទួលស្គាល់កម្រិតបែបនេះទេ ។ មាត្រានេះជ្រើសរើសយកគោលគំនិតទី ២ ទៅវិញ ។

## ផ្នែកទី ៤ ឧបាទេសកម្ម

**មាត្រា ៩១៦.–** ឧបាទេសកម្មដោយការសង

១-អ្នកធានាដែលបានរួចផុតពីកាតព្វកិច្ចចម្បង ដោយបានសង ឬ ចេញចំណាយផ្សេងទៀតរបស់ខ្លួន ត្រូវទទួលពីម្ចាស់បំណុល នូវសិទ្ធិលើបំណុលដែលជាកម្មវត្ថុនៃការធានា ហើយអាចប្រើសិទ្ធិប្រាតិភោគដែលបានធានាសិទ្ធិលើបំណុលនោះ ជំនួសម្ចាស់បំណុលបាន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកធានាដែលបានរួចផុតពីកាតព្វកិច្ចមួយភាគ អាចប្រើសិទ្ធិជាមួយម្ចាស់បំណុល តាមសមាមាត្រ និង ចំនួនប្រាក់ដែលខ្លួនបានរួចផុតនោះ ។ ក្នុងករណីនេះ មានតែម្ចាស់បំណុលប៉ុណ្ណោះ ដែលអាចប្រើសិទ្ធិរំលាយបាន ។ ប៉ុន្តែ ក្នុងករណីនេះ ម្ចាស់បំណុលត្រូវសងទៅវិញនូវចំនួនប្រាក់ ដែលឧបាទេសិកបានរួចផុតពីកាតព្វកិច្ច និង ការប្រាក់ទៅឧបាទេសិកនោះ ។

(កំណត់)

ដើម្បីឱ្យមានប្រសិទ្ធភាពក្នុងការអនុវត្តសិទ្ធិទាមទារសំណង គួរតែឱ្យអ្នកដែលមានសិទ្ធិទាមទារសំណង ប្រើសិទ្ធិប្រាតិភោគ ជាអាទិ៍ ដែលម្ចាស់បំណុលដែលបានទទួលការប្រមូលសិទ្ធិលើបំណុលនោះមាន ។ ហេតុដូច្នេះ មាត្រានេះទទួលស្គាល់ឱ្យអ្នកធានាដែលបានរួចពីកាតព្វកិច្ចដោយសារបានសង ឬ បានចេញចំណាយផ្សេងទៀតរបស់ខ្លួន ទទួលសិទ្ធិដែលម្ចាស់បំណុលមាន ព្រមជាមួយគ្នានេះ ទទួលស្គាល់ឱ្យអ្នកធានានោះប្រើសិទ្ធិប្រាតិភោគដែលធានាសិទ្ធិលើបំណុលនោះជំនួសម្ចាស់បំណុលបាន (កថាខណ្ឌទី ១) ។

ក្នុងករណីដែលបានរួចផុតពីកាតព្វកិច្ចតែមួយភាគ មាត្រានេះទទួលស្គាល់នូវឧបាទេសកម្មត្រឹមតែកម្រិតដែលម្ចាស់បំណុលមិនមានឧបសគ្គប៉ុណ្ណោះ (កថាខណ្ឌទី ២) ។ ក្នុងករណីនេះ តើត្រូវគិតយ៉ាងណាដែរ ចំពោះទំនាក់ទំនងរវាងម្ចាស់បំណុល និង អ្នកធានា នេះជាបញ្ហាមួយ ។ មានន័យថា តើគួរចាត់ទុកអ្នកទាំងពីរនេះស្មើភាពគ្នា ឬ តើគួរចាត់ទុកឱ្យម្ចាស់បំណុលមានអាទិភាពជាងអ្នកធានា រហូតដល់ពេលដែលម្ចាស់បំណុលបានប្រមូលចំនួនទឹកប្រាក់ទាំងអស់នៃសិទ្ធិលើបំណុល ។ ចំពោះចំណុចនេះ ចាំបាច់ត្រូវសម្រួលនូវផលប្រយោជន៍លំអិតថែមទៀត ហើយមិនគួរចែងលំអិតក្នុងបញ្ញត្តិនេះឡើយ សូមទុកឱ្យការបកស្រាយ ហើយរំពឹងទៅលើយុត្តិសាស្ត្រទៅវិញ ។

**មាត្រា ៩១៧.–** ករណីយកិច្ចប្រគល់លិខិតបញ្ជាក់សិទ្ធិលើបំណុល

១-ម្ចាស់បំណុលដែលបានទទួលការជម្រះសិទ្ធិលើបំណុលទាំងអស់ ដោយសារអ្នកធានាបានសង ឬ បានចេញចំណាយផ្សេងទៀត ត្រូវប្រគល់លិខិតបញ្ជាក់សិទ្ធិលើបំណុល និង វត្ថុប្រាតិភោគដែលនៅក្រោមការកាន់កាប់របស់ខ្លួន ទៅឱ្យអ្នកធានាដែលបានសង ឬ បានចេញចំណាយផ្សេងទៀតនោះ ។

២-ម្ចាស់បំណុលដែលបានទទួលការជម្រះសិទ្ធិលើបំណុលតែមួយភាគ ដោយសារអ្នកធានាបានសង ឬ បានចេញចំណាយផ្សេងទៀត ត្រូវកត់ត្រាអំពីឧបាទេសកម្មនោះលើលិខិតបញ្ជាក់សិទ្ធិលើបំណុល ហើយត្រូវឱ្យអ្នកធានានោះត្រួតពិនិត្យលើការថែរក្សាវត្ថុប្រាតិភោគដែលនៅក្រោមការកាន់កាប់របស់ខ្លួន ។

(កំណត់)

សម្រាប់អ្នកធានារួចផុតពីកាតព្វកិច្ចដោយសារបានសង ឬ បានចេញចំណាយផ្សេងទៀត ម្ចាស់បំណុលដែលបានទទួលការជម្រះសិទ្ធិលើបំណុល មានករណីយកិច្ចប្រគល់នូវលិខិតបញ្ជាក់សិទ្ធិលើបំណុល និង ប្រាតិភោគដែលត្រូវបានដាក់ធានាកាតព្វកិច្ចចម្បងទៅឱ្យអ្នកធានានោះ (កថាខណ្ឌទី ១) ។ បញ្ញត្តិនេះត្រូវបានធ្វើឡើងដើម្បីឱ្យឧបាទេសកម្មដោយអ្នកធានាមានភាពច្បាស់លាស់ និង ដើម្បីរក្សានូវផលប្រយោជន៍របស់អ្នកធានាផងដែរ ។ ម្យ៉ាងទៀត ក្នុងករណីដែលម្ចាស់បំណុលបានទទួលការជម្រះសិទ្ធិលើបំណុលតែមួយភាគ ម្ចាស់បំណុលមានករណីយកិច្ចកត់ត្រាអំពីការសងសិទ្ធិលើបំណុលមួយភាគនោះ ព្រមទាំងយល់ព្រមត្រួតពិនិត្យលើការរក្សា និង គ្រប់គ្រងវត្ថុប្រាតិភោគ (កថាខណ្ឌទី ២) ។ បញ្ញត្តិនេះក៏មានន័យដូចគ្នានឹងកថាខណ្ឌទី ១ ដែរ ។ ក៏ប៉ុន្តែ ការប្រគល់លិខិតបញ្ជាក់សិទ្ធិលើបំណុល ឬ វត្ថុប្រាតិភោគ ទៅឱ្យអ្នកធានា គឺជាការមួយដែលមិនអាចទទួលស្គាល់បានដោយម្ចាស់បំណុលដែលមិនទាន់បានទទួលការជម្រះសិទ្ធិលើបំណុលទាំងអស់ ហេតុនេះហើយបានជាបញ្ញត្តិនេះទទួលស្គាល់ត្រឹមតែករណីយកិច្ចកត់ត្រាលើលិខិតបញ្ជាក់សិទ្ធិលើបំណុល និងករណីយកិច្ចយល់ព្រមត្រួតពិនិត្យលើការថែរក្សាវត្ថុប្រាតិភោគប៉ុណ្ណោះ ។

**មាត្រា ៩១៨.-** ករណីយកិច្ចថែរក្សាប្រាតិភោគ

ម្ចាស់បំណុលដែលបានទទួលការជម្រះសិទ្ធិលើបំណុល ដោយសារអ្នកធានាបានសង ឬ បានចេញចំណាយផ្សេងទៀត មានករណីយកិច្ចត្រូវថែរក្សាប្រាតិភោគ សម្រាប់អ្នកធានាដែលបានសង ឬ បានចេញចំណាយផ្សេងទៀតនោះ ។

(កំណត់)

មាត្រានេះតម្រូវឱ្យម្ចាស់បំណុលដែលបានទទួលការជម្រះសិទ្ធិលើបំណុល ថែរក្សាប្រាតិភោគ ដើម្បីរក្សាការពារនូវសិទ្ធិឧបាទេសកម្មរបស់អ្នកធានា រហូតដល់ពេលបញ្ចប់ ប្រគល់វត្ថុប្រាតិភោគនោះទៅឱ្យអ្នកធានា ។

**មាត្រា ៩១៩.–** លំដាប់នៃឧបាទេសកម្ម

១-អ្នកធានាមិនអាចស្នងម្ចាស់បំណុលដោយឧបាទេសកម្ម ចំពោះតតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុដែលជាវត្ថុប្រាតិភោគបានឡើយ ប្រសិនបើខ្លួនមិនបានចុះបញ្ជីក្រោយពីបានសង ឬ ចេញចំណាយផ្សេងទៀត ។

២-រវាងអ្នកធានាដោយបុគ្គល និង អ្នកធានាដោយវត្ថុ ត្រូវស្នងដោយឧបាទេសកម្មដោយគិតទៅតាមចំនួនអ្នកទាំងនោះ ។

(កំណត់)

ចំពោះសិទ្ធិប្រាតិភោគប្រត្យក្សលើអចលនវត្ថុ ចាំបាច់ចុះបញ្ជីអំពីឧបាទេសកម្ម (កថាខណ្ឌទី ១) ។ ចំពោះតតិយជនដែលបានធ្វើលទ្ធកម្មមុនពេលសង ជាអាទិ៍ អ្នកធានាអាចធ្វើឧបាទេសកម្មដោយមិនបានចុះបញ្ជីបាន ក៏ប៉ុន្តែ ចំពោះតតិយជនដែលបានធ្វើលទ្ធកម្មក្រោយការសង ជាអាទិ៍ អ្នកធានាមិនអាចធ្វើឧបាទេសកម្មបានទេ ប្រសិនបើមិនបានចុះបញ្ជីអំពីឧបាទេសកម្មនោះ មុនពេលតតិយជននេះធ្វើលទ្ធកម្ម ។

ទំនាក់ទំនងនៃឧបាទេសកម្មរវាងអ្នកធានា និង អ្នកធានាដោយវត្ថុ គឺស្មើភាពគ្នា (កថាខណ្ឌទី ២) ។ ក្នុងករណីដែលអ្នកធានា ក៏ជាអ្នកធានាដោយវត្ថុដែរ របៀបរាប់អ្នកនោះជាបញ្ហាមួយ ។ ក៏ប៉ុន្តែ ដើម្បីឱ្យស្រួលចាត់ចែង និង ដើម្បីឱ្យមានសមភាព គួររាប់តែម្នាក់ជាការល្អ ។ ចំណុចនេះ សូមភាគីកម្ពុជាបកស្រាយ ។

**មាត្រា ៩២០.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្ដីពីឧបាទេសកម្មដោយការសង

ក្រៅពីបញ្ញត្តិនៃផ្នែកទី ៤ (ឧបាទេសកម្ម) នេះ បញ្ញត្តិនៃកថាភាគទី ៤ (ឧបាទេសកម្មដោយការសង) ផ្នែកទី ១ ជំពូកទី ៧ នៃគន្ថីទី ៤ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះឧបាទេសកម្មដោយការសង ឬ ចេញចំណាយផ្សេងទៀតរបស់អ្នកធានា ។

(កំណត់)

ឧបាទេសកម្មរបស់អ្នកធានា គឺជាឧបាទេសកម្មដោយការសងមួយប្រភេទដែរ ហេតុដូច្នេះ មាត្រានេះបញ្ជាក់ឱ្យបានច្បាស់លាស់ថា ក្រៅពីបញ្ញត្តិនៃផ្នែកនេះ បញ្ញត្តិទូទៅស្ដីពីឧបាទេសកម្មដោយការសង ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

## ជំពូកទី ៨ កាតព្វកិច្ចដោយសាមគ្គីភាព

### ផ្នែកទី ១ ការបង្កើតកាតព្វកិច្ចដោយសាមគ្គីភាព

**មាត្រា ៩២១.–** អត្ថន័យនៃកាតព្វកិច្ចដោយសាមគ្គីភាព

១-ក្នុងករណីដែលបុគ្គលច្រើននាក់ទទួលបន្ទុកនូវកាតព្វកិច្ចសាមគ្គីភាព ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលណាម្នាក់ អនុវត្តកាតព្វកិច្ចទាំងអស់ ឬ មួយភាគ ឬ ឱ្យកូនបំណុលទាំងអស់ អនុវត្តកាតព្វកិច្ចទាំងអស់ ឬ មួយភាគ ដោយព្រមគ្នា ឬ ដោយបន្តបន្ទាប់ ។

២-ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចទាំងអស់ ឬ កូនបំណុលណាម្នាក់ ត្រូវបានប្រកាសក្ស័យធន ម្ចាស់បំណុលអាចចូលរួម ក្នុងការចែកចំណែកនៅក្នុងនីតិវិធីក្ស័យធនរបស់កូនបំណុលនីមួយៗ ចំពោះចំនួនប្រាក់ទាំងអស់នៃសិទ្ធិលើបំណុលរបស់ខ្លួន ។

(កំណត់)

ចំពោះកាតព្វកិច្ចដោយសាមគ្គីភាព កូនបំណុលម្នាក់ៗត្រូវទទួលបន្ទុកកាតព្វកិច្ចទាំងស្រុង ហើយវិធីទទួលបន្ទុក ក៏គ្មានភាពចម្បង ឬ បន្ទាប់បន្សំទេ (កថាខណ្ឌទី ១) ។

ម្យ៉ាងទៀត ចំពោះករណីក្ស័យធន ចាំបាច់ត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីចំណុចនេះ (កថាខណ្ឌទី ២) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៣២ និង មាត្រា ៤៤១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៩២២.-** ការបង្កើតកាតព្វកិច្ចដោយសាមគ្គីភាព

១-ក្រៅពីករណីដែលមានបញ្ញត្តិនៅក្នុងច្បាប់ កាតព្វកិច្ចដោយសាមគ្គីភាពត្រូវបានបង្កើតឡើង ដោយការព្រមព្រៀង ដោយជាក់លាក់ ឬ ដោយតុណ្ហីភាព រវាងម្ចាស់បំណុល និង កូនបំណុលច្រើននាក់ដែលឆន្ទៈសាមគ្គីភាពរួមគ្នាទៅវិញទៅមក ត្រូវបានទទួលស្គាល់ ។

២-ការព្រមព្រៀងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើឡើងរវាងម្ចាស់បំណុល និង កូនបំណុលនីមួយៗ ដោយព្រមគ្នា ឬ ដោយបន្តបន្ទាប់ ។

៣-ម្ចាស់បំណុលអាចលើកលែងសាមគ្គីភាព ចំពោះកូនបំណុលណាមួយបាន ។[៥]

៤-ក្រោយពេលលើកលែងសាមគ្គីភាព កូនបំណុលដែលបានទទួលការលើកលែងត្រូវទទួលបន្ទុកនូវកាតព្វកិច្ច ត្រឹមតែចំនួនប្រាក់ដែលស្មើនឹងបន្ទុកដែលខ្លួនធ្លាប់មានមុនពេលលើកលែង ។

---

[៥] កថាខណ្ឌទី ៣ នៃមាត្រា ៩២២ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

៥-ភាគនៃបន្ទុករបស់កូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពនីមួយៗ ត្រូវបានសន្មតថាស្មើគ្នា ។

(កំណត់)

កាតព្វកិច្ចដោយសាមគ្គីភាពត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងរវាងម្ចាស់បំណុល និង កូនបំណុលម្នាក់ៗ ក្នុងករណីដែលឆន្ទៈសាមគ្គីភាពរួមគ្នាទៅវិញទៅមករវាងកូនបំណុលទាំងអស់ ត្រូវបានទទួលស្គាល់ (កថាខណ្ឌទី ១ និង កថាខណ្ឌទី ២) ។

មាត្រានេះមិនចែងអំពីកាតព្វកិច្ចដែលមានលក្ខណៈប្រហាក់ប្រហែលនឹងកាតព្វកិច្ចដោយសាមគ្គីភាព និង ករណីយកិច្ចទាំងស្រុង (obligation *in solidum*) ទេ ។

ទោះបីជាកូនបំណុលមានទំនាក់ទំនងគ្នាដោយសាមគ្គីភាពរួមគ្នាក៏ដោយ ការលើកលែងនូវសាមគ្គីភាពដល់កូនបំណុលណាម្នាក់ ហើយទទួលស្គាល់ឱ្យកូនបំណុលនោះរួចពីទំនាក់ទំនងសាមគ្គីភាពទៅវិញទៅមក គ្មានឥទ្ធិពលនាំឱ្យមានការខូចប្រយោជន៍របស់កូនបំណុលផ្សេងទៀតទេ ។ ចំណុចនេះជាបញ្ហាស្វ័យភាពឯកជនទេ ហេតុនេះហើយត្រូវទទួលស្គាល់ (កថាខណ្ឌទី ៣) ។ បន្ទាប់មក ចំពោះកូនបំណុលដែលបានទទួលការលើកលែងនូវសាមគ្គីភាព អានុភាពនៃការលើកលែងនូវសាមគ្គីភាពនោះ គឺ កូនបំណុលនោះគ្រាន់តែទទួលបន្ទុកនូវកាតព្វកិច្ចត្រឹមតែចំនួនទឹកប្រាក់ស្មើនឹងចំណែកជាបន្ទុកដែលខ្លួនធ្លាប់មានមុនពេលទទួលការលើកលែងប៉ុណ្ណោះ (កថាខណ្ឌទី ៤) ។

ម្យ៉ាងទៀត ចំពោះភាគនៃបន្ទុករបស់កូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាព ប្រសិនបើមានការសន្យាពិសេស ត្រូវអនុលោមតាមការសន្យាពិសេសនោះ ប៉ុន្តែ មានករណីខ្លះដែលអត្ថិភាពនៃការសន្យាពិសេសមិនច្បាស់លាស់ទេ ហេតុដូច្នេះ មាត្រានេះចែងថា ត្រូវសន្មតថាស្មើគ្នា (កថាខណ្ឌទី ៥) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៣២ និង មាត្រា ៤៤១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៩២៣.-** មោឃភាព និង ការលុបចោល ចំពោះកូនបំណុល

ទោះបីជាមានមូលហេតុនៃមោឃភាព ឬ ការលុបចោលសកម្មភាព ចំពោះកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ក៏ដោយ ក៏ការណ៍នេះមិនមានឥទ្ធិពលដល់អានុភាពនៃកាតព្វកិច្ចរបស់កូនបំណុលផ្សេងទៀតឡើយ ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីលទ្ធផលដែលកើតឡើង ដោយសារកិច្ចសន្យាដែលបង្កើតកាតព្វកិច្ចដោយសាមគ្គីភាព ផ្សេងៗគ្នារវាងម្ចាស់បំណុល និង កូនបំណុលម្នាក់ៗ ក្នុងករណីដែលជាកាតព្វកិច្ចដោយសាមគ្គីភាព ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៣៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ២ អានុភាពនៃហេតុដែលកើតឡើងចំពោះកូនបំណុលដែលមានកាតព្វកិច្ច ដោយសាមគ្គីភាពណាម្នាក់

**មាត្រា ៩២៤.-** អានុភាពដាច់ខាតនៃការទាមទារ និង ហេតុដែលផ្អាកអាជ្ញាយុកាលផ្សេងទៀត

ការទាមទារឱ្យកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់អនុវត្ត និង ហេតុដែលផ្អាកអាជ្ញាយុកាលផ្សេងទៀត ដែលកើតឡើងចំពោះកូនបំណុលនោះ ត្រូវមានអានុភាពចំពោះកូនបំណុលផ្សេងទៀតផងដែរ ។

(កំណត់)

មាត្រានេះបញ្ញត្តថា តាមរយៈការទាមទារឱ្យអនុវត្តចំពោះកូនបំណុលណាម្នាក់ អានុភាពនៃការយឺតយ៉ាវក្នុងការអនុវត្ត និង ការផ្អាកអាជ្ញាយុកាល ត្រូវកើតឡើងចំពោះកូនបំណុលផ្សេងទៀតដែរ ។ ចំណុចនេះសមរម្យដោយសារសាមគ្គីភាពរួមគ្នា ។ ម្យ៉ាងទៀត ក្រមរដ្ឋប្បវេណីជប៉ុន មិនទទួលស្គាល់នូវអានុភាពដាច់ខាតនៃហេតុនៃការផ្អាកអាជ្ញាយុកាល ក្រៅពីការទាមទារទេ ក៏ប៉ុន្តែ ក្រមនេះទទួលស្គាល់ទៅវិញ ។ ថា តើគំនិតមួយណាត្រូវជាងនោះ នេះជាបញ្ហាមួយដែលត្រូវជជែកថែមទៀត ក៏ប៉ុន្តែ ប្រសិនបើគិតដល់ការមានឆន្ទៈសាមគ្គីភាពរួមរវាងកូនបំណុល ព្រមទាំងភាពងាយស្រួល ក្នុងការគ្រប់គ្រងសិទ្ធិលើបំណុលដោយម្ចាស់បំណុល ត្រូវតែទទួលស្គាល់ជាការល្អ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៣៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៩២៥.-** អានុភាពដាច់ខាតនៃការសង ជាអាទិ៍

ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ បានសង ឬ សងដោយវត្ថុជំនួស ឬ តម្កល់ អានុភាពនៃការរំលត់កាតព្វកិច្ចដែលបានកើតឡើងដោយការណ៍នោះ ត្រូវមានចំពោះកូនបំណុលផ្សេងទៀតផងដែរ ។

(កំណត់)

ក្រមរដ្ឋប្បវេណីជប៉ុនគ្មានបញ្ញត្តិច្បាស់លាស់ដូចមាត្រានេះទេ ប៉ុន្តែ មាត្រា ៤២៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ចែងច្បាស់លាស់អំពីចំណុចនេះ ។ កាតព្វកិច្ចដោយសាមគ្គីភាព មានគោលបំណងចំពោះតាវកាលិកតែមួយ ហើយការសង

ការសងដោយវត្ថុជំនួស និង ការតម្កល់ នាំឱ្យជម្រះសិទ្ធិលើបំណុល ហេតុដូច្នេះ គួរតែទទួលស្គាល់នូវអានុភាពដាច់ខាត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤២៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៩២៦.-** អានុភាពដាច់ខាតនៃការទូទាត់

១-ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ មានសិទ្ធិលើបំណុលចំពោះម្ចាស់បំណុល ហើយកូនបំណុលនោះបានលើកឡើងនូវការទូទាត់ សិទ្ធិលើបំណុលត្រូវរលត់ សម្រាប់ផលប្រយោជន៍របស់កូនបំណុលទាំងអស់ ។

២-នៅក្នុងពេលដែលកូនបំណុលដែលមានសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនទាន់លើកឡើងនូវការទូទាត់ កូនបំណុលផ្សេងទៀតអាចបដិសេធការសង ចំពោះបន្ទុករបស់ខ្លួនបាន ។

(កំណត់)

ការទូទាត់ គឺជាការរំលត់កាតព្វកិច្ចដោយបន្ទុករបស់កូនបំណុលដែលបានលើកឡើងនូវការទូទាត់ ហើយចំពោះចំណុចនេះ មានន័យប្រហាក់ប្រហែលនឹងការសងដែរ ហេតុនេះហើយ អានុភាពនៃការទូទាត់នេះក៏ត្រូវឱ្យមានទៅលើកូនបំណុលផ្សេងទៀតដែរ ។

បញ្ហាដែលកើតឡើង គឺជាការចាត់ចែងមុនពេលលើកឡើងនូវការទូទាត់នេះ ។ មានគំនិតចម្បងមួយ គឺ គួរតែទទួលស្គាល់ការលើកឡើងដោយកូនបំណុលផ្សេង ត្រឹមតែចំណែកនៃបន្ទុករបស់អ្នកនោះ ។ ក៏ប៉ុន្តែ ការផ្ដល់សិទ្ធិចាត់ចែងនូវសិទ្ធិរបស់អ្នកផ្សេង ជាការទទួលស្គាល់ជ្រុលពេល គ្រាន់តែការផ្ដល់នូវសិទ្ធិតតាំងនៃការបដិសេធការសង ជាការគ្រប់គ្រាន់ហើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៣៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៩២៧.-** អានុភាពដាច់ខាតនៃនវកម្ម

ក្នុងករណីដែលនវកម្មត្រូវបានធ្វើឡើង រវាងកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ និង ម្ចាស់បំណុល សិទ្ធិលើបំណុលត្រូវរលត់ សម្រាប់ផលប្រយោជន៍របស់កូនបំណុលទាំងអស់ ។

(កំណត់)

មាត្រានេះត្រូវបានរៀបចំ ដោយសន្មតនូវឆន្ទៈរបស់ភាគីនៃនវកម្ម ។ ហេតុនេះហើយ ភាគីនៃនវកម្មអាចធ្វើការសន្យាពិសេសបាន ដោយកំណត់ថា នវកម្មនោះគ្មានឥទ្ធិពលទៅលើកូនបំណុលផ្សេងទេ (មាត្រា ១២៨១ នៃក្រមរដ្ឋប្បវេណីបារាំង) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៣៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៩២៨.-** អានុភាពដាច់ខាតនៃល្បាកុលភាព

ក្នុងករណីដែលល្បាកុលភាពបានកើតឡើង រវាងកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ និង ម្ចាស់បំណុល កូនបំណុលនោះត្រូវបានចាត់ទុកថា បានសង ។

(កំណត់)

មាត្រានេះត្រូវបានបញ្ញត្តឡើងដើម្បីជៀសវាងនូវការទាមទារសំណងទៅវិញទៅមកដដែលៗ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៣៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៩២៩.-** អានុភាពដាច់ខាតនៃការលើកលែង

១-ការលើកលែងកាតព្វកិច្ចទាំងអស់ដែលបានធ្វើឡើង ចំពោះកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ ត្រូវមានអានុភាពចំពោះតែបន្ទុករបស់កូនបំណុលនោះសម្រាប់ផលប្រយោជន៍របស់កូនបំណុលផ្សេងទៀត ។

២-ក្នុងករណីដែលការលើកលែងបានធ្វើឡើងចំពោះតែកាតព្វកិច្ចមួយភាគ ចំពោះកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ អានុភាពនៃការលើកលែងចំពោះកូនបំណុលផ្សេងទៀត ត្រូវកើតឡើង តាមសមាមាត្រនៃចំនួនប្រាក់ ក្នុងករណីដែលមានការលើកលែងកាតព្វកិច្ចទាំងអស់ ។

(កំណត់)

មាត្រានេះបញ្ញត្តដើម្បីជៀសវាងនូវការទាមទារសំណងទៅវិញទៅមកដដែលៗ ។ ក៏ប៉ុន្តែ មាត្រានេះមិនមែនជាបញ្ញត្តិដែលត្រូវអនុវត្តដោយបង្ខំទេ ហេតុដូច្នេះ ក្នុងករណីដែលម្ចាស់បំណុលបានធ្វើការលើកលែងដែលមានខ្លឹមសារផ្សេងពីមាត្រានេះ ត្រូវធ្វើការវិនិច្ឆ័យនូវឥទ្ធិពលចំពោះកូនបំណុលផ្សេងទៀត តាមខ្លឹមសារនោះ ។

ក្នុងករណីដែលជាការលើកលែងកាតព្វកិច្ចមួយភាគ នឹងមានយោបល់ផ្សេងៗគ្នា ក៏ប៉ុន្តែ មាត្រានេះបញ្ញត្តថា មានឥទ្ធិពលតាមសមាមាត្រនៃចំនួនប្រាក់លើកលែងកាតព្វកិច្ចទាំងអស់ ។ ម្យ៉ាងទៀត សូមបញ្ជាក់ថា មាត្រានេះជាបញ្ញត្តិដែលមិនត្រូវអនុវត្តដោយបង្ខំទេ (អាចធ្វើការសន្យាផ្សេងពីនេះ) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៣៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៩៣០.- អានុភាពដាច់ខាតនៃអាជ្ញាយុកាល

១-ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ បានលើកឡើងនូវអាជ្ញាយុកាលដែលត្រូវបានសម្រេចចំពោះខ្លួន កូនបំណុលផ្សេងទៀតក៏ត្រូវរួចផុតពីកាតព្វកិច្ច ត្រឹមបន្ទុករបស់កូនបំណុលដែលបានលើកឡើងនូវអាជ្ញាយុកាលនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ នៅក្នុងពេលដែលអាជ្ញាយុកាលត្រូវបានសម្រេច តែមិនទាន់ត្រូវបានលើកឡើង កូនបំណុលផ្សេងទៀតអាចលើកឡើងនូវអាជ្ញាយុកាលនោះ ចំពោះបន្ទុករបស់កូនបំណុលដែលអាចលើកឡើងនូវអាជ្ញាយុកាលនោះ ។

(កំណត់)

ប្រសិនបើទទួលស្គាល់នូវអានុភាពដាច់ខាត ចំពោះហេតុនៃការផ្អាកអាជ្ញាយុកាល មាត្រានេះមានន័យតែចំពោះករណីដែលកាលបរិច្ឆេទនៃការសងរបស់កូនបំណុលនីមួយៗមានខុសៗគ្នាប៉ុណ្ណោះ ហេតុដូច្នេះ តាមការជាក់ស្តែង មានករណីដូច្នេះតិចតួចណាស់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៣៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៩៣១.- គោលការណ៍នៃអានុភាពមិនដាច់ខាត

ហេតុដែលបានកើតឡើងចំពោះកូនបំណុល ដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ មិនត្រូវមានអានុភាព ចំពោះកូនបំណុលផ្សេងទៀតឡើយ លើកលែងតែហេតុដែលបានកំណត់ពីមាត្រា ៩២៤ (អានុភាពដាច់ខាតនៃការទាមទារ និង ហេតុដែលផ្អាក

អាជ្ញាយុកាលផ្សេងទៀត) ដល់មាត្រា ៩៣០ (អានុភាពដាច់ខាតនៃអាជ្ញាយុកាល) ខាងលើនេះ ។

(កំណត់)

តាមគោលការណ៍ អានុភាពនៃសិទ្ធិលើបំណុល មិនមែនជាអានុភាពដាច់ខាតទេ ។ មាត្រានេះចែងដើម្បីបញ្ជាក់អំពីចំណុចនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៤០ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៣ ការទាមទារសំណង

**មាត្រា ៩៣២.-** សិទ្ធិទាមទារសំណងរបស់កូនបំណុលដែលបានសង

១-ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ បានរួចផុតពីកាតព្វកិច្ច ដោយបានសង ឬ បានចេញចំណាយផ្សេងទៀតរបស់ខ្លួន ហើយធ្វើឱ្យកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពផ្សេងទៀតរួចផុតពីកាតព្វកិច្ច កូនបំណុលនោះត្រូវទទួលសិទ្ធិទាមទារសំណងពីកូនបំណុលផ្សេងទៀត ចំពោះបន្ទុករៀងៗខ្លួន ។ ក្នុងករណីដែលការសង ឬ ចំណាយផ្សេងទៀតរបស់កូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ មានចំពោះតែកាតព្វកិច្ចមួយភាគ ហើយកូនបំណុលនោះ និង កូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពផ្សេងទៀត បានទទួលការរួចផុតពីកាតព្វកិច្ច តាមកម្រិតនៃភាគនោះ កូនបំណុលនោះអាចទាមទារសំណង តាមសមាមាត្រនឹងចំនួនភាគរយនៃចំនួនទឹកប្រាក់សរុបនៃកាតព្វកិច្ចបាន ។[៦]

២-ការទាមទារសំណងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបាន ដោយរាប់បញ្ចូលការប្រាក់ដែលច្បាប់បានកំណត់ ដោយគិតពីថ្ងៃរួចផុតពីកាតព្វកិច្ចដោយបានសង ឬ បានចេញចំណាយផ្សេងទៀតរបស់ខ្លួន និង សោហ៊ុយឬការខូចខាតផ្សេងទៀតដែលមិនអាចជៀសវាងបាន ។

(កំណត់)

[៦] វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ៩៣២ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

រវាងកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាព ជាធម្មតា មានការព្រមព្រៀងអំពីភាគនៃបន្ទុករវាងខ្លួន ។ ម្យ៉ាងទៀត ក្នុងករណីដែលគ្មានការព្រមព្រៀងទេ អាចសន្មតថា ត្រូវទទួលបន្ទុកស្មើភាពគ្នា ។ ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពទាំងនោះ ទទួលបានរួមគ្នានូវការរួចផុតពីកាតព្វកិច្ច ដោយសារកូនបំណុលណាម្នាក់ក្នុងចំណោមកូនបំណុលទាំងអស់ បានសង ឬ ចេញចំណាយផ្សេងទៀត ការផ្តល់សិទ្ធិឱ្យកូនបំណុលដែលបានសង ឬ ចេញចំណាយផ្សេងទៀតនោះ ទាមទារសំណងពីកូនបំណុលផ្សេងទៀត ទៅតាមសមាមាត្រនៃបន្ទុករបស់កូនបំណុលផ្សេងទៀត ជាការត្រឹមត្រូវ ។ ថែមពីនេះ ទោះបីជាក្នុងករណីដែលបានរួចផុតពីកាតព្វកិច្ចមួយភាគក៏ដោយ ប្រសិនបើគិតដល់ហានិភ័យនៃការស្ថិតនៅក្រោមអសាធនីយនៃកូនបំណុលផ្សេងទៀត ការផ្តល់សិទ្ធិឱ្យទាមទារសំណងទៅតាមសមាមាត្រនៃការរួចផុតពីកាតព្វកិច្ចនោះ នៅពេលបានរួចម្តងៗ ជាការត្រឹមត្រូវ ។

សិទ្ធិទាមទារសំណង អាចត្រូវបានគិតថាជាប្រភេទមួយនៃសិទ្ធិទាមទារឱ្យសងមកវិញនូវសោហ៊ុយ នៅក្នុងករណីនៃអាណត្តិដែរ ហេតុនេះហើយបានជាអាចទាមទារឱ្យសងការប្រាក់ដែលច្បាប់កំណត់ ដោយគិតពីថ្ងៃដែលបានសង ឬ ចេញចំណាយដោយខ្លួនឯង សោហ៊ុយចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សា និង សំណងនៃការខូចខាត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៤២ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៩៣៣.–** ការជូនដំណឹងដែលជាល័ក្ខខ័ណ្ឌដើម្បីទាមទារសំណង

១-ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ បានរួចផុតពីកាតព្វកិច្ច ដោយបានសង ឬ បានចេញចំណាយផ្សេងទៀតរបស់ខ្លួន ហើយបានធ្វើឱ្យកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពផ្សេងទៀតរួចផុតពីកាតព្វកិច្ច ដោយពុំបានជូនដំណឹងទៅឱ្យកូនបំណុលផ្សេងទៀតថា ខ្លួនបានទទួលការទាមទារពីម្ចាស់បំណុល បើកូនបំណុលផ្សេងទៀតណាមួយ មានហេតុដែលអាចតតាំងចំពោះម្ចាស់បំណុល កូនបំណុលនោះអាចយកហេតុនេះមកតតាំងចំពោះការទាមទារសំណងពីកូនបំណុលដែលបានទទួលការរួចផុត ដោយបានសង ឬ ចេញចំណាយបាន ។ ប៉ុន្តែ បើហេតុដែលអាចតតាំងជាការទូទាត់ កូនបំណុលដែលត្រូវបានតតាំង អាចទាមទារឱ្យម្ចាស់បំណុលអនុវត្តកាតព្វកិច្ចដែលនឹងត្រូវរលត់ ដោយការទូទាត់ ។

២-ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ បានធ្វើឱ្យខ្លួន និង កូនបំណុលផ្សេងទៀត រួចផុតពីកាតព្វកិច្ច ដោយបានសង ឬ ចេញចំណាយផ្សេងទៀតរបស់ខ្លួន តែមិនបានជូនដំណឹងអំពីហេតុនោះ ទៅកូនបំណុលផ្សេង

ទៀត បើកូនបំណុលផ្សេងទៀតបានរួចផុតពីកាតព្វកិច្ច ដោយបានសង ឬ ចេញចំណាយផ្សេងទៀតរបស់ខ្លួន ដោយមិនបានដឹងអំពីហេតុនោះ កូនបំណុលដែលបានរួចផុតពីកាតព្វកិច្ចពេលក្រោយនោះ អាចចាត់ទុកថា ការសង ឬ សកម្មភាពផ្សេងទៀតរបស់ខ្លួនដែលធ្វើឱ្យរួចផុតពីកាតព្វកិច្ចនោះ មានសុពលភាព ។

៣-ក្នុងករណីដែលការសង ឬ សកម្មភាពដែលធ្វើឱ្យរួចផុតពីកាតព្វកិច្ចដោយចេញចំណាយផ្សេងទៀតរបស់ខ្លួន ត្រូវបានធ្វើឡើង ដោយកូនបំណុលច្រើន ក្នុងចំណោមកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាព ហើយបើការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ មិនបានធ្វើឡើង នោះការសង ឬ សកម្មភាពដែលឱ្យរួចផុតពីកាតព្វកិច្ចដោយចេញចំណាយផ្សេងទៀតរបស់ខ្លួន ដែលកូនបំណុលណាបានធ្វើមុន ត្រូវបានចាត់ទុកថា មានសុពលភាព ។

(កំណត់)

ក្នុងករណីដែលកូនបំណុលច្រើននាក់បានទទួលបន្ទុកកាតព្វកិច្ចតែមួយ ការសងបំណុលត្រួតគ្នាអាចកើតឡើង ព្រមជាមួយគ្នានេះ អាចបំបាត់ឱកាសដាក់ការតវ៉ារបស់កូនបំណុលផ្សេងទៀត ។ ដើម្បីជៀសវាងកុំឱ្យមានករណីនេះកើតឡើង មាត្រានេះចែងថា ដើម្បីទាមទារសំណង កូនបំណុលដែលបានសង ត្រូវជូនដំណឹងជាមុន ឬ ក្រោយ (កថាខណ្ឌទី ១ និង កថាខណ្ឌទី ២) ។

ក្នុងករណីដែលបានធ្វេសប្រហែសមិនបានជូនដំណឹងជាមុន និង ក្រោយ ការសងណាដែលបានធ្វើមុនត្រូវចាត់ទុកថា មានសុពលភាព (កថាខណ្ឌទី ៣) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៤៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៩៣៤.-** ការទាមទារសំណងក្នុងករណីដែលមានអ្នកជាអសាធនីយ៍ក្នុងការសង

បើមានអ្នកដែលស្ថិតនៅក្នុងស្ថានភាពអសាធនីយ៍ក្នុងការសង ក្នុងចំណោមកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាព ផ្នែកដែលមិនអាចសងបាននោះ ត្រូវជាបន្ទុករបស់អ្នកដែលទាមទារសំណង និង អ្នកដែលជាសាធនីយ៍ តាមសមាមាត្រនៃបន្ទុករៀងៗខ្លួន ។ ប៉ុន្តែ បើអ្នកដែលទាមទារសំណងមានកំហុស អ្នកនោះមិនអាចទាមទារឱ្យកូនបំណុលផ្សេងទៀតទទួលបន្ទុកឡើយ ។

( កំណត់ )

ក្នុងករណីដែលមានអ្នកអសាធនីយ៍ ក្នុងចំណោមកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាព ហើយកូនបំណុលដែលបានធ្វើការសង ជាអាទិ៍ មិនអាចទទួលសំណងឱ្យបានគ្រប់គ្រាន់ ពីកូនបំណុលដែលជាអ្នកអសាធនីយ៍នោះដែលបានរួចផុតពីកាតព្វកិច្ចរួម ដោយការសង ជាអាទិ៍ នោះ ការបង្ខំឱ្យកូនបំណុលដែលបានធ្វើការសង ជាអាទិ៍ នោះ ទទួលបន្ទុកតែម្នាក់ឯង ជាការចាត់ចែងមួយដែលមិនត្រឹមត្រូវ ធ្វើឱ្យខូចប្រយោជន៍ដល់អ្នកដែលបានទទួលការរួចផុតពីកាតព្វកិច្ចរួមដោយការសង ជាអាទិ៍ របស់ខ្លួន ហើយទៅជារារាំងមិនឱ្យធ្វើសកម្មភាពឱ្យរួចផុតពីកាតព្វកិច្ចរួម ដូចជាការសង ជាអាទិ៍ដោយស្ម័គ្រចិត្តផង ។ ហេតុនេះហើយ មាត្រានេះចែងថា ត្រូវឱ្យកូនបំណុលផ្សេងទៀតដែលមានកាតព្វកិច្ចដោយសាមគ្គីភាព និង អ្នកមានសិទ្ធិទាមទារសំណង ទទួលបន្ទុកនូវបន្ទុករបស់អ្នកអសាធនីយ៍ តាមសមាមាត្រនៃបន្ទុករៀងៗខ្លួន ។

( មាត្រាពាក់ព័ន្ធ )

មាត្រា ៤៤៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៩៣៥.- ការលើកលែងសាមគ្គីភាព និង បន្ទុករបស់អ្នកដែលជាអសាធនីយ៍ក្នុងការសង

ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ ក្នុងចំណោមកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាព បានទទួលការលើកលែងសាមគ្គីភាព បើមានអ្នកដែលជាអសាធនីយ៍ក្នុងការសង ក្នុងចំណោមកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពផ្សេងទៀត ម្ចាស់បំណុលត្រូវទទួលបន្ទុកនូវផ្នែកដែលអ្នកដែលបានទទួលការលើកលែងសាមគ្គីភាពត្រូវទទួលបន្ទុក ចំពោះផ្នែកដែលអ្នកដែលជាអសាធនីយ៍នោះមិនអាចឆ្លើយតបនឹងការទាមទារសំណងបាន ។

( កំណត់ )

ក្នុងករណីដែលទាមទារឱ្យបន្ថែមនូវបន្ទុកដូចដែលបានចែងនៅក្នុងមាត្រាមុននេះ បញ្ហាដែលកើតឡើង ត្រង់ចំណុចថាតើអាចទាមទារឱ្យអ្នកដែលបានទទួលការលើកលែងសាមគ្គីភាពនោះ បន្ថែមនូវបន្ទុកនោះដែរ ឬទេ ? ប្រសិនបើទទួលស្គាល់ឱ្យអាចទាមទារបានទៅ បុគ្គលដែលបានទទួលការលើកលែងសាមគ្គីភាព នឹងត្រូវទទួលបន្ទុកលើសពីបន្ទុករបស់ខ្លួនផ្ទាល់ ទោះជាបានទទួលការលើកលែងក៏ដោយ ។ ហេតុនេះហើយបានជាឱ្យម្ចាស់បំណុលដែលបានលើកលែងសាមគ្គីភាពទទួលបន្ទុកបន្ថែមរបស់កូនបំណុលដែលបានទទួលការលើកលែងទៅវិញ ។ ក៏ប៉ុន្តែ បញ្ញត្តិស្តីពីការលើកលែងសាមគ្គីភាពមិនមែនជាបញ្ញត្តិដែលត្រូវអនុវត្តដោយបង្ខំទេ ដូច្នេះ ការចាត់ចែងមានភាពខុសគ្នា ដោយយោងទៅតាមឆន្ទៈនៃការលើកលែងសាមគ្គីភាពដោយម្ចាស់បំណុល ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៤៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៤ ឧបាទេសកម្មដោយការសង

**មាត្រា ៩៣៦.–** ឧបាទេសកម្ម

១-ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ ទទួលសិទ្ធិទាមទារសំណង ចំពោះកូនបំណុលផ្សេងទៀត អ្នកទាមទារសំណង ត្រូវស្នង ម្ចាស់បំណុលដោយឧបាទេសកម្ម ចំពោះសិទ្ធិលើបំណុលដែលម្ចាស់បំណុលធ្លាប់មានចំពោះ កូនបំណុលផ្សេងទៀត និង សិទ្ធិប្រាតិភោគដើម្បីធានាសិទ្ធិលើបំណុលនោះ ក្នុងទំហំនៃ ការទាមទារសំណងនោះ ។

២-ក្រៅពីបញ្ញត្តិនៃមាត្រានេះ បញ្ញត្តិនៃកថាភាគទី ៤ (ឧបាទេសកម្មដោយការសង) ផ្នែកទី ១ ជំពូកទី ៧ នៃគន្ថីទី ៤ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះឧបាទេសកម្ម របស់អ្នកទាមទារសំណង ។

(កំណត់)

សូមមើលបញ្ញត្តិស្តីពីឧបាទេសកម្មដោយការសង ។

## ផ្នែកទី ៥ បែបយ៉ាងផ្សេងទៀតនៃកាតព្វកិច្ចដែលមានកូនបំណុលច្រើននាក់

**មាត្រា ៩៣៧.–** កាតព្វកិច្ចអវិភាគីយ៍ និង កាតព្វកិច្ចដែលមានលក្ខណៈប្រហាក់ប្រហែល នឹងកាតព្វកិច្ចដោយសាមគ្គីភាព និង កាតព្វកិច្ចវិភាគីយ៍

១-បញ្ញត្តិនៃមាត្រា ៩២១ (អត្ថន័យនៃកាតព្វកិច្ចដោយសាមគ្គីភាព) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកូនបំណុលច្រើននាក់ទទួលកាតព្វកិច្ច ដែលមានគោលបំណងដូចគ្នា ចំពោះម្ចាស់បំណុលតែម្នាក់ ហើយឆន្ទៈសាមគ្គីភាពរួមគ្នា ទៅវិញទៅមក មិនត្រូវបានទទួលស្គាល់រវាងកូនបំណុលទាំងនេះ ។ ប៉ុន្តែ ក្នុងករណីដែល តាវកាលិកនៃកាតព្វកិច្ចនោះ អាចបែងចែកបាន ហើយការបែងចែកនោះមិនខូចខាតដល់ ផលប្រយោជន៍របស់ម្ចាស់បំណុលនោះ កូនបំណុលនីមួយៗត្រូវទទួលកាតព្វកិច្ចដែលត្រូវ

បានបែងចែក តាមសមាមាត្រនៃបន្ទុករៀងៗខ្លួន ។ បើបន្ទុករបស់កូនបំណុលម្នាក់ៗមិនច្បាស់លាស់ បន្ទុកនោះត្រូវបានសន្មតថា ស្មើៗគ្នា ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ហេតុដែលបានកើតឡើងចំពោះកូនបំណុលម្នាក់ មិនត្រូវមានឥទ្ធិពលដល់កូនបំណុលផ្សេងទៀត លើកលែងតែករណីដែលបានកំណត់នៅក្នុងមាត្រា ៩២៥ (អានុភាពដាច់ខាតនៃការសង ជាអាទិ៍) និង កថាខណ្ឌទី ១ នៃមាត្រា ៩២៦ (អានុភាពដាច់ខាតនៃការទូទាត់) ខាងលើនេះ ។

៣-ក្នុងករណីដែលកូនបំណុលណាម្នាក់ ក្នុងចំណោមកូនបំណុលដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ បានរួចផុតពីកាតព្វកិច្ច ដោយបានសង ឬ ចេញចំណាយផ្សេងទៀតរបស់ខ្លួន ហើយធ្វើឱ្យកូនបំណុលផ្សេងទៀតរួចផុតពីកាតព្វកិច្ច បើមានភាពចាំបាច់ត្រូវរក្សាសមភាពរវាងកូនបំណុលដែលបានចេញចំណាយ និង កូនបំណុលផ្សេងទៀត អ្នកដែលបានចេញចំណាយ ត្រូវទទួលសិទ្ធិទាមទារសំណងចំពោះកូនបំណុលផ្សេងទៀត ក្នុងកម្រិតដែលអាចធ្វើឱ្យមានសមភាពនោះ ។

(កំណត់)

មាត្រានេះចែងអំពីកាតព្វកិច្ចអវិភាគីយ៍ និង កាតព្វកិច្ចដែលមានលក្ខណៈប្រហាក់ប្រហែលនឹងកាតព្វកិច្ចដោយសាមគ្គីភាព ។ ជាគោលការណ៍ កាតព្វកិច្ចទាំងពីរនេះត្រូវចាត់ចែងដូចគ្នា ។ មានន័យថា មិនទទួលស្គាល់អានុភាពដាច់ខាតចំពោះហេតុក្រៅពីហេតុនៃការជម្រះសិទ្ធិលើបំណុល ព្រមជាមួយគ្នានេះ សិទ្ធិទាមទារសំណង មិនត្រូវកើតឡើងដោយស្វ័យប្រវត្តិទេ ។ ក៏ប៉ុន្តែ មិនមែនមិនឱ្យធ្វើការកំណត់នូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិទាមទារសំណង និង ទំហំនៃការទាមទារនេះ ដោយយោងតាមករណីនីមួយៗទេ ។

ម្យ៉ាងទៀត នៅមានបញ្ហាមួយដែលគួរឱ្យគិតដែរ គឺ តើគួរទទួលស្គាល់ដែរ ឬទេ នូវអានុភាពដាច់ខាតនៃការសងដោយវត្ថុជំនួស និង ការទូទាត់ ។ ទស្សនៈទូទៅនៅប្រទេសជប៉ុន មិនសូវទទួលស្គាល់ដោយសកម្មទេ ។ ក៏ប៉ុន្តែ ចំពោះចំណុចដែលការសងដោយវត្ថុជំនួស និង ការទូទាត់ ក៏ជម្រះសិទ្ធិលើបំណុល មិនមានភាពចាំបាច់ធ្វើការបែងចែកការសងដោយវត្ថុជំនួស និង ការទូទាត់ ពីការសងធម្មតាទេ ហេតុនេះហើយបានជានៅក្នុងក្រមនេះ ជ្រើសរើសយកការទទួលស្គាល់នូវអានុភាពដាច់ខាតនេះ ។

មាត្រានេះបញ្ញត្តថា ក្នុងករណីដែលតាវកាលិកអាចបែងចែកបាន ហើយការបែងចែកនោះមិននាំឱ្យមានការខូចខាតដល់ផលប្រយោជន៍របស់ម្ចាស់បំណុល ទើបកាតព្វកិច្ចអាចក្លាយជាកាតព្វកិច្ចវិភាគីយ៍ ។

ក្នុងករណីដែលកាតព្វកិច្ចជាកាតព្វកិច្ចអវិភាគីយ៍ និង កាតព្វកិច្ចដែលមានលក្ខណៈប្រហាក់ប្រហែលនឹងកាតព្វកិច្ចដោយសាមគ្គីភាព សិទ្ធិទាមទារសំណងត្រូវបានទទួលស្គាល់ត្រឹមកម្រិតដែលអាចសម្រេចនូវសមភាពរវាងកូនបំណុលតែប៉ុណ្ណោះ ។ ប្រសិនបើសិនជាមានការព្រមព្រៀងជាមុនអំពីភាគនៃបន្ទុក ត្រូវអនុលោមតាមការព្រមព្រៀងនោះ ប៉ុន្តែតាមការជាក់ស្តែង មានតិចណាស់ ។ ហេតុនេះហើយ ភាគនៃបន្ទុកត្រូវបានកំណត់ ដោយគិតពិចារណាហេតុផ្សេងៗដែលធ្វើឱ្យកូនបំណុលទាំងនោះត្រូវទទួលបន្ទុកកាតព្វកិច្ច ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤២៧ និង មាត្រា ៤៣០ នៃក្រមរដ្ឋប្បវេណីជប៉ុន